សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងអាជីវកម្មក្នុងវិស័យទេសចរណ៍នៃប្រទេសកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ　　　　　　　　　　　　សាស្ត្រាចារ្យណែនាំ

និស្សិតឈ្មោះ **តាំង ហាយ**　　　　　　　　**លោក យូ តូនី**

**ហ៊ិ ស៊ីវជី**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**　　　　ឆ្នាំចូលសិក្សា ២០១៦

ជំនាន់ទី ១៣　　　　　　　　　　　　　　ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ស្តីពី "ការគ្រប់គ្រងអាជីវកម្មក្នុងវិស័យទេសចរណ៍នៅប្រទេសកម្ពុជា" នេះ ត្រូវបានរៀបចំចងក្រងឡើងយ៉ាងយកចិត្តទុកដាក់របស់ក្រុមយើងខ្ញុំ។ ដើម្បីជាការដឹងគុណចំពោះការជួយជ្រោមជ្រែងក្នុងការបង្កើតឱ្យមានសារណានេះ យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក **តាំង ប៊ុនហ៊ី** និងអ្នកម្តាយ **កាន់ ហៀង** ព្រមទាំងលោកឪពុក **សុខ ថៃ** និងអ្នកម្តាយ **តាំង សុខខេង** ដែលមានគុណបំណាច់ធំធេងក្នុងការផ្តល់កំណើត ថែរក្សា ចិញ្ចឹមបីបាច់ និងអប់រំបណ្តុះបណ្តាលក្នុងន័យតម្រង់ទិសកូនឱ្យក្លាយជាមនុស្សល្អនិងមានតម្លៃក្នុងសង្គម។ លោកបានលះបង់និងពលីជាច្រើនសម្រាប់ចិញ្ចឹមបីបាច់រូបកូនឱ្យធំដឹងក្តី និងមានចំណេះដឹងជ្រៅជ្រះ និងឈានទៅរកនូវអនាគតដ៏ភ្លឺស្វាង។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្នុងមុខងារជាសាកលវិទ្យាធិការ ឯកឧត្តមបណ្ឌិតបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីចូលរួមនឹងរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា តាមរយៈការគ្រប់គ្រងនិងអភិវឌ្ឍសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយផ្តល់នូវការអប់រំដ៏មានគុណភាពដល់និស្សិតគ្រប់រូប។ បន្ថែមពីនេះទៅទៀត ឯកឧត្តមបណ្ឌិតបានផ្តល់ឱកាសដែលនិស្សិតគ្រប់រូបប្រាថ្នាចង់បានមកកាន់យើងខ្ញុំ នោះគឺបានចូលរួមសរសេរនិងការពារសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

លោកគ្រូ អ្នកគ្រូដែលបានបង្ហាត់បង្រៀនរូបយើងខ្ញុំតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សានេះ។ លោកគ្រូ អ្នកគ្រូបានព្យាយាមអស់ពីលទ្ធភាពក្នុងការផ្ទេរចំណេះដឹង បទពិសោធន៍ គុណធម៌ សុជីវធម៌ និងតម្រង់តិរិយាបទមារយាទរបស់រូបយើងខ្ញុំដើម្បីឱ្យក្លាយមនុស្សមានតម្លៃសម្រាប់សង្គម។

លោកសាស្ត្រាចារ្យ **យូ តូនី** សាស្ត្រាចារ្យផ្នែកច្បាប់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការអប់រំ ណែនាំ បណ្តុះបណ្តាល តម្រង់ទិស និងកែលម្អចំណុចខ្វះខាតក្នុងការរៀបចំបង្កើតសារណានេះឡើង។ លោកបានពន្យល់និងណែនាំអំពីវិធីសាស្ត្រ ប្រឹក្សាយោបល់និងផ្តល់ជាគំនិតសំខាន់ៗ ដើម្បីជាទុនដ៏មានសារៈប្រយោជន៍សម្រាប់យើងខ្ញុំក្នុងការរៀបចំបង្កើតសារណានេះឡើង។

លោក **ស៊ូ គឹមព្រឹទ្ធា** ប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងទេសចរណ៍ បានផ្តល់ឱកាសដ៏ពិសេសដល់យើងខ្ញុំក្នុងការស្នើសុំឯកសារច្បាប់ និងឯកសារសំខាន់នានាពីក្រសួងទេសចរណ៍ យកមកចងក្រងនិងរៀបចំសារណានេះ។ បន្ថែមពីនេះទៀត លោកបានផ្តល់ពេលវេលាសម្រាប់ការប្រឹក្សាយោបល់និងបកស្រាយនូវបញ្ហាផ្សេងៗជុំវិញប្រធានបទ នេះយ៉ាងក្បោះក្បាយនិងពិស្តារ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ក្រោមប្រធានបទ "ការគ្រប់គ្រងអាជីវកម្មក្នុងវិស័យទេសចរណ៍នៅប្រទេសកម្ពុជា" គឺជាស្នាដៃដំបូងរបស់ក្រុមយើងខ្ញុំ ដែលត្រូវបានរៀបចំចងក្រងឡើងសម្រាប់ជាកម្មវត្ថុក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។ ដើម្បីរៀបចំបង្កើតឡើងបាននូវសារណាមួយនេះ យើងខ្ញុំបានព្យាយាមក្នុងការស្វែងរកនូវឯកសារសំខាន់ៗជាច្រើនពីគ្រប់ប្រភព ដូចជា ក្រសួងទេសចរណ៍ បណ្ណាគារដែលមានសៀវភៅទាក់ទងនឹងឧស្សាហកម្មទេសចរណ៍ គេហទំព័ររបស់អង្គភាព ស្ថាប័នរដ្ឋដែលមានផ្ទុកនូវឯកសារទាំងនោះ និងប្រភពឯកសារផ្សេងៗទៀត។ ក្នុងការរៀបចំចងក្រង យើងខ្ញុំបានប្រើប្រាស់ឯកសារទាំងនោះ យកមកស្វែងយល់ វិភាគ និងចងក្រងឡើងតាមលំដាប់លំដោយនៃខ្លឹមសាររបស់ប្រធានបទ។

សព្វថ្ងៃនេះ វិស័យទេសចរណ៍កំពុងមានភាពរីកដុះដាលគួរឱ្យកត់សម្គាល់។ មានកត្តាជាច្រើនដែលជំរុញឱ្យវិស័យនេះមានភាពរីកចម្រើនដូចនេះ ដូចជាកត្តាសង្គម កត្តាសុខសន្តិភាព កត្តាធនធានធម្មជាតិដែលកម្ពុជាមាន និងកត្តាសេដ្ឋកិច្ចជាដើម។ ក្នុងនោះផ្នែកដែលសំខាន់ជាងគេដែលជំរុញឱ្យវិស័យទេសចរណ៍កម្ពុជាមានសក្តានុពលនោះគឺផ្នែកឧស្សាហកម្មទេសចណ៍ ពោលគឺ អាជីវកម្មទេសចរណ៍ ដែលវាជាផ្នែកសេវាកម្មសម្រាប់បម្រើដល់ដំណើរកម្សាន្តរបស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ។ បើអាជីវកម្មទេសចរណ៍មានដំណើរការមិនល្អ ឬមានចំណុចអវិជ្ជមានជាច្រើនកើតមានឡើង នោះនឹងធ្វើឱ្យភ្ញៀវទេសចរនឹងថយចុះដែលអាចបណ្តាលឱ្យប៉ះពាល់ដល់វិស័យទេសចរណ៍ទាំងមូល។ ដើម្បីគ្រប់គ្រងបាននូវស្ថានការណ៍បែបនេះ រាជរដ្ឋាភិបាល ជាពិសេសក្រសួងទេសចរណ៍ត្រូវមានយន្តការនិងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងអាជីវកម្មទេសចណ៍ទាំងនោះប្រកបដោយប្រសិទ្ធភាពនិងគុណភាព។

ដោយមានការយល់ឃើញបែបនេះហើយ បានយើងខ្ញុំចាប់អារម្មណ៍និងសម្រេចចិត្តជ្រើសរើសប្រធានបទមួយនេះយកមកសិក្សាស្វែងយល់ និងអាចទទួលបាននូវចំណេះដឹងថ្មីៗទាក់ទងនឹងវិស័យផ្សេងៗក្រៅពីវិស័យនៃជំនាញដែលយើងខ្ញុំកំពុងសិក្សា។ ការសិក្សានេះបានផ្តល់សារៈសំខាន់ជាច្រើនមកដល់យើងខ្ញុំ ទាំងបន្ថែមចំណេះដឹងទាក់ទងនឹងទេសចរណ៍ និងបានយល់ដឹងអំពីប្រព័ន្ធគ្រប់គ្រងរបស់ស្ថាប័នរដ្ឋទៅលើមូលដ្ឋាននានាក្នុងសង្គម ដែលនេះជាការចាំបាច់សម្រាប់យើងខ្ញុំដែលជានិស្សិតរដ្ឋបាលសាធារណៈ។

ទោះជាមានការយកចិត្តទុកដាក់ខ្ពស់ និងការពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក្តី ក៏កំហុសអចេតនានានានឹងកើតឡើងជាក់ជាមិនខាន។ ក្នុងករណីនេះ យើងខ្ញុំសូមការអនុញ្ញាតធ្វើការអធ្យាស្រ័យចំពោះកំហុសឆ្គងទាំងនោះនិង បើកចិត្តទូលាយស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យស្នាដៃក្រោយៗទៀតនឹងមានភាពប្រសើរឡើង។

# មាតិកា

## សេចក្តីផ្តើម


១. លំនាំបញ្ហា ....................................................................................................... ១
២. ចំណោទបញ្ហា ....................................................................................................... ៣
៣. គោលបំណងនៃការស្រាវជ្រាវ ....................................................................................... ៣
៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ ................................................................................ ៤
៥. សារៈសំខាន់នៃការស្រាវជ្រាវ........................................................................................ ៤
៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ ........................................................................................ ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....................................................................................... ៦


## ជំពូកទី១

## ស្ថានភាពអាជីវកម្មទេសចរណ៍


១. និយមន័យនិងប្រភេទអាជីវកម្មទេសចរណ៍ ........................................................................ ៧
១.១. និយមន័យអាជីវកម្មទេសចរណ៍.................................................................................. ៧
១.២. ប្រភេទអាជីវកម្មទេសចរណ៍....................................................................................... ៨
១.២.១. សេវាកម្មទីភ្នាក់ងារ សេវាកម្មដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ ....................... ១០
១.២.២ សេវាកម្មស្នាក់នៅនិងម្ហូបអាហារទេសចរណ៍ ................................................... ១៣
១.២.៣ សេវាកម្សាន្តនិងកីឡាទេសចរណ៍ ................................................................. ១៧
១.២.៤ សេវាកម្មរមណីយដ្ឋានទេសចរណ៍................................................................... ១៩
២. ស្ថិតិអាជីវកម្មទេសចរណ៍ ......................................................................................... ២២
៣. អត្ថប្រយោជន៍នៃអាជីវកម្មទេសចរណ៍ ............................................................................ ២៣


## ជំពូកទី២

## ការគ្រប់គ្រងអាជីវកម្មទេសចរណ៍


១. ស្ថាប័ននិងអង្គភាពមានសមត្ថកិច្ច ................................................................................. ២៥
១.១. ថ្នាក់ជាតិ ............................................................................................................ ២៥
១.២. ថ្នាក់ក្រោមជាតិ...................................................................................................... ២៧
២. យន្តការក្នុងការគ្រប់គ្រង............................................................................................... ២៨

២.១. យន្តការនៅថ្នាក់ជាតិ..........២៨
ក. នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍..........២៩
ខ. នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ..........៣០
គ. នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍..........៣២
ឃ. នាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍..........៣៣
ង. អគ្គាធិការដ្ឋាន..........៣៥
២.២. យន្តការនៅថ្នាក់ក្រោមជាតិ..........៣៦
ក. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ..........៣៦
ខ. មន្ទីរទេសចរណ៍រាជធានី ខេត្ត..........៣៨
៣. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងអាជីវកម្មទេសចរណ៍..........៤០
៣.១. ច្បាប់និងអនុក្រឹត្យ..........៤១
៣.២. ប្រកាស ប្រកាសរួម សារាចរ និងសេចក្ដីណែនាំ..........៤២

## ជំពូកទី៣

## ការផ្ដល់អាជ្ញាបណ្ណទេសចរណ៍

១. អាជ្ញាបណ្ណនិងប្រភេទអាជ្ញាបណ្ណទេសចរណ៍..........៤៦
២. ការផ្ដល់អាជ្ញាបណ្ណទេសចរណ៍លើសេវាកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍..........៤៩
៣. ការផ្ដល់អាជ្ញាបណ្ណទេសចរណ៍លើសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ..........៥៦
៤. ការផ្ដល់អាជ្ញាបណ្ណទេសចរណ៍លើសេវាកម្មសេវាកម្សាន្តនិងកីឡាទេសចរណ៍..........៦០
៥. ការផ្ដល់អាជ្ញាបណ្ណទេសចរណ៍លើសេវាកម្មមណ្ឌលយដ្ឋានទេសចរណ៍..........៦៦
៦. ពិន័យសម្រាប់អាជីវកម្មគ្មានអាជ្ញាបណ្ណទេសចរណ៍..........៦៧
**សេចក្ដីសន្និដ្ឋាន**..........៧០
**វាយតម្លៃនិងអនុសាសន៍**..........៧២
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

គ្រប់បណ្តាប្រទេសនៅលើពិភពលោក ប្រទេសអភិវឌ្ឍន៍ក្តី និងកំពុងអភិវឌ្ឍន៍ក្តី បាននិងកំពុងខិតខំប្រឹងប្រែងធ្វើឱ្យវិស័យសេដ្ឋកិច្ចរបស់ប្រទេសខ្លួនមានភាពរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ ដើម្បីសម្រេចបាននូវភាពរីកលូតលាស់របស់វិស័យសេដ្ឋកិច្ចខ្លួន ប្រទេសទាំងអស់នោះបាននិងកំពុងប្រើប្រាស់នូវធនធានដែលខ្លួនមានមកកែច្នៃ អភិវឌ្ឍ រៀបចំ និងកែលម្អ ក្នុងគោលបំណងបង្កើនចំណូលបន្ថែមទៅក្នុងចរន្តសេដ្ឋកិច្ចរបស់ខ្លួន។ ជាក់ស្តែងប្រទេសទំនើបមួយចំនួនបាននិងកំពុងប្រឹងប្រែងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ដើម្បីបម្រើដល់តម្រូវការជាចាំបាច់ក្នុងជីវភាពរស់នៅរបស់មនុស្សនាពេលបច្ចុប្បន្ន។ ប្រទេសមួយចំនួនធំផ្សេងទៀតបានចាត់ទុកវិស័យ កសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ជាវិស័យនាំមុខគេក្នុងការពង្រឹង និងពង្រីកវិស័យសេដ្ឋកិច្ចជាតិខ្លួន។

ទន្ទឹមនឹងនេះ ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅក្នុងភូមិសាស្ត្រដែលមានលក្ខណៈអំណោយផលពីធម្មជាតិ ដែលលក្ខណៈទាំងអស់នោះមានសារៈប្រយោជន៍សំខាន់ណាស់សម្រាប់វិស័យកសិកម្ម វប្បធម៌ និងសេវាកម្ម។ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យសំខាន់ៗជាច្រើនរួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យអចលនទ្រព្យនិងសំណង់ ព្រមទាំងវិស័យទេសចរណ៍... ជាកត្តារួមផ្សំចម្បងៗសម្រាប់លើកស្ទួយកិច្ចអភិវឌ្ឍសេដ្ឋកិច្ចជាតិនៅកម្ពុជា។ ក្នុងចំណោមវិស័យចម្បងៗទាំងនោះ វិស័យទេសចរណ៍ជាវិស័យមួយដែលរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ក្នុងការរៀបចំនិងប្រែក្លាយវិស័យនេះឱ្យទៅជាប្រភពចំណូលធំមួយសម្រាប់វិស័យសេដ្ឋកិច្ចជាតិកម្ពុជា។

ជាក់ស្តែង ក្នុងក្របខណ្ឌសកលលោក នៅឆ្នាំ២០១៩[1] ពិភពលោកទាំងមូលបានទទួលស្វាគមន៍ទេសចរអន្តរជាតិប្រមាណ ១ ៤៦១លាននាក់ កើនឡើង ៣.៨% ធៀបនឹងឆ្នាំ២០១៨ ក្នុងនោះតំបន់អឺរ៉ុបទទួលបាន ៧៤២.៣លាននាក់ (កើន៣.៧%) តំបន់អាស៊ីប៉ាស៊ីហ្វិក ៣៦៣.៦លាននាក់ (កើន៤.៦%) តំបន់អាមេរិក ២២០.១លាននាក់ (កើន២%) តំបន់អាហ្វ្រិក ៧១.២លាននាក់ (កើន៤.២%) និងតំបន់មជ្ឈិមបូព៌ា ៦៣.៩លាននាក់ (កើន៧.៦%)។ តាមការព្យាករ ទេសចរពិភពលោកនឹងនៅតែបន្តកើនឡើងតទៅទៀត ដោយនៅឆ្នាំ២០២០ នឹងមានកំណើន ៣-៤% និងនៅឆ្នាំ២០៣០ ពិភពលោករំពឹងនឹងទទួលបានទេសចរអន្តរជាតិជាង ១ ៨០០លាននាក់។ ក្រលេកមកពិនិត្យ មើលស្ថានភាពទេសចរណ៍ប្រចាំតំបន់វិញ នៅឆ្នាំ២០១៩ [2] កន្លងទៅ តំបន់អាស៊ានទាំងមូល

[1] របាយការណ៍បូកសរុបការងារទេសចរណ៍ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តឆ្នាំ២០២០

[2] របាយការណ៍បូកសរុបការងារទេសចរណ៍ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តឆ្នាំ២០២០

ទទួលបានទេសចរអន្តរជាតិចំនួន ១៣៨.៦លាននាក់ ក្នុងកំណើន ៧.៨% ក្នុងនោះការធ្វើដំណើរទេសចរផ្ទៃក្នុងអាស៊ានមាន ៤០% នៃចំនួនទេសចរអន្តរជាតិសរុប។

ចំណែកឯប្រទេសកម្ពុជាវិញ វិស័យទេសចរណ៍កំពុងមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយនៅឆ្នាំ២០១៩ [3] ចំនួនទេសចរអន្តរជាតិមកទស្សនាប្រទេសកម្ពុជាសរុប គឺ ៦ ៦១០ ៥៩២នាក់ (កើនឡើង ៦.៦% ធៀបនឹងឆ្នាំ២០១៨) ក្នុងនោះទេសចរធ្វើដំណើរតាមផ្លូវអាកាសមានចំនួន ៤ ៤០៣ ៩៩៥នាក់ តាមផ្លូវគោកមានចំនួន ២ ០៤៩ ៧៤៨នាក់ និងតាមផ្លូវទឹកមានចំនួន ១៥៦ ៨៤៩នាក់។ ទីផ្សារទេសចរណ៍សំខាន់ៗមកប្រទេសកម្ពុជាមានចំនួន១០ប្រទេស គឺ ចិន វៀតណាម ថៃ ឡាវ កូរ៉េ សហរដ្ឋអាមេរិក ជប៉ុន ម៉ាឡេស៊ី បារាំង និងអង់គ្លេស ក្នុងចំណោមនោះភ្ញៀវទេសចរចិនមានចំនួនច្រើនជាងគេ គឺ ២ ៣៦១ ៨៤៩នាក់។ ម្យ៉ាងវិញទៀត ក្នុងឆ្នាំ២០១៩ វិស័យទេសចរណ៍កម្ពុជាបានរកចំណូលជូនជាតិប្រមាណ ៤ ៩១៩លានដុល្លារអាមេរិក (ក្នុងកំណើន ២០.៣%) បានចូលរួមចំណែកប្រមាណ ១២.១% នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា (GDP) និងបានបង្កើតការងារនិងមុខរបរដោយផ្ទាល់ប្រមាណ ៦៣ម៉ឺននាក់ និងការងារដោយប្រយោលរាប់ម៉ឺននាក់បន្ថែមទៀត។

ដើម្បីរក្សាលំនឹងនៃស្ថានភាពទេសចរណ៍នៅកម្ពុជា ក៏ដូចជាចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវចក្ខុវិស័យទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិកាន់តែច្រើនឡើងៗនោះ ក្រសួងទេសចរណ៍បាននិងកំពុងយកចិត្តយ៉ាងខ្លាំងក្នុងការគ្រប់គ្រង កែលម្អ និងអភិវឌ្ឍឧស្សាហកម្មទេសចរណ៍។ ឧស្សាហកម្មទេសចរណ៍គឺជាផ្នែកមួយនៃសេវាកម្មដែលបង្កើតឡើងសម្រាប់បំពេញតម្រូវការរបស់ភ្ញៀវទេសចរមុនពេល ក្នុងពេល និងក្រោយពេលនៃខ្សែទស្សនកិច្ចរបស់ពួកគេ។ នៅកម្ពុជា ឧស្សាហកម្មទេសចរណ៍បានក្លាយជាចំណុចអាទិភាពក្នុងការអភិវឌ្ឍវិស័យទេសចរណ៍នាពេលបច្ចុប្បន្ន ដោយហេតុថា សេវាកម្មទេសចរណ៍ទាំងអស់គឺជាផ្នែកដ៏សំខាន់ជាបំផុតសម្រាប់បម្រើដល់តម្រូវការរបស់ភ្ញៀវទេសចរណ៍សម្រាប់ខ្សែទស្សនកិច្ចរបស់ពួកគេ។ សេវាកម្មទេសចរណ៍ទាំងអស់នោះបានចូលរួមបង្កើតការងារនិងមុខរបរជូនដល់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការបង្កើត "អាជីវកម្មទេសចរណ៍" សម្រាប់រកប្រាក់ចំណូលផង និងបម្រើដល់វិស័យទេសចរណ៍ផង។

បច្ចុប្បន្ននេះ អាជីវកម្មទេសចរណ៍ទាំងឡាយនៅក្នុងប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងនៃសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ដោយការគ្រប់គ្រងនេះផ្តោតសំខាន់ទៅលើការពិនិត្យអំពីលទ្ធភាពនៃការប្រកបអាជីវកម្មផ្តល់អាជ្ញាបណ្ណ ដកហូតអាជ្ញាបណ្ណ និងការធ្វើអធិការកិច្ចជាដើម។ ក្នុងន័យនេះ ក្រសួងទេសចរណ៍ត្រូវមានយន្តការនិងលិខិតបទដ្ឋានគតិយុត្តជាច្រើនសម្រាប់គាំទ្រនិងជំរុញឱ្យការអនុវត្តនូវតួនាទីនិងកាតព្វកិច្ចទៅលើសកម្មភាពអាជីវកម្មទេសចរណ៍ទាំងអស់នោះ។

[3] របាយការណ៍បូកសរុបការងារទេសចរណ៍ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តឆ្នាំ២០២០

ដូច្នេះ ការសិក្សាទៅលើប្រធានបទ "ការគ្រប់គ្រងអាជីវកម្មក្នុងវិស័យទេសចរណ៍នៅប្រទេសកម្ពុជា" នឹងចូលរួមជាផ្នែកមួយសម្រាប់អ្នកសិក្សាគ្រប់ឯកទេស ដើម្បីបានក្លាយជាចំណេះដឹងមួយបែបទៀតទាក់ទងនឹងអាជីវកម្មទេសចរណ៍ ព្រមទាំងការគ្រប់គ្រងនិងយន្តការនៃគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ទៅលើអាជីវកម្មទេសចរណ៍។

## ២. ចំណោទបញ្ហា

នាពេលបច្ចុប្បន្ន អាជីវកម្មទេសចរណ៍នៅកម្ពុជាបាននិងកំពុងមានភាពពេញនិយមសម្រាប់ប្រជាពលរដ្ឋក្នុងស្រុកចាប់យកមកបង្កើតធ្វើជាមុខរបរចិញ្ចឹមជីវិតក៏ដូចជាចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា។ ក្នុងន័យនេះដើម្បីរក្សាបាននូវនីត្យានុកូលភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងគ្រប់គ្រងបាននូវហានិភ័យទាំងឡាយដែលកើតមានឡើងពីអាជីវកម្មទេសចរណ៍ ក្រសួងទេសចរណ៍និងស្ថាប័នពាក់ព័ន្ធបានខិតខំបង្កើតនូវយន្តការ និងលិខិតបទដ្ឋានគតិយុត្តគាំទ្រជាច្រើន សម្រាប់អនុវត្តនូវការងារគ្រប់គ្រងរបស់ខ្លួន។ ទោះជាអាជីវកម្មទេសចរណ៍កម្ពុជាមានភាពរីកចម្រើនយ៉ាងណាក៏ដោយ ក៏ចំណេះដឹងរបស់ប្រជាពលរដ្ឋក្នុងស្រុកទាក់ទងនឹងអាជីវកម្មទេសចរណ៍ និងការគ្រប់គ្រងអាជីវកម្មទេសចរណ៍នៅមានកម្រិតនៅឡើយ ដែលជាហេតុធ្វើឱ្យចំណុចអសកម្មមួយចំនួនបានកើតឡើងនាពេលបច្ចុប្បន្ន។ ដូច្នេះដើម្បីស្រាយនូវរាល់បញ្ហា និងចម្ងល់ដែលកំពុងកើតមានឡើង ការសិក្សាប្រធានបទនេះនឹងធ្វើការបកស្រាយទៅលើសំណួរសំខាន់ៗពីរគឺៈ

១. តើអ្វីទៅជាអាជីវកម្មទេសចរណ៍?

២. តើក្រសួងទេសចរណ៍មានយន្តការនិងយុទ្ធសាស្ត្រយ៉ាងណាខ្លះក្នុងការគ្រប់គ្រងអាជីវកម្មក្នុងវិស័យទេសចរណ៍នៅកម្ពុជា?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ក្នុងការសិក្សាទៅលើប្រធានបទនេះគោលបំណងធំៗដែលនឹងសម្រេចបានមានដូចជាៈ

១. អត្ថន័យជាទូទៅនៃអាជីវកម្មទេសចរណ៍ ឧស្សាហកម្មទេសចរណ៍ និងវិស័យទេសចរណ៍ទាំងមូល។ ក្នុងគោលបំណងនេះ យើងនឹងបានដឹងលម្អិតអំពីផ្នែកសំខាន់ៗនៃវិស័យទេសចរណ៍ ជាពិសេសសេវាកម្មទេសចរណ៍ (អាជីវកម្មទេសចរណ៍)។ ក្នុងន័យនេះ យើងក៏នឹងបានដឹងអំពីប្រភេទអាជីវកម្មទាំងឡាយណាដែលចាត់ទុក និងមិនចាត់ទុកចូលជាអាជីវកម្មទេសចរណ៍ និងស្ថិតឬមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍។

២. លិខិតបទដ្ឋានគតិយុត្តគាំទ្រចាំបាច់នានាសម្រាប់បម្រើដល់ការគ្រប់គ្រង។ គោលបំណងមួយនេះផ្តោតសំខាន់ទៅលើឯកសារផ្លូវច្បាប់ដែលក្រសួងទេសចរណ៍បាននិងកំពុងបង្កើតរៀបចំសម្រាប់បង្កើតនិងបង្កើនភាពងាយស្រួលដល់ដំណើរការនៃការគ្រប់គ្រងអាជីវកម្មទេសចរណ៍របស់ខ្លួន។ លិខិតបទដ្ឋានគតិយុត្តទាំងនោះស្ថិតនៅក្នុងទម្រង់ផ្សេងៗគ្នា ដូចជា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សារាចរ និងសេចក្តីណែនាំនានា។

៣. យន្តការនិងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងអាជីវកម្មទេសចរណ៍។ ចំណុចនេះសំដៅទៅដល់ការបង្កើតបាននូវរចនាសម្ព័ន្ធគ្រប់គ្រងមួយប្រកបដោយគុណភាព និងភាពអាចជឿទុកចិត្តបានរបស់ក្រសួងទេសចរណ៍ក្នុងការគ្រប់គ្រងអាជីវកម្ម។ រចនាសម្ព័ន្ធគ្រប់គ្រងនេះស្ថិតក្នុងទម្រង់ជាប្រព័ន្ធពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ ពោលគឺយន្តការនិងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍មានលក្ខណៈរឹងមាំដែលបង្កើតឡើងសម្រាប់ធានាបាននូវប្រសិទ្ធភាព និងភាពជាក់លាក់ក្នុងការអនុវត្តការងារគ្រប់គ្រងអាជីវកម្មទេសចរណ៍នេះ។

គោលបំណងធំៗទាំងបីខាងលើនេះ គឺមានសារៈសំខាន់ណាស់ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទទាំងមូល ដោយហេតុថាអត្ថន័យនិងខ្លឹមសារសំខាន់ៗនៃការសិក្សាស្រាវជ្រាវសំដៅទៅលើយន្តការនិងយុទ្ធសាស្ត្ររបស់ក្រសួងទេសចរណ៍ក្នុងការគ្រប់គ្រងអាជីវកម្មទេសចរណ៍នៅកម្ពុជា។

### ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ទំហំនិងដែនកំណត់នៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ ពាក់ព័ន្ធនឹងគ្របខណ្ឌនានាក្នុងវិស័យទេសចរណ៍ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។ ក្នុងការសិក្សានេះ យើងផ្តោតសំខាន់តែទៅលើអាជីវកម្មទាំងឡាយណាដែលស្ថិតក្នុងវិស័យទេសចរណ៍ និងការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នដែលពាក់ព័ន្ធនឹងអាជីវកម្មទេសចរណ៍ទាំងនោះ។ ជារួម យើងធ្វើការសិក្សាតែទៅលើរាល់អាជីវកម្មណាដែលបម្រើសំខាន់ដល់វិស័យទេសចរណ៍ ពោលគឺចូលរួមចំណែកក្នុងការផ្គត់ផ្គង់ដល់តម្រូវការទេសចរណ៍ ព្រមទាំងសិក្សាតែទៅលើការគ្រប់គ្រងរបស់ក្រសួងស្ថាប័ននានាដែលពាក់ព័ន្ធទៅនឹងអាជីវកម្មទាំងនោះប៉ុណ្ណោះ។

### ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងផ្តល់នូវសារៈសំខាន់ជាច្រើនដល់យើងខ្ញុំ ក៏ដូចជាអ្នកសិក្សាគ្រប់មជ្ឈដ្ឋាន ដូចជា៖

- បានស្គាល់និងយល់ដឹងច្បាស់អំពីស្ថានភាពទូទៅនៃវិស័យទេសចរណ៍ ជាពិសេសឧស្សាហកម្មទេសចរណ៍ក្នុងប្រទេសកម្ពុជា។ ការយល់ដឹងនេះផ្តល់សារៈសំខាន់ដល់បុគ្គលគ្រប់រូបសម្រាប់ជាចំណេះដឹងទូទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួននិងអាចយកទៅអនុវត្តក្នុងការសិក្សា ការងារនិងភារកិច្ចផ្សេងៗ។ ការយល់ដឹងនេះក៏អាចចូលរួមអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជាផងដែរ ពីព្រោះសកម្មភាពទេសចរណ៍ទាំងឡាយដែលកើតមានឡើងនឹងមានសណ្តាប់ធ្នាប់ល្អ និងមានរបៀបរៀបរយ។
- បានស្វែងយល់អំពីរបៀបរបប និងយុទ្ធសាស្ត្ររបស់ក្រសួងទេសចរណ៍ក្នុងការអនុវត្តការងារគ្រប់គ្រងនូវរាល់អាជីវកម្មទេសចរណ៍ក្នុងប្រទេសកម្ពុជា។ លើសពីនេះ យើងក៏បានយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តនានាដែលមាននិងកំពុងរៀបចំបង្កើតសម្រាប់គាំទ្រដល់ការគ្រប់គ្រងរបស់ក្រសួងស្ថាប័ន។ ចំណេះដឹងក្នុងផ្នែកនេះ មានប្រយោជន៍ដល់ការចូលរួមនិងការពង្រឹងការអនុវត្តច្បាប់ទាក់ទងនឹង

ឧស្សាហកម្មទេសចរណ៍របស់ប្រជាពលរដ្ឋនិងមន្ត្រីអនុវត្តន៍ច្បាប់ សំដៅដល់ការធានាបាននូវការគ្រប់គ្រង អាជីវកម្មទេសចរណ៍មួយប្រកបដោយគុណភាព ប្រសិទ្ធភាព និងភាពដែលអាចជឿទុកចិត្តបាន។

- បានជ្រួតជ្រាបនិងស្វែងយល់អំពីនីតិវិធីមួយចំនួនក្នុងការស្នើសុំអាជ្ញាបណ្ណសម្រាប់ប្រកបអាជីវកម្មទេសចរណ៍។ សារៈសំខាន់មួយនេះ ពិតជាបានចូលរួមចំណែកជាច្រើនក្នុងការពង្រឹងគុណភាពនៃការគ្រប់គ្រងអាជីវកម្មទេសចរណ៍ ដោយយល់ឃើញថាចំណេះដឹងទាក់ទងនឹងការស្នើសុំអាជ្ញាបណ្ណនេះធ្វើឱ្យរាល់សកម្មភាពអាជីវកម្មក្នុងវិស័យទេសចរណ៍ត្រូវបានប្រព្រឹត្តឡើងប្រកបដោយនីត្យានុកូលភាព និងធ្វើឱ្យសង្គមជាតិកម្ពុជាក្លាយជានីតិរដ្ឋ។

ជារួម សារៈសំខាន់ដូចដែលបានរៀបរាប់ខាងលើ មិនត្រឹមតែសម្រាប់យើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវនោះទេ ពោលវាជាផ្នែកមួយដ៏សំខាន់នៃចំណេះដឹងទូទៅរបស់អ្នកសិក្សាគ្រប់មជ្ឈដ្ឋាន គ្រប់បុគ្គលទាំងឡាយគ្រប់ស្រទាប់វណ្ណៈ។ ខ្លឹមសារនៃការសិក្សាស្រាវជ្រាវនេះបានចូលរួមចំណែកក្នុងការអភិវឌ្ឍចំណេះដឹងរបស់មនុស្សគ្រប់រូបឱ្យបានស្វែងយល់ពីទិដ្ឋភាពទូទៅរបស់ទេសចរណ៍នៃកម្ពុជា ទិដ្ឋភាពគតិយុត្តក្នុងការគ្រប់គ្រងអាជីវកម្មទេសចរណ៍ យន្តការនិងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងអាជីវកម្មទេសចរណ៍របស់ក្រសួងទេសចរណ៍ ដែលទាំងអស់នេះបានជួយដល់ការពង្រឹង ការអនុវត្តច្បាប់ និងចូលរួមបង្កើនភាពងាយស្រួលក្នុងការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍ ជាពិសេសពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិកម្ពុជា។

### ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវការសិក្សាស្រាវជ្រាវនិងចងក្រងឡើងបាននូវសារណានេះ វិធីសាស្ត្រចម្បងជាងគេ គឺឯកសារដែលមានស្រាប់នៅតាមក្រសួង ស្ថាប័នមានសមត្ថកិច្ច ជាពិសេសគឺក្រសួងទេសចរណ៍។ ឯកសារដែលមានសារៈសំខាន់ជាងគេក្នុងការសិក្សាស្រាវជ្រាវនេះមានដូចជា ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរ សេចក្តីណែនាំ ផែនការយុទ្ធសាស្ត្រ និងរបាយការណ៍បូកសរុបការងារជាដើម។ ដើម្បីស្រាវជ្រាវរកនូវឯកសារទាំងអស់នោះ យើងខ្ញុំបានចុះធ្វើការស្រាវជ្រាវ និងស្នើសុំដល់ទីស្តីការក្រសួងផ្ទាល់ និងបានសាកសួររកនូវព័ត៌មានចាំបាច់មួយចំនួនដែលមានសារៈប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវនេះ។

ទន្ទឹមនឹងការស្រាវរកនូវឯកសារទាំងនោះនិងដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះមានភាពត្រឹមត្រូវទៅតាមតថភាពជាក់ស្តែង ទាំងទិដ្ឋភាពច្បាប់និងទិដ្ឋភាពបច្ចេកទេស យើងខ្ញុំបានសាកសួរព័ត៌មានសំខាន់ៗ និងស្រាយនូវចម្ងល់នានាដែលយើងខ្ញុំមាន ពីមន្ត្រីជំនាញមួយចំនួននៃក្រសួងទេសចរណ៍ដែលពួកគេជាអ្នកអនុវត្តការងារផ្ទាល់។ យោងតាមវិធីសាស្ត្រខាងលើ យើងខ្ញុំសង្ឃឹមថាការសិក្សាស្រាវជ្រាវនេះនឹងមានភាពត្រឹមត្រូវទៅតាម

ទិដ្ឋភាពច្បាប់និងទិដ្ឋភាពជាក់ស្តែងនៃសង្គម ព្រមទាំងប្រកបដោយគុណភាព និងភាពដែលអាចជឿទុកចិត្តបានសម្រាប់អ្នកសិក្សានិងបុគ្គលគ្រប់រូបគ្រប់មជ្ឈដ្ឋាន។

### ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវភាពងាយស្រួលក្នុងការស្វែងយល់ និងយល់ដឹងរបស់អ្នកអាន ការសិក្សាស្រាវជ្រាវចំពោះប្រធានបទខាងលើនេះ ត្រូវបានបែងចែកជា ៣ជំពូកធំៗគឺៈ

ជំពូកទី១ និយាយពី ស្ថានភាពអាជីវកម្មទេសចរណ៍

ជំពូកទី២ និយាយពី ការគ្រប់គ្រងអាជីវកម្មទេសចរណ៍

ជំពូកទី៣ និយាយពី ការផ្តល់អាជ្ញាបណ្ណអាជីវកម្មទេសចរណ៍

# ជំពូកទី១
# ស្ថានភាពអាជីវកម្ម
# ទេសចរណ៍

# ជំពូកទី១

# ស្ថានភាពអាជីវកម្មទេសចរណ៍

## ១. និយមន័យនិងប្រភេទអាជីវកម្មទេសចរណ៍

### ១.១. និយមន័យអាជីវកម្មទេសចរណ៍

មុននឹងឈានដល់ការបកស្រាយអត្ថន័យនៃពាក្យ "អាជីវកម្មទេសចរណ៍" យើងគួរស្វែងពីខ្លឹមសារនៃពាក្យ "ឧស្សាហកម្មទេសចរណ៍" ជាមុនសិន។ យោងទៅតាមវចនានុក្រមខ្មែររៀបរៀងសម្តេចសង្ឃរាជ ជួន ណាត ពាក្យថា "ឧស្សាហកម្ម" មានន័យថា ការដែលកើតមានឡើងដោយសេចក្តីខិតខំប្រឹងប្រែងធ្វើ ការធ្វើរបស់អ្វីៗឱ្យកើតបានជាជំនួញទូទៅ ការបង្កើតរបស់ប្រើប្រាស់តាមសម័យនិយម។ រីឯពាក្យថា "ទេសចរណ៍" សំដៅទៅលើការធ្វើដំណើរកម្សាន្តលម្ហែចិត្តនៃជនបរទេស។ រួមមក ឧស្សាហកម្មទេសចរណ៍ បើយោងតាមន័យរបស់វចនានុក្រមខ្មែរ មានន័យថា ការដែលកើតឡើងពីការខិតខំប្រឹងប្រែងធ្វើឱ្យសម្រេចបានជំនួញផ្សេងសម្រាប់បម្រើដល់ដំណើរកម្សាន្តលម្ហែចិត្តរបស់ មនុស្ស ពិសេសរបស់ជនបរទេស។ ក្រៅពីនេះ បើក្រឡេកមកមើលខ្លឹមសារនៃច្បាប់ស្តីពីទេសចរណ៍ (ប្រកាសឱ្យប្រើនៅឆ្នាំ២០០៩) បានចែងថា **ឧស្សាហកម្មទេសចរណ៍** សំដៅដល់ផ្នែកមួយនៃឧស្សាហកម្មសេវាកម្មដែលបង្កើតឡើង ក្នុងគោលបំណងផ្គត់ផ្គង់ដល់សេចក្តីត្រូវការរបស់ទេសចរនិងសង្គមដែលរួមមានជាសម្បទា ឬសេវាកម្មទាំងឡាយដែលពាក់ព័ន្ធដោយផ្ទាល់និងដោយប្រយោលដល់ការអភិវឌ្ឍវិស័យទេសចរណ៍និងជួយបង្កឱ្យមានភាពអាចអនុវត្តទៅបាននៃខ្សែទស្សនកិច្ច។ [4]

ដោយឡែក ចំពោះពាក្យថា "អាជីវកម្មទេសចរណ៍" បើយោងតាមវចនានុក្រមខ្មែរបានចែងអត្ថន័យនៃពាក្យ "អាជីវកម្ម" ថា ការប្រកបមុខរបរចិញ្ចឹមជីវិត ការចាត់ចែងធ្វើយកផលពីដំណាំ ពីឈើព្រៃ ពីព្រះធរណីជាដើម ទីដីដែលគេប្រកបធ្វើការយកផលនោះ។ ដូច្នេះ អាជីវកម្មទេសចរណ៍ សំដៅដល់ការប្រកបរបរចិញ្ចឹមជីវិតដោយបំពេញនូវតម្រូវការរបស់ដំណើរកម្សាន្តលម្ហែចិត្តរបស់ជនបរទេស ឬន័យមួយបែបទៀត យើងអាចនិយាយបានថា អាជីវកម្មទេសចរណ៍សំដៅទៅដល់ ការផ្តល់សេវាកម្មទាំងឡាយសម្រាប់ផ្គត់ផ្គង់ដល់ដំណើរកម្សាន្តរបស់មនុស្សគ្រប់រូប ដើម្បីរកបានកម្រៃសម្រាប់ចិញ្ចឹមជីវិត។ ដោយយោងតាមខ្លឹមសាររបស់ច្បាប់ស្តីពីទេសចរណ៍ បានចែងថា **អាជីវកម្មទេសចរណ៍** សំដៅទៅដល់អាជីវកម្មលើសេវាកម្មទេសចរណ៍ដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍ដូចជា មគ្គុទ្ទេសក៍ទេសចរណ៍ ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ព័ត៌មាននិងការផ្សព្វផ្សាយទេសចរណ៍ សេវាកម្មស្នាក់នៅទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ គោលដៅទាក់ទាញទេសចរណ៍ សេវាកម្មដឹកជញ្ជូនទេសចរណ៍ អាហារដ្ឋាននិងភោជនីយដ្ឋានទេសចរណ៍ សាលាវិជ្ជាជីវៈទេសចរណ៍ មណ្ឌលកម្សាន្ត

[4] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ២០០៩)

ទេសចរណ៍ មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ សកម្មភាពកីឡាទេសចរណ៍ និងព្រឹត្តិការណ៍និងពិព័រណ៍ទេសចរណ៍។ [5]

ដូច្នេះ យោងតាមការវិភាគទៅលើអត្ថន័យរបស់ពាក្យ "ឧស្សាហកម្មទេសចរណ៍" និងពាក្យ "អាជីវកម្មទេសចរណ៍" យើងឃើញថា ពាក្យទាំងពីរនេះសុទ្ធសឹងតែមានទំនាក់ទំនងទៅនឹងសេវាកម្មទេសចរណ៍ដែលបម្រើដល់ការធ្វើដំណើរកម្សាន្តរបស់ទេសចរទាំងជាតិទាំងអន្តរជាតិ។ ពាក្យទាំងពីរខុសគ្នានៅត្រង់ថា ឧស្សាហកម្មទេសចរណ៍ប្រមូលផ្ដុំនូវគ្រប់សេវាកម្មទេសចរណ៍ទាំងអស់ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមស្មារតីនៃច្បាប់ស្ដីពីទេសចរណ៍។ ចំណែកឯ អាជីវកម្មទេសចរណ៍ សំដៅដល់ការប្រកបមុខរបរចិញ្ចឹមជីវិតទៅលើសេវាកម្មទេសចរណ៍ទាំងនោះ ឬយកសេវាកម្មទាំងអស់នោះមកធ្វើជាមុខរបរចិញ្ចឹមជីវិតស្របតាមបទប្បញ្ញត្តិនៃច្បាប់។

រួមមក ការជ្រើសរើសយកសេវាកម្មទេសចរណ៍ មកធ្វើជាអាជីវកម្មដើម្បីរកកម្រៃចិញ្ចឹមជីវិត នាពេលបច្ចុប្បន្ន បាននិងកំពុងមានភាពពេញនិយម ដោយយោងទៅតាមភាពរីកចម្រើនគួរឱ្យកត់សម្គាល់នៃវិស័យទេសចរណ៍។ សេវាកម្មដែលប្រជាពលរដ្ឋអាចយកមកធ្វើជាអាជីវកម្មសម្រាប់ចិញ្ចឹមជីវិតបាននោះ លុះត្រាតែមានចែងនៅក្នុងច្បាប់ជាធរមាន ពោលគឺការប្រកបអាជីវកម្មលើសេវាកម្មទេសចរណ៍អាចប្រព្រឹត្តទៅបានលុះត្រាតែមានច្បាប់ចែងនិងអនុញ្ញាត។ អាជីវកម្មទេសចរណ៍នេះទៀតសោត ក៏មានលក្ខណៈសំបូរបែបជាច្រើនផងដែរ ដោយយោងទៅនឹងចំណង់ចំណូលចិត្តរបស់មនុស្ស ភាពច្នៃប្រតិដ្ឋ និងការវិវត្តនៃសង្គម។ លក្ខណៈសំបូរបែបទាំងនោះ បានជំរុញឱ្យការគ្រប់គ្រងអាជីវកម្មទេសចរណ៍របស់ក្រសួងស្ថាប័នមានសមត្ថកិច្ច មានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្ដែងនាពេលបច្ចុប្បន្ន ពោលគឺត្រូវធ្វើបច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងអាជីវកម្មទេសចរណ៍ ឱ្យមានភាពទាន់ពេលវេលានឹងតម្រូវការជាក់ស្ដែងរបស់សង្គម។

### ១.២. ប្រភេទអាជីវកម្មទេសចរណ៍

អាជីវកម្មទេសចរណ៍ត្រូវបានបែងចែកប្រភេទដោយយោងទៅតាមប្រភេទនៃសេវាកម្មទេសចរណ៍។ ឧទាហរណ៍៖ សេវាកម្មស្នាក់នៅរបស់ទេសចរណ៍ ត្រូវបានអាជីវករទេសចរណ៍បង្កើតបានជា ផ្ទះសំណាក់ សណ្ឋាគារជាដើម ដែលទាំងអស់នោះហៅថា អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍។ ក្នុងន័យនេះ គ្រប់អាជីវកម្មទេសចរណ៍សុទ្ធសឹងតែជាសេវាកម្មទេសចរណ៍ដែលនឹងត្រូវបម្រើដល់ខ្សែទស្សនកិច្ចរបស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ។

ដោយយោងទៅតាមស្មារតីនៃច្បាប់ស្ដីពីទេសចរណ៍ បានចែងអំពីសកម្មភាពអាជីវកម្មទេសចរណ៍ដែលត្រូវបានបែងចែកចេញជាបីប្រភេទធំៗគឺ៖ សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវជាចម្បង សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវរួមគ្នា និងសកម្មភាពអាជីវកម្ម

[5] ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីទេសចរណ៍ (ឆ្នាំ២០០៩)

ទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវដោយមានការទទួលខុសត្រូវដោយការប្រឹក្សា។ ក្នុងចំណោមក្រុមសកម្មភាពអាជីវកម្មទេសចរណ៍ទាំងនោះ សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវជាចម្បង ជាសកម្មភាពអាជីវកម្មទេសចរណ៍សំខាន់ដែលជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវនេះ។

សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវជាចម្បងមានជាអាទិ៍ដូចតទៅៈ

- មគ្គុទ្ទេសក៍ទេសចរណ៍
- ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍
- ព័ត៌មាននិងការផ្សព្វផ្សាយទេសចរណ៍
- សេវាកម្មស្នាក់នៅទេសចរណ៍
- រមណីយដ្ឋានទេសចរណ៍
- គោលដៅទាក់ទាញទេសចរណ៍
- សេវាកម្មដឹកជញ្ជូនទេសចរណ៍
- អាហារដ្ឋាននិងភោជនីយដ្ឋានទេសចរណ៍
- សាលាវិជ្ជាជីវៈទេសចរណ៍
- មណ្ឌលកម្សាន្តទេសចរណ៍
- មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- សកម្មភាពកីឡាទេសចរណ៍
- ព្រឹត្តិការណ៍និងពិព័រណ៍ទេសចរណ៍។ [6]

សកម្មភាពអាជីវកម្មទេសចរណ៍ដែលបានរៀបរាប់ខាងលើ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងជាចម្បងពីក្រសួងទេសចរណ៍ ពោលក្រសួងទេសចរណ៍មានសមត្ថកិច្ចក្នុងការពិនិត្យលើពាក្យស្នើសុំអាជ្ញាបណ្ណ ផ្តល់អាជ្ញាបណ្ណក៏ដូចជាផ្តល់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មទេសចរណ៍ដោយស្របច្បាប់។

ក្នុងចំណោមបណ្តុំនៃសកម្មភាពអាជីវកម្មទេសចរណ៍ដូចដែលបានរៀបរាប់ខាងលើ គេសង្កេតឃើញថាសកម្មភាពអាជីវកម្មសំខាន់ៗដែលបម្រើយ៉ាងសកម្មដល់សកម្មភាពទេសចរណ៍របស់ភ្ញៀវទេសចរមានដូចជាៈ

ក. សេវាកម្មទីភ្នាក់ងារ សេវាកម្មដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍

ខ. សេវាកម្មស្នាក់នៅនិងម្ហូបអាហារទេសចរណ៍

គ. សេវាកម្សាន្តនិងកីឡាទេសចរណ៍

ឃ. រមណីយដ្ឋានទេសចរណ៍។

[6] ច្បាប់ស្តីពីទេសចរណ៍, មាត្រា៣០ ចំណុច "ក"

### ១.២.១. សេវាកម្មទីភ្នាក់ងារ សេវាកម្មដឹកជញ្ជូន និងមគ្គុទេសក៍ទេសចរណ៍

#### ក. សេវាកម្មទីភ្នាក់ងារទេសចរណ៍

ទីភ្នាក់ងារទេសចរណ៍ អាចហៅម៉្យាងទៀតថា **អន្តរការីនៃឧស្សាហកម្មទេសចរណ៍** អ្នកដែលដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យទេសចរណ៍ ជាអ្នករៀបចំនិងចាត់ចែងឱ្យមានការធ្វើដំណើរកម្សាន្ត ដំណើរជាទេសចរណ៍ និងធានានូវការធ្វើទំនាក់ទំនងជាមួយមូលដ្ឋានសេវាកម្មនានាដើម្បីបង្កលក្ខណៈងាយស្រួលនិងបំពេញឱ្យបានគ្រប់គ្រាន់ចំពោះសេចក្តីត្រូវការរបស់ទេសចរ។

អន្តរការីនៃឧស្សាហកម្ម (ទីភ្នាក់ងារទេសចរណ៍) សំដៅដល់នីតិបុគ្គលឬរូបវន្តបុគ្គលដែលបំពេញតួនាទីរបស់ខ្លួនជាអ្នកផលិតនិងលក់ផលិតផលទេសចរណ៍ បង្កើតនិងលក់កម្មវិធីដំណើរទេសចរណ៍ រៀបចំចាត់ចែងការងារប្រជុំ សន្និបាត រៀបចំពិធីតាំងពិព័រណ៍ និងផ្តល់សេវាកម្មផ្សេងៗដែលចាំបាច់សម្រាប់ទេសចរណ៍។

ទីភ្នាក់ងារទេសចរណ៍ (Travel Agency) ត្រូវបានបែងចែកជាពីរផ្នែកដាច់ពីគ្នា៖

- ការីទេសចរណ៍ (Tour Operator) ជាអ្នករៀបចំនូវប្រតិបត្តិការកម្សាន្ត
- ភ្នាក់ងារទេសចរណ៍ (Travel Agents) ជាអ្នកលក់បន្តឬលក់រាយកម្មវិធីដំណើរកម្សាន្ត។ [7]

យោងតាមច្បាប់ស្តីពីទេសចរណ៍ បានឱ្យនិយមន័យនៃពាក្យ "ការីទេសចរណ៍" និង "ភ្នាក់ងារទេសចរណ៍" ថា៖

- ការីទេសចរណ៍ សំដៅដល់បុគ្គលដែលរៀបចំនិងលក់ខ្សែទស្សនកិច្ច ព្រមទាំងប្រមូលផ្តុំសេវាកម្មទេសចរណ៍ផ្សេងៗទៀត សម្រាប់លក់ដោយផ្ទាល់ឬតាមរយៈ**ភ្នាក់ងារទេសចរណ៍** ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា។
- ភ្នាក់ងារទេសចរណ៍ សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរ ដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត រាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតដោយ**ការីទេសចរណ៍**ផងដែរ។ [8]

ភាពខុសគ្នារវាងអ្នកចាត់ចែងសកម្មភាពការងារទេសចរណ៍ទាំងពីរប្រភេទនេះ (ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍) គឺស្ថិតនៅលើវិស័យការងារ។ ការីទេសចរណ៍ ក្រៅពីសកម្មភាពការងារដើម្បីជំរុញផលិតផលនិងសេវាកម្មទៅទីផ្សារ ហើយនិងលក់សេវាកម្មទាំងនេះ បន្ថែមទាំងផលិតនូវផលិតផលនិងសេវាកម្មទេសចរណ៍ ជាពិសេសគឺខ្សែទស្សនកិច្ច។ មានន័យថា ការីទេសចរណ៍ធ្វើការងារជាអ្នកប្រមូលសេវាគ្រប់ផ្នែក

---

[7] សៀវភៅ "ទេសចរណ៍ ទ្រឹស្តីនិងទស្សនៈជាមូលដ្ឋាន", បណ្ឌិត សួន វ៉ានី ឆ្នាំ២០០៦

[8] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ២០០៩)

*ឧទាហរណ៍៖* រៀបចំធ្វើទិដ្ឋាការ ការដឹកជញ្ជូនដំណើរភ្ញៀវ ផ្តល់ទីសំណាក់ ធានារ៉ាប់រងផ្តល់ដំណើរទេសស្សនកិច្ច -ល- បង្កើតកម្មវិធីដំណើរកម្សាន្ត ជំរុញផលិតផលដែលបង្កើតឡើងនេះទៅកាន់ទីផ្សារជាតិនិងអន្តរជាតិ លក់វាឱ្យអតិថិជនដោយផ្ទាល់ និងលក់ឱ្យភ្នាក់ងារទេសចរណ៍សម្រាប់លក់បន្ត។ រីឯភ្នាក់ងារទេសចរណ៍ជាអ្នកដែលដើរតួលក់ផលិតផល ឬខ្សែទស្សនកិច្ចដែលផលិតដោយការីទេសចរណ៍ ដើម្បីស្វែងរកប្រាក់ចំណេញ និងជាឈ្មួញកណ្តាលរវាងការីទេសចរណ៍និងអតិថិជន។ គួរបញ្ជាក់ដែរថា សព្វថ្ងៃនេះ ក្រៅពីមុខងារនៃការលក់រាយ (ខ្សែទស្សនកិច្ច និង/ឬ បណ្តាសេវាកម្មទេសចរណ៍ផ្សេងៗ) ភ្នាក់ងារទេសចរណ៍អាចធ្វើការងារជាអ្នកលក់បន្តឬលក់ដុំនូវខ្សែទស្សនកិច្ច និង/ឬបណ្តាសេវាកម្មទេសចរណ៍ផ្សេងៗ។ [9]

### ខ. សេវាកម្មដឹកជញ្ជូនទេសចរណ៍

មធ្យោបាយដឹកជញ្ជូនឬប្រព័ន្ធគមនាគមន៍ទាំងស្រុង ជាកត្តាចម្បងសម្រាប់ការរីកដុះដាលនិងអភិវឌ្ឍវិស័យទេសចរណ៍ ព្រោះថាបើគ្មានគមនាគមន៍ទេនោះ ទេសចរណ៍ក៏មិនអាចកើតមានដែរ ដែលនេះបង្ហាញថាការដឹកជញ្ជូននិងគមនាគមន៍មានសារៈសំខាន់បំផុតសម្រាប់ទេសចរណ៍។ ធ្វើដំណើរតាមផ្លូវដែក (រថភ្លើង) ផ្លូវអាកាស (យន្តហោះ) ផ្លូវគោក (រថយន្ត យានយន្តតូច ធំ និងមធ្យោបាយធ្វើដំណើរផ្សេងៗ) ផ្លូវទឹក (នាវាតូច ធំ ទូកតាមសមុទ្រ បឹង ទន្លេ ព្រែក) ជាមធ្យោបាយធ្វើដែលមនុស្សប្រើប្រាស់សម្រាប់ចូលទៅកាន់តំបន់ ប្រទេស ឬទីបណាមួយ។ ចំនួននិងទីតាំងនៃចំណត អាកាសយានដ្ឋាន កំពង់ផែសមុទ្រ ផែទឹកសាប ការអភិវឌ្ឍផ្លូវ និងប្រព័ន្ធបណ្តាញផ្សេងៗ ជាលក្ខណៈចាំបាច់សម្រាប់ផ្តល់លក្ខណៈល្អប្រសើរក្នុងការធ្វើដំណើរ។ ជាមួយគ្នានេះ ទេសចរណ៍ត្រូវប្រើប្រាស់នូវមធ្យោបាយផ្សេងៗដើម្បីដោះដូរទីកន្លែងតាមរយៈការធ្វើដំណើរ ដូចជា យន្តហោះ នាវាត្រាច់ចរ (Cruise Ship) មធ្យោបាយដីគោក។ ការដឹកជញ្ជូនបានផ្តល់ជាលទ្ធភាពដល់ទេសចរណ៍ក្នុងការតភ្ជាប់ពីតំបន់មួយទៅតំបន់មួយ ក្រុងមួយទៅក្រុងមួយ ប្រទេសមួយទៅប្រទេសមួយ និងពីទ្វីបមួយទៅទ្វីបមួយ។ [10]

រួមមក ការដឹកជញ្ជូននាពេលបច្ចុប្បន្នមានបីប្រភេទធំៗគឺ៖

- ការដឹកជញ្ជូនតាមផ្លូវអាកាស
- ការដឹកជញ្ជូនតាមផ្លូវគោក ផ្លូវដែក
- ការដឹកជញ្ជូនតាមទឹក

ដោយឡែក សេវាកម្មដឹកជញ្ជូនទេសចរណ៍ ដែលស្ថិតក្រោមរូបភាពជាអាជីវកម្មទេសចរណ៍នាពេលបច្ចុប្បន្នមានពីរប្រភេទសំខាន់ៗគឺ៖ អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក និងអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក។

---

[9] សៀវភៅ "ទេសចរណ៍ ទ្រឹស្តីនិងទស្សនៈជាមូលដ្ឋាន", បណ្ឌិត សួន វ៉ានី ឆ្នាំ២០០៦

[10] សៀវភៅ "ទេសចរណ៍ ទ្រឹស្តីនិងទស្សនៈជាមូលដ្ឋាន", បណ្ឌិត សួន វ៉ានី ឆ្នាំ២០០៦

នៅក្នុងក្របខណ្ឌគតិយុត្តបានឱ្យនិយមន័យសេវាកម្មដឹកជញ្ជូនទេសចរណ៍ថា ជាអាជីវកម្មរៀបចំឡើងដើម្បីបម្រើសេវាកម្មដឹកជញ្ជូនសម្រាប់ទេសចរណ៍ តាមផ្លូវគោក និងផ្លូវទឹក ដោយរួមទាំងនាវាទេសចរណ៍សមុទ្រផងដែរ។ សេវាកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោកគឺ សំដៅដល់រាល់ការធ្វើអាជីវកម្មដោយប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវគោករបស់ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ ក្រុមហ៊ុនដឹកជញ្ជូនទេសចរណ៍ និងមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន សម្រាប់ដឹកជញ្ជូនទេសចរជាតិ និងអន្តរជាតិ ធ្វើដំណើរកម្សាន្តតាមផ្លូវគោក។ ចំណែកឯសេវាកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក សំដៅទៅលើអាជីវកម្មដែលប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមនាវាទេសចរណ៍ កាណូត ទេសចរណ៍ ដែលមានគោលបំណងបម្រើការកម្សាន្តដល់ទេសចរជាតិនិងអន្តរជាតិ ឬបម្រើឱ្យវិស័យទេសចរណ៍។

### គ. មគ្គុទ្ទេសក៍ទេសចរណ៍

មគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់បុគ្គលដែលប្រកបអាជីពជា អ្នកទទួល ជូន ថែរក្សាភ្ញៀវជាតិ អន្តរជាតិ និងធ្វើអត្ថាធិប្បាយពន្យល់ អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ និងសេដ្ឋកិច្ច សង្គមនៃទីកន្លែងទស្សនា។ [11]

យោងតាមអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ បានចែកមគ្គុទ្ទេសក៍ទេសចរណ៍នៅកម្ពុជាជា៥ប្រភេទគឺ៖

- មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍ដែលត្រូវបានអនុញ្ញាតឱ្យបំពេញការងារនៅតាមប្រាសាទឬតាមសារមន្ទីរដែលជាបេតិកភណ្ឌថ្នាក់ជាតិឬថ្នាក់ពិភពលោក។
- មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅគ្រប់គោលដៅទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍នៅក្នុងតំបន់មួយចំនួននៃព្រះរាជាណាចក្រកម្ពុជា។
- មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍ តែនៅក្នុងដែនដីនៃរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

[11] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ២០០៩)

- មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវតែនៅក្នុងសហគមន៍ប៉ុណ្ណោះ។

### ១.២.២. សេវាកម្មស្នាក់នៅនិងម្ហូបអាហារទេសចរណ៍

#### ក. សេវាកម្មស្នាក់នៅទេសចរណ៍

សេវាកម្មស្នាក់នៅ គឺជាសេវាកម្មសហគ្រាសមួយចំនួនដូចជា៖ សណ្ឋាគារ ផ្ទះសំណាក់ ម៉ូតែល បឹងកាឡូ ផ្ទះជួល ដែលផ្តល់លទ្ធភាពដល់អ្នកដំណើរ ឬទេសចរ ទទួលនិងទិញសេវាកម្មផ្សេងៗ *ឧទាហរណ៍៖* បន្ទប់ស្នាក់នៅ ម្ហូបអាហារ ភេសជ្ជៈ និងសេវាដទៃដែលអាចផ្គត់ផ្គង់ទេសចរណ៍។ ការទិញសេវាកម្មនៅក្នុងសហគ្រាសស្នាក់នៅនេះអាចធ្វើបានភ្លាមៗឬដោយទិញកក់ទុកមុន។ នៅក្នុងសហគ្រាសដែលបម្រើសេវាកម្មស្នាក់នៅបាននិងមានការប្រើប្រាស់នូវសកម្មភាពជាច្រើន៖

- ម្ហូបអាហារនិងភេសជ្ជៈ
- សកម្មភាពកម្សាន្តសប្បាយ
- ព័ត៌មានផ្សេងៗ
- ទីភ្នាក់ងារទេសចរណ៍
- សកម្មភាពដឹកជញ្ជូន
- សកម្មភាពជំនួញ
- សកម្មភាពដែលទាក់ទងនឹងនាំឱ្យមានការពង្រឹង ពង្រីកវិស័យអប់រំសិក្សាធិការ វប្បធម៌។

សហគ្រាស (មូលដ្ឋានសេវាកម្ម) ស្នាក់នៅមានច្រើនប្រភេទត្រូវបានគេកំណត់ដូចខាងក្រោម៖

**សណ្ឋាគារ** (Hotel) ជាអគារស្នាក់នៅដែលមានចំនួនបន្ទប់យ៉ាងតិច១០ និងនៅក្នុងនោះ ចំនួនបន្ទប់មានគ្រែគេងលើសពី២ ត្រូវមានមិនលើសពី២០%។ សណ្ឋាគារត្រូវតែជាអគារដែលមានស្ថាបត្យកម្មរឹងមាំ និងមានលក្ខណៈពិសេសទៅតាមទីកន្លែង ឬទីតាំងស្ថិតនៅរបស់វា បម្រើសេវាកម្មស្នាក់នៅរាល់គ្រប់រដូវសម្រាប់រយៈពេលខ្លី និងរយៈពេលវែង ដោយមានភ្ជាប់មកជាមួយនូវការផ្គត់ផ្គង់ម្ហូបអាហារ និងសេវាកម្មផ្សេងៗទៀតទៅតាមលទ្ធភាពនិងចំណង់ចំណូលចិត្តរបស់ភ្ញៀវ។

**ផ្ទះសំណាក់** (Guesthouse) ជាអគារដែលមានបន្ទប់យ៉ាងតិច៧ និងផ្តល់សេវាកម្មស្នាក់នៅដោយអាចមានភ្ជាប់ជាមួយនូវសេវាកម្មម្ហូបអាហារប្រចាំថ្ងៃ។ ផ្ទះសំណាក់ដែលស្ថិតនៅតំបន់ដាច់ស្រយាលអាចមានបន្ទប់យ៉ាងតិច៣០សម្រាប់ស្នាក់នៅ ហើយចំនួនបន្ទប់ស្នាក់នៅ ៥០% នៃចំនួនបន្ទប់ស្នាក់នៅទាំងអស់ត្រូវស្ថិតនៅក្នុងបន្ទប់ទាំងឡាយណា ដែលរៀបចំសម្រាប់មនុស្ស (ភ្ញៀវ) លើសពី៣នាក់ឡើងទៅ។

**ផ្ទះជួលសាធារណៈ** (Shelter House) ជាសណ្ឋាននៃមូលដ្ឋានសេវាកម្មបម្រើឱ្យការស្នាក់នៅដែលមានលក្ខណៈជាលំនៅដ្ឋានផង និងសម្រាប់ជួលផង តែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការស្នាក់នៅ និងសកម្មភាពអាជីវកម្មសេវាស្នាក់នៅ។

**ផ្ទះផ្តល់អាហារ និងការស្នាក់អាស្រ័យ** (Boarding House) ជាអគារដែលទទួលនិងបម្រើការស្នាក់នៅរបស់ភ្ញៀវជាមួយនឹងការផ្តល់អាហារពេញលេញ (ការស្នាក់នៅនិងម្ហូបអាហារ)។ តែចំពោះភ្ញៀវពីខាងក្រៅការបម្រើសេវាកម្មម្ហូបអាហារមានការកំណត់។ ផ្ទះផ្តល់អាហារ និងការស្នាក់អាស្រ័យមួយចំនួន មិនបម្រើប្រភេទភេសជ្ជៈដែលមានជាតិស្រវឹងកម្រិតខ្ពស់នោះទេ។ ការរៀបចំបំពាក់នូវឧបករណ៍បរិក្ខារផ្នែកខាងក្នុងត្រូវបានធ្វើឡើងសម្រាប់បំពេញអារម្មណ៍អតិថិជនដែលនៅញឹកញាប់ដូចជាក្រុមក្មេងនៅពេលវិស្សមកាល (Summer camp) អ្នកសម្រាកព្យាបាល ។ល។

**សណ្ឋាគារបម្រើការស្នាក់នៅ លក្ខណៈជាផ្ទះសម្រាប់សម្រាកលំហែនៅពេលវិស្សមកាល (Country House Hotel)** ជាប្រភេទសណ្ឋាគារ ដែលមានសកម្មភាពតែតាមរដូវកាល *ឧទាហរណ៍៖* អន្តេវាសិកដ្ឋានសម្រាប់បុគ្គលិក កម្មករ សណ្ឋាគារសម្រាប់ទាហាន។ ភាគច្រើននៃអគារស្នាក់នៅទាំងអស់នេះមិនផ្តល់នូវម្ហូបអាហារសម្រាប់ភ្ញៀវពីខាងក្រៅនោះទេ គឺបម្រើតែអតិថិជនរបស់ខ្លួនប៉ុណ្ណោះ (Buffet)។

**អគារស្នាក់នៅដែលមានទីតាំងស្ថិតនៅតំបន់ភ្នំ និងតាមតំបន់ចរាចរទេសចរណ៍** (គ្រប់រូបភាព) – Shelter House ជាប្រភេទអគារស្នាក់នៅ ដែលមានឱកាសបម្រើសេវាកម្មផ្សេងៗពីគ្នា។ មួយចំនួនទទួលភ្ញៀវ ឬធ្វើសកម្មភាពបម្រើសេវាកម្មគ្រប់រដូវកាល និងឱកាសដូចគ្នានឹងសណ្ឋាគារធម្មតា ឯខ្លះទៀតផ្តល់ឱ្យតែសេវាកម្មស្នាក់នៅតែប៉ុណ្ណោះ។

**អគារស្នាក់នៅដែលស្ថិតនៅនឹងចរាចរផ្លូវទឹក** (Boatel) ជាអគារដែលបម្រើឱ្យការស្នាក់នៅដល់ភ្ញៀវទេសចរណ៍ដែលធ្វើដំណើរតាមផ្លូវទឹកដោយប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់ខ្លួនឬដោយមធ្យោបាយធ្វើដំណើរសាធារណៈ។ ការសាងសង់និងបំពាក់ឧបករណ៍បរិក្ខារត្រូវបានធ្វើឡើងសំដៅលើការបង្កលក្ខណៈងាយស្រួលដល់ការចូលចតនៃនាវាដូចជាការបង្កើតឱ្យមាននូវទម្រង់កំពង់ផែតូចៗ។

**ម៉ូតែល** (Motel) គឺជាអគារដែលមានបន្ទប់យ៉ាងតិច១០ និងនៅក្នុងនោះ ចំនួនបន្ទប់ដែលមានគ្រែគេងលើសពី២ ត្រូវមានមិនលើសពី៤០%។ ម៉ូតែលជាអគារស្នាក់នៅបម្រើសេវាកម្មសម្រាប់ទេសចរ ដែលធ្វើដំណើរកម្សាន្តដោយមធ្យោបាយយានយន្តផ្ទាល់ខ្លួន ឬតាមរយៈក្រុមហ៊ុនទេសចរណ៍។ អគារស្នាក់នៅនេះច្រើនស្ថិតនៅតាមដងផ្លូវធំៗដែលជាចរាចរទេសចរណ៍ និងមានលក្ខណៈជាតិនិងអន្តរជាតិ។ ម៉ូតែលមានការរៀបចំរចនាសម្ព័ន្ធប្រហាក់ប្រហែលនឹងសណ្ឋាគារដែរ។

**បឹងកាឡូ (Bungalow)** ជាអគារស្នាក់នៅដែលស្ថិតនៅដាច់ពីគ្នា និងអាចមានចំណាត់ថ្នាក់ខ្ពស់។ អគារប្រភេទនេះ ត្រូវបានរៀបចំឡើងដោយមានផ្ទះបាយ បន្ទប់ទទួលភ្ញៀវ បន្ទប់គេង កន្លែងធ្វើការងារ និងកន្លែងហាត់កីឡាសុខភាព។

**អគារស្នាក់នៅជាលក្ខណៈឯកជន** ជាអគារស្នាក់នៅដែលម្ចាស់ផ្ទះរៀបចំឡើងបម្រុងទុកសម្រាប់ភ្ញៀវទេសចរស្នាក់នៅដោយឡែកឬជាមួយ។ នៅក្នុងអគារនោះអាចត្រូវបន្ថែមបន្ទប់ស្នាក់នៅសម្រាប់ទេសចរបើសិនមានតម្រូវការ។ ការផ្គត់ផ្គង់អាហារ គឺអាស្រ័យលើលទ្ធភាពរបស់ម្ចាស់ផ្ទះ (ផ្គត់ផ្គង់ពេញលេញឬមិនពេញលេញ)។ អគារស្នាក់នៅអាចសង្កេតឃើញនៅតាមតំបន់ភ្នំ មាត់សមុទ្រ និងនៅតាមទីកន្លែងដែលមានកម្មវត្ថុទាក់ទាញនៃទេសចរណ៍ *ឧទាហរណ៍៖* តំបន់ទីប្រជុំទៅដោយស្ទឹង ឬបឹងពិសេស តំបន់ទឹកជ្រោះ ឬទឹកធ្លាក់។

**ខ. សេវាកម្មម្ហូបអាហារទេសចរណ៍**

មូលដ្ឋានសេវាកម្មហូបចុក (ម្ហូបអាហារនិងភេសជ្ជៈ) មានអត្ថន័យសំខាន់សម្រាប់បំពេញនូវសេចក្តីត្រូវការខាងម្ហូបអាហារដល់មនុស្សទូទៅ ជាពិសេសទេសចរ។ លក្ខណៈពិសេសនៃសេចក្តីត្រូវការទាំងឡាយរបស់ទេសចរ គឺទាមទារធ្វើយ៉ាងណាឱ្យមានកន្លែងហូបចុកស្ថិតនៅជិតបំផុតពីកន្លែងស្នាក់នៅរបស់ខ្លួន។ ក្នុងនោះមិនមែនមានន័យថា រាល់គ្រប់អគារស្នាក់នៅទាំងអស់ ត្រូវតែមាននូវមូលដ្ឋានសេវាកម្មម្ហូបអាហារនោះទេ ក៏ប៉ុន្តែជាទូទៅអាជីវកម្មសេវាកម្មស្នាក់នៅ ដូចជា សណ្ឋាគារ និងផ្ទះសំណាក់មួយចំនួនដែលធ្វើសកម្មភាពតែងភ្ជាប់ជាមួយនូវសេវាកម្មម្ហូបអាហារ។

អាជីវកម្មភោជនីយដ្ឋាននិងអាហារដ្ឋាននៅកម្ពុជានាពេលបច្ចុប្បន្ន មានពីរប្រភេទគឺ៖

- ភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍
- ភោជនីយដ្ឋាននិងអាហារដ្ឋានក្នុងស្រុក

ភោជនីយដ្ឋានទេសចរណ៍ គឺជាអាជីវកម្មបម្រើសេវាកម្មម្ហូបអាហារនិងភេសជ្ជៈដែលមានអ្នកបម្រើ មានដំណើរការច្រើនពេល និងរាល់ថ្ងៃនៅគ្រប់ទីកន្លែង ដែលបម្រើឱ្យទេសចរជាធំ ហើយមានប្រភេទដូចជា៖ ភោជនីយដ្ឋានខ្នាតធំ ភោជនីយដ្ឋានខ្នាតមធ្យម Barbistro ភោជនីយដ្ឋានខ្នាតតូច និងភោជនីយដ្ឋានបៀរហ្គាឌិន។

- ភោជនីយដ្ឋានខ្នាតធំ គឺជាអាជីវកម្មបម្រើសេវាកម្មម្ហូបអាហារ ភេសជ្ជៈ ដែលមានអ្នកបម្រើ និងមានម្ហូបអាហារ ភេសជ្ជៈច្រើនមុខសម្រាប់ជ្រើសរើស សម្ភារៈទំនើប ការបម្រើសេវាកម្រិតខ្ពស់តាមលក្ខណៈស្តង់ដារ មានបម្រើអាហារច្រើនពេល និងរៀបចំបម្រើក្នុងពិធីផ្សេងៗ មានការប្រគុំតន្ត្រីកំដរនៅពេលល្ងាច និងពេលយប់ ឬគ្មានការប្រគុំតន្ត្រី។

- ភោជនីយដ្ឋានខ្នាតមធ្យម Barbistro មានបម្រើម្ហូបអាហារជាលក្ខណៈចម្អិនស្រាប់ បម្រើដោយសេរី (Buffet) មានលក់នំនិងភេសជ្ជៈគ្មានជាតិស្រវឹង ឬមានជាតិស្រវឹងតិច ដែលរៀបចំនៅក្បែរអតិថិជន ការបម្រើតាមលក្ខណៈស្តង់ដារកម្រិតខ្ពស់។
- ភោជនីយដ្ឋានខ្នាតតូច មានផ្តល់អាហារ ភេសជ្ជៈ គ្មានជាតិស្រវឹងឬមានជាតិស្រវឹងតិច ដែលមុខម្ហូបអាហារមានកំណត់ទៅតាមអាហារបណ្ណ ហើយពុំមានសម្ភារៈទំនើប និងពុំមានការប្រគុំតន្ត្រីកំដរ ដែលមានចំនួនកៅអីក្រោម១០០។
- ភោជនីយដ្ឋាន បៀរហ្គាឌិន គឺជាភោជនីយដ្ឋានដែលបម្រើភេសជ្ជៈគ្រប់ប្រភេទ និងមុខម្ហូបអាហារមានកំណត់ ព្រមទាំងមានការប្រគុំកំដរសម្រាប់ភ្ញៀវជាតិនិងអន្តរជាតិច្រៀងនិងស្តាប់កម្សាន្ត។

អាហារដ្ឋានទេសចរណ៍ គឺជាអាជីវកម្មផ្តល់សេវាកម្មម្ហូបអាហារ ភេសជ្ជៈ មានអ្នកបម្រើឬបម្រើដោយខ្លួនឯង និងការផ្តល់សេវាម្ហូបអាហារ ភេសជ្ជៈមានកំណត់ មានបម្រើសេវាកម្មអាហារក្រៅពេល អាហារវេចខ្ចប់ និងសាច់អាំង។ អាហាដ្ឋានខ្លះ មានបម្រើច្រើនពេល ខ្លះមានតែមួយពេលឬពីរពេល។ អាហារដ្ឋានខ្លះបម្រើភេសជ្ជៈជាធំ មានដូចជា៖

- Pub ជាប្រភេទអាជីវកម្មដែលបម្រើភេសជ្ជៈជាធំ និងអាហារមានកំណត់ដូចជាអាហារត្រជាក់ អាហារវេចខ្ចប់ ជាទូទៅតម្លៃសមរម្យ។
- Hotelbar ជាប្រភេទអាជីវកម្មដែលមានដំណើរការនៅតាមសណ្ឋាគារ។ អាជីវកម្មប្រភេទនេះមានបម្រើភេសជ្ជៈជាធំ និងអាហារមានកំណត់ ដែលតម្រូវឱ្យអ្នកលាយស្រាដើម្បីលក់ភេសជ្ជៈគ្រប់ប្រភេទ និងមានគុណភាពកម្រិតខ្ពស់ ហើយមានដំណើរការក្នុងរយៈពេលមានកំណត់។
- Coffeebar ជាប្រភេទអាជីវកម្មដែលបម្រើភេសជ្ជៈជាធំ មានបច្ចេកទេសកម្រិតខ្ពស់ ដូចជាកាហ្វេ និងមានបម្រើជាមួយអាហារបន្ទាប់បន្សំ។
- Coffee house ជាហាងកាហ្វេ ដែលមានលក់កាហ្វេនៅតាមបច្ចេកទេសផ្សេងៗនិងមានលក្ខណៈតុបតែងផ្សេងៗគ្នា។ ក្រៅពីកាហ្វេ ក៏មានភេសជ្ជៈកម្រិតខ្ពស់ដែលមានជាតិស្រវឹង និងមានដំណើរការចាប់ពីពេលបើករហូតដល់អស់ភ្ញៀវ។
- Drink bar ជាប្រភេទអាជីវកម្មដែលបម្រើភេសជ្ជៈលាយនិងមានបម្រើអាហារត្រជាក់នៅពេលមានបម្រើបន្ថែមនូវកាហ្វេ តែ និងភេសជ្ជៈផ្សេងៗទៀត។

អាហាដ្ឋានបម្រើសេវាកម្មម្ហូបអាហារជាធំ មានដូចជា៖

- Self service bar ជាប្រភេទអាជីវកម្មដែលបម្រើសេវាដោយខ្លួនឯង មានបម្រើម្ហូបអាហារក្តៅ (ស៊ុប) ម្ហូបអាហារដែលចម្អិនស្រាប់ ម្ហូបអាហារត្រជាក់ ម្ហូបវេចខ្ចប់ដាក់នៅក្នុងទូកញ្ចក់ មានបម្រើភេសជ្ជៈដែលគ្មានជាតិស្រវឹង ឬមានជាតិស្រវឹងតិច។

- **Universal bar** ជាប្រភេទអាជីវកម្មដែលបម្រើសេវាដោយខ្លួនឯង មានអាហារដ្ឋានតូចៗជាច្រើនរួមគ្នាបង្កើតបានជាភោជនីយដ្ឋាន ហៅថា សហភោជនីយដ្ឋាន ដែលមានម្ហូបអាហារច្រើនមុខសម្រាប់ជ្រើសរើសទៅតាមការនិយមរបស់អតិថិជន។
- **Fast food bar** ជាប្រភេទអាជីវកម្ម ដែលបម្រើសេវាដោយខ្លួនឯង មានបម្រើអាហារក្រៅពេល អាហារត្រជាក់ អាហារវេចខ្ចប់ ដូចជា Hamburger Pizza ។ល។
- **Snack bar** ជាអាជីវកម្មម្ហូបអាហារ ដែលមានអ្នកបម្រើ មានបម្រើអាហារត្រជាក់ស្រស់ អាហារក្ដៅ អាហារក្រៅពេល ភេសជ្ជៈគ្មានជាតិស្រវឹង និងមានជាតិស្រវឹងតិច និងមានបង្អែម។ ចាប់បើកពីព្រឹករហូតដល់ពេលយប់។
- **Grill bar** ជាប្រភេទអាជីវកម្មដែលបម្រើអាហារដូចជា សាច់អាំង នំប៉ុងសាច់ ដំឡូងចៀន ត្រីចៀន ។ល។
- **Catering bar** ជាប្រភេទអាជីវកម្ម ដែលផលិតម្ហូបអាហារសម្រាប់គ្រឹះស្ថានណាមួយ ឬទីកន្លែងកម្សាន្តសាធារណៈដូចជាអាហារបម្រុងទុក អាហារវេចខ្ចប់ ។ល។

ភោជនីយដ្ឋាននិងអាហារដ្ឋានក្នុងស្រុក គឺជាអាជីវកម្មបម្រើសេវាម្ហូបអាហារ និងភេសជ្ជៈមានកំណត់ ពុំមានសម្ភារៈទំនើប មានដំណើរការតែមួយពេល ឬពីរពេល។ ភោជនីយដ្ឋាននិងអាហារដ្ឋានប្រភេទនេះមិនបិតនៅតាមតំបន់ទេសចរណ៍ និងបម្រើអតិថិជនក្នុងស្រុកជាធំ ដែលមានចំនួនកៅអីក្រោម១០០ ដូចជា ហាងលក់គុយទាវ ហាងលក់បាយ ហាងកាហ្វេ។

### ១.២.៣. សេវាកម្សាន្តនិងកីឡាទេសចរណ៍

#### ក. សេវាកម្មកម្សាន្តទេសចរណ៍មនុស្សពេញវ័យ

មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ សំដៅដល់ទីតាំងសេវាកម្មទាំងឡាយដែលធ្វើអាជីវកម្មបម្រើឱ្យការសម្រាក លម្ហែ និងកម្សាន្តសម្រាប់មនុស្សពេញវ័យ ហើយប្រភេទអាជីវកម្មទាំងនោះមានដូចជា៖

- **រង្គសាល**៖ សំដៅដល់អាជីវកម្មក្នុងអគារដោយមានការប្រគំតន្ត្រីនិងច្រៀងសម្រាប់ភ្ញៀវរាំកម្សាន្ត ព្រមទាំងមានការផ្ដល់សេវាភេសជ្ជៈនិងម្ហូបអាហារបន្ទាប់បន្សំ។
- **ឌីស្កូតែក**៖ សំដៅដល់អាជីវកម្មក្នុងអគារដោយមានការប្រើប្រាស់ឧបករណ៍ចាក់បទភ្លេងចម្រៀងសម្រាប់ភ្ញៀវរាំកម្សាន្ត ព្រមទាំងមានការផ្ដល់សេវាភេសជ្ជៈនិងម្ហូបអាហារបន្ទាប់បន្សំ។
- **ខារ៉ាអូខេ**៖ សំដៅដល់អាជីវកម្មនៅក្នុងបន្ទប់នៃអគារដោយប្រើប្រាស់ឧបករណ៍សំឡេងនិងរូបភាព និងអក្សរសម្រាប់បម្រើភ្ញៀវច្រៀងកម្សាន្ត ព្រមទាំងមានការផ្ដល់សេវាភេសជ្ជៈនិងម្ហូបអាហារបន្ទាប់បន្សំ។

- **បៀរហ្គាឌិនៈ** សំដៅដល់អាជីវកម្មដែលមានប្រគំតន្ត្រីនិងការច្រៀងកំដរជូនភ្ញៀវដោយមានការបម្រើភេសជ្ជៈ និងម្ហូបអាហារគ្រប់ប្រភេទ។
- មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដទៃទៀត ដែលមានឧបនិស្ស័យបម្រើឱ្យវិស័យទេសចរណ៍។

**ខ. សេវាកម្មកីឡាទេសចរណ៍**

កីឡាទេសចរណ៍សំដៅដល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងកីឡារបស់បុគ្គលដែលធ្វើដំណើរទៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់ពួកគេក្នុងគោលបំណងទស្សនា កម្សាន្ត សប្បាយ និងចូលរួមលេងកម្សាន្ត ឬប្រកួតប្រជែងក្នុងសកម្មភាពកីឡាទេសចរណ៍។ សកម្មភាពកីឡាទេសចរណ៍ សំដៅដល់ការធ្វើអាជីវកម្មកីឡាទេសចរណ៍ និងការរៀបចំព្រឹត្តិការណ៍កីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ ដែលបម្រើដល់វិស័យទេសចរណ៍។ សកម្មភាពកីឡាទេសចរណ៍មានច្រើនប្រភេទ និងច្រើនទម្រង់ដូចជាៈ

- **ការរៀបចំព្រឹត្តិការណ៍កីឡាទេសចរណ៍ (Sport Tourism Event)**
- **ប្រភេទអាជីវកម្មកីឡាទេសចរណ៍ស្គី (Skiing)** មានដូចជាៈ ខ្សែរ៉ូកអូសស្គីលើទឹក (Cable Skiing) កីឡាជិះស្គីរលកសិប្បនិម្មិត (Flow Riding) ស្គីអូសដោយអូប៉រ ឬម៉ូតូទឹក (Knee Boarding) ឆ័ត្រទាញទូកឬទាញស្គីបណ្ដែត (Kite Boating and Kite Boarding) កីឡាជិះស្គី (លើទឹកកក និងផ្ទៃរាប) (Ice Skating) ស្គីលើទឹក (Wave Skiing) និងស្គីប្រើក្ដោង (Wind Surfing)។
- **ប្រភេទអាជីវកម្មកីឡាទេសចរណ៍សកម្ម (Active Sport Tourism)** មានដូចជាៈ កីឡាប៊ូលីង (Bowling) កីឡាវាយកូនគោល (Golf Course) កីឡាហាត់វាយកូនគោល (Golf Driving Range) កីឡាបាញ់ព្រួញ (Archery) កីឡាបាញ់កាំភ្លើងគ្រាប់មិនពិត (Paintball) អាជីវកម្មក្លឹបហាត់ប្រាណ (Fitness center, Gym) កីឡាយោគៈ (Yoga) កីឡាក្ដារបណ្ដែត (Paddle Boarding) កីឡាជិះអូប៉រ (Speed Boat) អូប៉រទាញឆ័ត្របង្ហោះ (Parasailing) ពោងបណ្ដែត (Floating Water Park) សួនទឹកកម្សាន្ត (Water Park) កីឡាម៉ូតូទឹក (Jet Ski) អាងហែលទឹក (Swimming Pool) កីឡាស្ទូចត្រីឬស្ទូចបង្កង (Fishing) កីឡាទូកក្ដោង (Sailing) និងកីឡាជិះលេងកម្សាន្តលើផ្លូវដែក (Roller Coaster)។
- **ប្រភេទកីឡាទេសចរណ៍បែបផ្សងព្រេង (Adventure Sport Tourism)** មានដូចជាៈ កីឡាលោតទម្លាក់ខ្លួនពីលើទីខ្ពស់ (Bungee Jumping) កីឡាប្រណាំងម៉ូតូឆ្លងឧបសគ្គ (Dirt Biking) ការប្រណាំងយានយន្តកម្សាន្តលើផ្ទៃរាប (Go Kart) កីឡាមុជទឹក (Scuba Diving and Snorkeling) កីឡាពោងបង្វិល (Zorbing) កីឡាជិះកង់ក្នុងព្រៃឬលើភ្នំ (Mountain

Biking) កីឡាឡើងជញ្ជាំងភ្នំឬជញ្ជាំងសិប្បនិម្មិត (Rock Climbing) កីឡាពាក់ស្លាបហោះ (Hang Gliding) កីឡាហោះហើរលើទឹក (Fly Board) កីឡាដើរក្នុងព្រៃឬឡើងភ្នំ (Hiking) ទូកជិះកម្សាន្ត កៃយ៉ាក់ កានូ រ៉ូវីង (Kayaking Canoeing and Rowing) កីឡាចូលក្នុងរូងភ្នំ (Caving) កីឡាបោះជំរុំ (Camping) បាឡុងបង្ហោះ (Balloon) កីឡាហោះហើរលើអាកាស (Fly Board Air) ខ្សែរ៉ក រថយន្តខ្សែកាប (Cable Car) កីឡាលោតឆ័ត្រយោង (Parachuting) និងកីឡាហោះបណ្តែតខ្លួន (Sky Diving)។

- **ប្រភេទកីឡាទេសចរណ៍ដែលមានឧបនិស្ស័យនឹងកីឡាដែលបម្រើការកម្សាន្តសប្បាយរបស់ភ្ញៀវ**

### ១.២.៤. សេវាកម្មរមណីយដ្ឋានទេសចរណ៍

យោងតាមវចនានុក្រមខ្មែរ បានឱ្យនិយមន័យ រមណីយដ្ឋាន ថា ជាស្ថាន ឬភូមិ ទី តំបន់ដែលគួររីករាយ ដែលសប្បាយ។ ដោយឡែក ច្បាប់ស្តីពីទេសចរណ៍ បានកំណត់និយមន័យ រមណីយដ្ឋានទេសចរណ៍ថា សំដៅដល់ទីតាំងដែលមានភាពទាក់ទាញទេសចរណ៍ ដូចជា វប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ ឆ្នេរសមុទ្រ ឬដែលរៀបចំ កែច្នៃឡើងហើយត្រូវបានអនុញ្ញាតឱ្យរៀបចំសម្រាប់ធ្វើអាជីវកម្ម បម្រើឱ្យការសម្រាក លម្ហែ និងកម្សាន្តតាមគោលបំណងទេសចរណ៍ស្របច្បាប់។

អាជីវកម្មរមណីយដ្ឋានទេសចរណ៍ គឺជាការប្រកបអាជីវកម្មសេវាកម្មទេសចរណ៍មួយ លើតំបន់ទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានជ្រើសរើសរៀបចំ គ្រប់គ្រង និងធ្វើការអភិវឌ្ឍ ដើម្បីបម្រើឱ្យទេសចរជាតិនិងអន្តរជាតិ សម្រាប់សម្រាក លម្ហែ បំប៉នសុខភាព កម្សាន្ត សប្បាយរីករាយ និងការស្វែងយល់ពីធម្មជាតិ ប្រពៃណី ទំនៀមទម្លាប់ សាសនារបស់ជាតិសាសន៍នីមួយៗក្នុងតំបន់ និងទូទាំងប្រទេស ព្រមទាំងផ្តល់សេវាកម្មទេសចរណ៍ផ្សេងទៀត។ រមណីយដ្ឋានទេសចរណ៍រួមមាន៖

- រមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ
- រមណីយដ្ឋានធម្មជាតិនិងឆ្នេរ
- រមណីយដ្ឋានកែច្នៃ

លក្ខណៈពិសេសនៃរមណីយដ្ឋាន៖

**ក. ទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ៖** សារៈសំខាន់នៃវប្បធម៌ដើមនិងធនធានប្រវត្តិសាស្ត្ររក្សាភាពដើម បូរាណភាពរមណីយដ្ឋាន និងកំណត់បុរាណវត្ថុដែលនៅសល់ តម្លៃមនុស្សជាតិ ការរស់នៅ ទំនៀមទម្លាប់ ការប្រើប្រាស់ដីធ្លី ការរស់នៅបែបប្រពៃណី។

**ខ. ទេសចរណ៍កែច្នៃ៖** ការកែច្នៃទៅតាមសក្តានុពលធម្មជាតិ កំណត់បុរាណវត្ថុដែលនៅសល់ តម្លៃមនុស្សជាតិ ការរស់នៅ ទំនៀមទម្លាប់ ការរស់នៅបែបប្រពៃណី និងកំណត់ប្លង់មេក្នុងការអភិវឌ្ឍសេវាកម្មកម្សាន្ត។

**គ. ទេសចរណ៍ធម្មជាតិ៖** សារៈសំខាន់នៃប្រព័ន្ធអេកូឡូស៊ីនិងលំនៅដ្ឋានធម្មជាតិ បរិស្ថានដែលមិនត្រូវបានបំផ្លាញ ដូចជាតំបន់ដីសើមឬតំបន់ឆ្នេរ និងលក្ខណៈពិសេសនិងភាពកម្រមានផ្សេងៗនៅក្នុងរមណីយដ្ឋាន។

**ឃ. ទេសចរណ៍វប្បធម៌ ធម្មជាតិ៖** សារៈសំខាន់នៃវប្បធម៌ដើមនិងធនធានប្រវត្តិសាស្ត្រ រក្សាភាពដើមបូរាណភាពរមណីយដ្ឋាន កំណត់បុរាណវត្ថុដែលនៅសល់ តម្លៃមនុស្សជាតិ ការរស់នៅ ទំនៀមទម្លាប់ ការប្រើប្រាស់ដីធ្លី ការរស់នៅបែបប្រពៃណី ធម្មជាតិដែលអាចទាក់ទាញភ្ញៀវទេសចរ សារៈសំខាន់នៃប្រព័ន្ធជីវៈចម្រុះនិងលំនៅស្ថានធម្មជាតិ និងបរិស្ថានដែលមិនត្រូវបានបំផ្លាញដូចជាតំបន់ដីសើម ទីរហោដ្ឋាន ឬតំបន់ឆ្នេរ។

**ង. កសិទេសចរណ៍៖** ទេសភាពវាលស្រែ ប្រឡាយទឹកដែលអាចទាក់ទាញភ្ញៀវទេសចរ ធនធានជីវៈចម្រុះក្នុងវាលស្រែនិងការរស់នៅបែបធម្មជាតិនិងប្រពៃណី ជាតំបន់មិនសូវមានលំនៅដ្ឋាន និងវប្បធម៌សុចរិតនៃការរស់នៅរបស់សហគមន៍ក្នុងតំបន់។

**ច. អេកូទេសចរណ៍៖** ធម្មជាតិដែលអាចទាក់ទាញភ្ញៀវទេសចរ ធនធានជីវៈចម្រុះនិងការរស់នៅបែបធម្មជាតិនិងប្រពៃណី បរិស្ថានដែលមិនត្រូវបានបំផ្លាញ ឬបរិស្ថានដែលបង្ហាញពីការវិវឌ្ឍរបស់ធម្មជាតិ (តំបន់ដីសើម ទីរហោដ្ឋាន តំបន់ឆ្នេរ សមុទ្រ កោះ ទន្លេ ទឹកធ្លាក់ ព្រៃភ្នំ ។ល។) ជាតំបន់មិនសូវមានលំនៅដ្ឋាន វប្បធម៌ សុចរិតនៃការរស់នៅរបស់សហគមន៍ក្នុងតំបន់ និងភាពដើមនៃធនធានវប្បធម៌និងធម្មជាតិមានក្នុងរមណីយដ្ឋាន។

**ការគ្រប់គ្រងទេសចរណ៍និងរមណីយដ្ឋាន**

ក. សម្រាប់តំបន់រមណីយដ្ឋាន៖

- ត្រូវមានស្លាកឈ្មោះមុនដល់រមណីយដ្ឋានចម្ងាយ២០០ម៉ែត្រ និងស្លាកឈ្មោះតំបន់រមណីយដ្ឋានត្រូវសរសេរអក្សរឱ្យបានធំៗច្បាស់ ជាអក្សរខ្មែរខាងលើ និងអក្សរបរទេសនៅខាងក្រោម
- មានបញ្ជរលក់សំបុត្រ
- ចំណតយានយន្តគ្រប់ប្រភេទ
- បង្គន់អនាម័យបុរស-នារីត្រូវស្អាត និងមានការថែទាំអនាម័យដោយមិនបង់ប្រាក់
- រៀបចំឱ្យមានសណ្តាប់ធ្នាប់ល្អ ដោយលុបបំបាត់អ្នកសុំទាន ក្មេងបក់ផ្លិតដែលបង្កឱ្យមានការរំខានដល់អ្នកទេសចរ
- រៀបចំឱ្យមានសួនច្បារពណ៌បៃតងស្រស់ក្នុងរមណីយដ្ឋាន
- គ្រប់សំណង់ទាំងអស់នៅក្នុងរមណីយដ្ឋានត្រូវសិក្សាទៅតាមរចនាបថក្នុងតំបន់ឬរចនាបថខ្មែរ (តូបសម្រាកលម្ហែ ត្រូវកំណត់តម្លៃនៅលើតូប)

- ភោជនីយដ្ឋាន អាហារដ្ឋានមានអនាម័យស្អាត ឆ្ងាញ់ ផ្តល់សុវត្ថិភាពដល់ភ្ញៀវ ដោយមានមុខម្ហូប និងតម្លៃមុខម្ហូបត្រឹមត្រូវ
- អ្នកលក់ដូរនិងអ្នកបម្រើសេវាកម្មត្រូវមានភាពរួសរាយរាក់ទាក់និងសម្លៀកបំពាក់សមរម្យ
- ត្រូវមានការចូលរួមរបស់ប្រជាជនក្នុងសហគមន៍ដើម្បីដំណើរការអភិវឌ្ឍន៍និងការគ្រប់គ្រងទេសចរណ៍
- បង្កើតមុខរបរនិងលើកទឹកចិត្តដល់ការផលិត និងប្រើប្រាស់ផលិតផលក្នុងស្រុក
- លើកទឹកចិត្តឱ្យមានការប្រើកម្លាំងពលកម្ម ចំណេះដឹង ជំនាញ និងប្រពៃណីក្នុងតំបន់
- ប្រើប្រាស់នូវមធ្យោបាយផ្តល់ព័ត៌មានឱ្យបានសមស្របនៅក្នុងទីតាំងរមណីយដ្ឋានដើម្បីឱ្យភ្ញៀវបានសិក្សារៀនសូត្រពីរមណីយដ្ឋាន
- មានកន្លែងលក់វត្ថុអនុស្សាវរីយ៍ជាផលិតផលក្នុងស្រុកដូចជាសប្បកម្ម ផ្កា ផ្លែឈើ ។ល។
- មានសេវាកម្មស្នាក់នៅឱ្យបានសមរម្យ (ដូចជា សណ្ឋាគារ ម៉ូតែល បឹងកាឡូ ផ្ទះសំណាក់ បោះតង់ ជាដើម)
- ការិយាល័យបម្រើការងាររបស់រមណីយដ្ឋាន
- អគារស្នាក់នៅរបស់បុគ្គលិកប្រចាំការ
- មានសេវាកម្មមធ្យោបាយធ្វើដំណើរក្នុងរមណីយដ្ឋាន ដូចជា ជិះកង់ ម៉ូតូ រទេះសេះ គោក្របី ...
- ត្រូវមានមគ្គុទ្ទេសក៍ក្នុងតំបន់ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវដើម្បីបម្រើភ្ញៀវ
- ពន្យល់ណែនាំភ្ញៀវពីក្រមប្រតិបត្តិ អ្វីដែលភ្ញៀវគួរធ្វើ និងអ្វីដែលគួរចៀសវាងពេលទស្សនាក្នុងរមណីយដ្ឋាន
- ត្រូវមានកម្មវិធីត្រួតពិនិត្យក្នុងរមណីយដ្ឋានដើម្បីប៉ាន់ប្រមាណពីផលប៉ះពាល់ទេសចរណ៍មកលើរមណីយដ្ឋាន
- សេវាទូរគមនាគមន៍ (ប្រព័ន្ធទូរសព្ទ E-mail Website)

ខ. សម្រាប់ឆ្នេរសមុទ្រ ទន្លេ បឹង និងជ្រោះ៖

- ពោងកំណត់ជម្រៅទឹក សញ្ញាគ្រោះថ្នាក់ (ថ្មប៉ប្រះទឹក ថ្មក្នុងទឹក អន្លង់ ទឹកក្ងួច រអិល ខ្សាច់ផុង ឬស្រូប)
- ទង់សញ្ញាខ្យល់ រលក (ទង់សុវត្ថិភាព ទង់ប្រុងប្រយ័ត្ន ទង់គ្រោះថ្នាក់)
- នៅតាមឆ្នេរ មានប៉មឆ្មាំឆ្នេរចេះសង្គ្រោះអ្នកលង់ទឹក ទូក ឬអូប័រសង្គ្រោះអ្នកលង់ទឹក ឃោសនៈប្រកាសអាសន្ន និងវិទ្យុទាក់ទង
- លើឆ្នេរមានឆ័ត្រពណ៌ឬឆ័ត្រស្បូវ និងបន្ទប់ផ្លាស់សម្លៀកបំពាក់ដោយមានអនាម័យល្អ។

## ២. ស្ថិតិអាជីវកម្មទេសចរណ៍

យោងតាមរបាយការណ៍ស្ថិតិប្រចាំឆ្នាំ២០១៨ រៀបចំឡើងដោយក្រសួងទេសចរណ៍ អាជីវកម្មសេវាកម្មទេសចរណ៍ត្រូវបានរាយលម្អិតដូចខាងក្រោម៖

| ល.រ | អាជីវកម្មទេសចរណ៍ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
|---|---|---|---|---|---|---|
| ១ | សណ្ឋាគារ | ៥៥៤ | ៦៦៨ | ៧៦០ | ៧៣១ | ៨៤៦ |
| ២ | ផ្ទះសំណាក់ | ១៥៦៣ | ២២២៩ | ២១៧០ | ២៤០៥ | ២៣១៣ |
| ៣ | ភោជនីយដ្ឋាន | ១២២០ | ២៦២០ | ១៩៨២ | ២៤៣៧ | ២១៩៩ |
| ៤ | ទីភ្នាក់ងារទេសចរណ៍ | ៦១៣ | ៦៣២ | ៦៦៥ | ៦៨២ | ៦៣៧ |
| ៥ | មគ្គុទ្ទេសក៍តំបន់ភ្នំពេញ | | | | | ២៧២ |
| ៦ | មគ្គុទ្ទេសក៍តំបន់សៀមរាប | | | | | ១៨៣៦ |
| ៧ | មគ្គុទ្ទេសក៍តំបន់ឆ្នេរ | | | | | ២៦ |
| ៨ | មគ្គុទ្ទេសក៍ថ្នាក់ជាតិ | | | | | ៨០ |

យោងតាមរបាយការណ៍បូកសរុបការងារទេសចរណ៍ឆ្នាំ២០១៨ ត្រីមាសទី១ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តត្រីមាសទី២ និងឆមាសទី២ ឆ្នាំ២០១៩ ចំនួនអាជ្ញាបណ្ណអាជីវកម្មទេសចរណ៍ ដែលចេញដោយក្រសួងទេសចរណ៍ រាយលម្អិតដូចខាងក្រោម៖

| ល.រ | ប្រភេទអាជីវកម្ម | អាជ្ញាបណ្ណទេសចរណ៍ឆ្នាំ២០១៨ | | | |
|---|---|---|---|---|---|
| | | ថ្មី | បន្ត | ពិន័យ | សរុប |
| ១ | សណ្ឋាគារ | ៦០ | ៤៣៣ | ១៦ | ៤៩៣ |
| ២ | ផ្ទះភ្ញៀវ | ១១ | ៣៩៥ | ២ | ៤០៦ |
| ៣ | ភោជនីយដ្ឋាន និងអាហារដ្ឋាន | ៩០ | ៣៦០ | ៧ | ៤៥០ |
| ៤ | ម៉ាស្សា និងស្ប៉ា | ១៩ | ៥៦ | ១ | ៧៥ |
| ៥ | ទីភ្នាក់ងារទេសចរណ៍ | ១១១ | ៤៥៨ | ២៧ | ៥៦៩ |
| ៦ | ខារ៉ាអូខេ | ០ | ៣ | ០ | ៣ |
| ៧ | រង្គសាល និងឌីស្កូតែក | ០ | ២ | ០ | ២ |
| ៨ | កីឡាទេសចរណ៍ | ១០ | ៣១ | ១ | ៤១ |
| ៩ | ដឹកជញ្ជូនទេសចរណ៍ | ៦ | ៣៩ | ១ | ៤៥ |
| ១០ | រមណីយដ្ឋានទេសចរណ៍ | ៩ | ១៤ | ០ | ២៣ |
| ១១ | មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ | ៤៦៨ | ១៧៦៧ | ២៨ | ២២៣៥ |
| ១២ | មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ | ២៦ | ៥១ | ០ | ៧៧ |
| ១៣ | អ្នកបកប្រែបន្តភាសាកូរ៉េ | ១៥៩ | ៣៩២ | ០ | ៥៥១ |
| **សរុប** | | **៩៦៩** | **៤០០១** | **៨៣** | **៤៩៧០** |

## ៣. អត្ថប្រយោជន៍នៃអាជីវកម្មទេសចរណ៍

អាជីវកម្មទេសចរណ៍បានចូលរួមចំណែកជាច្រើនក្នុងការអភិវឌ្ឍជាតិជាមួយនឹងរាជរដ្ឋាភិបាលតាមរយៈក្រសួងទេសចរណ៍ជាសេនាធិការ។ ឧស្សាហកម្មទេសចរណ៍និយាយជារួម និងអាជីវកម្មទេសចរណ៍និយាយដោយឡែក ជាកត្តាមួយដ៏សំខាន់ក្នុងការជំរុញកិច្ចអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា និងសំដៅទៅដល់ការរកចំណូលចូលជាតិបានច្រើនក្នុងកម្រិតអតិបរមា។ អាជីវកម្មទេសចរណ៍បានផ្តល់នូវសារៈប្រយោជន៍ជាច្រើនមានដូចជា៖

- **សម្រាប់វិស័យទេសចរណ៍៖** អាជីវកម្មទេសចរណ៍ជាចំណែកដ៏សំខាន់ក្នុងវិស័យទេសចរណ៍ ដែលក្តោបទាំងមូលនូវសេវាកម្មទាំងអស់សម្រាប់ផ្គត់ផ្គង់ដល់ទេសចរ។ គុណភាពនៃវិស័យទេសចរណ៍គឺត្រូវពឹងផ្អែកលើគុណភាពនៃអាជីវកម្មទេសចរណ៍ទាំងនោះ ដោយហេតុថាគេនឹងវាយតម្លៃការគ្រប់គ្រង វិស័យទេសចរណ៍តាមរយៈការសង្កេតទៅលើសកម្មភាពអាជីវកម្មទេសចរណ៍ទាំងនោះ។ ដូច្នេះដើម្បីរក្សាបានគុណភាពនៃវិស័យទេសចរណ៍ទាំងមូល គេត្រូវពង្រឹង និងបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការធានាបាននូវគុណភាពខ្ពស់នៃអាជីវកម្មទេសចរណ៍ដែលបាននិងកំពុងធ្វើសកម្មភាពរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។
- **សម្រាប់វប្បធម៌ ប្រវត្តិសាស្ត្រ៖** អាជីវកម្មទេសចរណ៍ជាផ្នែកមួយដែលបានចូលរួមចំណែកក្នុងការថែរក្សា អភិរក្ស និងអភិវឌ្ឍវិស័យវប្បធម៌ និងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា តាមរយៈការកំណត់ស្តង់ដាររួមនៃរមណីយដ្ឋានដោយបានកំណត់ឱ្យមានយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សាវប្បធម៌ខ្មែរ។ លើសពីនេះទៀតនោះ មគ្គុទ្ទេសក៍ទេសចរណ៍ដែលកំពុងធ្វើសកម្មភាពក្នុងការនាំភ្ញៀវ បរិយាយអំពីកម្ពុជាជូនភ្ញៀវ ក៏ត្រូវបានកំណត់ឱ្យធ្វើយ៉ាងណាដើម្បីថែរក្សាឱ្យបានល្អខ្ជាប់ខ្ជួននូវវប្បធម៌ដ៏ល្អរបស់ខ្មែរ។
- **សម្រាប់វិស័យសង្គមកិច្ច៖** ប្រជាពលរដ្ឋជាច្រើនម៉ឺននាក់បាននិងកំពុងមានការងារធ្វើក្នុងវិស័យទេសចរណ៍ ពិសេសពីអាជីវកម្មទេសចរណ៍។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ វិស័យទេសចរណ៍បានបង្កើតការងារនិងមុខរបរផ្ទាល់ប្រមាណ ៦២ម៉ឺននាក់ និងការងារដោយប្រយោលរាប់ម៉ឺននាក់បន្ថែមទៀត។ ការណ៍នេះបញ្ជាក់ថា អាជីវកម្មទេសចរណ៍បានចូលរួមចំណែកយ៉ាងសកម្មភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ជាតិឱ្យកាន់តែរីកចម្រើន និងចូលរួមកាត់បន្ថយភាពក្រីក្រជាមួយនឹងរាជរដ្ឋាភិបាលបានមួយកម្រិត។
- **សម្រាប់វិស័យវិនិយោគ៖** នៅពេលប្រទេសមានការគ្រប់គ្រងនិងលិខិតបទដ្ឋានគតិយុត្តច្បាស់លាស់ក្នុងការគ្រប់គ្រងអាជីវកម្មទេសចរណ៍ប្រកបដោយគុណភាពនិងភាពដែលអាចទទួលយកបាននោះ

ការទាក់ទាញភ្ញៀវទេសចរមកកាន់ប្រទេសកម្ពុជាបានកាន់តែច្រើនឡើង។ ក្នុងនោះ យើងក៏អាចទាក់ទាញបាននូវវិនិយោគិនឱ្យចូលមកវិនិយោគក្នុងប្រទេសកម្ពុជាយើងក៏បានកាន់តែច្រើន ដោយពួកគេអាចមកបង្កើតជារោងចក្រ សហគ្រាស ឧស្សាហកម្មផ្សេង ផលិតនូវផលិតផលដើម្បីផ្គត់ផ្គង់ដល់រាល់អាជីវកម្មទេសចរណ៍ ឬក៏ចូលរួមក្នុងការបង្កើតអាជីវកម្មទេសចរណ៍ប្រភេទណាមួយស្របច្បាប់ ហើយនឹងអាចបង្កើតការងារជាច្រើនដល់ប្រជាពលរដ្ឋខ្មែរផងដែរ។

- **សម្រាប់សេដ្ឋកិច្ចជាតិ៖** តាមរយៈការបកស្រាយខាងលើ យើងឃើញថាអាជីវកម្មទេសចរណ៍ពិតជាបានចូលរួមចំណែកយ៉ាងសកម្មក្នុងការរកចំណូលជូនជាតិ និងចំណូលជាច្រើនដល់ប្រជាពលរដ្ឋជាច្រើនដែលជាប្រតិបត្តិករទេសចរណ៍ និងដែលមានការងារធ្វើពីអាជីវកម្មទេសចរណ៍។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ វិស័យទេសចរណ៍ជារួម អាជីវកម្មទេសចរណ៍ដោយឡែក បានរួមចំណែកប្រមាណ ១២.៧%[12]នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា។ ការណ៍នេះបានសបង្ហាញឱ្យឃើញពីសារៈសំខាន់ នៃអាជីវកម្មទេសចរណ៍សម្រាប់វិស័យទេសចរណ៍ ក៏ដូចជាសង្គមជាតិកម្ពុជាទាំងមូល។

[12] របាយការណ៍បូកសរុបការងារទេសចរណ៍ឆ្នាំ២០១៨ ត្រីមាសទី១ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តត្រីមាសទី២ និងឆមាសទី២ ឆ្នាំ២០១៩

# ជំពូកទី២
# ការគ្រប់គ្រងអាជីវកម្ម
# ទេសចរណ៍

# ជំពូកទី២

# ការគ្រប់គ្រងអាជីវកម្មទេសចរណ៍

## ១. ស្ថាប័ននិងអង្គភាពមានសមត្ថកិច្ច

### ១.១. ថ្នាក់ជាតិ

តួនាទីនៃការគ្រប់គ្រងអាជីវកម្មទេសចរណ៍ ក៏ដូចជាវិស័យទេសចរណ៍ទាំងមូល គឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលមានក្រសួងទេសចរណ៍ជាសេនាធិការ។ ក្រសួងទេសចរណ៍តែឯងក៏មិនអាចអនុវត្តបានល្អនូវតួនាទីនិងកាតព្វកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងអាជីវកម្មទេសចរណ៍បានឡើយ ពោលគឺត្រូវមានការចូលរួមសហការរបស់ក្រសួងស្ថាប័នផ្សេងៗទៀតដែលមានការពាក់ព័ន្ធនឹងផ្នែកណាមួយនៃតួនាទីរបស់ក្រសួងស្ថាប័ននោះ។

មាត្រា១០នៃច្បាប់ស្តីពីទេសចរណ៍បានចែងថាៈ ក្រសួងទេសចរណ៍ត្រូវទទួលខុសត្រូវជាចម្បងក្នុងការចេញបទប្បញ្ញត្តិសំខាន់ៗផ្នែកឧស្សាហកម្មទេសចរណ៍ ដើម្បីជំរុញការអនុវត្តផែនការអភិវឌ្ឍទេសចរណ៍ឱ្យមានប្រសិទ្ធភាព។ ផ្នែកសំខាន់ៗទាំងនោះរួមមានៈ

- ការផ្សព្វផ្សាយវិស័យទេសចរណ៍ក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា
- ការធានាគុណភាពនៅក្នុងវិស័យទេសចរណ៍
- ស្តង់ដារនានានៃវិស័យទេសចរណ៍
- អាជ្ញាបណ្ណទេសចរណ៍
- សកម្មភាពអាជីវកម្មទេសចរណ៍
- ការណែនាំពីភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍
- ការគ្រប់គ្រងនិងការត្រួតពិនិត្យព័ត៌មានទេសចរណ៍
- សហប្រតិបត្តិការអន្តរជាតិក្នុងវិស័យទេសចរណ៍ជាមួយប្រទេសជិតខាង និងពិភពលោក។

ក្រសួងទេសចរណ៍ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬអាជ្ញាធរណាមួយនោះ មានចំណាប់អារម្មណ៍ប្រឹក្សាយោបល់លើផ្នែកណាមួយនៃឧស្សាហកម្មទេសចរណ៍។ [13]

នៅក្នុងសមត្ថកិច្ចនៃការគ្រប់គ្រងអាជីវកម្មទេសចរណ៍ ក្រសួងទេសចរណ៍អាចនឹងត្រូវធ្វើការសហការរួមគ្នា ជាមួយនឹងក្រសួងស្ថាប័នផ្សេងទៀតដែលមានតួនាទីទៅលើផ្នែកណាមួយនៃអាជីវកម្មទេសចរណ៍នោះ ដែលក្រសួងស្ថាប័នទាំងនោះរួមមានៈ

[13] ច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ២០០៩)

- **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ទាក់ទងនឹងការគ្រប់គ្រងការប្រមូលថវិកាជាតិតាមរយៈការប្រមូលកម្រៃនៃអាជ្ញាបណ្ណទេសចរណ៍ឬបានមកពីការពិន័យផ្សេងៗក្នុងអាជីវកម្មទេសចរណ៍ ព្រមទាំងគ្រប់គ្រងនិងបែងចែកនៃប្រាក់ចំណូលទាំងនោះប្រកបដោយតម្លាភាពនិងសុច្ចរិតភាព។
- **ក្រសួងសាធារណការនិងដឹកជញ្ជូន** ទាក់ទងនឹងការពិនិត្យលើលក្ខណៈវិនិច្ឆ័យដើម្បីពិចារណាក្នុងការផ្តល់អាជ្ញាបណ្ណដឹកជញ្ជូនទេសចរណ៍ និងដឹកជញ្ជូនភ្ញៀវក្នុងស្រុក។
- **ក្រសួងមហាផ្ទៃ** ដែលក្រសួងទេសចរណ៍ត្រូវសហការជាមួយនគរបាលទេសចរណ៍ដើម្បីធានាបាននូវសុខសុវត្ថិភាពរបស់ទេសចរក្នុងអំឡុងពេលធ្វើដំណើររបស់ពួកគេ។ ក្រសួងមហាផ្ទៃក៏បានជួយក្រសួងទេសចរណ៍ក្នុងការធ្វើប្រតិភូកម្មមុខងារនៃការផ្តល់សេវាសាធារណៈក្នុងវិស័យទេសចរណ៍ផងដែរ។ ម៉្យាងទៀត ក្រសួងមហាផ្ទៃ បានចូលរួមពិនិត្យនូវសុខសុវត្ថិភាពនៃអគារជាពិសេសសុវត្ថិភាពអគ្គីភ័យនៃមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងនោះ។
- **ក្រសួងសុខាភិបាល** ទាក់ទងនឹងការពិនិត្យលើគុណភាពអនាម័យនៃមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ពិសេសមូលដ្ឋានសេវាកម្មម្ហូបអាហារទេសចរណ៍ ដើម្បីធានាបាននូវគុណភាពនិងអនាម័យនៃម្ហូបអាហារដែលបម្រើដល់ភ្ញៀវទេសចរ។
- **ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** ទាក់ទងនឹងការចូលរួមអភិរក្ស ថែរក្សា និងអភិវឌ្ឍសម្បត្តិវប្បធម៌ជាតិ តាមរយៈការពិនិត្យទៅលើការបង្កើត តុបតែង និងរចនានៃតំបន់ទេសចរណ៍និងមូលដ្ឋានអាជីវកម្មទាំងឡាយ ពិសេសរមណីយដ្ឋានទេសចរណ៍បែបវប្បធម៌ ប្រវត្តិសាស្ត្រ ដែលមានសកម្មភាពអាជីវកម្មស្របតាមច្បាប់កំណត់។
- **ក្រសួងពាណិជ្ជកម្ម** ទាក់ទងនឹងនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជាដើម្បីធានាដល់ការធ្វើអាជីវកម្មមួយប្រកបដោយភាពស្របច្បាប់ និងរក្សាបាននូវកម្មសិទ្ធិបញ្ញារបស់ប្រតិបត្តិករទេសចរណ៍។
- **ក្រសួងបរិស្ថាន** ជួយក្រសួងទេសចរណ៍ក្នុងការពិនិត្យមើលលទ្ធភាពក្នុងការរៀបចំបង្កើតមូលដ្ឋានអាជីវកម្មរមណីយដ្ឋានទេសចរណ៍បែបធម្មជាតិ ជៀសវាងបាននូវការធ្វើឱ្យប៉ះពាល់ណាមួយដល់បរិស្ថាន និងអេកូទេសចរណ៍។
- **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ជួយពិនិត្យមើលគុណភាពនៃសំណង់ដែលត្រូវបានសង់ឡើងសម្រាប់ធ្វើជាមូលដ្ឋានអាជីវកម្មទេសចរណ៍ ជាពិសេសសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាន អាហារដ្ឋាន និងរមណីយដ្ឋានទេសចរណ៍កែច្នៃ... តាមរយៈការផ្តល់នូវលិខិតអនុញ្ញាតសាងសង់។
- ក្រសួងស្ថាប័នដទៃទៀតដែលមានតួនាទីក្នុងការគ្រប់គ្រងផ្នែកណាមួយនៃអាជីវកម្មទេសចរណ៍។

## ១.២. ថ្នាក់ក្រោមជាតិ

តាមរយៈការអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល សំដៅដល់ការផ្ដល់សេវាឱ្យកៀក នឹងប្រជាពលរដ្ឋ ការគ្រប់គ្រងអាជីវកម្មត្រូវបានរាជរដ្ឋាភិបាលដែលមានក្រសួងទេសចរណ៍ជាសេនាធិការ បាន រៀបចំឱ្យមានប្រព័ន្ធនៃការគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ។ ការទទួលពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ការពិនិត្យ លទ្ធភាពនៃការផ្ដល់ និងការផ្ដល់អាជ្ញាបណ្ណអាជីវកម្មទេសចរណ៍ ត្រូវបានក្រសួងទេសចរណ៍ធ្វើប្រតិភូកម្មមុខងារ ទៅឱ្យរដ្ឋបាលរាជធានីខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងមន្ទីរទេសចរណ៍រាជធានី ខេត្ត ដើម្បីធ្វើការអនុវត្ត ការងារគ្រប់គ្រងអាជីវកម្មទេសចរណ៍ស្របតាមច្បាប់បានកំណត់។

ក្នុងការធ្វើប្រតិភូកម្មមុខងារឱ្យទៅរដ្ឋបាលរាជធានីខេត្ត ដើម្បីគ្រប់គ្រងអាជីវកម្មទេសចរណ៍ ក្រសួង ទេសចរណ៍ បានរៀបចំបែងចែកឱ្យមានប្រភេទនិងទំហំនៃអាជីវកម្មទេសចរណ៍ ដែលត្រូវដាក់ពាក្យស្នើសុំនៅត្រឹម រដ្ឋបាលរាជធានីខេត្ត។ រដ្ឋបាលរាជធានីខេត្ត (អង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត) មានភារកិច្ចក្នុងការ គ្រប់គ្រង ចាត់ចែង និងផ្ដល់សេវាទេសចរណ៍ ដែលបានធ្វើប្រតិភូកម្ម ដូចតទៅ៖ [14]

- រៀបចំលិខិតបទដ្ឋាន សេចក្ដីណែនាំ និងធ្វើការផ្សព្វផ្សាយនូវមុខងារដែលបានធ្វើប្រតិភូកម្ម ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្ដល់អាជ្ញាបណ្ណទេសចរណ៍ ដោយអនុលោមតាមលក្ខខណ្ឌ បែបបទ នីតិវិធី កម្រៃសេវា និងរយៈពេល ដែលបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន
- លុបចោល ព្យួរ ឬបញ្ចុះថ្នាក់អាជ្ញាបណ្ណ ទៅជាអាជ្ញាបណ្ណបណ្ដោះអាសន្ន ក្នុងករណីដែល ប្រតិបត្តិករទេសចរណ៍មិនគោរពទៅតាមលក្ខខណ្ឌដែលបានកំណត់។ ក្នុងករណីដែលពិនិត្យ ឃើញថា ការបន្តប្រតិបត្តិការអាជីវកម្មលើមុខងារទាំងនេះ បង្កឱ្យមានហានិភ័យធ្ងន់ធ្ងរមកលើ សន្តិសុខ សុវត្ថិភាព និងសុខភាព រដ្ឋបាលរាជធានីខេត្ត អាចលុប ឬព្យួរអាជ្ញាបណ្ណនោះជា បន្ទាន់ដោយបញ្ជាក់ហេតុផលច្បាស់លាស់។ ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណនេះ មិនធ្វើឱ្យប្រតិបត្តិករទេសចរណ៍រួចផុតពីការទទួលខុសត្រូវចំពោះបទល្មើសនិងទោសប្បញ្ញត្តិ ដែលបានកំណត់ក្នុងច្បាប់ស្ដីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាជាមានធរមាន
- គ្រប់គ្រងនិងបែងចែកចំណូលបានមកពីការផ្ដល់អាជ្ញាបណ្ណទេសចរណ៍តាមគោលការណ៍កំណត់
- ត្រួតពិនិត្យ វាយតម្លៃ និងចាត់វិធានការ ទប់ស្កាត់បទល្មើសដែលអាចកើតមានឡើងក្នុងការ ផ្ដល់សេវាទេសចរណ៍

[14] ប្រកាសលេខ០៤៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្ដីពីការធ្វើប្រតិភូកម្មមុខងារផ្ដល់សេវាទេសចរណ៍ ទៅឱ្យរដ្ឋបាលរាជធានីខេត្ត

- អនុវត្តពិន័យអន្តរការណ៍ចំពោះការធ្វើអាជីវកម្មណាដែលអាជ្ញាបណ្ណហួសសុពលភាព ឬគ្មានអាជ្ញាបណ្ណទេសចរណ៍ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនក្រសួងទេសចរណ៍ អំពីការអនុវត្តមុខងារ ដែលបានធ្វើប្រតិភូកម្ម។

មន្ទីរទេសចរណ៍រាជធានីខេត្ត មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានីខេត្ត ក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម ដោយសហការជាមួយអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត និងធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនក្រសួងទេសចរណ៍ ក្នុងករណីចាំបាច់ ត្រូវរាយការណ៍បន្ទាន់។

មន្ទីរទេសចរណ៍រាជធានីខេត្តជាសេនាធិការឱ្យក្រសួងទេសចរណ៍ទទួលបន្ទុកអនុវត្ត គ្រប់គ្រង តាមដានត្រួតពិនិត្យ វាយតម្លៃ រៀបចំផែនការអភិវឌ្ឍ ពង្រឹងគុណភាពផលិតផល អាជីវកម្ម និងសេវាកម្មទេសចរណ៍ សំដៅធានាដល់ការគ្រប់គ្រងនិងការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ។[15]

មន្ទីរទេសចរណ៍រាជធានីខេត្តចូលរួមនិងជំរុញអនុវត្តយន្តការនិងនីតិវិធីនៅថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្តការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្ម និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ដើម្បីគ្រប់គ្រងអាជីវកម្មទេសចរណ៍នៅតាមថ្នាក់មូលដ្ឋាន មន្ទីរទេសចរណ៍ រាជធានីខេត្ត មានការិយាល័យចំណុះជាច្រើន ដែលក្នុងនោះការិយាល័យជំនាញក្នុងការពិនិត្យនិងវាយតម្លៃលើពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ មានដូចជាៈ ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍផលិតផលទេសចរណ៍ ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងការិយាល័យគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍។

## ២. យន្តការក្នុងការគ្រប់គ្រង

### ២.១. យន្តការនៅថ្នាក់ជាតិ

នៅថ្នាក់ជាតិ ការគ្រប់គ្រងអាជីវកម្មទេសចរណ៍ ជាតួនាទីរបស់ក្រសួងទេសចរណ៍ជាចម្បង។ ក្រសួងទេសចរណ៍ បានរៀបចំរចនាសម្ព័ន្ធក្នុងការគ្រប់គ្រងការងាររបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព និងភាពដែលអាចជឿជាក់បាន។ ក្នុងនោះ ការងារគ្រប់គ្រងអាជីវកម្មទេសចរណ៍ ក្រសួងទេសចរណ៍មានអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ និងអគ្គាធិការដ្ឋាន

[15] ប្រកាសលេខ១២៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត

ជាសេនាធិការ។ ក្រោមចំណុះ នៃអគ្គនាយកដ្ឋានទាំងពីរ មាននាយកដ្ឋានចំនួនបួនដែលមានតួនាទីចម្បងក្នុងការគ្រប់គ្រងអាជីវកម្មទេសចរណ៍នៅក្នុងប្រទេសកម្ពុជា រួមមាន៖

- នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ
- នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍
- នាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍។

### ក. នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍

នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ ជានាយកដ្ឋានស្ថិតក្រោមចំណុះនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖[16]

- គ្រប់គ្រងនិងត្រួតពិនិត្យលើរាល់អាជីវកម្មនិងសេវាកម្មទាក់ទងនឹងទីភ្នាក់ងារទេសចរណ៍ ដឹកជញ្ជូនទេសចរ និងមគ្គុទ្ទេសក៍ទេសចរណ៍
- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ប្រព័ន្ធចំណាត់ថ្នាក់ ស្តង់ដាអប្បបរមា និងការអនុវត្តនានាដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងរក្សាគុណភាពសេវាកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យស្របតាមកម្រិតស្តង់ដារជាតិ អន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់យន្តការនិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្តការលុបចោល ឬការព្យួរអាជ្ញាបណ្ណទេសចរណ៍ ទាំងការសុំបិទអាជីវកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- គ្រប់គ្រងប្រព័ន្ធតាមដាននិងត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់កម្រិត ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សហការជំរុញផែនផលិតកម្មទេសចរណ៍ បង្កើត និងបង្កើនខ្សែទស្សនកិច្ចទេសចរណ៍ ដើម្បីឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ដ៏សំបូរបែប
- សហការជាមួយនឹងសមាគមក្នុងសេវាកម្មទីភ្នាក់ងារទេសចរណ៍ សមាគមដឹកជញ្ជូនទេសចរណ៍ និងសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ដើម្បីរៀបចំបង្កើត និងបំផុសឱ្យមានការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍

[16] អនុក្រឹត្យលេខ២២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

- សហការជាមួយផ្នែកឯកជនដើម្បីពង្រឹងគុណភាពសេវាកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ និងការអនុវត្តរបស់សមាគមដែលពាក់ព័ន្ធនឹងសេវាកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- សហការធានាសន្តិសុខ សុវត្ថិភាព និងសេវាកម្មប្រកបដោយគុណភាព និងភាពពេញចិត្តរបស់ទេសចរ
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ដែលបណ្តាលមកពីការធ្វើអាជីវកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍។

នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ មានការិយាល័យចំណុះចំនួន៧ ដូចខាងក្រោម៖ [17]

- ការិយាល័យការីទេសចរណ៍នាំភ្ញៀវចេញក្រៅប្រទេស
- ការិយាល័យការីទេសចរណ៍នាំភ្ញៀវចូលក្នុងប្រទេស
- ការិយាល័យការីទេសចរណ៍ក្នុងស្រុក
- ការិយាល័យភ្នាក់ងារទេសចរណ៍
- ការិយាល័យដឹកជញ្ជូនទេសចរផ្លូវគោកនិងផ្លូវទឹក
- ការិយាល័យមគ្គុទ្ទេសក៍ទេសចរណ៍
- ការិយាល័យទំនាក់ទំនងសាធារណៈនិងកិច្ចការសមាគម។

### ខ. នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ

នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ជានាយកដ្ឋានស្ថិតក្រោមចំណុះនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖ [18]

- គ្រប់គ្រងនិងត្រួតពិនិត្យលើរាល់អាជីវកម្ម និងសេវាកម្មទាក់ទងនឹងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ទេសចរណ៍ MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា
- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ប្រព័ន្ធចំណាត់ថ្នាក់ ស្តង់ដាអប្បបរមា និងការអនុវត្តនានាដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងរក្សាគុណភាពសេវាកម្មស្នាក់នៅទេសចរណ៍

[17] ប្រកាសលេខ១៤៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

[18] អនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

និងម្ហូបអាហារ ទេសចរណ៍ MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យស្របតាមកម្រិតស្តង់ដារជាតិ អន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៃព្រះរាជាណាចក្រកម្ពុជា

- កំណត់យន្តការនិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្តការលុបចោល ឬការព្យួរអាជ្ញាបណ្ណទេសចរណ៍ ទាំងការសុំបិទអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ទេសចរណ៍ MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា
- ពង្រឹងនិងជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុកសំដៅបង្កើនតម្លៃបន្ថែមក្នុងវិស័យទេសចរណ៍ឱ្យបានជាអតិបរមា
- សហការជាមួយផ្នែកឯកជននិងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើតស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ និងការលើកទឹកចិត្ត
- សហការជាមួយផ្នែកឯកជននិងផ្នែកពាក់ព័ន្ធដើម្បីពង្រឹងគុណភាពសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ទេសចរណ៍ MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា និងការអនុវត្តរបស់សមាគមដែលពាក់ព័ន្ធនឹងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ទេសចរណ៍ MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា
- សហការជំរុញនិងកំណត់យន្តការក្នុងការរក្សាអនាម័យនិងសុវត្ថិភាពចំណីអាហារទាំងក្នុងភោជនីយដ្ឋាន អាហារដ្ឋាន ទាំងក្នុងទីសាធារណៈ
- សហការជាមួយនឹងសមាគមក្នុងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ទេសចរណ៍ MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ាដើម្បីរៀបចំបង្កើតនិងបំផុសឱ្យមានការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ដែលបណ្តាលមកពីការធ្វើអាជីវកម្មលើសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ទេសចរណ៍ MICE (ម៉ាយ : ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) ព្រមទាំងសេវាកម្មម៉ាស្សានិងស្ប៉ា។

នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ មានការិយាល័យចំណុះចំនួន៧ ដូចខាងក្រោម៖ [19]

- ការិយាល័យសេវាកម្មសណ្ឋាគារ
- ការិយាល័យសេវាកម្មផ្ទះភ្ញៀវ
- ការិយាល័យសេវាកម្មបោះជំរុំទេសចរណ៍និងផ្ទះស្នាក់
- ការិយាល័យសេវាកម្មម្ហូបអាហារ
- ការិយាល័យសេវាកម្មទេសចរណ៍ម៉ាយ
- ការិយាល័យសេវាកម្មម៉ាស្សានិងស្ប៉ា
- ការិយាល័យទំនាក់ទំនងសាធារណៈនិងកិច្ចការសមាគម។

**គ. នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍**

នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍ ជានាយកដ្ឋានស្ថិតក្រោមចំណុះនៃអគ្គ-នាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖ [20]

- គ្រប់គ្រងនិងត្រួតពិនិត្យលើរាល់អាជីវកម្មនិងសេវាកម្មទាក់ទងនឹងសេវាកម្សាន្តនិងកីឡាទេសចរណ៍
- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ប្រព័ន្ធចំណាត់ថ្នាក់ ស្តង់ដាអប្បបរមា និងការអនុវត្តនានាដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងរក្សាគុណភាពសេវាកម្សាន្តនិងកីឡាទេសចរណ៍ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យស្របតាមកម្រិតស្តង់ដារជាតិ អន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់យន្តការនិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុប ចោល ឬការព្យួរអាជ្ញាបណ្ណទេសចរណ៍ ទាំងការសុំបិទអាជីវកម្មសេវាកម្សាន្តនិងកីឡាទេសចរណ៍
- សហការជំរុញ ណែនាំវិធានការ និងរៀបចំកម្មវិធីផ្សព្វផ្សាយសំដៅលើកកម្ពស់ និងបង្កើនការធានាគុណភាព និងអភិវឌ្ឍអាជីវកម្មសេវាកម្សាន្តនិងកីឡាទេសចរណ៍

[19] ប្រកាសលេខ១៤៤ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

[20] អនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

- សហការជាមួយនឹងសមាគមក្នុងសេវាកម្មសេវាកម្សាន្តនិងកីឡាទេសចរណ៍ ដើម្បីរៀបចំបង្កើត និងបំផុសឱ្យមានការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មសេវាកម្សាន្ត និងកីឡាទេសចរណ៍
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ដែលបណ្ដាលមកពីការធ្វើអាជីវកម្មលើសេវាកម្សាន្តនិងអភិវឌ្ឍកីឡាទេសចរណ៍

នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍មានការិយាល័យចំណុះចំនួន៥ ដូចខាងក្រោម៖ [21]

- ការិយាល័យគ្រប់គ្រងសេវាកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- ការិយាល័យគ្រប់គ្រងសេវាកម្មកីឡាទេសចរណ៍លើគោកនិងលើអាកាស
- ការិយាល័យគ្រប់គ្រងសេវាកម្មកីឡាទេសចរណ៍លើទឹកនិងក្នុងទឹក
- ការិយាល័យគ្រប់គ្រងព្រឹត្តិការណ៍កីឡាទេសចរណ៍
- ការិយាល័យទំនាក់ទំនងសាធារណៈនិងកិច្ចការសមាគម។

### ឃ. នាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍

នាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ ជានាយកដ្ឋានស្ថិតក្រោមចំណុះនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ និងមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖ [22]

- សិក្សាស្រាវជ្រាវនិងរៀបចំផែនការយុទ្ធសាស្ត្រ បង្កើត គ្រប់គ្រង និងអភិវឌ្ឍផលិតផលទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ បេតិកភណ្ឌ និងធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការរៀបចំផែនការយុទ្ធសាស្ត្រអេកូទេសចរណ៍ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើការគ្រប់គ្រង តំបន់ឆ្នេរសមុទ្រកម្ពុជានិងអេកូទេសចរណ៍
- ជំរុញ បង្កើត អនុវត្ត និងត្រួតពិនិត្យលើរមណីយដ្ឋានទេសចរណ៍វប្បធម៌ ធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិ-ទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀត
- **កំណត់យន្តការនិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីពិនិត្យ និងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការផ្តល់ ការបន្ត ការលុបចោល ឬការព្យួរអាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្មរមណីយដ្ឋានទេសចរណ៍**

---

[21] ប្រកាសលេខ១៤៦ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

[22] អនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

**វប្បធម៌ ធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិ-ទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀត**

- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ស្តង់ដាអប្បបរមា និងការអនុវត្តនានា ដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងរក្សាគុណភាពមណីយដ្ឋានទេសចរណ៍ វប្បធម៌ ធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិ-ទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀត នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យស្របតាមកម្រិតស្តង់ដារជាតិ តំបន់ អន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៃព្រះរាជាណាចក្រកម្ពុជា
- សហការសិក្សាស្រាវជ្រាវប្រវត្តិមណីយដ្ឋាន ប្រវត្តិវប្បធម៌ប្រពៃណី ទំនៀមទម្លាប់ និងចងក្រងជាឯកសារ និងរៀបចំធ្វើជាព្រឹត្តការណ៍ទេសចរណ៍នៅតាមរាជធានី ខេត្ត និងគោលដៅទេសចរណ៍
- ចូលរួមជំរុញ និងអនុវត្តចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ និងអង្គភាពពាក់ព័ន្ធក្នុងការអភិវឌ្ឍផលិតផលទេសចរណ៍
- សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈក្នុងការពិនិត្យលើផ្នែកសំណង់ស្ថាបត្យកម្មទេសចរណ៍ ឱ្យស្របតាមរចនាបថខ្មែរ ទាំងការតុបតែងលម្អ ការប្រគុំតន្រ្តីបុរាណ សម្លៀកបំពាក់តាមបែបបុរាណ ខ្មែរ ទាំងការប្រើប្រាស់ផលិតផលក្នុងស្រុកនៅតាមមូលដ្ឋានអាជីវកម្មនិងសេវាកម្មទេសចរណ៍ ដោយរក្សាបាននូវអត្តសញ្ញាណជាតិ
- សហការត្រួតពិនិត្យការលក់ដូរវត្ថុអនុស្សាវរីយ៍ដល់ភ្ញៀវទេសចរ
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ដែលបណ្តាលមកពីការធ្វើអាជីវកម្មមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្រ្ត បេតិកភណ្ឌ និងធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិ-ទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀត។

នាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍មានការិយាល័យចំណុះចំនួន៧ ដូចខាងក្រោម៖ [23]

- ការិយាល័យផលិតផលទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍ និងទេសចរណ៍សហគមន៍
- ការិយាល័យផលិតផលទេសចរណ៍វប្បធម៌-ប្រវត្តិសាស្រ្ត

[23] ប្រកាសលេខ១៤១ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ

- ការិយាល័យផលិតផលទេសចរណ៍តំបន់ឆ្នេរ
- ការិយាល័យផលិតផលទេសចរណ៍កែច្នៃ
- ការិយាល័យមណឌលទេសចរណ៍
- ការិយាល័យស្ថាបត្យកម្មនិងតុបតែងលម្អទេសចរណ៍
- ការិយាល័យវត្ថុអនុស្សាវរីយ៍និងសិប្បកម្មទេសចរណ៍។

## ខ. អគ្គាធិការដ្ឋាន

អគ្គាធិការដ្ឋានជាសេនាធិការឱ្យក្រសួងទេសចរណ៍ ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖ [24]

- ធ្វើអធិការដ្ឋានគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ដោយមានការណែនាំរបស់ប្រធានស្ថាប័ន
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការចាត់វិធានការលើភាពមិនប្រក្រតីក្នុងវិស័យទេសចរណ៍
- ស្រាវជ្រាវ អង្កេត និងធ្វើអធិការកិច្ចលើប្រតិបត្តិករនិងមូលដ្ឋានអាជីវកម្មទេសចរណ៍ ក្នុងករណីមានភាពមិនប្រក្រតីនៃការប្រកបអាជីវកម្ម សេវាកម្មទេសចរណ៍ ឬការអនុវត្តផ្ទុយទៅនឹងច្បាប់និងបទប្បញ្ញត្តិផ្សេងៗក្នុងវិស័យទេសចរណ៍
- ធ្វើអធិការកិច្ចលើទីកន្លែងប្រកបអាជីវកម្ម លើទីបរិវេណ ឬសម្ភារៈ ដែលបានប្រើប្រាស់ឬសង្ស័យថាបានប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្មទេសចរណ៍ និងដែលបានប្រើប្រាស់ ឬដែលបានសង្ស័យថាបានប្រើប្រាស់ផ្ទុយនឹងច្បាប់
- ពិនិត្យនិងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- កសាងសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសទេសចរណ៍ទៅតុលាការ។

អគ្គាធិការដ្ឋានមានការិយាល័យចំណុះចំនួន៤ ដូចខាងក្រោម៖ [25]

- ការិយាល័យទទួលនិងដោះស្រាយបណ្តឹងទេសចរណ៍
- ការិយាល័យអង្កេតស្រាវជ្រាវ
- ការិយាល័យអធិការកិច្ចទេសចរណ៍
- ការិយាល័យសរុបនិងតាមដានអនុវត្ត។

[24] អនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

[25] ប្រកាសលេខ១៥៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គាធិការដ្ឋាននៃក្រសួងទេសចរណ៍

## ២.២. យន្តការនៅថ្នាក់ក្រោមជាតិ

នៅថ្នាក់ក្រោមជាតិ មុខងារនៃការគ្រប់គ្រងអាជីវកម្មទេសចរណ៍ ត្រូវបានប្រគល់ជូន រដ្ឋបាលរាជធានី ខេត្ត (តាមរយៈអង្គភាពច្រកចេញចូលតែមួយ) រដ្ឋបាលក្រុង ស្រុក ខណ្ឌ (តាមរយៈការិយាល័យច្រកចេញចូលតែមួយ) និងមន្ទីរទេសចរណ៍រាជធានី ខេត្ត។ ការពិនិត្យ ការវាយតម្លៃ និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ទៅដល់ប្រតិបត្តិករទេសចរណ៍ ត្រូវបានកំណត់ទៅតាមប្រភេទនិងទំហំនៃអាជីវកម្ម ទៅតាមកម្រិតនៃឋានានុក្រមរដ្ឋបាលដែលបានកំណត់តាមច្បាប់ជាធរមាន។

### ក. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

#### ក.១. រដ្ឋបាលរាជធានី ខេត្ត

រដ្ឋបាលរាជធានី ខេត្ត (អង្គភាពច្រកចេញចូលតែមួយ) ត្រូវបានប្រគល់នូវមុខងារក្នុងការគ្រប់គ្រងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍។ បន្ទាប់ពីទទួលបានសំណុំឯកសារស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីប្រតិបត្តិករទេសចរណ៍រួចមក មន្ត្រីជំនាញមន្ទីរទេសចរណ៍រាជធានី ខេត្ត ដែលប្រចាំនៅក្នុងអង្គភាពច្រកចេញចូលតែមួយ មានភារកិច្ចដូចតទៅ៖ [26]

- ពិនិត្យសំណុំបែបបទ និងឯកសារពាក់ព័ន្ធត្រឹមត្រូវតាមគោលការណ៍កំណត់
- ក្នុងករណីពិនិត្យឃើញថា សំណុំបែបបទ មិនគ្រប់គ្រាន់ ត្រូវបញ្ជូនទៅឱ្យមន្ត្រីជួរមុខ ដើម្បីផ្តល់ព័ត៌មានជូនទៅម្ចាស់អាជីវកម្មវិញ
- ក្នុងករណីពិនិត្យឃើញថា សំណុំបែបបទ និងឯកសារគ្រប់គ្រាន់ មន្ត្រីជំនាញទទួលបន្ទុកត្រូវចាត់ចែងអនុវត្តតាមសមត្ថកិច្ចជំនាញ
- វាយតម្លៃ និងផ្តល់យោបល់អំពី "ការអនុញ្ញាតផ្តល់ ឬមិនអាចអនុញ្ញាតផ្តល់" អាជ្ញាបណ្ណទេសចរណ៍ លើសំណើសុំប្រកបអាជីវកម្មដោយផ្អែកតាមលិខិតបទដ្ឋានគតិយុត្តនិងស្តង់ដារជាធរមានរបស់ក្រសួង រួចបញ្ជូនសំណុំឯកសារស្នើសុំនោះទៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តវិញ។

ប្រភេទនិងទំហំនៃអាជីវកម្មទេសចរណ៍ដែលត្រូវបានធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត រួមមានដូចខាងក្រោម៖ [27]

- ផ្ទះភ្ញៀវ ចំណុះត្រឹម ២០ បន្ទប់ចុះ

[26] សេចក្តីណែនាំលេខ០០៣សណន របស់ក្រសួងទេសចរណ៍ ចុះថ្ងៃ១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការអនុវត្តប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍ ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

[27] ប្រកាសលេខ០៤៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

- សណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វីត ឬសណ្ឋាគាររីសត ប៊ឹងហ្គាឡូ ឬម៉ូតែល ឬឡដ៍ (Lodge) ចំណុះត្រឹមតែ ២០ បន្ទប់ចុះ
- ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ ចំណុះត្រឹម ១០០នាក់/កៅអីចុះ មិនស្ថិតនៅក្នុងអាជីវកម្មដែលចេញអាជ្ញាបណ្ណដោយក្រសួងទេសចរណ៍
- បៀហ្គាឌិន
- ខារ៉ាអូខេ ចាប់ពី ៦បន្ទប់ ឡើងទៅ (លើកលែងខារ៉ាអូខេ ដែលមានស្តង់ដារចំណាត់ថ្នាក់ផ្កាយ៤ និងផ្កាយ៥ ឬស្ថិតនៅក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ចាប់ពីផ្កាយ៤ឡើងទៅ)
- ម៉ាស្សាសុខភាពចំណុះពី៦ដល់១០គ្រែ ឬកៅអី (លើកលែងតែម៉ាស្សាដែលស្ថិតនៅក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ផ្កាយ៤ឡើង)
- រង្គសាលឌីស្កូតែក ឬរង្គសាល-ឌីស្កូតែក (លើកលែង រង្គសាលឌីស្កូតែក ឬរង្គសាល-ឌីស្កូតែក ដែលមានស្តង់ដាចំណាត់ថ្នាក់ផ្កាយ៤ និងផ្កាយ៥ ឬស្ថិតនៅក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ចាប់ពីផ្កាយ៤ឡើង)
- ស្ប៉ាដែលមិនស្ថិតនៅក្នុងអាជីវកម្មដែលចេញអាជ្ញាបណ្ណដោយក្រសួងទេសចរណ៍
- ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក (មិនមែនជាលក្ខណៈក្រុមហ៊ុន)
- ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវគោក (មិនមែនជាលក្ខណៈក្រុមហ៊ុន)
- កីឡាស្នូកឃ័រ ចាប់ពី៦តុឡើង
- ម៉ាស៊ីនហ្គេម (ល្បែងកម្សាន្តកុមារ និង E-Sport)
- សៀក (របាំសូត្រកម្ម និង Acrobafic)
- កីឡាជិះកង់រង្វង់ (គ្រឿងយន្តកម្សាន្តធុនតូចគ្រប់ប្រភេទ)
- កីឡាជិះដំរី (កម្សាន្ត)
- កីឡាជិះសេះ (កម្សាន្ត)
- រថយន្ត ឬរថភ្លើងអគ្គិសនី (គ្រឿងយន្តកម្សាន្តធុនតូចគ្រប់ប្រភេទ)។

**ក.២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ (ការិយាល័យច្រកចេញចូលតែមួយ) ត្រូវបានប្រគល់ភារកិច្ចនិងមុខងារក្នុងការផ្តល់សេវាទេសចរណ៍ (អាជ្ញាបណ្ណទេសចរណ៍) នូវប្រភេទនិងទំហំនៃអាជីវកម្មលើសេវាកម្មដូចខាងក្រោម៖ [28]

[28] ប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រក របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ផ្ទះសំណាក់ចាប់ពី៨បន្ទប់ចុះក្រោម
- ផ្ទះជួលបន្ទប់ស្នាក់នៅ
- ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ចាប់ពី៥០នាក់ចុះក្រោម
- ភោជនីយដ្ឋាន និងអាហារដ្ឋាក្នុងស្រុក
- តូបលក់អាហារ
- ហាងលក់គុយទាវ កាហ្វេ
- ម៉ាស្សា ចាប់ពី៥គ្រែឬ៥កៅអីចុះក្រោម
- ខារ៉ាអូខេ ចាប់ពី៥បន្ទប់ចុះក្រោម
- ស្នូកឃ័រ ចាប់ពី៥តុចុះក្រោម
- រថយន្តដឹកទេសចរណ៍ ចំណុះចាប់ពី៥កៅអីចុះក្រោម
- ម៉ូតូឌុបទេសចរណ៍
- ម៉ូតូជួលទេសចរណ៍
- រ៉ឺម៉កម៉ូតូដឹកទេសចរណ៍។

**ខ. មន្ទីរទេសចរណ៍រាជធានី ខេត្ត**

ក្នុងការធ្វើប្រតិភូកម្មមុខងារនៃការផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានីខេត្ត មន្ទីរទេសចរណ៍រាជធានីខេត្ត មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានីខេត្តក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មដោយសហការជាមួយអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត និងធ្វើរបាយការណ៍ជូនក្រសួងទេសចរណ៍។

មន្ទីរទេសចរណ៍រាជធានី ខេត្តមានតួនាទី និងភារកិច្ចដូចខាងក្រោម៖ [29]

- ដឹកនាំ គ្រប់គ្រង សម្របសម្រួល និងអភិវឌ្ឍវិស័យទេសចរណ៍នៅថ្នាក់ក្រោមជាតិ
- គ្រប់គ្រងរមណីយដ្ឋានទេសចរណ៍ អាជីវកម្មទេសចរណ៍ និងសេវាកម្មផ្សេងៗទៀត ដែលបម្រើឱ្យវិស័យទេសចរណ៍
- គ្រប់គ្រងនិងថែរក្សាតំបន់ទេសចរណ៍ មណ្ឌលទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ កសិទេសចរណ៍ និងអេកូទេសចរណ៍ក្នុងរាជធានីខេត្ត
- ចូលរួមនិងជំរុញអនុវត្តយន្តការនិងនីតិវិធីនៅថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត

[29] ប្រកាសលេខ១២៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានី ខេត្ត

ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្ម និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន

- សម្រាប់មន្ទីរទេសចរណ៍ដែលមានឆ្នេរសមុទ្រនិងកោះ ត្រូវចូលរួមគ្រប់សកម្មភាពក្នុងការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រនិងកោះស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្ត
- សហការគ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្ម ផលិតកម្ម សេវាកម្ម និងប្រតិបត្តិករទេសចរណ៍ ធានាបាននូវប្រសិទ្ធភាព គុណភាព និរន្តរភាព របៀបរៀបរយ អនាម័យ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

មន្ទីរទេសចរណ៍រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តបាត់ដំបង មានការិយាល័យចំណុះចំនួន៧ ដូចខាងក្រោមៈ [30]

- ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
- ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- ការិយាល័យអប់រំបណ្តុះបណ្តាល
- ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
- ការិយាល័យគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍
- ការិយាល័យទីក្រុងស្អាត។

មន្ទីរទេសចរណ៍ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ មានការិយាល័យចំណុះចំនួន៦ ដូចខាងក្រោមៈ [31]

- ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
- ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

[30] ប្រកាសលេខ១២៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានី ខេត្ត

[31] ប្រកាសលេខ១២៣ របស់ក្រសួងទេសចរណ៍ ប្រក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានី ខេត្ត

- ការិយាល័យអប់រំបណ្តុះបណ្តាល
- ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
- ការិយាល័យទីក្រុងស្អាត។

មន្ទីរទេសចរណ៍ខេត្តកំពត ខេត្តកែប និងខេត្តកោះកុង មានការិយាល័យចំណុះចំនួន៧ ដូចខាងក្រោម៖ [32]

- ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
- ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- ការិយាល័យអប់រំបណ្តុះបណ្តាល
- ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
- ការិយាល័យគ្រប់គ្រងឆ្នេរ
- ការិយាល័យទីក្រុងស្អាត។

មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ មានការិយាល័យចំណុះចំនួន៩ ដូចខាងក្រោម៖ [33]

- ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
- ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- ការិយាល័យអប់រំបណ្តុះបណ្តាល
- ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
- ការិយាល័យគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍
- ការិយាល័យគ្រប់គ្រងឆ្នេរ
- ការិយាល័យទេសចរណ៍កោះរ៉ុង
- ការិយាល័យទីក្រុងស្អាត។

## ៣. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងអាជីវកម្មទេសចរណ៍

ក្នុងកិច្ចការងារគ្រប់គ្រងអាជីវកម្មទេសចរណ៍ ក្រសួងទេសចរណ៍បានរៀបចំនិងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំបង្កើតនូវលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីធានាបាននូវការគ្រប់គ្រងមូលដ្ឋាន

[32] ប្រកាសលេខ១២៣ របស់ក្រសួងទេសចរណ៍ ប្រក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានី ខេត្ត

[33] ប្រកាសលេខ១២៣ របស់ក្រសួងទេសចរណ៍ ប្រក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានី ខេត្ត

អាជីវកម្ម ទេសចរណ៍មួយប្រកបដោយគុណភាព ប្រសិទ្ធភាព និរន្តរភាព និងភាពដែលអាចជឿទុកចិត្តបាន។ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង មានដូចខាងក្រោម៖

### ៣.១. ច្បាប់និងអនុក្រឹត្យ

#### ក. ច្បាប់

ច្បាប់ស្តីពីទេសចរណ៍ ដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ និងត្រូវបានប្រកាសឱ្យប្រើតាមរយៈព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩។ ច្បាប់នេះត្រូវបានបែងចែកចេញជា ១២ជំពូក និង ៧៧មាត្រា ហើយមានគោលបំណង [34] ដូចតទៅ៖

- គ្រប់គ្រង និងអភិវឌ្ឍវិស័យទេសចរណ៍ ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ
- រួមចំណែកការពារ និងថែរក្សាធនធានធម្មជាតិ វប្បធម៌ និងទំនៀមទម្លាប់ ដែលជាមូលដ្ឋានបម្រើឱ្យវិស័យទេសចរណ៍
- ធានា និងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតប្រព័ន្ធធានាគុណភាព ដោយផ្តល់សន្តិសុខ សុវត្ថិភាព ផាសុកភាព និងបង្កើនការពេញចិត្តដល់ទេសចរ
- លើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយ រកទីផ្សារ និងជំរុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពដោយមានការចូលរួមពីផ្នែកសាធារណៈនិងផ្នែកឯកជន
- អភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍
- រួមចំណែកកសាងមិត្តភាពនិងការយោគយល់ជាអន្តរជាតិ តាមរយៈឧស្សាហកម្មទេសចរណ៍។

ដោយឡែក នៅមានច្បាប់មួយទៀត គឺច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍ ដែលត្រូវបានរដ្ឋសភាអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១។ ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦។

#### ខ. អនុក្រឹត្យ

មានអនុក្រឹត្យចំនួន៤ដែលបាននិងកំពុងប្រើប្រាស់ដើម្បីគ្រប់គ្រងសកម្មភាពអាជីវកម្មលើសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដូចខាងក្រោម៖

- អនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍។ អនុក្រឹត្យនេះមានគោលដៅ [35] រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធ

[34] មាត្រា២នៃច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ២០០៩)

របស់ក្រសួងទេសចរណ៍ រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានានៃក្រសួងទេសចរណ៍ និងធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យទេសចរណ៍។

- អនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។ អនុក្រឹត្យនេះមានគោលបំណង [36] ពង្រឹងការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលបម្រើឱ្យវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- អនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍។ អនុក្រឹត្យនេះមានគោលបំណង [37] កំណត់អំពីវិធានគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់បម្រើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- អនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍។ អនុក្រឹត្យនេះមានគោលបំណង [38] ផ្តល់ចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ សំដៅបញ្ជាក់អំពីកម្រិតគុណភាព សេវាកម្ម សម្ភារៈ និងគ្រឿងបំពាក់ នៅតាមសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ ឱ្យបានសមស្របតាមនិយាមអន្តរជាតិ។

### ៣.២. ប្រកាស ប្រកាសរួម សារាចរ និងសេចក្តីណែនាំ

#### ក. ប្រកាសនិងប្រកាសរួម

មានប្រកាសនិងប្រកាសរួមជាច្រើនពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណនិងការពិន័យអន្តរការណ៍ដែលបាននិងកំពុងប្រើប្រាស់ដើម្បីគ្រប់គ្រងសកម្មភាពអាជីវកម្មលើសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដូចខាងក្រោម៖

- ប្រកាសលេខ១៥១ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្ត
- ប្រកាសលេខ១៥២ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងសកម្មភាពកីឡាទេសចរណ៍

[35] មាត្រា២នៃអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

[36] មាត្រា១នៃអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ

[37] មាត្រា១នៃអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍

[38] មាត្រា១នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

- ប្រកាសលេខ១៩៩ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីនីតិវិធីនៃការគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍
- ប្រកាសលេខ១១៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងសាខា
- ប្រកាសលេខ០៤០ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៩ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ អាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវទឹក
- ប្រកាសលេខ០៤៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ ទៅឱ្យរដ្ឋបាលរាជធានីខេត្ត
- ប្រកាសរួមលេខ២៦២ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍
- ប្រកាសលេខ០៩៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការអាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ
- ប្រកាសលេខ០៦៩ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មមុខងារ "ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ឱ្យទៅរដ្ឋបាលរាជធានីខេត្ត
- ប្រកាសលេខ១៧៤ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មខារ៉ាអូខេ
- ប្រកាសលេខ១៧៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មបៀរហ្គាឌិន
- ប្រកាសលេខ១៧៦ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរង្គសាល និងឌីស្កូតែក
- ប្រកាសលេខ១៨៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសលេខ១៥៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍តំបន់

- ប្រកាសលេខ០៤៧ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្ដីពីការអនុវត្តក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍
- ប្រកាសលេខ០៩២ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ស្ដីពីការគ្រប់គ្រងអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍
- ប្រកាសលេខ០៧៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មសេវាកម្មម៉ាស្សាសុខភាព ស្ប៉ា
- ប្រកាសលេខ០៧៦ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់ អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន
- ប្រកាសលេខ០៦២ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់ អាជីវកម្មរមណីយដ្ឋានទេសចរណ៍
- ប្រកាសលេខ០៦៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់ អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- ប្រកាសលេខ០៦៤ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកម្សាន្តតាមផ្លូវគោក។

**ខ. សារាចរនិងសេចក្ដីណែនាំ**

មានសេចក្ដីណែនាំនិងសារាចរណែនាំជាច្រើនបាននិងកំពុងប្រើប្រាស់ដើម្បីគ្រប់គ្រងសកម្មភាពអាជីវកម្មលើសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដូចខាងក្រោម៖

- សេចក្ដីណែនាំលេខ០០៣ សណន របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្ដីពីការអនុវត្តប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្ដីពីការធ្វើប្រតិភូកម្មមុខងារផ្ដល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានីខេត្ត
- សារាចរណែនាំលេខ០០៣ សរណន របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីការគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន

- សារាចរណែនាំលេខ០០២ សរណន របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍
- សារាចរណែនាំលេខ០០៣ សរណន របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងអាជីវកម្មសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍
- សារាចរណែនាំលេខ០០៤ សរណន របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងមធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកម្សាន្តតាមផ្លូវគោក
- សារាចរណែនាំលេខ០០៥ សរណន របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងមធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកម្សាន្តតាមផ្លូវទឹក។

# ជំពូកទី៣
# ការផ្តល់អាជ្ញាបណ្ណ
# ទេសចរណ៍

# ជំពូកទី៣

# ការផ្តល់អាជ្ញាបណ្ណទេសចរណ៍

## ១. អាជ្ញាបណ្ណនិងប្រភេទអាជ្ញាបណ្ណទេសចរណ៍

គ្មានបុគ្គលណាម្នាក់អាចប្រកបអាជីវកម្មទេសចរណ៍បានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីដែលអាជីវកម្មច្រើនប្រភេទត្រូវបានប្រតិបត្តិដោយបុគ្គលតែម្នាក់ចេញពីទីតាំងតែមួយប្រភេទអាជីវកម្មនីមួយៗ ត្រូវតែមានអាជ្ញាបណ្ណផ្សេងៗគ្នា ប្រៀបដូចជាអាជីវកម្មផ្សេងគ្នាដែលប្រតិបត្តិចេញពីទីតាំងផ្សេងគ្នាយ៉ាងដូច្នោះដែរ។ ក្នុងករណីដែលបុគ្គលម្នាក់មានអាជីវកម្មទេសចរណ៍មួយប្រភេទហើយមានសាខាច្រើនកន្លែង សាខានីមួយៗនោះត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍។[39] អាជ្ញាបណ្ណទេសចរណ៍ដែលចេញដោយក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិមិនធ្វើឱ្យប្រតិបត្តិករទេសចរណ៍ រួចផុតពីកាតព្វកិច្ចក្នុងការចុះបញ្ជីពាណិជ្ជកម្មឬទទួលការអនុញ្ញាតពីក្រសួងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលតម្រូវដោយច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ។ [40]

អាជ្ញាបណ្ណដែលបានចេញក្រោមច្បាប់ស្តីពីទេសចរណ៍ ត្រូវមានលក្ខខណ្ឌ [41] ដែលអ្នកទទួល ត្រូវអនុវត្តតាមដែលមានដូចជា៖

- អនុវត្តតាមផែនការ បទដ្ឋានស្តីពីសំណង់អគារ សុវត្ថិភាពអគ្គីភ័យ សុខភាព ម្ហូបអាហារ អនាម័យ កម្លាំងពលកម្ម ពន្ធ ច្បាប់ និងបទប្បញ្ញត្តិដទៃទៀត ដែលទាក់ទងនឹងសកម្មភាព ទីបរិវេណ បរិក្ខារ និយោជិត និងប្រតិបត្តិការអាជីវកម្មទេសចរណ៍។
- អនុវត្តតាមស្តង់ដារនិងការតម្រូវដែលបានចេញដោយក្រសួងទេសចរណ៍។
- អនុវត្តតាមប្រព័ន្ធចំណាត់ថ្នាក់ដែលបានចេញដោយក្រសួងទេសចរណ៍។
- អនុវត្តតាមវិធានការធានាគុណភាពដែលចេញដោយក្រសួងទេសចរណ៍ និងមិនប្រតិដ្ឋព័ត៌មានអំពីស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ ឬការលើកទឹកចិត្តដែលអាជីវកម្មនោះ មិនមានត្រឹមត្រូវនោះឡើយ។
- ប្រសិនបើអាជីវកម្មទេសចរណ៍ត្រូវបានផ្តល់ចំណាត់ថ្នាក់កម្រិតណាមួយ ចំណាត់ថ្នាក់នោះត្រូវតែដាក់តាំងនៅកន្លែងដែលងាយមើលឃើញក្នុងទីតាំងអាជីវកម្មរបស់ម្ចាស់អាជ្ញាបណ្ណ ហើយត្រូវបញ្ជាក់នូវគ្រប់ការធ្វើការងាររកទីផ្សារ ការផ្សាយពាណិជ្ជកម្ម និងការសរសេរឆ្លើយឆ្លង។

[39] មាត្រា៣២នៃច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ២០០៩)

[40] មាត្រា៣៣នៃច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ២០០៩)

[41] មាត្រា៣៩នៃច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ២០០៩)

- អនុវត្តតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈដែលចេញដោយក្រសួងទេសចរណ៍ ឬដោយសមាគមឧស្សាហកម្មទេសចរណ៍ដែលមានការយល់ព្រមពីក្រសួងទេសចរណ៍ សម្រាប់អាជីវកម្មទេសចរណ៍ប្រភេទនោះ។
- ផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដល់ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរយៈពេល១៤ថ្ងៃ ដោយមានការផ្លាស់ប្តូរចំណុចពិស្តារណាមួយដែលទាក់ទងទៅនឹងអាជីវកម្មរបស់ម្ចាស់អាជ្ញាបណ្ណ។
- ផ្តល់ជូនក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានទាន់ពេលវេលានូវស្ថិតិនិងព័ត៌មានផ្សេងៗ ដែលទាក់ទងនឹងអាជីវកម្មទេសចរណ៍តាមការស្នើសុំនិងការតម្រូវដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ដាក់តាំងអាជ្ញាបណ្ណទេសចរណ៍នៅទីកន្លែងដែលងាយមើលឃើញច្បាស់ក្នុងទីបរិវេណធ្វើអាជីវកម្មរបស់អ្នកទទួលអាជ្ញាបណ្ណ។
- ធានាថាលេខចុះបញ្ជីនិងប្រភេទអាជ្ញាបណ្ណទេសចរណ៍ត្រូវបញ្ជាក់រាល់ពេលសរសេរឆ្លើយឆ្លងជាមួយបណ្តាដៃគូពាក់ព័ន្ធនិងដៃគូអាជីវកម្ម។

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ [42] ដែលបានចេញក្រោមច្បាប់ស្តីពីទេសចរណ៍ មិនអាចធ្វើការផ្ទេរឬលក់បានទេ ដោយសារតែអាជ្ញាបណ្ណនេះផ្អែកលើគុណវុឌ្ឍិបុគ្គលនិងបទពិសោធរបស់ម្ចាស់អាជ្ញាបណ្ណ។ ក្រៅពីអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ អាជ្ញាបណ្ណផ្សេងទៀតអាចផ្ទេរឬលក់បាន ក្រោមលក្ខខណ្ឌដូចតទៅៈ

- ម្ចាស់អាជ្ញាបណ្ណត្រូវដាក់ពាក្យសុំផ្ទេរឬលក់អាជ្ញាបណ្ណមកក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិតាមគំរូដែលបានកំណត់ និងដោយភ្ជាប់មកជាមួយនូវសោហ៊ុយសេវាផ្ទេរ ឬលក់អាជ្ញាបណ្ណ ឯកសាររួមទាំងព័ត៌មានផ្សេងៗទៀតដែលកំណត់ដោយក្រសួងទេសចរណ៍។
- បុគ្គលជាអ្នកទទួលអាជ្ញាបណ្ណពីការផ្ទេរ ឬទិញអាជ្ញាបណ្ណត្រូវបំពេញរាល់លក្ខខណ្ឌតម្រូវស្តីពីការចេញអាជ្ញាបណ្ណរបស់ក្រសួងទេសចរណ៍
- ការផ្ទេរឬការលក់អាជ្ញាបណ្ណទេសចរណ៍នេះអាចប្រព្រឹត្តទៅបាន លុះត្រាណាតែម្ចាស់អាជ្ញាបណ្ណបានបំពេញកាតព្វកិច្ចពន្ធ តាមច្បាប់ជាធរមាននិងបានដោះស្រាយរួចរាល់នូវបញ្ហាផ្សេងៗទៀតជាមួយបណ្តា ភាគីពាក់ព័ន្ធរបស់ខ្លួន ឬបុគ្គលជាអ្នកទទួលអាជ្ញាបណ្ណពីការផ្ទេរឬការទិញអាជ្ញាបណ្ណយល់ព្រមជាលាយលក្ខណ៍អក្សរបំពេញកាតព្វកិច្ចពន្ធ ឬដោះស្រាយបញ្ហាសេសសល់ទាំងនោះលើកលែងតែមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរផ្សេងពីនេះ រវាងភាគីពាក់ព័ន្ធ។

[42] មាត្រា៤៣នៃច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ២០០៩)

- ក្នុងករណីដែលអាជ្ញាបណ្ណជាអាជ្ញាបណ្ណបណ្ដោះអាសន្ន បុគ្គលជាអ្នកទទួលអាជ្ញាបណ្ណពីការផ្ទេរ ឬការទិញអាជ្ញាបណ្ណ ត្រូវផ្ដល់ជូនក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ នូវការយល់ព្រមជាលាយលក្ខណ៍ អក្សរនៅក្នុងការបំពេញលក្ខខណ្ឌដែលនៅសល់ក្នុងរយៈពេលនៅសល់។

ក្នុងការចេញអាជ្ញាបណ្ណទេសចរណ៍ ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពិនិត្យនិងវាយតម្លៃលើពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ដោយផ្អែកលើព័ត៌មានដែលបានទទួលឬសាកសួរបន្ថែមទៀតតាមការចាំបាច់។ ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជូនដំណឹងទៅអ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍អំពីសេចក្ដីសម្រេចឯកភាពផ្ដល់ឱ្យឬមិនឯកភាពផ្ដល់ឱ្យក្នុងរយៈពេល២៨ថ្ងៃ ចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំពេញលេញ។ ក្នុងករណីមិនឯកភាពផ្ដល់ឱ្យអាជ្ញាបណ្ណទេសចរណ៍ ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ជូនទៅសាមីជន។

ប្រសិនបើអ្នកស្នើសុំឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យនិងការតម្រូវដូចបានកំណត់ ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចេញអាជ្ញាបណ្ណដែលមានសុពលភាពអប្បបរមា ១ឆ្នាំ ដល់អ្នកស្នើសុំ។ ប្រសិនបើអ្នកស្នើសុំពុំបានបំពេញទៅតាមលក្ខខណ្ឌដូចបានកំណត់ទេ ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិយល់ព្រមទទួលយកកិច្ចសន្យាជាលាយលក្ខណ៍អក្សរពីអ្នកស្នើសុំ ក្នុងការអនុវត្តតាមលក្ខណវិនិឆ្ឆ័យនិងសេចក្ដីតម្រូវនោះ ក្រសួងទេសចណ៍ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចចេញនូវអាជ្ញាបណ្ណបណ្ដោះអាសន្នដែលមានសុពលភាពរយៈពេល៩០ថ្ងៃ ក្រោយពេលដែលអ្នកសុំបានបង់កម្រៃអាជ្ញាបណ្ណរួច។ ក្នុងរយៈពេលកំណត់នៃកិច្ចសន្យាបើពិនិត្យឃើញថា ម្ចាស់អាជ្ញាបណ្ណបណ្ដោះអាសន្នបានអនុវត្តទៅតាមលក្ខណវិនិច្ឆ័យនិងការតម្រូវទាំងអស់រួចហើយ ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្រេចផ្ដល់នូវអាជ្ញាបណ្ណពេញសិទ្ធិដល់អ្នកស្នើសុំ។ ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកស្នើសុំ មិនបានបំពេញតាមលក្ខខណ្ឌនៃកិច្ចសន្យាហើយនៅតែបន្តធ្វើអាជីវកម្មលើអាជ្ញាបណ្ណបណ្ដោះអាសន្នដែលអស់សុពលភាព ត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ។

ប្រភេទរបស់អាជ្ញាបណ្ណសម្រាប់ធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍នីមួយៗ ត្រូវបានកំណត់ទៅតាមប្រភេទនៃសេវាកម្មទេសចរណ៍។ ជារួម ប្រភេទអាជ្ញាបណ្ណទេសចរណ៍ដែលក្រសួងទេសចរណ៍និងរដ្ឋបាលថ្នាក់ក្រោមជាតិបានចេញជូនប្រតិបត្តិករទេសចរណ៍មានដូចជា៖

**ក. អាជ្ញាបណ្ណលើសេវាកម្មទីភ្នាក់ងារទេសចរណ៍ ដឹកជញ្ជូនទេសចរ និងមគ្គុទ្ទេសក៍ទេសចរណ៍**

- អាជ្ញាបណ្ណការីទេសចរណ៍
- អាជ្ញាបណ្ណភ្នាក់ងារទេសចរណ៍
- អាជ្ញាបណ្ណដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក
- អាជ្ញាបណ្ណដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍

**ខ. អាជ្ញាបណ្ណលើសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ**

- អាជ្ញាបណ្ណសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍
- អាជ្ញាបណ្ណភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍

**គ. អាជ្ញាបណ្ណលើសេវាកម្សាន្តនិងកីឡាទេសចរណ៍**

- អាជ្ញាបណ្ណបៀរហ្គាឌិន
- អាជ្ញាបណ្ណខារ៉ាអូខេ
- អាជ្ញាបណ្ណរង្គសាលនិងឌីស្កូតែក
- អាជ្ញាបណ្ណកីឡាទេសចរណ៍

**ឃ. អាជ្ញាបណ្ណលើសេវាកម្មរមណីយដ្ឋានទេសចរណ៍**

- អាជ្ញាបណ្ណរមណីយដ្ឋានទេសចរណ៍

## ២. ការផ្តល់អាជ្ញាបណ្ណលើសេវាកម្មទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍

**ក. សម្រាប់អាជីកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍**

អាជ្ញាបណ្ណត្រូវបានផ្តល់ទៅតាមប្រភេទអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍រួមមានៈ

- អាជ្ញាបណ្ណទេសចរណ៍ការីទេសចរណ៍នាំភ្ញៀវចូលកម្សាន្តក្នុងប្រទេសកម្ពុជា
- អាជ្ញាបណ្ណទេសចរណ៍ការីទេសចរណ៍នាំភ្ញៀវចេញកម្សាន្តក្រៅប្រទេសកម្ពុជា
- អាជ្ញាបណ្ណទេសចរណ៍ការីទេសចរណ៍នាំភ្ញៀវកម្សាន្តក្នុងប្រទេសកម្ពុជា
- អាជ្ញាបណ្ណទេសចរណ៍ភ្នាក់ងារទេសចរណ៍
- អាជ្ញាបណ្ណភ្នាក់ងារទេសចរណ៍ក្នុងស្រុក។

លក្ខណវិនិច្ឆ័យនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ភ្នាក់ងារទេសចរណ៍ក្នុងស្រុក ត្រូវបានកំណត់ដូចខាងក្រោមៈ

- បុគ្គលមានសញ្ជាតិខ្មែរ
- ធ្វើប្រតិបត្តិការអាជីវកម្មក្នុងដែនកំណត់មួយក្នុងតំបន់ ឬរាជធានីខេត្តដែលខ្លួនរស់នៅ
- ធ្វើអាជីវកម្មទេសចរណ៍ខ្នាតតូច ជាលក្ខណៈគ្រួសារដែលមិនជាប់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- ទទួលផលរបរប្រចាំឆ្នាំមិនលើសពី ៥០លានរៀល និងមានដើមទុនតិចជាងឬស្មើ ២០លានរៀល
- មានបុគ្គលិកបម្រើការងារតិចជាង៤នាក់ និងមានទីតាំងទីស្នាក់ការដែលមានទំហំមិនលើសពី ៣ម៉ែត្រការេ។

បុគ្គលដែលប្រកបអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ឬបើកសាខា ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនខាងក្រោម៖

- វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- លិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្មពីធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍
- លិខិតបញ្ជាក់ទីស្នាក់ការឬកិច្ចសន្យាជួលផ្ទះដោយមានបញ្ជាក់ពីភូមិឬឃុំ/សង្កាត់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស)
- រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ ៤x៦ ចំនួន៣សន្លឹក។

តម្លៃនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍[43] ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់ទីភ្នាក់ងារទេសចរណ៍** | | | | |
| ១ | ស្នាក់ការកណ្តាល | ១ ២០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | ស្នាក់ការសាខា | ៨០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |

ប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ត្រូវបានកំណត់ទៅតាមវិសាលភាពនិងទំហំអាជីវកម្ម ដូចខាងក្រោម៖

- ការីទេសចរណ៍ដែលនាំភ្ញៀវមកកម្សាន្តនៅប្រទេសកម្ពុជា (Inbound Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន ៥ ០០០ ដុល្លារអាមេរិក
- ការីទេសចរណ៍នាំភ្ញៀវទៅកម្សាន្តក្រៅប្រទេសកម្ពុជា (Outbound Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន ៧ ០០០ ដុល្លារអាមេរិក
- ភ្នាក់ងារទេសចរណ៍ (Travel Agent) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួណ ៥ ០០០ដុល្លារអាមេរិក
- ការីទេសចរណ៍នាំភ្ញៀវកម្សាន្តក្នុងប្រទេសកម្ពុជា (Domestic Tour Operators) ត្រូវមានប្រាក់តម្កល់ធានាអាជីវកម្មចំនួន ២ ០០០ដុល្លារអាមេរិក

[43] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

- ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) ត្រូវមានប្រាក់តម្កល់ធានាអាជីវកម្ម ចំនួន ៥ ០០ដុល្លារអាមេរិក
- ចំពោះប្រតិបត្តិករទេសចរណ៍ ដែលមានអាជ្ញាបណ្ណទេសចរណ៍ជាការីទេសចរណ៍ផង ជាភ្នាក់ងារទេសចរណ៍ផង ហើយស្ថិតនៅក្រោមឈ្មោះតែមួយត្រូវតម្កល់ប្រាក់ធានាអាជីវកម្មក្នុងកម្រិតទឹកប្រាក់ខ្ពស់ជាងគេ
- សាខា មិនត្រូវឱ្យតម្កល់ប្រាក់ធានាអាជីវកម្មដោយឡែកឡើយ ក្នុងករណីដែលការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (ស្នាក់ការកណ្តាល) របស់ខ្លួនបានអនុវត្តនីតិវិធីនៃការដាក់ប្រាក់តម្កល់ធានាអាជីវកម្មរួចរាល់ហើយ។

ប្រតិបត្តិករទេសចរណ៍អាចដាក់ពាក្យសុំដកប្រាក់តម្កល់ធានាអាជីវកម្មរបស់ខ្លួនមកវិញបាន នៅពេលបិទអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍។ ក្នុងករណីនេះ ប្រតិបត្តិករទេសចរណ៍ត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ និងធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈជាមុនក្នុងរយៈពេល ៣០ថ្ងៃមុនថ្ងៃបិទអាជីវកម្មរបស់ខ្លួន។

**ខ. សម្រាប់អាជីកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នៅក្រសួងទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ជាផ្លូវការដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួន ដូចខាងក្រោមៈ

- វិញ្ញាបនប័ត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសផ្តល់ដោយក្រសួងសាធារណការនិងដឹកជញ្ជូន ឬមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត
- អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស) របស់អ្នកគ្រប់គ្រង
- បណ្ណធានារ៉ាប់រងលើអ្នកដំណើររបស់ក្រុមហ៊ុនដឹកជញ្ជូនទេសចរណ៍ (ប្រសិនបើមាន)
- កិច្ចសន្យាគោរពច្បាប់រដ្ឋនិងអនុវត្តច្បាប់ស្តីពីទេសចរណ៍និងច្បាប់រដ្ឋជាធរមាន
- រូបថតជលយាន (១០ ស.ម x ១៥ ស.ម) ចំនួន២សន្លឹក
- រូបថតរបស់អ្នកគ្រប់គ្រង (៤ ស.ម x ៦ ស.ម) ចំនួន៣សន្លឹក)

សម្រាប់បុគ្គលដែលមានបំណងប្រកបអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក ដែលមិនមែនជាលក្ខណៈក្រុមហ៊ុន ត្រូវដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត និងបំពេញបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

- វិញ្ញាបនបត្រឬសៀវភៅត្រួតពិនិត្យបច្ចេកទេសយានយន្ត (សុពលភាព) ចំនួន១ច្បាប់
- វិញ្ញាបនបត្រធានារ៉ាប់រងអំពីភារៈទទួលខុសត្រូវសាធារណៈ ចំនួន១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន១ច្បាប់
- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (ថតចម្លង) ចំនួន១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ (៤ស.ម x ៦ស.ម) ចំនួន៣សន្លឹក
- រូបថតយានយន្តសម្រាប់ធ្វើអាជីវកម្មទេសចរណ៍ (ថតចម្លង) ចំនួន១ច្បាប់។

តម្លៃនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក [44]ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក** | | | | |
| ១ | ចំណុះត្រឹម១0កៅអី | ៨0 000 | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | ចំណុះពី ១១ ដល់ ៣0កៅអី | ១៥0 000 | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣ | ចំណុះពី ៣១ ដល់ ៥0កៅអី | ៣៥0 000 | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤ | ចំណុះពី ៥១ ដល់ ១00កៅអី | ៦00 000 | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៥ | ចំណុះលើសពី១០១កៅអី | ៨00 000 | ២៨ថ្ងៃ | ១ ឆ្នាំ |

### គ. សម្រាប់អាជីកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក

ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ត្រូវធ្វើឡើងដោយម្ចាស់ឬអ្នកគ្រប់គ្រងអាជីវកម្ម ដោយអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងភ្ជាប់ជាមួយនូវឯកសារចាំបាច់មួយចំនួនដូចជា៖

- អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនរបស់អ្នកបើកបរ (ចំពោះរូបវន្តបុគ្គល)
- បណ្ណសម្គាល់យានយន្តចេញដោយក្រសួងឬមន្ទីរសាធារណការនិងដឹកជញ្ជូន
- បណ្ណបើកបររថយន្ត (របស់អ្នកបើកបរ) ចេញដោយក្រសួងឬមន្ទីរសាធារណការនិងដឹកជញ្ជូន
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (របស់ក្រុមហ៊ុនដឹកជញ្ជូនទេសចរ)
- បណ្ណធានារ៉ាប់រងភារៈទទួលខុសត្រូវអ្នកដំណើរ (របស់ក្រុមហ៊ុនដឹកជញ្ជូនទេសចរ)

[44] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

- សៀវភៅត្រួតពិនិត្យលើលក្ខណៈបច្ចេកទេសរបស់ក្រសួងឬមន្ទីរសាធារណការនិងដឹកជញ្ជូន (មានសុពលភាព)
- សញ្ញាបត្រឬវិញ្ញាបនបត្ររបស់ម្ចាស់មធ្យោបាយដឹកជញ្ជូនទេសចរឬអ្នកបើកបរ ដែលបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ចឬគ្រប់គ្រងទេសចរណ៍។

សម្រាប់បុគ្គលដែលមានបំណងប្រកបអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក ដែលមិនមែនជាលក្ខណៈក្រុមហ៊ុន ត្រូវដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត និងបំពេញបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

- វិញ្ញាបនបត្រឬសៀវភៅត្រួតពិនិត្យបច្ចេកទេសយានយន្ត (សុពលភាព) ចំនួន១ច្បាប់
- វិញ្ញាបនបត្រធានារ៉ាប់រងអំពីភារៈទទួលខុសត្រូវសាធារណៈ ចំនួន១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន១ច្បាប់
- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (ថតចម្លង) ចំនួន១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ (៤ស.ម x ៦ស.ម) ចំនួន៣សន្លឹក
- រូបថតយានយន្តសម្រាប់ធ្វើអាជីវកម្មទេសចរណ៍ (ថតចម្លង) ចំនួន១ច្បាប់។

តម្លៃនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក[45] ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវគោក** | | | | |
| ១ | ចំណុះត្រឹម៥កៅអី | ១០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | ចំណុះពី ៦ ដល់ ១៥កៅអី | ១៥០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣ | ចំណុះពី ១៦ ដល់ ៤៥កៅអី | ២០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤ | ចំណុះពី ៤៦កៅអី ឡើងទៅ | ២៦០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៥ | រថយន្តដឹកទេសចរណ៍ចំណុះចាប់ពី ៥កៅអីចុះក្រោម | ១០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៦ | ម៉ូតូឌុបទេសចរណ៍ | ១០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៧ | ម៉ូតូជួលទេសចរណ៍ | ១០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៨ | រ៉ឺម៉កម៉ូតូដឹកទេសចរណ៍ | ១៥ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |

[45] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

**ឃ. សម្រាប់អាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍**

លក្ខណវិនិច្ឆ័យសម្រាប់ការពិនិត្យវាយតម្លៃនិងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ឱ្យមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវមានដូចខាងក្រោម៖

- ត្រូវតែជាបុគ្គលដែលមានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- មានវិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍
- លិខិតបញ្ជាក់កិរិយាមារយាទដែលចេញដោយរដ្ឋបាលឃុំ សង្កាត់ ដែលខ្លួនរស់នៅសម្រាប់ការសុំអាជ្ញាបណ្ណ
- វិញ្ញាបនបត្រសុខភាពនិងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានីខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលនិងមានការឯកភាពពីក្រសួងទេសចរណ៍
- ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត។

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍រួមមាន៖

- អាជ្ញាបណ្ណមគ្គុទេសក៍ទេសចរណ៍ថ្នាក់ពិសេស
- អាជ្ញាបណ្ណមគ្គុទេសក៍ទេសចរណ៍ថ្នាក់ជាតិ
- អាជ្ញាបណ្ណមគ្គុទេសក៍ទេសចរណ៍ថ្នាក់តំបន់
- អាជ្ញាបណ្ណមគ្គុទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ
- អាជ្ញាបណ្ណមគ្គុទេសក៍ទេសចរណ៍ថ្នាក់សហគមន៍។

បុគ្គលដែលស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ (ថ្នាក់តំបន់ និងថ្នាក់ជាតិ) ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍នៅទីស្តីការក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍រាជធានីខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន Online (តាមរយៈគេហទំព័រទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាងនិងព័ត៌មានផ្សេងៗទៀត ដូចខាងក្រោម៖

- ត្រូវមានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- វិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ (សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ) ឬវិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ (សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់)

ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

- លិខិតបញ្ជាក់កិរិយាមារយាទ ដែលចេញដោយរដ្ឋបាលឃុំ សង្កាត់ ដែលខ្លួនរស់នៅ
- វិញ្ញាបនបត្រពិនិត្យសុខភាពនិងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានីខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលដោយមានការឯកភាពពីក្រសួងទេសចរណ៍
- កិច្ចសន្យាគោរពច្បាប់រដ្ឋ
- ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត
- រូបថត (៤ស.ម x ៦ស.ម) ចំនួន៣សន្លឹក។

ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍នៅមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន Online (តាមរយៈគេហទំព័រទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមមានឯកសារសំអាងនិងព័ត៌មានផ្សេងៗទៀត ដូចខាងក្រោម៖

- ត្រូវមានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- វិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយមន្ទីរទេសចរណ៍រាជធានី ខេត្ត (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)
- លិខិតបញ្ជាក់កិរិយាមារយាទចេញដោយសហគមន៍ដែលខ្លួនរស់នៅ
- កិច្ចសន្យាគោរពច្បាប់រដ្ឋ
- ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត
- រូបថតទំហំ (៤x៦) ចំនួន៣សន្លឹក។

ក្រសួងទេសចរណ៍អាចអនុញ្ញាតឱ្យមានអ្នកបកប្រែភាសាបំពេញភារកិច្ចជាមួយនឹងមគ្គុទ្ទេសក៍ទេសចរណ៍បាន ដើម្បីដោះស្រាយជាបណ្តោះអាសន្ននូវបញ្ហាមគ្គុទ្ទេសក៍ទេសចរណ៍ដែលពុំចេះភាសាភ្ញៀវ។ អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់បុគ្គលជាជនបរទេស ដែលធ្វើជាអ្នកបកប្រែបន្តផ្ទាល់មាត់នូវអ្វីដែលមគ្គុទ្ទេសក៍ កម្ពុជាកំពុងនិយាយ ទៅជាភាសាមួយផ្សេងទៀតជូនភ្ញៀវទេសចរ។

បុគ្គលដែលមានបំណងធ្វើជាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំបណ្ណអនុញ្ញាតនៅក្រសួងទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍រាជធានីខេត្ត ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានផ្សេងៗទៀត ដូចខាងក្រោម៖

- លិខិតឆ្លងដែន (ថតចម្លងតាមច្បាប់ដើម)
- លិខិតស្នើសុំរបស់ទីភ្នាក់ងារទេសចរណ៍ឬសមាគមទេសចរណ៍
- កិច្ចសន្យាគោរពច្បាប់រដ្ឋ
- វិញ្ញាបនបត្របញ្ជាក់ការសិក្សាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ដែលការបណ្ដុះបណ្ដាល ត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ (ថតចម្លងតាមច្បាប់ដើម)
- វិញ្ញាបនបត្រពិនិត្យសុខភាពនិងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានីខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលដោយមានការឯកភាពពីក្រសួងទេសចរណ៍
- ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត
- រូបថត (៤ស.ម x ៦ស.ម) ថតថ្មីចំនួន២សន្លឹក។

តម្លៃនៃការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ [46] ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍** | | | | |
| ១ | ថ្នាក់សហគមន៍ | ៥០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | ថ្នាក់ក្រោមជាតិ | ១០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣ | ថ្នាក់តំបន់ | ២៥០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤ | ថ្នាក់ជាតិ | ៣០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៥ | ថ្នាក់ពិសេស | ៣០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៦ | អ្នកបកប្រែបន្តភាសាពីមគ្គុទ្ទេសក៍ | ៤០០ ០០០ | ២៨ថ្ងៃ | ៦ខែ |

### ៣. ការផ្ដល់អាជ្ញាបណ្ណទេសចរណ៍លើសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ

#### ក. សម្រាប់អាជីវកម្មសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍

ម្ចាស់ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវរៀបចំពាក្យស្នើសុំអាជ្ញាបណ្ណមកកាន់ក្រសួងទេសចរណ៍ ដោយអនុលោមតាមបែបបទដែលបានកំណត់ និងភ្ជាប់មកនូវឯកសារចាំបាច់ដូចខាងក្រោម៖

[46] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

- វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែន
- លិខិតអនុញ្ញាតដាក់ទីតាំងធ្វើអាជីវកម្មចេញដោយអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ ឬជួសជុស ចេញដោយក្រសួង ឬមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់
- លិខិតបញ្ជាក់លើប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព និងអគ្គីភ័យ ចេញដោយក្រសួងមហាផ្ទៃ ឬស្នងការដ្ឋាននគរបាលខេត្ត ក្រុង
- លិខិតបញ្ជាក់លើអនាម័យចេញដោយក្រសួងសុខាភិបាល ឬ មន្ទីរសុខាភិបាល
- លិខិតយល់ព្រមជាលាយល័ក្ខអក្សររបស់ម្ចាស់ បើសិនជាអ្នកគ្រប់គ្រងមិនមែនជាម្ចាស់កម្មសិទ្ធិ
- សញ្ញាបត្រ ឬវិញ្ញាបនបត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ពីការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍។

ម្ចាស់ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វីត ឬសណ្ឋាគាររីសត បឹងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ និងផ្ទះភ្ញៀវ ចំណុះត្រឹម២០បន្ទប់ចុះ ត្រូវរៀបចំពាក្យស្នើសុំអាជ្ញាបណ្ណមកកាន់រដ្ឋបាលរាជធានីខេត្ត (អង្គភាពច្រកចេញចូលតែមួយ) ដោយអនុលោមតាមបែបបទដែលបានកំណត់ និងភ្ជាប់មកនូវឯកសារចាំបាច់ ដូចខាងក្រោមៈ

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬ មន្ទីរពាណិជ្ជកម្មរាជធានីខេត្ត (ថតចម្លង) ចំនួន១ច្បាប់
- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល (ផ្តល់ដោយក្រសួងឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធិ (ថតចម្លង) ចំនួន១ច្បាប់
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន១ច្បាប់
- បង្ហាញប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន១ច្បាប់
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែនសម្រាប់ជនបរទេស (ថតចម្លង) ចំនួន១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤ x ៦ ចំនួន៣សន្លឹក។

តម្លៃនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ [47] ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **សណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វ៊ីត ឬសណ្ឋាគាររីសត ឬប៊ីងហ្គាឡូ ឬម៉ូតែល ឬឡូដ៍** | | | | |
| ១ | ចំណុះត្រឹម ១០ បន្ទប់ | ៣០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | ចំណុះពី ១១ ដល់ ២០បន្ទប់ | ៤០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣ | ចំណុះពី ២១ ដល់ ៣០បន្ទប់ | ៨០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤ | ចំណុះពី ៣១ ដល់ ៦០បន្ទប់ | ១ ១០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៥ | ចំណុះពី ៦១ ដល់ ១០០បន្ទប់ | ១ ៣០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៦ | ចំណុះពី ១០១ ដល់ ១៥០បន្ទប់ | ២ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៧ | ចំណុះពី ១៥១ ដល់ ២០០បន្ទប់ | ២ ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៨ | ចំណុះពី ២០១ ដល់ ៣០០បន្ទប់ | ៣ ៣០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៩ | ចំណុះពី ៣០១បន្ទប់ ឡើងទៅ | ៤ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ១០ | ផ្ទះភ្ញៀវ (ក្នុងមួយបន្ទប់) | ១៥ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |

**ខ. សម្រាប់អាជីវកម្មភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍**

ការរៀបចំស្នើសុំអាជ្ញាបណ្ណភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍ ត្រូវធ្វើឡើងដោយម្ចាស់ឬអ្នកគ្រប់គ្រងអាជីវកម្ម និងដាក់ពាក្យស្នើនោះមកកាន់ក្រសួងទេសចរណ៍ ដោយអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួន៖

- លិខិតអនុញ្ញាតដាក់ទីតាំងធ្វើអាជីវកម្ម ចេញដោយអាជ្ញាធរដែនដីសម្រាប់សំណង់កែច្នៃ ឬជួសជុល។ ចំពោះលិខិតអនុញ្ញាតសាងសង់សំណង់ថ្មី សម្រាប់មុខសញ្ញាអាជីវកម្មភោជនីយដ្ឋាននិងអាហារដ្ឋានត្រូវចេញដោយក្រសួង ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- លិខិតបញ្ជាក់លើប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព និងអគ្គីភ័យ ចេញដោយក្រសួងមហាផ្ទៃ ឬ ស្នងការដ្ឋាននគរបាលខេត្ត ក្រុង។
- លិខិតបញ្ជាក់លើអនាម័យចេញដោយក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាល
- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន
- វិញ្ញាបនបត្រធានារ៉ាប់រង អំពីភារៈទទួលខុសត្រូវសាធារណៈ

[47] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

- លិខិតយល់ព្រមជាលាយលក្ខអក្សររបស់ម្ចាស់ បើសិនអ្នកគ្រប់គ្រងមិនមែនជាម្ចាស់កម្មសិទ្ធិ
- សញ្ញាបត្រ ឬវិញ្ញាបនបត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍។

ការរៀបចំស្នើសុំអាជ្ញាបណ្ណភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍ ដែលមានចំណុះត្រឹម១០០ នាក់/កៅអី ចុះក្រោម ត្រូវធ្វើឡើងដោយម្ចាស់ឬអ្នកគ្រប់គ្រងអាជីវកម្ម និងដាក់ពាក្យស្នើនោះមកកាន់រដ្ឋបាលរាជធានីខេត្ត (អង្គភាពច្រកចេញចូលតែមួយ) ដោយអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនៈ

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត (ថតចម្លង) ចំនួន១ច្បាប់
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន១ច្បាប់
- បង្ហាញប្រព័ន្ធបង្គារ និងពន្លត់អគ្គីភ័យ
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន១ច្បាប់
- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល (ផ្តល់ដោយក្រសួងឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធិ (ថតចម្លង) ចំនួន១ច្បាប់
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែនសម្រាប់ជនបរទេស (ថតចម្លង) ចំនួន១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤ x ៦ ចំនួន៣សន្លឹក។

តម្លៃនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍ [48] ត្រូវបានកំណត់ដូចខាងក្រោមៈ

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាននិងអាហារដ្ឋាន** | | | | |
| ១ | ចំណុះត្រឹម ៥០នាក់ | ៣០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | ចំណុះពី ៥១ ដល់ ១០០នាក់ | ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣ | ចំណុះពី ១០១ ដល់ ២០០នាក់ | ៨០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤ | ចំណុះពី ២០១ ដល់ ៣០០នាក់ | ១ ៣០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៥ | ចំណុះពី ៣០១នាក់ឡើងទៅ | ១ ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |

[48] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

## ៤. ការផ្ដល់អាជ្ញាបណ្ណទេសចរណ៍លើសេវាកម្សាន្តនិងកីឡាទេសចរណ៍

### ក. សម្រាប់អាជីវកម្មបៀរហ្គាឌិន

ទីតាំងអាជីវកម្មបៀរហ្គាឌិន ត្រូវបានអនុញ្ញាតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកំណត់ទីតាំងអាជីវកម្មបៀរហ្គាឌិន ត្រូវស្ថិតនៅទីតាំងសមរម្យ និងសមស្របតាមប្រភេទអាជីវកម្មនីមួយៗផ្អែកលើលក្ខខណ្ឌដូចខាងក្រោមៈ

- មានចម្ងាយយ៉ាងតិច ២០០ ម៉ែត្រពីបរិវេណក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន វត្តអារាម ប្រាង្គប្រាសាទ ទីតាំងបតិកភណ្ឌវប្បធម៌
- ធានារក្សាសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឱ្យបានល្អ។
- មិនបង្កការរំខានដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន វត្តអារាម និងការរស់នៅរបស់ប្រជាពលរដ្ឋ

អាជីវកម្មបៀរហ្គាឌិន ត្រូវកំណត់ជាគោលការណ៍នូវពេលវេលាដំណើរការអាជីវកម្មចាប់ពីម៉ោង ១៨:០០នាទី ដល់ម៉ោង២៤:០០នាទី។ ការកំណត់ពេលវេលាដំណើរការអាជីវកម្មហួសពីម៉ោង២៤:០០នាទី ត្រូវបានអនុញ្ញាតចំពោះតែតំបន់អភិវឌ្ឍន៍ និងគោលដៅទេសចរណ៍សំខាន់ៗ និងត្រូវកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការគ្រប់គ្រងនិងការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវបានក្រសួងទេសចរណ៍ធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងទៅឱ្យរដ្ឋបាលរាជធានី ខេត្ត [49] ។ ការធ្វើប្រតិភូកម្មនេះ មិនអនុវត្តចំពោះមណ្ឌលកម្សាន្តដែលមានលក្ខណៈស្តង់ដាឬស្ថិតនៅក្នុងសណ្ឋាគារមានចំណាត់ថ្នាក់ចាប់ពីផ្កាយបួនឡើងទៅ និងមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

ដូច្នេះប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន នៅរដ្ឋបាលរាជធានីខេត្ត (អង្គភាពច្រកចេញចូលតែមួយ) និងភ្ជាប់មកនូវឯកសារសំខាន់ៗមួយចំនួន ដូចខាងក្រោមៈ

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្ដល់ដោយក្រសួងពាណិជ្ជកម្ម ឬ មន្ទីរពាណិជ្ជកម្មរាជធានីខេត្ត (ថតចម្លង) ចំនួន១ច្បាប់
- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល (ផ្ដល់ដោយក្រសួងឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធិ (ថតចម្លង) ចំនួន១ច្បាប់

[49] តាមរយៈប្រកាសលេខ០៦៩ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ស្ដីពីការធ្វើប្រតិភូកម្មមុខងារ "គ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន១ច្បាប់
- បង្ហាញប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន១ច្បាប់
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែនសម្រាប់ជនបរទេស (ថតចម្លង) ចំនួន១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤ x ៦ ចំនួន៣សន្លឹក។

តម្លៃនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មបៀរហ្គាឌិន [50] ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់បៀរហ្គាឌិន** | | | | |
| ១ | ចំណុះត្រឹម ៥០នាក់ | ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | ចំណុះពី ៥១ ដល់ ១០០នាក់ | ៨០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣ | ចំណុះពី ១០១ ដល់ ២០០នាក់ | ១ ១០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤ | ចំណុះពី ២០១ ដល់ ៣០០នាក់ | ១ ៣០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៥ | ចំណុះពី ៣០១នាក់ឡើងទៅ | ២ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |

**ខ. សម្រាប់អាជីវកម្មខារ៉ាអូខេ**

ទីតាំងអាជីវកម្មខារ៉ាអូខេ ត្រូវបានអនុញ្ញាតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកំណត់ទីតាំងអាជីវកម្មខារ៉ាអូខេ ត្រូវស្ថិតនៅទីតាំងសមរម្យ និងសមស្របតាមប្រភេទអាជីវកម្មនីមួយៗផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មានចម្ងាយយ៉ាងតិច ២០០ ម៉ែត្រពីបរិវេណក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន វត្តអារាម ប្រាង្គប្រាសាទ ទីតាំងបតិកភណ្ឌវប្បធម៌
- មិនបង្កការរំខានដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន វត្តអារាម និងការរស់នៅរបស់ប្រជាពលរដ្ឋ
- ធានារក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឱ្យបានល្អ។

អាជីវកម្មខារ៉ាអូខេ ត្រូវកំណត់ជាគោលការណ៍នូវពេលវេលាដំណើរការអាជីវកម្មចាប់ពីម៉ោង ១០:០០ នាទីព្រឹក ដល់ម៉ោង ២៤:០០នាទី។ ការកំណត់ពេលវេលាដំណើរការអាជីវកម្មហួសពីម៉ោង២៤:០០នាទី ត្រូវបានអនុញ្ញាតចំពោះតែតំបន់អភិវឌ្ឍន៍ និងគោលដៅទេសចរណ៍សំខាន់ៗ និងត្រូវកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

[50] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

ការគ្រប់គ្រងនិងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវបានក្រសួងទេសចរណ៍ធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងទៅឱ្យរដ្ឋបាលរាជធានី ខេត្ត [51] ។ ការធ្វើប្រតិភូកម្មនេះ មិនអនុវត្តចំពោះមណ្ឌលកម្សាន្តដែលមានលក្ខណៈស្តង់ដាឬស្ថិតនៅក្នុងសណ្ឋាគារមានចំណាត់ថ្នាក់ចាប់ពីផ្កាយបួនឡើងទៅ និងមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

ដូច្នេះប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេ នៅរដ្ឋបាលរាជធានីខេត្ត (អង្គភាពច្រកចេញចូលតែមួយ) និងភ្ជាប់មកនូវឯកសារសំខាន់ៗមួយចំនួន ដូចខាងក្រោមៈ

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬ មន្ទីរពាណិជ្ជកម្មរាជធានីខេត្ត (ថតចម្លង) ចំនួន១ច្បាប់
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន១ច្បាប់
- បង្ហាញប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ
- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល (ផ្តល់ដោយក្រសួងឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធិ (ថតចម្លង) ចំនួន១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន១ច្បាប់
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែនសម្រាប់ជនបរទេស (ថតចម្លង) ចំនួន១ច្បាប់
- លិខិតបញ្ជាក់ស្តង់ដាចំណាត់ថ្នាក់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ ចំនួន១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤ x ៦ ចំនួន៣សន្លឹក។

តម្លៃនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មខារ៉ាអូខេ [52] ត្រូវបានកំណត់ដូចខាងក្រោមៈ

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់ខារ៉ាអូខេ** | | | | |
| ១ | ចំណុះត្រឹម ៥បន្ទប់ | ៤០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | ចំណុះពី ៦ ដល់ ១០បន្ទប់ | ៨០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣ | ចំណុះពី ១១ ដល់ ២០បន្ទប់ | ១ ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤ | ចំណុះពី ២១ ដល់ ៤០បន្ទប់ | ៣ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៥ | ចំណុះពី ៤១នាក់ឡើងទៅ | ៤ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |

[51] តាមរយៈប្រកាសលេខ០៦៩ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មមុខងារ "គ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

[52] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

**គ. សម្រាប់អាជីវកម្មរង្គសាលនិងឌីស្កូតែក**

ទីតាំងអាជីវកម្មរង្គសាលនិងឌីស្កូតែក ត្រូវបានអនុញ្ញាតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកំណត់ទីតាំងអាជីវកម្មបៀរហ្គាឌិន ត្រូវស្ថិតនៅទីតាំងសមរម្យ និងសមស្របតាមប្រភេទអាជីវកម្មនីមួយៗផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មានចម្ងាយយ៉ាងតិច ២០០ ម៉ែត្រពីបរិវេណក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន វត្តអារាម ប្រាង្គប្រាសាទ ទីតាំងបតិកភណ្ឌវប្បធម៌
- មិនបង្កការរំខានដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន វត្តអារាម និងការរស់នៅរបស់ប្រជាពលរដ្ឋ
- ធានារក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឱ្យបានល្អ។

អាជីវកម្មរង្គសាលនិងឌីស្កូតែក ត្រូវកំណត់ជាគោលការណ៍នូវពេលវេលាដំណើរការអាជីវកម្មចាប់ពីម៉ោង ១៨:០០នាទី ដល់ម៉ោង២៤:០០នាទី។ ការកំណត់ពេលវេលាដំណើរការអាជីវកម្មហួសពីម៉ោង២៤:០០នាទី ត្រូវបានអនុញ្ញាតចំពោះតែតំបន់អភិវឌ្ឍន៍ និងគោលដៅទេសចរណ៍សំខាន់ៗ និងត្រូវកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការគ្រប់គ្រងនិងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវបានក្រសួងទេសចរណ៍ធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងទៅឱ្យរដ្ឋបាលរាជធានី ខេត្ត[53]។ ការធ្វើប្រតិភូកម្មនេះមិនអនុវត្តចំពោះមណ្ឌលកម្សាន្តដែលមានលក្ខណៈស្តង់ដាឬស្ថិតនៅក្នុងសណ្ឋាគារមានចំណាត់ថ្នាក់ចាប់ពីផ្កាយបួនឡើងទៅ និងមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

ដូច្នេះប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មរង្គសាល និងឌីស្កូតែកនៅរដ្ឋបាលរាជធានីខេត្ត (អង្គភាពច្រកចេញចូលតែមួយ) និងភ្ជាប់មកនូវឯកសារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត (ថតចម្លង) ចំនួន១ច្បាប់
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន១ច្បាប់

[53] តាមរយៈប្រកាសលេខ០៦៩ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មមុខងារ "គ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល (ផ្តល់ដោយក្រសួងឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធិ (ថតចម្លង) ចំនួន១ច្បាប់
- លិខិតបញ្ជាក់ស្តង់ដាចំណាត់ថ្នាក់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ ចំនួន១ច្បាប់
- បង្ហាញប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន១ច្បាប់
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែនសម្រាប់ជនបរទេស (ថតចម្លង) ចំនួន១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤ x ៦ ចំនួន៣សន្លឹក។

តម្លៃនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរង្គសាលនិងឌីស្កូតែក[54] ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់រង្គសាលឌីស្កូតែក ឬរង្គសាល-ឌីស្កូតែក** | | | | |
| ១ | ចំណុះត្រឹម ៥០នាក់ | ៨០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | ចំណុះពី ៥១ ដល់ ១០០នាក់ | ១ ២០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣ | ចំណុះពី ១០១ ដល់ ១៥០នាក់ | ២ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤ | ចំណុះពី ១៥១ ដល់ ២០០នាក់ | ៤ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៥ | ចំណុះពី ២០១នាក់ឡើងទៅ | ៦ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |

### ឃ. សម្រាប់អាជីវកម្មកីឡាទេសចរណ៍

កីឡាទេសចរណ៍មានច្រើនប្រភេទ និងច្រើនបែបទៅតាមលក្ខណៈវិនិច្ឆ័យរបស់អ្នកជំនាញ។ ដោយសារ សកម្មភាពកីឡាទេសចរណ៍នៅកម្ពុជាមិនទាន់មានសន្ទុះខ្លាំងក្លានៅឡើយ ក្រសួងទេសចរណ៍ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ក្នុងការគ្រប់គ្រងនិងផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មកីឡាទេសចរណ៍នៅឡើយទេ។ មានកីឡាទេសចរណ៍មួយប្រភេទដែលក្រសួងទេសចរណ៍បានចេញប្រកាសផ្តល់អាជ្ញាបណ្ណឱ្យប្រកបអាជីវកម្ម នោះគឺ កីឡាទេសចរណ៍ម៉ូតូទឹកនិងអូប័រជិះលេងកម្សាន្ត។

[54] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

ដើម្បីប្រកបអាជីវកម្មនេះបាន ប្រតិបត្តិករទេសចរណ៍ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ នៅក្រសួងទេសចរណ៍ឬតាមរយៈមន្ទីរទេសចរណ៍រាជធានីខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធអនឡាញ ទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទឯកសារ និងលក្ខខណ្ឌមួយចំនួន ដូចខាងក្រោម៖

- វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ដើម្បីប្រកបអាជីវកម្ម និងកិច្ចសន្យា
- លិខិតអនុញ្ញាតទីតាំងអាជីវកម្ម (ប្រកបអាជីវកម្មក្នុងទីតាំងដែលអាជ្ញាធរមូលដ្ឋានបានកំណត់)
- វិញ្ញាបនបត្រជំនាញរបស់អ្នកគ្រប់គ្រងឬឆ្នាំដែលទទួលស្គាល់ដោយសហព័ន្ធកីឡាម៉ូតូទឹកកម្ពុជា
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស)
- រូបថតបច្ចុប្បន្នភាពរបស់អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ (៤ x ៦ស.ម) ចំនួន៣សន្លឹក។

តម្លៃនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មកីឡាទេសចរណ៍ [55] ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់កីឡាទេសចរណ៍** | | | | |
| ១. កីឡាស្នូកឃ័រ | | | | |
| | ចំណុះត្រឹម ៥តុ | ១៥០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| | ចំណុះពី ៦តុឡើងទៅ | ៤០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២. ម៉ាស៊ីនហ្គេម | | | | |
| | ចំណុះត្រឹម ១០គ្រឿង | ៣០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| | ចំណុះពី ១១គ្រឿងឡើងទៅ | ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣. ក្លឹបកម្សាន្តប៊ូលីង | | | | |
| | ចំណុះត្រឹម ១០ខ្សែ | ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| | ចំណុះពី ១១ខ្សែឡើងទៅ | ១ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤. ក្លឹបហ្វឹកហាត់វាយកូនគោល | | | | |
| | ចំណុះត្រឹម ១០កន្លែង | ៨០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| | ចំណុះពី ១១ ដល់៥០កន្លែង | ២ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| | ចំណុះពី ៥១កន្លែងឡើងទៅ | ៤ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |

[55] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

| ៥. ក្លឹបកីឡាវាយកូនគោល | | | | |
|---|---|---|---|---|
| | ៩ រន្ធ | ៤ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| | ចំណុះពី ១៨ រន្ធឡើងទៅ | ៨ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៦ | កីឡាប្រណាំងឡាន | ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៧ | កីឡាបាញ់ព្រួញ និងកាំភ្លើងគ្រាប់មិនពិត | ១ ២០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៨ | កីឡាសៀក | ៥២០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៩ | កីឡាជិះកង់រង្វង់ | ២៦០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ១០ | កីឡាជិះដំរី | ២៦០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ១១ | កីឡាជិះសេះ | ៥០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ១២ | រថយន្តឬរថភ្លើងអគ្គិសនី | ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ១៣ | កីឡាស្គីលើទឹក កីឡាក្តារបណ្តែតទូកបណ្តែត កីឡាហែលទឹក ឬកីឡាមុជទឹក | ៦០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ១៤ | បាល់ឡុងបង្ហោះ រថយន្តខ្សែកាប | ៨០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |
| ១៥ | យន្តហោះឬឧទ្ធម្ភាចក្រជិះកម្សាន្តក្នុងមួយគ្រឿង | ២ ០០០ ០០០ | ២៨ថ្ងៃ | ១ ឆ្នាំ |

### ៥. ការផ្តល់អាជ្ញាបណ្ណទេសចរណ៍លើសេវាកម្មរមណីយដ្ឋានទេសចរណ៍

ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ឱ្យប្រកបអាជីវកម្មរមណីយដ្ឋាន ការផ្អាក ការដកហូត បិទអាជីវកម្ម គឺជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍។ ការរៀបចំសុំអាជ្ញាបណ្ណទេសចរណ៍រមណីយដ្ឋានបែបវប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ និងឆ្នេរ និងរមណីយដ្ឋានកែច្នៃ ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រង ដោយអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនៈ

- លិខិតអនុញ្ញាតដាក់ទីតាំងធ្វើអាជីវកម្មចេញដោយអាជ្ញាធរដែនដី
- លិខិតបញ្ជាក់ពីការយល់ព្រមរបស់ ក្រសួងបរិស្ថាន (ចំពោះរមណីយដ្ឋានធម្មជាតិ) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (ចំពោះរមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ) លិខិតអនុញ្ញាតសាងសង់ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ចំពោះរមណីយដ្ឋានកែច្នៃ)
- របាយការណ៍សេដ្ឋកិច្ចបច្ចេកទេសនៃការងារអាជីវកម្មនិងគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍
- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន

- សញ្ញាបត្រ ឬវិញ្ញាបនបត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ការសិក្សាលើមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍
- វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- វិញ្ញាបនបត្រធានារ៉ាប់រងអំពីភារៈទទួលខុសត្រូវសាធារណៈ
- លិខិតបញ្ជាក់លើប្រព័ន្ធការពារសុខភាព សុវត្ថិភាព និងអគ្គីភ័យ ចេញដោយក្រសួងមហាផ្ទៃ ឬស្នងការនគរបាលខេត្ត ក្រុង
- លិខិតយល់ព្រមជាលាយល័ក្ខអក្សររបស់ម្ចាស់អាជីវកម្ម។

តម្លៃនៃការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ [56] ត្រូវបានកំណត់ដូចខាងក្រោមៈ

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **អាជ្ញាបណ្ណទេសចរណ៍សម្រាប់រមណីយដ្ឋានទេសចរណ៍** | | | | |
| ១ | រមណីយដ្ឋានថ្នាក់ជាតិ | ១ 000 000 | ២៨ថ្ងៃ | ១ ឆ្នាំ |
| ២ | រមណីយដ្ឋានថ្នាក់ខេត្ត | ៥ 000 000 | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៣ | រមណីយដ្ឋានថ្នាក់ស្រុក | ៣ 000 000 | ២៨ថ្ងៃ | ១ ឆ្នាំ |
| ៤ | រមណីយដ្ឋានថ្នាក់កែច្នៃ | ២ 000 000 | ២៨ថ្ងៃ | ១ ឆ្នាំ |

## ៦. ពិន័យសម្រាប់អាជីវកម្មគ្មានអាជ្ញាបណ្ណទេសចរណ៍

ដើម្បីធានាបាននូវសុច្ចរិតភាព និងភាពស្របច្បាប់នៃរាល់អាជីវកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍ ដែលមានការសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ បាននិងកំពុងខិតខំធ្វើយ៉ាងណាឱ្យដំណើរការនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មទេសចរណ៍ មានភាពងាយស្រួល និងចំណេញពេលវេលាដល់ប្រតិបត្តិករទេសចរណ៍។ ក្នុងន័យនេះ ដើម្បីទប់ស្កាត់នូវរូបភាពអសកម្មមួយចំនួន ដែលកើតចេញពីការប្រកបអាជីវកម្មគ្មានអាជ្ញាបណ្ណរបស់ប្រតិបត្តិករទេសចរណ៍ ក៏ដូចជាការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទេសចរណ៍ ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញប្រកាសរួមលេខ២៦២ សហវ.ប្រក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ ដែលត្រូវបាន ចាប់ផ្ដើមអនុវត្តពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧។ យោងទៅតាមខ្លឹមសារនៃប្រកាសរួមនេះ ចំពោះអាជីវកម្មទេសចរណ៍ ដែលគ្មានអាជ្ញាបណ្ណ ឬអាជ្ញាបណ្ណហួសសុពលភាព ត្រូវបានពិន័យអន្តរការណ៍ជាប្រាក់ ដូចតទៅៈ

[56] ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

| ល.រ | បរិយាយ | ទឹកប្រាក់ពិន័យជាអន្តរការណ៍ (រៀល) | |
|---|---|---|---|
| | | គ្មានអាជ្ញាបណ្ណ | អាជ្ញាបណ្ណហួសសុពលភាព |
| ១ | អាជីវកម្មទីភ្នាក់ងារទេសចរណ៍ (ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍) | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ២ | អាជីវកម្មសណ្ឋាគារនិងសេវាកម្មស្នាក់នៅ | | |
| ២.១ | សណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វីត ឬសណ្ឋាគាររីសត ឬបឹងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ | | |
| | ចំណុះត្រឹម ១០០ បន្ទប់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ១០១ ដល់ ១៥០ បន្ទប់ | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ១៥១ ដល់ ២០០ បន្ទប់ | ៣ ៩០០ ០០០ | ២ ៦០០ ០០០ |
| | ចំណុះពី ២០១ ដល់ ៣០០ បន្ទប់ | ៤ ៩៥០ ០០០ | ៣ ៣០០ ០០០ |
| | ចំណុះពី ៣០១ ឡើងទៅ | ៦ ០០០ ០០០ | ៦ ០០០ ០០០ |
| ២.២ | ផ្ទះភ្ញៀវ | | |
| | ចំណុះត្រឹម ៩០ បន្ទប់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ៩១ ដល់ ១០០ បន្ទប់ | ២ ២៥០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ១០១ ឡើងទៅ | ៤ ៥០០ ០០០ | ៣ ០០០ ០០០ |
| ៣ | អាជីវកម្មភោជនីយដ្ឋាន អាហារដ្ឋាន | | |
| | ចំណុះត្រឹម ៣០០ នាក់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ៣០១ នាក់ឡើងទៅ | ២ ៤០០ ០០០ | ២ ០០០ ០០០ |
| ៤ | អាជីវកម្មបៀរហ្គាឌិន ខារ៉ាអូខេ និងរង្គសាលឌីស្កូតែក | | |
| ៤.១ | អាជីវកម្មបៀរហ្គាឌិន | | |
| | ចំណុះត្រឹម ៣០០ នាក់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ៣០១ នាក់ឡើងទៅ | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| ៤.២ | អាជីវកម្មខារ៉ាអូខេ | | |
| | ចំណុះត្រឹម ១០ បន្ទប់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ១១ ដល់ ២០ បន្ទប់ | ២ ៤០០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ២១ ដល់ ៤០ បន្ទប់ | ៤ ៥០០ ០០០ | ៣ ០០០ ០០០ |
| | ចំណុះពី ៤១ បន្ទប់ឡើងទៅ | ៦ ០០០ ០០០ | ៤ ០០០ ០០០ |
| ៤.៣ | អាជីវកម្មរង្គសាល ឌីស្កូតែក | | |
| | ចំណុះត្រឹម ១០០ នាក់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ១០១ ដល់ ១៥០ នាក់ | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| | ចំណុះពី ១៥១ ដល់ ២០០ នាក់ | ៦ ០០០ ០០០ | ៤ ០០០ ០០០ |

| | | | |
|---|---|---|---|
| | ចំណុះពី ២០១ នាក់ឡើងទៅ | ៩ 000 000 | ៦ 000 000 |
| ៥ | អាជីវកម្មដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹកនិងផ្លូវគោក | ២ 000 000 | ២ 000 000 |
| ៦ | អាជីវកម្មកីឡាទេសចរណ៍ | | |
| ៦.១ | កីឡាស្នូកឃ័រ ម៉ាស៊ីនហ្គេម ក្លឹបកម្សាន្តប៊ូលីង | ២ 000 000 | ២ 000 000 |
| ៦.២ | ក្លឹបហ្វឹកហាត់វាយកូនគោល | | |
| | ចំណុះត្រឹម ១០ កន្លែង | ២ 000 000 | ២ 000 000 |
| | ចំណុះពី ១០ ដល់ ៥០ កន្លែង | ៣ 000 000 | ២ 000 000 |
| | ចំណុះពី ៥១ កន្លែងឡើងទៅ | ៦ 000 000 | ៤ 000 000 |
| ៦.៣ | ក្លឹបកីឡាវាយកូនគោល | | |
| | ចំណុះត្រឹម ៩ រន្ធ | ៦ 000 000 | ៤ 000 000 |
| | ចំណុះពី ១៨ រន្ធឡើងទៅ | ១២ 000 000 | ៨ 000 000 |
| ៦.៤ | កីឡាប្រណាំងឡាន កីឡាបាញ់ព្រួញនិងកាំភ្លើងគ្រាប់មិនពិត កីឡាសៀក កីឡាជិះកង់រង្វង់ កីឡាជិះដំរី រថយន្តឬរថយន្តអគ្គិសនី កីឡាស្គីលើទឹក ក្តារបណ្តែត ហែលទឹក មុជទឹក បាល់ទះបង្ហោះ រថយន្តខ្សែកាប | ២ 000 000 | ២ 000 000 |
| ៦.៥ | យន្តហោះ ឬឧទ្ធម្ភាចក្រជិះកម្សាន្ត | ៣ 000 000 | ២ 000 000 |
| ៧ | អាជីវកម្មរមណីយដ្ឋានទេសចរណ៍ | | |
| | រមណីយដ្ឋានថ្នាក់ជាតិ | ១៥ 000 000 | ១០ 000 000 |
| | រមណីយដ្ឋានថ្នាក់ខេត្ត | ៧ ៥00 000 | ៥ 000 000 |
| | រមណីយដ្ឋានថ្នាក់ស្រុក | ៤ ៥00 000 | ៣ 000 000 |
| | រមណីយដ្ឋានថ្នាក់កែច្នៃ | ៣ 000 000 | ២ 000 000 |
| ៨ | អាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ | | |
| | ថ្នាក់សហគមន៍ | ២ 000 000 | ២ 000 000 |
| | ថ្នាក់ក្រោមជាតិ | ២ 000 000 | ២ 000 000 |
| | ថ្នាក់តំបន់ | ២ 000 000 | ២ 000 000 |
| | ថ្នាក់ជាតិ | ២ 000 000 | ២ 000 000 |
| | ថ្នាក់ពិសេស | ២ 000 000 | ២ 000 000 |
| ៩ | អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ | ២ 000 000 | ២ 000 000 |

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយផ្អែកទៅលើការសិក្សាស្រាវជ្រាវ និងវែកញែកខាងលើរួចមក យើងអាចសន្និដ្ឋានបានថា អាជីវកម្មក្នុងវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាពិតជាមានសារៈសំខាន់ណាស់សម្រាប់សង្គមជាតិយើងទាំងមូល។ វាបានរួមចំណែកក្នុងគ្រប់វិស័យ ជំរុញកិច្ចអភិវឌ្ឍជាតិមានសន្ទុះខ្លាំងឡើងៗ និងសម្រេចបាននូវសេដ្ឋកិច្ចជាតិមួយមានលំនឹងនិងភាពរីកចម្រើន។ តួយ៉ាង វាបានផ្តល់នូវមុខរបរចិញ្ចឹមជីវិតដល់ប្រជាពលរដ្ឋរាប់សិបម៉ឺននាក់ឱ្យមានការងារធ្វើនិងចូលរួមកាត់បន្ថយអត្រានៃភាពក្រីក្របានមួយកម្រិត ទាក់ទាញភ្ញៀវទេសចរបានច្រើនឡើងៗនៅពេល អាជីវកម្មទេសចរណ៍ទាំងនោះមានគុណភាពល្អប្រសើរ ទាក់ទាញនូវការវិនិយោគជាច្រើនចូលមកក្នុងប្រទេសកម្ពុជា និងអត្ថប្រយោជន៍ជាច្រើនផ្សេងទៀតដែលមានគុណតម្លៃសម្រាប់សេដ្ឋកិច្ចជាតិកម្ពុជា។

ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងទេសចរណ៍បាននិងកំពុងខិតខំព្យាយាមធ្វើយ៉ាងណាឱ្យការគ្រប់គ្រងមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងនោះប្រកបដោយគុណភាព ប្រសិទ្ធភាព និរន្តរភាព និងភាពដែលអាចជឿជាក់បាន។ ជាក់ស្តែង ក្រសួងទេសចរណ៍បាននិងកំពុងសហការជាមួយក្រសួង ស្ថាប័ន អង្គភាព ឬផ្នែកឯកជនដែលពាក់ព័ន្ធ រៀបចំជាលិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ និងវិធីសាស្ត្រនានា សម្រាប់ជាមធ្យោបាយនិងយន្តការក្នុងការគ្រប់គ្រងអាជីវកម្មទេសចរណ៍ទាំងនោះ។ ក្នុងការគ្រប់គ្រងអាជីវកម្មទេសចរណ៍ ក្រសួងទេសចរណ៍បាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តជាច្រើន ដែលពាក់ព័ន្ធនឹងយន្តការនៃការគ្រប់គ្រង នីតិវិធីនៃស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មទេសចរណ៍ ការពិន័យសម្រាប់ជនល្មើសនឹងច្បាប់ទេសចរណ៍ និងការធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។ល។ ទាក់ទងនឹងការគ្រប់គ្រងនេះផងដែរ ក្រសួងទេសចរណ៍បានរៀបចំយន្តការរបស់ខ្លួនពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ ដែលមានអង្គភាពក្រោមឱវាទក្រសួងជាអង្គភាពជំនាញ ដូចជា អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ និងអគ្គាធិការដ្ឋាន ដែលក្នុងនោះមាននាយកដ្ឋាននិងការិយាល័យក្រោមឱវាទជាច្រើនចូលរួមជំរុញ និងពង្រឹងគុណភាពនៃការគ្រប់គ្រងអាជីវកម្មទាំងនោះ។ លើសពីនេះ ដើម្បីឱ្យការផ្តល់សេវារបស់ខ្លួននៅកៀកនឹងប្រជាពលរដ្ឋ ដែលជាប្រតិបត្តិករទេសចរណ៍ ក្រសួងទេសចរណ៍ក៏បានធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានដូចជា រដ្ឋបាលរាជធានី ខេត្ត (តាមរយៈអង្គភាពច្រកចេញចូលតែមួយ) រដ្ឋបាលក្រុង ស្រុក ខណ្ឌ (តាមរយៈការិយាល័យច្រកចេញចូលតែមួយ) និងមន្ទីរទេសចរណ៍ទាំង២៥ រាជធានី ខេត្ត ជាដើម។

ក្រៅពីនេះ ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ប្រជាពលរដ្ឋសម្រាប់ប្រកបអាជីវកម្មទេសចរណ៍ ក៏ជាវិធីសាស្ត្រដ៏ចម្បងមួយក្នុងការគ្រប់គ្រងនិងអភិវឌ្ឍអាជីវកម្មទេសចរណ៍ផងដែរ។ វាបានរួមចំណែកពង្រឹងគុណភាព

នៃអាជីវកម្មទាំងនោះ ដូចជា បដិសណ្ឋារកិច្ច សេវាកម្ម សុវត្ថិភាពអគ្គីភ័យ គុណភាពចំណីអាហារ គុណភាពបរិស្ថាន ព្រមទាំងចំណេះជំនាញរបស់ម្ចាស់ឬអ្នកគ្រប់គ្រង ក្នុងគោលបំណងធានាឱ្យបាននូវការផ្តល់សេវាដ៏មានគុណភាពល្អឥតខ្ចោះជូនភ្ញៀវទេសចរទាំងជាតិនិងអន្តរជាតិ។ ការផ្តល់អាជ្ញាបណ្ណនេះទៀត ក៏បានបង្ហាញអំពីស្មារតីនៃការគោរពច្បាប់និងបទប្បញ្ញត្តិនានារបស់ប្រតិបត្តិករទេសចរណ៍ និងមន្ត្រីអនុវត្តន៍ច្បាប់ ទាក់ទងនឹងការប្រកបអាជីវកម្មដោយស្របច្បាប់ដែលបានកំណត់ ការពារបាននូវកម្មសិទ្ធិបញ្ញារបស់ម្ចាស់ដើម (ម៉ាកនិងពាណិជ្ជនាម) ព្រមទាំងបានបំពេញកាតព្វកិច្ចជាពលរដ្ឋ (តាមរយៈការបង់ពន្ធនិងបង់កម្រៃអាជ្ញាបណ្ណ) ដែលទាំងអស់នេះបញ្ជាក់អំពីកម្រិតនៃការយល់ដឹងក្នុងការអនុវត្តច្បាប់របស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា។

ម៉្យាងវិញទៀត ការផ្តល់អាជ្ញាបណ្ណក៏បានរកចំណូលចូលជាតិគួរឱ្យកត់សម្គាល់ ក្នុងរង្វង់ជិត២ពាន់លានរៀលក្នុងឆ្នាំ២០១៩ ដែលចំណូលបានជួយយ៉ាងច្រើនដល់សេដ្ឋកិច្ចជាតិនិងការអភិវឌ្ឍប្រទេសជាតិរបស់រាជរដ្ឋាភិបាល។ កម្រៃជាតិដែលបានមកពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍នេះ ក៏បានបញ្ជាក់អំពីកំណើននៃអាជីវកម្មទេសចរណ៍នាពេលបច្ចុប្បន្ន ដោយសារកត្តាសន្តិសុខជាតិ សុវត្ថិភាពក្នុងការសម្រាកលម្ហែ និងភាពមានលំនឹងនៃចរន្តសេដ្ឋកិច្ចជាតិ ។ល។

រួមមក ដើម្បីសម្រេចបាននូវវិស័យទេសចរណ៍ប្រកបដោយគុណភាព គេត្រូវធ្វើការឱ្យបានម៉ត់ចត់ទៅលើការរៀបចំយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងយន្តការឱ្យបានរឹងមាំ ក្នុងការគ្រប់គ្រង អភិវឌ្ឍ និងធ្វើឱ្យរីកចម្រើនឡើងនៃអាជីវកម្មលើសេវាកម្មទេសចរណ៍។ បើគុណភាពនៃអាជីវកម្មទេសចរណ៍មានការថយចុះ វិស័យទេសចរណ៍ទាំងមូលនឹងរងផលប៉ះពាល់អវិជ្ជមានខ្លាំង តែផ្ទុយមកវិញ ប្រសិនបើអាជីវកម្មទេសចរណ៍ក្នុងប្រទេសកម្ពុជាយើងមានគុណភាពល្អប្រសើរ នោះវិស័យទេសចរណ៍ក៏ដូចជាសង្គមជាតិទាំងមូលនឹងទទួលបាននូវឥទ្ធិពលវិជ្ជមាននិងភាពរីកចម្រើន។

# វាយតម្លៃ
# និងអនុសាសន៍

# វាយតម្លៃនិងអនុសាសន៍

ឆ្លងតាមការសិក្សានិងពិនិត្យយ៉ាងយកចិត្តទុកដាក់លើខ្លឹមសារនៃប្រធានបទខាងលើរួចមក យើងខ្ញុំយល់ឃើញថា ការគ្រប់គ្រងអាជីវកម្មទេសចរណ៍នៅកម្ពុជានាពេលបច្ចុប្បន្នមានភាពប្រសើរ ដែលអាចទទួលយកបាន។ រាល់នីតិវិធីនៃការគ្រប់គ្រង ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ក្រសួងទេសចរណ៍បានខិតខំយកចិត្តទុកដាក់ក្នុងការធ្វើបច្ចុប្បន្នកម្ម បង្កើតថ្មី និងអភិវឌ្ឍ ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការនៃសង្គមពិសេសសង្គមនាយុគ្គសម័យទំនើបនេះ។ ក្រសួងទេសចរណ៍បានដាក់ឱ្យដំណើរការជាបណ្តើរៗនូវប្រព័ន្ធចុះឈ្មោះសុំអាជ្ញាបណ្ណអាជីវកម្មទេសចរណ៍តាមរយៈ Online ដល់ប្រជាពលរដ្ឋដែលមានបំណងប្រកបអាជីវកម្មទេសចរណ៍។ ក្នុងកិច្ចការងាររៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងអាជីវកម្មទេសចរណ៍ ក្រសួងទេសចរណ៍បានដាក់ចេញនូវបទប្បញ្ញត្តិជាច្រើនពាក់ព័ន្ធនឹងវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ចំណាត់ថ្នាក់សណ្ឋាគារ ស្តង់ដារមណីយដ្ឋាន ពិសេសបទប្បញ្ញត្តិទាក់ទងនឹងដំណើរការនៃមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងឡាយដែលមានក្នុងប្រទេសកម្ពុជា។ នេះបង្ហាញឱ្យឃើញថា ការគ្រប់គ្រងទៅលើអាជីវកម្មទេសចរណ៍ទាំងនោះមានគុណភាព ប្រសិទ្ធភាព និងភាពជឿទុកចិត្តបាន ដោយសារយើងមានច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងនេះ ច្បាស់លាស់និងសំបូរបែប។

ថ្វីត្បិតតែ យើងសង្កេតឃើញថាការគ្រប់គ្រងអាជីវកម្មទេសចរណ៍មានភាពល្អប្រសើរហើយនោះ ក៏មិនមែនមានន័យថា គ្មានចំណុចអសកម្មនោះដែរ។ ដោយហេតុថា ក្រសួងទេសចរណ៍ទើបនឹងកែប្រែរចនាសម្ព័ន្ធរបស់ខ្លួនឡើងវិញ (នៅឆ្នាំ២០១៦) ការរៀបចំលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងអាជីវកម្មទេសចរណ៍មានភាពយឺតយ៉ាវដែលមិនអាចឆ្លើយតបទៅនឹងតម្រូវការសង្គមទាន់ពេលវេលា។ ជាក់ស្តែង សកម្មភាពអាជីវកម្មទេសចរណ៍មួយចំនួន ពុំទាន់មានលិខិតបទដ្ឋានគិតយុត្តណាដែលនិយាយពីការផ្តល់អាជ្ញាបណ្ណនៅឡើយទេ ដូចជា មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស ថ្នាក់ក្រោមជាតិ និងសកម្មភាពអាជីវកម្មលើកីឡាទេសចរណ៍ ជាដើម។ ម៉្យាងវិញទៀត ការចូលរួមក្នុងការអនុវត្តច្បាប់របស់ប្រជាពលរដ្ឋក៏នៅកម្រិត ដែលធ្វើឱ្យការគ្រប់គ្រងសកម្មភាពអាជីវកម្មទេសចរណ៍មួយចំនួន មានភាពខ្វះចន្លោះដោយសារកង្វះនូវការចូលរួមរបស់ប្រតិបត្តិករទេសចរណ៍។ ទន្ទឹមនឹងនេះ ការដាក់ឱ្យដំណើរការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធ Online របស់ក្រសួងទេសចរណ៍ ក៏មិនទាន់មានប្រសិទ្ធភាព ១០០%ដែរ ដោយសារចំនួននៃការប្រើប្រាស់មិនទាន់មានច្រើននៅឡើយ ព្រមទាំងការយល់ដឹងអំពីប្រព័ន្ធបច្ចេកវិទ្យារបស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ។

ដើម្បីចូលរួមក្នុងការពង្រឹងគុណភាពនៃការគ្រប់គ្រងអាជីវកម្មទេសចរណ៍ យើងខ្ញុំសូមការអនុញ្ញាតជូនជាយោបល់ ក្នុងន័យស្ថាបនាមួយចំនួនដូចជា៖

*ក. ចំពោះប្រជាពលរដ្ឋ (ប្រតិបត្តិករទេសចរណ៍)៖*

- ចូលរួមអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងទេសចរណ៍ (ពិសេសអាជីវកម្មទេសចរណ៍)
- ដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសម្រាប់ប្រកបអាជីវកម្មទេសចរណ៍ តាមលំដាប់លំដោយនៃនីតិវិធីដូចមានចែងក្នុងច្បាប់ជាធរមាន ដើម្បីរក្សាបាននូវនីត្យានុកូលភាព និងកម្មសិទ្ធិបញ្ញានៃអាជីវកម្មរបស់យើង
- គោរពឱ្យបានម៉ឺងម៉ាត់នូវបទបញ្ជា កិច្ចសន្យា និងគោលការណ៍នៃការប្រកបអាជីវកម្មដោយសុច្ចរិតទៀងត្រង់ និងភាពស្មោះស ចំពោះមុខរដ្ឋ អាជ្ញាធរ និងភ្ញៀវទេសចរជាតិអន្តរជាតិ
- ចូលរួមសហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច ក្នុងការអនុវត្តបេសកកម្មត្រួតពិនិត្យ ឬអធិការកិច្ចនានា ដើម្បីធានាបាននូវភាពស្មោះត្រង់របស់អាជីវកម្មរបស់យើង។

*ខ. ចំពោះមន្ត្រីអនុវត្តន៍ច្បាប់៖*

- ចូលរួមនឹងរាជរដ្ឋាភិបាលក្នុងការអនុវត្តនូវតួនាទីរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ដើម្បីផ្តល់នូវសេវាមួយដ៏ល្អប្រសើរចំពោះប្រតិបត្តិករទេសចរណ៍
- រៀនអភិវឌ្ឍន៍ខ្លួន ដោយចូលរួមបណ្តុះបណ្តាលខ្លួនឱ្យមានសមត្ថភាពខ្ពស់ក្នុងការអនុវត្តការងារដោយឆ្លើយតបទៅនឹងការរៀបចំបង្កើតថ្មីនានារបស់ក្រសួងទេសចរណ៍ ជាពិសេស ប្រព័ន្ធបច្ចេកវិទ្យាទំនើប
- ជៀសឱ្យបាននូវសកម្មភាពមិនគប្បីក្នុងការស្នើសុំអាជ្ញាបណ្ណរបស់ប្រតិបត្តិករទេសចរណ៍ ដូចជាការសុំលុយបន្ថែមលើសពីតារាងតម្លៃកំណត់ ការពន្យារពេលដំណើរការឯកសារ និងការគំរាមកំហែងដើម្បីបានប្រយោជន៍បន្ថែម ជាដើម...។

*គ. ចំពោះក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ៖*

- បង្កើតនិងអភិវឌ្ឍនូវប្រព័ន្ធគ្រប់គ្រងអាជីវកម្មទេសចរណ៍ តាមបែបបច្ចេកវិទ្យាទំនើបទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដូចជា ការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធ Online ការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តថ្មីៗដល់ប្រតិបត្តិករទេសចរណ៍តាមរយៈបណ្តាញសង្គមនានា ការជូនដំណឹងដែលមានលក្ខណៈបច្ចេកវិទ្យាទំនើប និងប្រព័ន្ធសម្រាប់ទំនាក់ទំនងរវាងប្រតិបត្តិករទេសចរណ៍ និងអាជ្ញាធរមានសមត្ថកិច្ច ជាដើម...
- បណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ទាំងឡាយ ដែលទទួលបន្ទុកក្នុងការងារគ្រប់គ្រងអាជីវកម្មទេសចរណ៍ ឱ្យមានសមត្ថភាពក្នុងការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាទំនើបដែលបានបង្កើតនោះ
- ជំរុញរៀបចំនិងបង្កើតលិខិតបទដ្ឋានគតិយុត្តដែលនៅសេសសល់ និងថ្មីៗឱ្យបានទាន់ពេលវេលាដើម្បីធានាបាននូវការឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

- ច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍ ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីទេសចរណ៍ ឆ្នាំ២០០៩
- អនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- អនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- អនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍
- ប្រកាសលេខ១៥១ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្ត
- ប្រកាសលេខ១៥២ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងសកម្មភាពកីឡាទេសចរណ៍
- ប្រកាសលេខ១៩៩ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីនីតិវិធីនៃការគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មភាគីទេសចរណ៍និងភ្នាក់ងារទេសចរណ៍
- ប្រកាសលេខ១១៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ភាគីទេសចរណ៍ និងសាខា
- ប្រកាសលេខ០៤០ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៩ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវទឹក
- ប្រកាសលេខ០៤៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានីខេត្ត
- ប្រកាសរួមលេខ២៦២ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍
- ប្រកាសលេខ១៣៩ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍
- ប្រកាសលេខ០៩៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ

- ប្រកាសលេខ០៦៩ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មមុខងារ "ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ឱ្យទៅរដ្ឋបាលរាជធានីខេត្ត
- ប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រក របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ១៧៤ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មខារ៉ាអូខេ
- ប្រកាសលេខ១៧៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មបៀរហ្គាឌិន
- ប្រកាសលេខ១៧៦ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរង្គសាល និងឌីស្កូតែក
- ប្រកាសលេខ១៥៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍តំបន់
- ប្រកាសរួមលេខ៩៩៧ សហវ.ប្រក របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍
- ប្រកាសលេខ០៩២ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ស្តីពីការគ្រប់គ្រងអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍
- ប្រកាសលេខ០៧៦ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន
- ប្រកាសលេខ០៦២ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរមណីយដ្ឋានទេសចរណ៍
- ប្រកាសលេខ០៦៣ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- ប្រកាសលេខ០៦៤ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកម្សាន្តតាមផ្លូវគោក
- សេចក្តីណែនាំលេខ០០៣ សណន របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការអនុវត្តប្រកាសលេខ០៤៥ ប្រក របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានីខេត្ត

- សារាចរណែនាំលេខ០០២ សរណន របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍
- ប្រកាសស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍
- របាយការណ៍ស្ថិតិប្រចាំឆ្នាំ២០១៨ រៀបចំឡើងដោយក្រសួងទេសចរណ៍
- របាយការណ៍បូកសរុបការងារទេសចរណ៍ឆ្នាំ២០១៨ ត្រីមាសទី១ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តត្រីមាសទី២ និងឆមាសទី២ ឆ្នាំ២០១៩
- វចនានុក្រមខ្មែរ រៀបរៀងដោយសម្ដេចសង្ឃ ជួន ណាត
- សៀវភៅ "ទេសចរណ៍ ទ្រឹស្ដីនិងទស្សនៈជាមូលដ្ឋាន" រៀបរៀងដោយ បណ្ឌិត សួន វ៉ានី ឆ្នាំ២០០៦

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ


| ល.រ | បរិយាយ | ទំព័រ |
|---|---|---|
| ១ | អនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ | ១ |
| ២ | អនុក្រឹត្យស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ | ១១ |
| ៣ | អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ | ១៨ |
| ៤ | ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារ "ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត | ២៦ |
| ៥ | ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត | ២៩ |
| ៦ | សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍ ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត | ៣៣ |
| ៧ | ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍ | ៣៨ |
| ៨ | ប្រកាសរួមស្តីពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ | ៤៩ |
| ៩ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ | ៥៧ |
| ១០ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ | ៦៣ |
| ១១ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ | ៧០ |
| ១២ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ ភ្នាក់ងារទេសចរណ៍ និងសាខា | ៧៥ |
| ១៣ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក | ៨៥ |
| ១៤ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក | ៩១ |
| ១៥ | សារាចរណែនាំស្តីពីការគ្រប់គ្រងមធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក | ៩៥ |
| ១៦ | ប្រកាសស្តីពីការគ្រប់គ្រងអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ | ៩៨ |
| ១៧ | ប្រកាសស្តីការអនុវត្តក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា | ១០៤ |
| ១៨ | ប្រកាសស្តីពីនីតិវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា | ១១៦ |
| ១៩ | ប្រកាសស្តីពីនីតិវិធីនៃការគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ | ១២៤ |
| ២០ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន | ១២៩ |
| ២១ | សារាចរណែនាំស្តីពីការគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន | ១៣៦ |
| ២២ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ | ១៣៩ |

| | | |
|---|---|---|
| ២៣ | សារាចរណែនាំស្តីពីការគ្រប់គ្រងអាជីវកម្ម សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ | ១៤៥ |
| ២៤ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មសេវាកម្ម ម៉ាស្សាសុខភាព ស្ប៉ា | ១៤៩ |
| ២៥ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មកីឡាទេសចរណ៍ ម៉ូតូទឹក និងអូប៉័រជិះលេងកម្សាន្ត | ១៥៤ |
| ២៦ | ប្រកាសស្តីពីការគ្រប់គ្រងសកម្មភាពកីឡាទេសចរណ៍ | ១៦០ |
| ២៧ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មខារ៉ាអូខេ | ១៦៤ |
| ២៨ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មបៀរហ្គាឌិន | ១៧១ |
| ២៩ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរង្គសាល និងឌីស្កូតែក | ១៧៨ |
| ៣០ | ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ | ១៨៦ |
| ៣១ | សារាចរណែនាំស្តីពីការគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍ | ២០៣ |
| ៣២ | គំរូវិញ្ញាបនបត្របញ្ជាក់ការចុះក្នុងបញ្ជីពាណិជ្ជកម្ម | ២០៦ |
| ៣៣ | គំរូប័ណ្ណពន្ធប៉ាតង់ឆ្នាំ២០១៩ (អាជីវកម្មទីភ្នាក់ងារទេសចរណ៍) | ២០៧ |
| ៣៤ | គំរូលិខិតធានាប្រាក់តម្កល់អាជីវកម្មការីទេសចរណ៍ជូនភ្ញៀវចូលមកកម្សាន្តក្នុងប្រទេស | ២០៨ |
| ៣៥ | គំរូអាជ្ញាបណ្ណទេសចរណ៍អាជីវកម្មការីទេសចរណ៍នាំភ្ញៀវចូលមកកម្សាន្តក្នុងប្រទេស | ២០៩ |
| ៣៦ | គំរូប័ណ្ណស្រង់ព័ត៌មានការប្រកបអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ | ២១០ |
| ៣៧ | គំរូពាក្យសុំអាជ្ញាបណ្ណទេសចរណ៍ (ថ្មី) | ២១៤ |
| ៣៨ | គំរូពាក្យសុំអាជ្ញាបណ្ណទេសចរណ៍ (បន្ត) | ២១៥ |
| ៣៩ | គំរូកិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ | ២១៦ |
| ៤០ | គំរូរបាយការណ៍អំពីសកម្មភាពអាជីវកម្មទេសចរណ៍ | ២១៨ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩១ . អនក្រ-បក

# អនុក្រឹត្យ
# ស្តីពី
# មគ្គុទ្ទេសក៍ទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីវិធានគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ សម្រាប់បម្រើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.–**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការគ្រប់គ្រងនិងការអភិវឌ្ឍមគ្គុទ្ទេសក៍ទេសចរណ៍ឲ្យទទួលបាននូវប្រសិទ្ធភាពនិងគុណភាព
- ធានាឲ្យមានការគោរពតាមក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
- ចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ ព្រមទាំងធានាដល់ការថែរក្សាធនធានធម្មជាតិ ប្រវត្តិសាស្ត្រ បេតិកភណ្ឌ វប្បធម៌ ប្រពៃណី សិល្បៈ និងទំនៀមទម្លាប់ល្អរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.–**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ ដែលប្រកបវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកឧទ្ទេសនាមតាមប្រាសាទឬតាមសារមន្ទីរនិងអ្នកបកប្រែភាសាមិនត្រូវបានរាប់បញ្ចូលជាមគ្គុទេសក៍ទេសចរណ៍ទេ។

**មាត្រា ៤.–**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

មគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់បុគ្គលប្រកបអាជីពជាអ្នកទទួលជូន ថែរក្សាភ្ញៀវជាតិ អន្តរជាតិ និងធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ និងសេដ្ឋកិច្ចសង្គមនៃទីកន្លែងទស្សនា។

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលផ្តល់ដោយក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ជាអាជ្ញាបណ្ណពេញសិទ្ធិឬអាជ្ញាបណ្ណបណ្តោះអាសន្ន។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស សំដៅដល់មគ្គុទេសក៍ទេសចរណ៍ដែលត្រូវបានអនុញ្ញាតឲ្យបំពេញការងារនៅតាមប្រាសាទឬតាមសារមន្ទីរដែលជាបេតិកភណ្ឌថ្នាក់ជាតិឬថ្នាក់ពិភពលោក។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅគ្រប់គោលដៅទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចណ៍ថ្នាក់តំបន់ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍នៅក្នុងតំបន់មួយចំនួននៃព្រះរាជាណាចក្រកម្ពុជា។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍ តែនៅក្នុងដែនដីនៃរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវតែនៅក្នុងសហគមន៍ប៉ុណ្ណោះ។

អ្នកឧទ្ទេសនាម សំដៅដល់បុគ្គលដែលត្រូវបានប្រគល់ភារកិច្ចឲ្យពន្យល់ អធិប្បាយជូនភ្ញៀវនៅតាមប្រាសាទឬតាមសារមន្ទីរ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍។

ក្រសួងទេសចរណ៍និងក្រសួង ស្ថាប័នសាមី មានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេសដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស។

ក្រសួងទេសចរណ៍មានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិនិងថ្នាក់តំបន់ ដល់មគ្គុទ្ទេសក៍ទេសចរណ៍។

រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិនិងថ្នាក់សហគមន៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ ដោយមានមន្ទីរទេសចរណ៍រាជធានី ខេត្ត ជាសេនាធិការ។

**មាត្រា ៦.-**

ការគ្រប់គ្រង ការផ្តល់អាជ្ញាបណ្ណ និងការបែងចែកកម្រិតមគ្គុទ្ទេសក៍ទេសចរណ៍ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិនិង ថ្នាក់សហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ៧.-**

ក្រសួងទេសចរណ៍មានសិទ្ធិចាត់តាំងមន្ត្រីជំនាញឲ្យចុះធ្វើអធិការកិច្ចត្រួតពិនិត្យសកម្មភាពមគ្គុទ្ទេសក៍ទេសចរណ៍តាមគោលដៅទេសចរណ៍នានានៅក្នុងរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការធ្វើអធិការកិច្ច មន្ត្រីជំនាញនៃក្រសួងទេសចរណ៍អាចសហការនិងសម្របសម្រួលជាមួយនគរបាលទេសចរណ៍ មន្ត្រីនៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។ ទំនាក់ទំនងរវាងមន្ត្រីអធិការកិច្ចទេសចរណ៍និងនគរបាលទេសចរណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៣
## វិធានគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍
### ផ្នែកទី១
### អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍

**មាត្រា ៨.-**

លក្ខណវិនិច្ឆ័យសម្រាប់ការពិនិត្យវាយតម្លៃនិងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវមានដូចខាងក្រោម៖

ក- ត្រូវតែជាបុគ្គលដែលមានសញ្ជាតិខ្មែរនិងមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។

ខ- មានវិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍។

គ- លិខិតបញ្ជាក់កិរិយាមារយាទ ដែលចេញដោយរដ្ឋបាលឃុំ សង្កាត់ ដែលខ្លួនរស់នៅសម្រាប់ការសុំអាជ្ញាបណ្ណទេសចរណ៍។

ឃ- វិញ្ញាបនបត្រពិនិត្យសុខភាពនិងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលនិងមានការឯកភាពពីក្រសួងទេសចរណ៍។

ង- ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត។

**មាត្រា ៩.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍រួមមាន៖

- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍។

**មាត្រា ១០.-**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មជាមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍នៅក្រសួងទេសចរណ៍ឬនៅរដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមប្រភេទនៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍។

ទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ១១.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មានសុពលភាពអប្បបរមា០១(មួយ)ឆ្នាំ គិតពីថ្ងៃចេញអាជ្ញាបណ្ណ។ សុពលភាពជាក់លាក់នៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មិនអាចធ្វើការផ្ទេរឬការលក់បានទេ ដោយសារតែអាជ្ញាបណ្ណនេះផ្អែកលើគុណវុឌ្ឍិបុគ្គលនិងបទពិសោធរបស់ម្ចាស់អាជ្ញាបណ្ណ។

**មាត្រា ១២.-**

នៅពេលមានការខូចខាតឬការបាត់បង់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់និងមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតាឡើងវិញក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលខូចខាតឬបាត់បង់។ ក្នុងករណីនេះ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវរាយការណ៍ជាបន្ទាន់ជូនសមត្ថកិច្ចដែលនៅជិតបំផុត អំពីមូលហេតុនៃការខូចខាតឬការបាត់បង់ដើម្បីទទួលបាននូវលិខិតបញ្ជាក់ដឹងឮពីសមត្ថកិច្ចសម្រាប់កាន់តាមខ្លួនពេលធ្វើអាជីវកម្មមុនពេលទទួលអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតា។

នៅពេលអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវបានលុបឬព្យួរ ឬពេលមគ្គុទ្ទេសក៍ទេសចរណ៍ឈប់ប្រកបអាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវប្រគល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ជូនក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិវិញ។

## ផ្នែកទី២
## ការប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍

**មាត្រា ១៣.-**

គ្មានបុគ្គលណាម្នាក់អាចប្រកបអាជីវកម្មជាមគ្គុទ្ទេសក៍ទេសចរណ៍បានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ពីក្រសួងទេសចរណ៍ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៤.-**

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវមានកាតព្វកិច្ចដូចតទៅ៖

ក- គោរព អនុវត្តឲ្យបានត្រឹមត្រូវនូវក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍

ទេសចរណ៍ព្រមទាំងប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឲ្យបានល្អ។

ខ- ប្រតិបត្តិត្រឹមត្រូវតាមវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ដោយមិនដើរតួនាទីជាការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍។

គ- មិនត្រូវទាមទារកម្រៃឬផលប្រយោជន៍ពីអ្នកលក់ឬពីអ្នកផ្តល់សេវាកម្មទេសចរណ៍ផ្សេងៗ។

ឃ- មិនត្រូវធ្វើសកម្មភាពដែលប៉ះពាល់ជាអវិជ្ជមានដល់គោលនយោបាយជាតិលើវិស័យទេសចរណ៍។

ង- ការពារប្រយោជន៍ជាតិនិងប្រយោជន៍ទេសចរ និងចូលរួមចំណែកនៅក្នុងការថែរក្សានិងគ្រប់គ្រងធនធានធម្មជាតិ លម្អបៃតង មិនបំពុលឬមិនបំផ្លាញបរិស្ថាន ការពារនិងអភិរក្សមរតកវប្បធម៌ ការពារសម្បត្តិវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន។

ច- ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់និងទទួលខុសត្រូវផ្តល់សេវាកម្មដូចដែលបានសន្យាព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរក្នុងពេលដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ឆ- ប្តឹងឬរាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ ដែលនៅជិតបំផុតក្នុងករណីដឹងឬមានការសង្ស័យថាមានការប្រព្រឹត្តបទល្មើសការជួញដូរវត្ថុបុរាណ និងបទល្មើសបេតិកភណ្ឌ ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាពនិងសម្ភារៈអាសអាភាស ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងទៀត។

**មាត្រា ១៥.-**

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់អត្តលេខ និងពាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។

ឯកសណ្ឋានរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ១៦.-**

មគ្គុទ្ទេសក៍ទេសចរណ៍ណាម្នាក់ដែលគិតថាបានទទួលរងគ្រោះដោយសារសេចក្តីសម្រេចរបស់ក្រសួងទេសចរណ៍ឬរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការបដិសេធ ការព្យួរ ការស្តីបន្ទោស ការបញ្ឈប់ ឬការសម្រេចដែលមានការពាក់ព័ន្ធផ្សេងៗដូចមានចែងក្នុងមាត្រា២៣ មាត្រា២៤ និងមាត្រា២៥ នៃ

អនុក្រឹត្យនេះ មានសិទ្ធិធ្វើលិខិតតវ៉ាទៅរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការសម្រេចណាមួយដូចរៀបរាប់ខាងលើ។ បន្ទាប់ពីបានទទួលលិខិតតវ៉ា ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការព្យួរសេចក្តីសម្រេចរបស់ខ្លួន ហើយធ្វើការសម្រេចជាថ្មីឡើងវិញក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ។

**មាត្រា ១៧.-**

ក្រសួងទេសចរណ៍ត្រូវបំផុសនិងជួយរៀបចំបង្កើតសមាគមមគ្គុទ្ទេសក៍ទេសចរណ៍នៅថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ព្រមទាំងបង្កលក្ខណៈឲ្យសមាគមនេះរៀបចំបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវដាក់ឆ្លងសេចក្តីព្រាងក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈនេះទៅក្រសួងទេសចរណ៍ដើម្បីពិនិត្យនិងយល់ព្រម។

## ផ្នែកទី៣
## ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍

**មាត្រា ១៨.-**

ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស។

មុខវិជ្ជាក្នុងការប្រឡងជ្រើសរើស ដើម្បីទទួលបានការបណ្តុះបណ្តាលជាមគ្គុទ្ទេសក៍ទេសចរណ៍ ដែលត្រូវតែមានជាការចាំបាច់រួមមាន៖

ក- ភាសាបរទេសមួយ។

ខ- ភូមិសាស្ត្រប្រទេសកម្ពុជា។

គ- ប្រវត្តិសាស្ត្រប្រទេសកម្ពុជា។

ឃ- ចំណេះដឹងទូទៅអំពីទេសចរណ៍ សេដ្ឋកិច្ច នយោបាយ វប្បធម៌ និងសង្គមរបស់កម្ពុជា។

ក្រសួងទេសចរណ៍អាចបំពេញបន្ថែមមុខវិជ្ជាមួយចំនួនទៀតស្របតាមការចាំបាច់ឬការតម្រូវ ដែលមានកំណត់ក្នុងផែនការអភិវឌ្ឍទេសចរណ៍។

លក្ខខណ្ឌនិងនីតិវិធីនៃការប្រឡងជ្រើសរើស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ១៩.-**

ក្រសួងទេសចរណ៍អាចធ្វើសហការជាមួយសាលាវិជ្ជាជីវៈទេសចរណ៍រដ្ឋឬឯកជនក្នុងការបណ្តុះ

បណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍។ ការរៀបចំកម្មវិធីសិក្សានិងគ្រូសម្រាប់ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវបានពិនិត្យនិងទទួលស្គាល់ដោយក្រសួងទេសចរណ៍។

**មាត្រា ២០.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំផែនការជ្រើសរើស ការបណ្តុះបណ្តាល និងវិក្រឹតការមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ ស្របតាមផែនការអភិវឌ្ឍទេសចរណ៍។

គម្រោងការងារជ្រើសរើស ការបណ្តុះបណ្តាល និងវិក្រឹតការមគ្គុទ្ទេសក៍ទេសចរណ៍ ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី៤
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២១.-**

ក្រសួងទេសចរណ៍អាចអនុញ្ញាតឲ្យមានអ្នកបកប្រែភាសាបំពេញភារកិច្ចជាមួយនឹងមគ្គុទ្ទេសក៍ទេសចរណ៍បាន ដើម្បីដោះស្រាយជាបណ្តោះអាសន្ននូវបញ្ហាមគ្គុទ្ទេសក៍ទេសចរណ៍ដែលពុំចេះភាសារបស់ភ្ញៀវ។

ការគ្រប់គ្រងអ្នកបកប្រែភាសា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ២២.-**

អ្នកឧទ្ទេសនាមតាមប្រាសាទឬតាមសារមន្ទីរស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ឬស្ថាប័នសាមីដោយមានកិច្ចសហការជាមួយក្រសួងទេសចរណ៍ក្នុងការបណ្តុះបណ្តាលជំនាញបដិសណ្ឋារកិច្ច និងទេសចរណ៍។

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវបានទទួលស្គាល់ជាមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេសដោយមានវិញ្ញាបនបត្រជំនាញដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍និងក្រសួង ស្ថាប័នសាមី។ មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេសនេះ ត្រូវបានអនុញ្ញាតឲ្យបំពេញការងារបន្ថែមនៅតាមប្រាសាទឬតាមសារមន្ទីរដែលជាបេតិកភណ្ឌថ្នាក់ជាតិឬថ្នាក់ពិភពលោក។

## ជំពូកទី៥
## ទណ្ឌកម្ម

**មាត្រា ២៣.-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការលុបចោលអាជ្ញាប័ណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ណាដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសថាមានទោសពីបទឧក្រិដ្ឋឬពីបទមជ្ឈិម។

**មាត្រា ២៤.-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើការព្យួរអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ជាបន្ទាន់ ក្នុងករណីដែលមគ្គុទ្ទេសក៍ទេសចរណ៍មានបញ្ហាកាយសម្បទាឬអសមត្ថភាពផ្នែកបញ្ញាសម្បទា ឬមានជំងឺឆ្លងធ្ងន់ធ្ងរដែលមានលក្ខណៈអាចប៉ះពាល់ដល់សុខភាពទេសចរក្នុងរយៈពេលសុពលភាពនៃអាជ្ញាបណ្ណ។

**មាត្រា ២៥.-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មកជាអាជ្ញាបណ្ណបណ្ដោះអាសន្ន ក្នុងករណីដែលមគ្គុទ្ទេសក៍ទេសចរណ៍បានផ្ដល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យសុំ ឬខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងអស់ឬលក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ។ ក្នុងករណីនេះក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ៣០(សាមសិប)ថ្ងៃជាមុន ទៅកាន់ម្ចាស់អាជ្ញាបណ្ណ និងត្រូវមានបញ្ជាក់ហេតុផលច្បាស់លាស់។

**មាត្រា ២៦.-**

លក្ខខណ្ឌនិងនីតិវិធីនៃការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មកជាអាជ្ញាបណ្ណបណ្ដោះអាសន្ន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ២៧.-**

ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មកជាអាជ្ញាបណ្ណបណ្ដោះអាសន្ន ឬការពិន័យអន្តរការណ៍មិនធ្វើឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីនិង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ។

**មាត្រា ២៨.-**

បុគ្គលណាដែលប្រកបអាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា៦៥នៃច្បាប់ស្ដីពីទេសចរណ៍។

**មាត្រា ២៩.-**

ជនណាដែលក្លែងអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ឬឯកសារសាធារណៈផ្សេងៗ ត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា ៣០.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ដែលចេញដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្ត កន្លងមកដែលនៅមានសុពលភាព ត្រូវនៅបន្តអនុវត្តរហូតដល់អស់សុពលភាព។

មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មជាមគ្គុទ្ទេសក៍ទេសចរណ៍បន្តទៀត ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍និងអនុក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិនា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៤។

## សំរេច
## ជំពូកទី ១

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ សំដៅបញ្ជាក់អំពីកំរិតគុណភាព សេវាកម្ម សំភារៈនិងគ្រឿងបរិក្ខារនៅតាមសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ អោយបានសមស្របតាមនិយាមអន្តរជាតិ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តគ្រប់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ គឺជាមូលដ្ឋានផ្គត់ផ្គង់សេវាកម្មស្នាក់នៅមានលក្ខណៈជាបន្ទប់ គ្រែ និងមានផ្តល់នូវសម្ភារ និងសេវាផ្សេងៗទៀតទៅតាមប្រភេទនៃមូលដ្ឋានសេវាកម្មស្នាក់នៅនីមួយៗ ដូចជា : សណ្ឋាគារ (Hotel) ម៉ូតែល (Motel) ឡូដ៍ (Lodge) ប៊ីងហ្គាឡូ (Bungalow) សណ្ឋាគារអាផាតម៉ិន ( Hotel Apartment) សណ្ឋាគារស្វ៊ីត (Suite Hotel) សណ្ឋាគាររីសត (Resort Hotel) ផ្ទះភ្ញៀវ (Guest House) កន្លែងបោះជំរុំទេសចរណ៍ (Tourist Camping) ដូចមាននៅក្នុងឧបសម្ព័ន្ធ៥ និងមូលដ្ឋានសេវាកម្មស្នាក់នៅផ្សេងៗទៀត ដែលមានឧប្បនិស្ស័យក្នុងការបំរើភ្ញៀវទេសចរ ។

**មាត្រា ៤.-**

ការផ្តល់ចំណាត់ថ្នាក់នេះមិនត្រូវបានអនុវត្តលើមូលដ្ឋានសេវាកម្មស្នាក់នៅណាដែលមានលក្ខណៈសម្បត្តិ ឬ សម្ភារមិនគ្រប់គ្រាន់ តាមល័ក្ខខ័ណ្ឌអប្បបរមានៃប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដូចជា ផ្ទះសំណាក់ខ្នាតតូច ផ្ទះសំរាប់លំហែ ផ្ទះជួល ឬផ្ទះល្វែងជួលរយៈពេលវែង រយៈពេលខ្លី សំរាប់ប្រជាពលរដ្ឋ ឬជនបរទេស ។

**មាត្រា ៥.-**

ក្រសួងទេសចរណ៍មានភារកិច្ចរៀបចំវាយតម្លៃ និងសំរេចផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២

# ជំពូកទី ២
# ការផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ

**មាត្រា ៦.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំប្រព័ន្ធស្តង់ដារចំណាត់ថ្នាក់ និងគោលការណ៍ណែនាំសំរាប់វាយតំលៃផ្តល់ចំណាត់ ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ។ រាល់សណ្ឋាគារត្រូវមានចំណាត់ថ្នាក់ទៅតាមប្រព័ន្ធស្តង់ដាចំណាត់ថ្នាក់ ដែលកំណត់ដោយក្រសួងទេសចរណ៍ ដូចមានក្នុងឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤ ។ ចំពោះសេវាកម្មស្នាក់នៅទេសចរណ៍ផ្សេងទៀត ត្រូវមានប្រព័ន្ធស្តង់ដាចំណាត់ថ្នាក់តាមការកំណត់របស់ក្រសួងទេសចរណ៍ ។

**មាត្រា ៧.-**

គោលការណ៍ៗ សំរាប់វិនិច្ឆ័យផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍មាន :

- ទីតាំង ស្ថាបត្យកម្ម និងទិដ្ឋភាពទូទៅ ដោយរាប់បញ្ចូលទាំងគុណភាព និងល័ក្ខខ័ណ្ឌផ្នែកខាងក្រៅអាគារ ទស្សនីយភាព ទីសាធារណៈក្នុងអាគារ និងបន្ទប់ភ្ញៀវ
- ការបំពាក់សំភារៈ បរិក្ខារ ដោយរាប់បញ្ចូលផ្នែកម្រាល និងជញ្ជាំង វាំងនន អគ្គិសនីបំភ្លឺ ប្រព័ន្ធប្រើប្រាស់ អគ្គិសនី គ្រឿងសង្ហារឹម ព័ត៌មាន និងទូរគមនាគមន៍
- អនាម័យ និងការថែទាំ ដោយរាប់បញ្ចូលបន្ទប់ភ្ញៀវ បន្ទប់ទឹក កន្លែងសាធារណៈ កន្លែងកំសាន្ត
- សេវា និងគុណភាពសេវា ដោយរាប់បញ្ចូលឯកសណ្ឋាន អាកប្បកិរិយារបស់បុគ្គលិកចំពោះភ្ញៀវ ការគ្រប់គ្រង និងទំនាក់ទំនងរវាងបុគ្គលិក និងភ្ញៀវ សុវត្ថិភាព និងសន្តិសុខភ្ញៀវ
- សេវាកម្មផ្តល់ម្ហូបអាហារ ដោយប្រើប្រាស់ផលិតផលក្នុងស្រុកដែលមានគុណភាព និងអនាម័យរាប់បញ្ចូលភោជនីយដ្ឋាន ការបំរើអាហារដល់បន្ទប់ គុណភាពម្ហូបអាហារ ចំនួនមុខម្ហូប ការរៀបចំតុ និងពិធីផ្សេងៗ ភ្លេងប្រពៃណី និងរបាំបុរាណខ្មែរ ។

**មាត្រា ៨.-**

សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដែលទទួលចំណាត់ថ្នាក់បាន

សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ហៅកាត់ថា គ.រ.ច។ គ.រ.ច ត្រូវមានការចូលរួមពីសមាសភាពផ្នែកឯកជនដែលមានការពាក់ព័ន្ធ។ គ.រ.ច នេះត្រូវដឹកនាំដោយអគ្គនាយកជំនាញ និងមាននាយកដ្ឋានជំនាញជាលេខាធិការដ្ឋាន។

**មាត្រា ១៣.-**

បន្ទាប់ពីបានទទួលពាក្យស្នើសុំត្រឹមត្រូវ គ.រ.ច ត្រូវចាត់តាំងក្រុមការងារចុះត្រួតពិនិត្យប្រមូលទិន្នន័យវាយតំលៃសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍យ៉ាងយូរម្ភៃ (២០) ថ្ងៃ នៃថ្ងៃធ្វើការ។ ការបង់ថ្លៃសំរាប់ការចុះបំពេញការងារត្រួតពិនិត្យ និងវាយតំលៃ រៀបចំចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍ ដោយមានការពិគ្រោះ យោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៤.-**

ការវាយតំលៃចំណាត់ថ្នាក់ អាចត្រូវធ្វើលើសពីមួយដងទៅតាមសំណូមពរចាំបាច់របស់អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍។

**មាត្រា ១៥.-**

ក្រុមការងារនៃ គ.រ.ច ត្រូវពាក់ប័ណ្ណសំគាល់ពេលចុះត្រួតពិនិត្យសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងបង្ហាញដល់អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារនូវលិខិតឧទ្ទេសនាមរបស់ គ.រ.ច។ ក្រុមការងារនៃ គ.រ.ច ត្រូវធ្វើកំណត់ហេតុ និងរបាយការណ៍ អំពីលទ្ធផលនៃការងារត្រួតពិនិត្យ ដោយផ្ដល់យោបល់លើចំណាត់ថ្នាក់ផ្អែកតាមប្រព័ន្ធចំណាត់ថ្នាក់ជាមូលដ្ឋាន។

**មាត្រា ១៦.-**

គ.រ.ច ត្រូវពិនិត្យ ដោយផ្ដល់ចំណាត់ថ្នាក់ក្នុងជំហានដំបូង ផ្អែកលើមូលដ្ឋានសំខាន់ៗ ដូចខាងក្រោម :

- សំណុំបែបបទសុំចំណាត់ថ្នាក់
- កំណត់ហេតុចុះត្រួតពិនិត្យ
- របាយការណ៍វាយតម្លៃរបស់ក្រុមការងារនៃ គ.រ.ច
- ឯកសារ និងព័ត៌មានផ្សេងៗទៀតដែលចាំបាច់ ។

**មាត្រា ១៧.-**

គ.រ.ច ត្រូវចេញលិខិតជូនដំណឹងអំពីការវាយតម្លៃចំណាត់ថ្នាក់ជំហានដំបូង

លុះត្រាតែមានអាជ្ញាបណ្ណ ទេសចរណ៍ស្ថិតក្នុងសុពលភាព និងល័ក្ខខ័ណ្ឌតម្រូវដូចតទៅ :

- ត្រូវមានការចុះបញ្ជីពាណិជ្ជកម្ម
- អាគារសំណង់ត្រូវមានលិខិតអនុញ្ញាតនិងការទទួលស្គាល់ជាផ្លូវការ
- មានវិញ្ញាបនប័ត្រធានារ៉ាប់រង
- អាគារស្នាក់នៅត្រូវធានាសន្តិសុខ សុវត្ថិភាព បង្ការអគ្គីភ័យ
- ការពារបរិស្ថាន
- មានអនាម័យល្អ
- អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋ ។

**មាត្រា ៩.-**

សញ្ញាសំគាល់ចំណាត់ថ្នាក់នៃសណ្ឋាគារត្រូវកំណត់ដោយរូបផ្កាយចាប់ពីថ្នាក់ផ្កាយ១ ផ្កាយ២ ផ្កាយ៣ ផ្កាយ៤ ផ្កាយ៥ ដែល ជាកំរិតខ្ពស់បំផុត តាមប្រព័ន្ធវាយតំលៃចំណាត់ថ្នាក់ ។ សញ្ញាសំគាល់ចំណាត់ថ្នាក់នៃសេវាកម្មស្នាក់នៅទេសចរណ៍ដទៃទៀតត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងទេសចរណ៍ ។

**មាត្រា ១០.-**

ផ្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍ ។

## ជំពូកទី ៣
## ការសុំចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

**មាត្រា ១១.**

អ្នកទទួលខុសត្រូវគ្រប់គ្រងត្រូវដាក់ពាក្យស្នើសុំចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍របស់ខ្លួននៅក្រសួងទេសចរណ៍ ដោយបំពេញបែបបទតាមគំរូពាក្យស្នើសុំ និងល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យនេះ និងល័ក្ខខ័ណ្ឌផ្សេងទៀត ដែលតម្រូវដោយក្រសួងទេសចរណ៍ ។

## ជំពូកទី ៤
## និតិវិធីនៃការរៀបចំ និងសុពលភាពចំណាត់ថ្នាក់

**មាត្រា ១២.-**

ក្រសួងទេសចរណ៍ត្រូវបង្កើតគណៈកម្មការរៀបចំ និងវាយតម្លៃចំណាត់ថ្នាក់

ជូនអ្នកស្នើសុំក្នុងរយៈពេលម្ភៃ(២០)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរក្រោយពីក្រុមការងារនៃ គ.រ.ច ចុះពិនិត្យ ។ ក្រោយរយៈពេលដប់ប្រាំ (១៥) ថ្ងៃ នៃថ្ងៃធ្វើការ នៃសេចក្ដីជូនដំណឹងនេះបើគ្មានការជំទាស់ជាលាយល័ក្ខណ៍អក្សរពីអ្នកស្នើសុំនោះទេ ការប្រកាសលទ្ធផលចំណាត់ថ្នាក់ជំហានដំបូង ត្រូវចាត់ទុកជាបានការ ។ ក្រសួងទេសចរណ៍ ត្រូវចេញសេចក្ដីទទួលស្គាល់ និងផ្ដល់ចំណាត់ថ្នាក់សំរេចជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងទេសចរណ៍ មិនឱ្យលើសពីដប់ប្រាំ (១៥) ថ្ងៃ នៃថ្ងៃធ្វើការ ។

### មាត្រា ១៨.-

អ្នកស្នើសុំចំណាត់ថ្នាក់មានសិទ្ធិធ្វើលិខិតតវ៉ាជំទាស់ ចំពោះលទ្ធផលនៃចំណាត់ថ្នាក់ជំហានដំបូងលើសណ្ឋាគារ ឬសេវាកម្មស្នាក់នៅទេសចរណ៍របស់ខ្លួន និងស្នើសុំវាយតម្លៃឡើងវិញមិនឱ្យហួសរយៈពេលដប់ប្រាំ (១៥) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលការជូនដំណឹងអំពីការវាយតម្លៃចំណាត់ថ្នាក់ជំហានដំបូង ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។ ក្នុងករណីនេះ គ.រ.ច ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា ១៣ និង១៧ នៃអនុក្រឹត្យនេះ ។

### មាត្រា ១៩.-

ក្នុងករណីសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ណាពុំអាចបំពេញបានតាមគំរិតប្រព័ន្ធស្តង់ដាអប្បបរមាដូចមានកំណត់ក្នុងប្រព័ន្ធវាយតម្លៃចំណាត់ថ្នាក់របស់ក្រសួងទេសចរណ៍ នោះ គ.រ.ច ត្រូវធ្វើលិខិតឆ្លើយតប និងបញ្ជាក់អំពីមូលហេតុច្បាស់លាស់ជូនដល់អ្នកស្នើសុំ ។

### មាត្រា ២០.-

ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍មានសុពលភាពរយៈពេលពីរ (២) ឆ្នាំ ។ អ្នកទទួលខុសត្រូវគ្រប់គ្រង សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវដាក់ពាក្យសុំចំណាត់ថ្នាក់ឡើងវិញមុនពេលផុតសុពលភាពយ៉ាងតិចកៅសិប (៩០) ថ្ងៃ នៃថ្ងៃធ្វើការ ។ ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍អាចត្រូវតម្លើងថ្នាក់ បញ្ចុះថ្នាក់ ព្យួរ ឬបដិសេធ ក្នុងរយៈពេលសុពលភាព ។

### មាត្រា ២១.-

ការប្រើប្រាស់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ហួសសុពលភាព ឬធ្វើការផ្សព្វផ្សាយចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ដោយគ្មានការទទួលស្គាល់ពីក្រសួងទេសចរណ៍ ត្រូវចាត់ទុកថាខុសច្បាប់ ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ២២.-**

អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦ មាត្រា ២១ នៃអនុក្រឹត្យនេះ ត្រូវពិន័យរដ្ឋបាលជាប្រាក់ចំនួនពី ១ 000 000 (មួយលាន) រៀលទៅ ៥ 000 000 (ប្រាំលាន) រៀល ។

ក្នុងករណីសាមីខ្លួនមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២00៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ២៤
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

រាជរដ្ឋាភិបាលកម្ពុជា　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

លេខ: ១៨១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ចនិងការបង្កើតក្រុមអ្នកច្បាប់និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១[illegible]

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងពង្រឹងការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដែលបម្រើឱ្យវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យឱ្យទទួលបាននូវប្រសិទ្ធភាព និងធានាបាននូវគុណភាពសេវាកម្មទេសចរណ៍
- ចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ រក្សាបាននូវសណ្តាប់ធ្នាប់ សុវត្ថិភាព ព្រមទាំងធានាដល់ការថែរក្សាបរិស្ថាន វប្បធម៌ ប្រពៃណី និងសេចក្តីថ្លៃថ្នូរ របស់ជាតិ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើរាល់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ សំដៅដល់ទីតាំងសេវាកម្មទាំងឡាយដែលធ្វើអាជីវកម្មដើម្បីបម្រើឱ្យការសម្រាកលំហែនិងកម្សាន្តសម្រាប់មនុស្សពេញវ័យ។

អាជីវកម្មរង្គសាល សំដៅដល់អាជីវកម្មក្នុងអគារដោយមានការប្រគំតន្ត្រីនិងច្រៀងសម្រាប់ភ្ញៀវរាំកម្សាន្ត ព្រមទាំងមានការផ្តល់សេវាភេសជ្ជៈនិងម្ហូបអាហារបន្ទាប់បន្សំ។

អាជីវកម្មឌីស្កូតែក សំដៅដល់អាជីវកម្មក្នុងអគារដោយមានការប្រើប្រាស់ឧបករណ៍ចាក់បទភ្លេងចម្រៀងសម្រាប់ភ្ញៀវរាំកម្សាន្ត ព្រមទាំងមានការផ្តល់សេវាភេសជ្ជៈនិងម្ហូបអាហារបន្ទាប់បន្សំ។

អាជីវកម្មខារ៉ាអូខេ សំដៅដល់អាជីវកម្មនៅក្នុងបន្ទប់នៃអគារដោយប្រើប្រាស់ឧបករណ៍សំឡេង និងរូបភាព និងអក្សរសម្រាប់បម្រើភ្ញៀវច្រៀងកម្សាន្ត ព្រមទាំងមានការផ្តល់សេវាភេសជ្ជៈនិងម្ហូបអាហារបន្ទាប់បន្សំ។

អាជីវកម្មបៀរហ្គាឌិន សំដៅដល់អាជីវកម្មដែលមានការប្រគំតន្ត្រីនិងការលក់ស្រាបៀរជូនភ្ញៀវ ដោយមានការបម្រើភេសជ្ជៈ និងម្ហូបអាហារគ្រប់ប្រភេទ។/.

អនីតិជន សំដៅដល់ជនដែលមានអាយុក្រោម១៨ឆ្នាំ លើកលែងតែអនីតិជននោះទទួលបានអគ្គាធិនភាព។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ ៈ-**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការដឹកនាំ ការគ្រប់គ្រង ការត្រួតពិនិត្យវាយតម្លៃការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ សម្រាប់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងការត្រួតពិនិត្យសកម្មភាពអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។

**មាត្រា៦ ៈ-**

ការធ្វើប្រតិភូកម្មអំណាចក្នុងការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ ការគ្រប់គ្រង ការត្រួតពិនិត្យវាយតម្លៃការផ្ដល់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យមានសុពលភាពអប្បបរមារយៈពេល០១(មួយ)ឆ្នាំ គិតពីថ្ងៃចេញអាជ្ញាបណ្ណ។

**មាត្រា៧ ៈ-**

លក្ខណវិនិច្ឆ័យក្នុងការផ្ដល់អាជ្ញាបណ្ណទេសចរណ៍សម្រាប់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី៣
## ការកំណត់ប្រភេទ ទីតាំង និងពេលវេលា

**មាត្រា៨ ៈ-**

ប្រភេទអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យរួមមាន៖

- រង្គសាល
- ឌីស្កូតែក
- ខារ៉ាអូខេ
- បៀរហ្គាឌិន
- មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដទៃទៀត ដែលមានឧបនិស្ស័យបម្រើឱ្យវិស័យទេសចរណ៍។

**មាត្រា៩ ៈ-**

ទីតាំងនៃមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវបានអនុញ្ញាតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការកំណត់ទីតាំងធ្វើសកម្មភាពរបស់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ទីតាំងសមរម្យ និងសមស្របតាមប្រភេទអាជីវកម្មនីមួយៗ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

១- មានចម្ងាយយ៉ាងតិច២០០(ពីររយ)ម៉ែត្រពីបរិវេណក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន ទីតាំងសាសនា ប្រាង្គប្រាសាទ ទីតាំងបេតិកភណ្ឌវប្បធម៌។

២- មិនបង្កការរំខានដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន ទីតាំងសាសនា និងការរស់នៅរបស់ប្រជាពលរដ្ឋ។

៣- ធានារក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឱ្យបានល្អ។

**មាត្រា១០ .-**

អាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវកំណត់ជាគោលការណ៍នូវពេលវេលាដំណើរការអាជីវកម្មដូចខាងក្រោម៖

១- អាជីវកម្មរង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន ចាប់ដំណើរការអាជីវកម្មពីម៉ោង១៨:០០នាទីដល់ម៉ោង២៤:០០នាទី។

២- អាជីវកម្មខារ៉ាអូខេ ចាប់ដំណើរការអាជីវកម្មពីម៉ោង១០:០០នាទីព្រឹកដល់ម៉ោង២៤:០០នាទី។

ការកំណត់ពេលវេលាដំណើរការអាជីវកម្មហួសពីម៉ោង២៤:០០ត្រូវបានអនុញ្ញាតចំពោះតែតំបន់អភិវឌ្ឍន៍និងគោលដៅទេសចរណ៍សំខាន់ៗ និងត្រូវកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៤
## ការប្រតិបត្តិអាជីវកម្ម

**មាត្រា១១ .-**

គ្មានបុគ្គលណាម្នាក់អាចប្រកបអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យបានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១២ .-**

ប្រតិបត្តិករមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យត្រូវមានកាតព្វកិច្ចដូចតទៅ៖

ក. គោរពច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ខ. គោរពប្រពៃណី ទំនៀមទម្លាប់ និងមិនត្រូវចូលរួមឬធ្វើសកម្មភាពណាមួយដែលបំពានឬធ្វើឱ្យខូចប្រពៃណីនិងវប្បធម៌ជាតិ។

គ. មិនធ្វើអាជីវកម្មដែលបង្កឱ្យមានការប្រមូលផ្តុំក្មេងទំនើងនិងឱ្យសិស្សគេចសាលារៀន។

ឃ. ហាមអនីតិជននិងហាមយកអាវុធជាតិផ្ទុះចូលក្នុងទីតាំងធ្វើអាជីវកម្ម។

ង. រក្សាការពារសន្តិសុខសុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈដើម្បីបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវចូលកម្សាន្តនិងមិនធ្វើឱ្យមានសំឡេងរំខានដល់ប្រជាពលរដ្ឋរស់នៅជិតខាង។

ច. មិនត្រូវចូលរួម ឬមិនត្រូវធ្វើសកម្មភាពណាមួយដែលពាក់ព័ន្ធនឹង[illegible]ការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញ[illegible]អាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព[illegible]អាសអាភាស។

ឆ. ប្តឹងឬរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត ក្នុងករណីដឹងឬមានការសង្ស័យថាមានការប្រព្រឹត្តបទល្មើស ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទការផ្សព្វផ្សាយរូបភាពនិងសម្ភារៈអាសអាភាស ឬមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត។

ជ. ផ្តល់នូវព័ត៌មានពិតច្បាស់លាស់ដល់ភ្ញៀវចូលកម្សាន្តនិងទទួលខុសត្រូវផ្តល់សេវាកម្មល្អ ព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិការពារសន្តិសុខនិងសុវត្ថិភាពដល់ទេសចរក្នុងពេលដែលទេសចរស្ថិតក្នុងទីកន្លែងអាជីវកម្មរបស់ខ្លួន។

ឈ. ត្រូវមានផែនការបណ្តុះបណ្តាល និងហ្វឹកហ្វឺនបុគ្គលិកបម្រើការងារទាំងពីរភេទ ដើម្បីលើកកម្ពស់សមត្ថភាពមុខជំនាញវិជ្ជាជីវៈ បដិសណ្ឋារកិច្ច និងការគ្រប់គ្រងទេសចរណ៍។

ញ. ចូលរួមផ្សព្វផ្សាយច្បាប់ផ្សេងៗដែលពាក់ព័ន្ធនឹងការប្រយុទ្ធនឹងជំងឺអេដស៍ ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ និងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ រូបភាព និងសម្ភារៈអាសអាភាស។

ដ. ស្នើសហការជាមួយមន្ត្រីជំនាញ មន្ត្រីអធិការកិច្ចទេសចរណ៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ព័ត៌មាន និងការធ្វើអធិការកិច្ច។

ឋ. ចូលរួមក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ"។

**មាត្រា១៣ .-**

ប្រតិបត្តិករមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យណាម្នាក់ ដែលគិតថាបានទទួលរងគ្រោះអំពីការបដិសេធ ការព្យួរ ការលុប ការបញ្ចុះថ្នាក់ ឬការសម្រេចណាមួយ ដោយក្រសួងទេសចរណ៍ ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិធ្វើលិខិតតវ៉ាទៅរដ្ឋមន្ត្រីក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការសម្រេចណាមួយដូចរៀបរាប់ខាងលើ។ បន្ទាប់ពីបានទទួលលិខិតតវ៉ា ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការព្យួរសេចក្តីសម្រេចរបស់ខ្លួន ហើយធ្វើការសម្រេចជាថ្មីឡើងវិញក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ។

## ជំពូកទី៥
## ការហាមឃាត់អនីតិជន

**មាត្រា១៤ .-**

អនីតិជនមិនត្រូវបានអនុញ្ញាតឱ្យចូលទៅកាន់ទីបរិវេណមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដូចជាឌីស្កូតែកនិងរង្គសាលឡើយ។

អនីតិជនអាចចូលទៅកម្សាន្តក្នុងបរិវេណមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដូចជាខារ៉ាអូខេនិងបៀហ្គាឌិនបាន ក្នុងករណីមានឪពុកម្តាយឬអាណាព្យាបាលទៅជាមួយ ឬមានការធានាអះអាងច្បាស់លាស់។

**មាត្រា១៥ .-**

អ្នកគ្រប់គ្រងនិងម្ចាស់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ត្រូវធ្វើបញ្ជីត្រួតពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណបណ្ណអតិថិជនវ័យក្មេងទាំងអស់ ដើម្បីធានាឱ្យមានការប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន។

## ជំពូកទី៦
## អធិការកិច្ច

**មាត្រា១៦ .-**

ក្រសួងទេសចរណ៍ត្រូវដឹកនាំការងារអធិការកិច្ច ដោយចាត់តាំងមន្ត្រីជំនាញចុះត្រួតពិនិត្យសកម្មភាពមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យនៅក្នុងរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការធ្វើអធិការកិច្ច ក្រសួងទេសចរណ៍អាចសហការ និងសម្របសម្រួលជាមួយមន្ត្រីនៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងករណីមានការប្រព្រឹត្តបទល្មើស ចាប់ពីបទមជ្ឈិមជាក់ស្តែងឡើងទៅ រដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តនីតិវិធីច្បាប់ ដើម្បីផ្អាកសកម្មភាពអាជីវកម្មបណ្តោះអាសន្នជាបន្ទាន់និងត្រូវសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

## ជំពូកទី៧
## ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍

**មាត្រា១៧ .-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចលុបចោល ព្យួរ ឬបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យមកជាអាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្ន ក្នុងករណីដែលប្រតិបត្តិករទេសចរណ៍ផ្តល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យសុំឬខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងអស់ឬលក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណទេសចរណ៍។ ក្នុងករណីនេះ ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ៣០(សាមសិប)ថ្ងៃជាមុនទៅកាន់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ និងត្រូវមានបញ្ជាក់ហេតុផលច្បាស់លាស់។

នៅក្នុងស្ថានភាពបន្ទាន់ដែលក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យឃើញថាការបន្តប្រតិបត្តិការអាជីវកម្មទេសចរណ៍មួយ បង្កឱ្យមានហានិភ័យធ្ងន់ធ្ងរភ្លាមៗមកលើសុខភាពសុវត្ថិភាពឬសន្តិសុខនិងបង្កការរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋជិតខាង ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចលុបឬព្យួរអាជ្ញាបណ្ណទេសចរណ៍នោះ ជាបន្ទាន់ដោយបញ្ជាក់ហេតុផលច្បាស់លាស់។

**មាត្រា១៨ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យមកជាអាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្ន ... ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ស្របតាមមាត្រា៤៨នៃច្បាប់ស្តីពីទេសចរណ៍។

**មាត្រា១៩ ._**

ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យមកជាអាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នឬការពិន័យអន្តរការណ៍មិនធ្វើឱ្យប្រតិបត្តិករទេសចរណ៍ដែលប្រព្រឹត្តល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីនិង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ។

**មាត្រា២០ ._**

បុគ្គលណាដែលធ្វើអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា៦៥នៃច្បាប់ស្តីពីទេសចរណ៍។

**មាត្រា២១ ._**

ប្រតិបត្តិករទេសចរណ៍ដែលប្រព្រឹត្តរំលោភលើកាតព្វកិច្ចដូចមានចែងក្នុងមាត្រា១២ និងមាត្រា១៥នៃអនុក្រឹត្យនេះ អាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ស្របតាមមាត្រា៧០ និងមាត្រា៧១នៃច្បាប់ស្តីពីទេសចរណ៍។

**មាត្រា២២ ._**

ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យឬឯកសារសាធារណៈផ្សេងៗ ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌជាធរមាន។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា២៣ ._**

អាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលចេញដោយក្រសួងទេសចរណ៍និងមន្ទីរទេសចរណ៍រាជធានី ខេត្តកន្លងមកដែលនៅមានសុពលភាព ត្រូវនៅបន្តអនុវត្តរហូតដល់អស់សុពលភាព។

ប្រតិបត្តិករទេសចរណ៍ ដែលមានបំណងប្រកបអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យបន្តទៀត ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យស្របតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍និងអនុក្រឹត្យនេះ។

លក្ខខណ្ឌទីតាំងដែលមានចែងនៅក្នុងមាត្រា៩ កថាខណ្ឌទី២ ចំណុចទី១នៃអនុក្រឹត្យនេះ នឹងត្រូវយកមកអនុវត្តចំពោះតែការស្នើសុំអាជ្ញាបណ្ណថ្មីប៉ុណ្ណោះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២៤ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

ក្រសួងទេសចរណ៍

លេខ ០៦៩ (ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៥ ឆ្នាំ២០១

## ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារ "ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធាន ឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- បានឃើញប្រកាសលេខ ១៧៤ ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណដល់អាជីវកម្មខារ៉ាអូខេ
- បានឃើញប្រកាសលេខ ១៧៥ ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មបៀរហ្គាឌិន
- បានឃើញប្រកាសលេខ ១៧៦ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរង្គសាល និងឌីស្កូតែក

## សម្រេច

**ប្រការ ១.-**

ត្រូវបានធ្វើប្រតិភូកម្មមុខងារ ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត លើកលែង៖

-មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលមានលក្ខណៈស្តង់ដារឬស្ថិតនៅក្នុងសណ្ឋាគារមានចំណាត់ថ្នាក់ចាប់ពីផ្កាយបួនឡើង

-មុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌរួចហើយ។

**ប្រការ ២.-**

រដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចក្នុងការគ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលបានធ្វើប្រតិភូកម្មនេះ ដូចខាងក្រោម៖

- ផ្តល់អាជ្ញាបណ្ណទេសចរណ៍ ប្រកបអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ រួមមាន ខារ៉ាអូខេ រង្គសាល ឌីស្កូតែក បៀរហ្គាឌិន និងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដទៃទៀតដែលមានឧបនិស្ស័យ បម្រើឱ្យវិស័យទេសចរណ៍ អនុលោមតាមលក្ខខណ្ឌ បែបបទ នីតិវិធី កម្រៃសេវា និងរយៈពេលដែលបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំលិខិតបទដ្ឋានសេចក្តីណែនាំ សម្រាប់គ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យព្រមទាំងធ្វើការផ្សព្វផ្សាយនូវលិខិតបទដ្ឋានទាំងនេះក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានីខេត្តនីមួយៗ
- លុបចោលអាជ្ញាបណ្ណ ព្យួរអាជ្ញាបណ្ណ ឬបញ្ចុះថ្នាក់អាជ្ញាបណ្ណមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យទៅជាអាជ្ញាបណ្ណបណ្តោះអាសន្ន ក្នុងករណីដែលប្រតិបត្តិករទេសចរណ៍មិនគោរពទៅតាមលក្ខខណ្ឌដែលបានកំណត់។ ក្នុងករណីដែលពិនិត្យឃើញថា ការបន្តប្រតិបត្តិការអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ អាចបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរ ភ្លាមៗមកលើសុខភាព សុវត្ថិភាព ឬសន្តិសុខ រដ្ឋបាលរាជធានី ខេត្ត អាចលុប ឬព្យួរអាជ្ញាបណ្ណនោះ ជាបន្ទាន់ដោយបញ្ជាក់ ហេតុផលច្បាស់លាស់។ការ លុប ការព្យួរ ឬការបញ្ចុះថ្នាក់ អាជ្ញាបណ្ណនេះមិនធ្វើឱ្យម្ចាស់អាជ្ញាបណ្ណរួចផុតពីការទទួលខុសត្រូវ ចំពោះបទល្មើស និងទោសបញ្ញត្តិដែលមានកំណត់ក្នុងច្បាប់ស្តីពីទេសចរណ៍ និងច្បាប់ជាធរមាន ដទៃទៀតឡើយ
- ប្រមូលនិងគ្រប់គ្រងចំណូលបានមកពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន
- ត្រួតពិនិត្យនិងវាយតម្លៃលើសកម្មភាពអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- ចាត់វិធានការទប់ស្កាត់បទល្មើសដែលអាចកើតមានឡើងក្នុងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត
- អនុវត្តពិន័យអន្តរកាលចំពោះការធ្វើអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលគ្មានអាជ្ញាបណ្ណទេសចរណ៍ស្របតាមច្បាប់ជាធរមាន
- រៀបចំរបាយការណ៍តាមគោលការណ៍កំណត់ជូនក្រសួងទេសចរណ៍ អំពីការអនុវត្តមុខងារគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។

**ប្រការ ៣.-**

ក្រសួងទេសចរណ៍ទទួលខុសត្រូវក្នុងការគាំទ្រការណែនាំបច្ចេកទេសលើការរៀបចំស្តង់ដារ ការផ្សព្វផ្សាយ និង ការបណ្តុះបណ្តាលមន្ត្រី បុគ្គលិកដើម្បីអនុវត្តមុខងារដែលបាន ធ្វើប្រតិភូកម្មនេះព្រមទាំងត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តមុខងារនេះដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**ប្រការ ៤.-**

មន្ទីរទេសចរណ៍រាជធានីខេត្តមានតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានីខេត្តក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មនេះនិងរៀបចំរបាយការណ៍ជូនក្រសួងទេសចរណ៍ អំពីស្ថានភាពនៃការអនុវត្តមុខងារគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យរបស់រដ្ឋបាលរាជធានី ខេត្ត។

**ប្រការ ៥.-**

កិច្ចដំណើរការ បែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការអនុវត្តមុខងារ ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលបានធ្វើប្រតិភូកម្ម ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងទេសចរណ៍។

**ប្រការ ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

ខុទ្ទកាល័យអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានទេសចរណ៍ អធិការដ្ឋាន ក្រុមអ្នកច្បាប់ សវនកម្មផ្ទៃក្នុង រដ្ឋបាលរាជធានី ខេត្ត មន្ទីរទេសចរណ៍រាជធានីខេត្តត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័ន ពាក់ព័ន្ធ
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍
លេខ ០៤៥/២៣

## ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងសេចក្តីសម្រេចលេខ ៣៩ សសរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការរៀបចំផ្ទេរមុខងារជាក់លាក់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងប្រកាសលេខ៣៨៧១ ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយ
- យោងប្រកាសលេខ ០២៩ ប្រក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០១ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ជូនភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មកីឡាទេសចរណ៍ និងកម្សាន្ត
- យោងប្រកាសលេខ ០៦៣ ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្ម សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងប្រកាសលេខ ០៦៤ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរ ធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក



E-mail: admin@mot.gov.kh Website:www.tourismcambodia.or

- យោងប្រកាសលេខ ០៧៥ ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណ ទេសចរណ៍ដល់អាជីវកម្ម សេវាកម្មម៉ាស្សាសុខភាព ស្ប៉ា
- យោងប្រកាសលេខ ០៧៦ ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន
- យោងប្រកាសលេខ ១៧៤ ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មខារ៉ាអូខេ
- យោងប្រកាសលេខ ១៧៥ ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មបៀហ្គាឌិន
- យោងប្រកាសលេខ ១៧៦ ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរង្គសាល និងឌីស្កូតែក
- យោងប្រកាសលេខ ០៤០ ប្រក ចុះថ្ងៃទី០៩ ខែមិនា ឆ្នាំ២០១៨ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក

## សម្រេច

**ប្រការ១ ..**

ត្រូវបានធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត រួមមានដូចខាងក្រោម៖

១- សណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វីត ឬសណ្ឋាគាររីសត ប៊ីងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ ( Lodge ) ចំណុះត្រឹម ២០ បន្ទប់ចុះ

២- ផ្ទះភ្ញៀវ ចំណុះត្រឹម ២០ បន្ទប់ចុះ

៣- ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ ចំណុះត្រឹម១០០នាក់/កៅអីចុះ មិនស្ថិតនៅក្នុងអាជីវកម្មដែលចេញអាជ្ញាបណ្ណដោយក្រសួងទេសចរណ៍

៤- បៀហ្គាឌិន

៥- ខារ៉ាអូខេ ចាប់ពី ០៦បន្ទប់ឡើងទៅ (លើកលែងខារ៉ាអូខេ ដែលមានស្តង់ដាចំណាត់ថ្នាក់ផ្កាយ ៤និងផ្កាយ ៥ ឬស្ថិតនៅក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ចាប់ពីផ្កាយ៤ឡើង)

៦- ម៉ាស្សាសុខភាព ចំណុះពី ០៦ ដល់ ១០គ្រែ ឬកៅអី (លើកលែងតែម៉ាស្សាដែលស្ថិតនៅក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ផ្កាយ ៤ឡើង)

៧- ស្ប៉ាដែលមិនស្ថិតនៅក្នុងអាជីវកម្មដែលចេញអាជ្ញាបណ្ណដោយក្រសួងទេសចរណ៍

៨- រង្គសាលឌីស្កូតែក ឬរង្គសាល-ឌីស្កូតែក (លើកលែងរង្គសាលឌីស្កូតែក ឬ រង្គសាល-ឌីស្កូតែកដែលមានស្តង់ដាចំណាត់ថ្នាក់ផ្កាយ ៤ និងផ្កាយ ៥ ឬស្ថិតនៅក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ចាប់ពីផ្កាយ៤ឡើង)

៩- ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក (មិនមែនជាលក្ខណៈក្រុមហ៊ុន)

១០- ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវគោក (មិនមែនជាលក្ខណៈក្រុមហ៊ុន)

១១- កីឡាស្នូកឃ័រ ចាប់ពី ៦តុឡើង

១២- ម៉ាស៊ីនហ្គេម (ល្បែងកម្សាន្តកុមារ និង E-Sport )

១៣- សៀក (របាំស្បែកម្ម និង Acrobafic )

១៤- កីឡាជិះកង់រង្វង់ (គ្រឿងយន្តកម្សាន្តធុនតូចគ្រប់ប្រភេទ)

១៥- កីឡាជិះដំរី (កម្សាន្ត)

១៦- កីឡាជិះសេះ ( កម្សាន្ត)

១៧- រថយន្ត ឬរថភ្លើងអគ្គិសនី (គ្រឿងយន្តកម្សាន្តធុនតូចគ្រប់ប្រភេទ)។

**ប្រការ២ ..**

រដ្ឋបាលរាជធានី ខេត្ត ( អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ) មានភារកិច្ចក្នុងការគ្រប់គ្រង ចាត់ចែង និងផ្តល់សេវាទេសចរណ៍ដែលបានធ្វើប្រតិភូកម្ម ដូចតទៅៈ

- រៀបចំលិខិតបទដ្ឋាន សេចក្តីណែនាំ និងធ្វើការផ្សព្វផ្សាយនូវមុខងារដែលបានធ្វើប្រតិភូកម្មក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដោយអនុលោមតាមលក្ខខណ្ឌ បែបបទ នីតិវិធី កម្រៃសេវា និងរយៈពេល ដែលបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន
- លុបចោល ព្យួរ ឬបញ្ចុះថ្នាក់អាជ្ញាបណ្ណ ទៅជាអាជ្ញាបណ្ណបណ្តោះអាសន្ន ក្នុងករណី ដែលប្រតិបត្តិករទេសចរណ៍មិនគោរពទៅតាមលក្ខខណ្ឌដែលបានកំណត់។ ក្នុងករណី ដែលពិនិត្យឃើញថា ការបន្តប្រតិបត្តិការអាជីវកម្មលើមុខងារទាំងនោះ បង្កឱ្យមានហានិភ័យធ្ងន់ធ្ងរមកលើសន្តិសុខ សុវត្ថិភាព និងសុខភាព រដ្ឋបាលរាជធានី ខេត្ត អាចលុប ឬព្យួរអាជ្ញាបណ្ណនោះ ជាបន្ទាន់ ដោយបញ្ជាក់ហេតុផលច្បាស់លាស់។ ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណនេះ មិនធ្វើឱ្យប្រតិបត្តិករទេសចរណ៍រួចផុតពីការទទួលខុសត្រូវ ចំពោះបទល្មើស និងទោសបញ្ញត្តិ ដែលបានកំណត់ក្នុងច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន
- គ្រប់គ្រង និងបែងចែកចំណូលបានមកពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ តាមគោលការណ៍កំណត់
- ត្រួតពិនិត្យ វាយតម្លៃ និងចាត់វិធានការទប់ស្កាត់បទល្មើសដែលអាចកើតមានឡើងក្នុងការផ្តល់សេវាទេសចរណ៍
- អនុវត្តពិន័យអន្តរការណ៍ចំពោះការធ្វើអាជីវកម្មណាដែលអាជ្ញាបណ្ណហួសសុពលភាព ឬគ្មានអាជ្ញាបណ្ណទេសចរណ៍ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនក្រសួងទេសចរណ៍ អំពីការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម ។

**ប្រការ៣ ..**

ក្រសួងទេសចរណ៍ទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលមន្ត្រីជំនាញ ណែនាំផ្នែកបច្ចេកទេស ផ្សព្វផ្សាយ រៀបចំវាយតម្លៃផ្តល់ស្តង់ដាចំណាត់ថ្នាក់ និងធ្វើការត្រួតពិនិត្យ វាយតម្លៃការអនុវត្តមុខងារ ដែលបានធ្វើប្រតិភូកម្មនេះ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**ប្រការ៤ ..**

មន្ទីរទេសចរណ៍រាជធានី ខេត្ត មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ក្នុងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មនេះ ដោយសហការជាមួយអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនក្រសួងទេសចរណ៍ ក្នុងករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់។

**ប្រការ៥ ..**

ការធ្វើប្រតិភូកម្មមុខងារឱ្យទៅរដ្ឋបាលរាជធានីខេត្ត ដូចមានចែងក្នុងប្រការ១ខាងលើ មិនប៉ះពាល់ដល់មុខងារដែលបានធ្វើប្រតិភូកម្មរួចហើយឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅ។

**ប្រការ៦ ..**

កិច្ចដំណើរការ បែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងទេសចរណ៍។

**ប្រការ៧ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨ ..**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពចំណុះក្រសួងទេសចរណ៍ រដ្ឋបាលរាជធានី ខេត្ត និងប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧រោច ខែមាឃ ឆ្នាំច សំរិទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩

**ថោង ខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០០៣ ទសណន

ថ្ងៃ ៣ ៩ កើត ខែ មាឃ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩

(១)

**សេចក្តីណែនាំ**

**ស្តីពី**

**ការអនុវត្តប្រកាស លេខ ០៤៥ ប្រក ចុះថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១២ ខែ ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍ ស្តីពីការធ្វើប្រតិភូកម្មមុខងារ ផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត**

អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចដំណើរការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងទេសចរណ៍បានធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត តាមប្រកាសលេខ ០៤៥ ប្រក ចុះថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០១៩ ។

ដើម្បីធានាដល់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ ដែលបានធ្វើប្រតិភូកម្មប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដូចខាងក្រោម៖

**I- នីតិវិធី និងសមត្ថកិច្ចក្នុងការស្នើសុំផ្តល់អាជ្ញាបណ្ណទេសចរណ៍**

១.១- ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬសុំបន្តអាជ្ញាបណ្ណទេសចរណ៍ ក៏ដូចជា មកទទួលអាជ្ញាបណ្ណទេសចរណ៍ នៅអង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត។

១.២- បន្ទាប់ពីទទួលបានសំណុំឯកសារស្នើសុំអាជ្ញាបណ្ណទេសចរណ៍រួចមក មន្ត្រីជំនាញមន្ទីរទេសចរណ៍រាជធានី ខេត្ត ដែលប្រចាំនៅក្នុងអង្គភាពច្រកចេញចូលតែមួយ មានភារកិច្ចដូចតទៅ ៖

- ពិនិត្យសំណុំបែបបទ និងឯកសារពាក់ព័ន្ធត្រឹមត្រូវតាមគោលការណ៍កំណត់
- ក្នុងករណីពិនិត្យឃើញថា សំណុំបែបបទ មិនគ្រប់គ្រាន់ ត្រូវបញ្ជូនទៅឱ្យមន្ត្រីជួរមុខ ដើម្បីផ្តល់ព័ត៌មានជូនទៅម្ចាស់អាជីវកម្មវិញ
- ក្នុងករណីពិនិត្យឃើញថា សំណុំបែបបទ និងឯកសារគ្រប់គ្រាន់ មន្ត្រីជំនាញទទួលបន្ទុកត្រូវចាត់ចែងអនុវត្តតាមសមត្ថកិច្ចជំនាញ
- វាយតម្លៃ និងផ្តល់យោបល់អំពី "ការអនុញ្ញាតផ្តល់ ឬមិនអាចអនុញ្ញាតផ្តល់" អាជ្ញាបណ្ណទេសចរណ៍ លើសំណើសុំប្រកបអាជីវកម្មដោយផ្អែកតាមលិខិតបទដ្ឋានគតិយុត្តិ និងស្តង់ដាជាធរមានរបស់ក្រសួង រួចបញ្ជូនសំណុំឯកសារស្នើសុំនោះទៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តវិញ។

**II - សំណុំបែបបទសម្រាប់ការផ្តល់អាជ្ញាបណ្ណទេសចរណ៍**

**ក. ការស្នើសុំសម្រាប់អាជីវកម្មបើកថ្មី**

ការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មទេសចរណ៍ ( សម្រាប់អាជីវកម្មបើកថ្មី ) ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ដោយមានភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម៖

១. សេវាកម្មស្នាក់នៅ៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ( ថតចម្លង) ចំនួន ១ច្បាប់



ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧៤ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល ( ផ្តល់ដោយក្រសួង ឬមន្ទីរ ដ.ន.ស) ឬវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធ (ថតចម្លង) ចំនួន ១ច្បាប់
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន ១ច្បាប់
- បង្ហាញប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

២. សេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត (ថតចម្លង) ចំនួន ១ច្បាប់
- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល ( ផ្តល់ដោយក្រសួង ឬមន្ទីរ ដ.ន.ស) ឬវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធ (ថតចម្លង) ចំនួន ១ច្បាប់
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន ១ច្បាប់
- បង្ហាញប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

៣. សេវាកម្មបៀហ្គាឌិន៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត (ថតចម្លង) ចំនួន ១ច្បាប់
- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល ( ផ្តល់ដោយក្រសួង ឬមន្ទីរ ដ.ន.ស) ឬវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធ (ថតចម្លង) ចំនួន ១ច្បាប់
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន ១ច្បាប់
- បង្ហាញប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

៤. សេវាកម្មខារ៉ាអូខេ វង្គសាល និងឌីស្កូតែក៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត (ថតចម្លង) ចំនួន ១ច្បាប់
- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល ( ផ្តល់ដោយក្រសួង ឬមន្ទីរ ដ.ន.ស) ឬវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធ (ថតចម្លង) ចំនួន ១ច្បាប់
- លិខិតបញ្ជាក់ស្តង់ដាចំណាត់ថ្នាក់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ ចំនួន ១ច្បាប់
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន ១ច្បាប់
- បង្ហាញប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ

- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

៥. សេវាកម្មម៉ាស្សាសុខភាព និង ស្ប៉ា៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬ មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត (ថតចម្លង) ចំនួន ១ច្បាប់
- លិខិតអនុញ្ញាតសាងសង់ ឬជួសជុល ( ផ្តល់ដោយក្រសួង ឬមន្ទីរ ដ.ន.ស) ឬវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬកិច្ចសន្យាជួល ក្នុងករណីម្ចាស់អាជីវកម្មមិនមែនជាម្ចាស់កម្មសិទ្ធ (ថតចម្លង) ចំនួន ១ច្បាប់
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន ១ច្បាប់
- បង្ហាញប្រព័ន្ធបង្គារ និងពន្លត់អគ្គីភ័យ
- សញ្ញាបត្រ ឬវិញ្ញាបនបត្ររបស់ម្ចាស់ ឬអ្នកគ្រប់គ្រង ដែលបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ចទេសចរណ៍ ចំនួន ១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

៦. សេវាកម្មដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក និងផ្លូវគោក មិនមែនជាលក្ខណៈក្រុមហ៊ុន៖

- វិញ្ញាបនបត្រ ឬសៀវភៅត្រួតពិនិត្យបច្ចេកទេសយានយន្ត ( សុពលភាព) ចំនួន ០១ច្បាប់
- វិញ្ញាបនបត្រធានារ៉ាប់រងអំពីការៈទទួលខុសត្រូវសាធារណៈ ចំនួន ០១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន(ថតចម្លង) ចំនួន ០១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក
- រូបថតយានយន្ត សម្រាប់ ធ្វើអាជីវកម្មទេសចរណ៍ (ថតចម្លង) ចំនួន ០១ច្បាប់។

៧. សេវាកម្មកីឡាទេសចរណ៍៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ផ្តល់ដោយក្រសួងពាណិជ្ជកម្ម ឬ មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត (ថតចម្លង) ចំនួន ១ច្បាប់
- លិខិតបញ្ជាក់ពីស្ថាប័នពាក់ព័ន្ធ ( ក្នុងករណីអាជីវកម្មទេសចរណ៍មានលក្ខណៈបច្ចេកទេសពាក់ព័ន្ធជាមួយស្ថាប័នផ្សេង) សម្រាប់តែរថយន្ត ឬ រថភ្លើងអគ្គីសនី (គ្រឿងយន្តកម្សាន្តធន់តូចគ្រប់ប្រភេទ)
- គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម ចំនួន ១ច្បាប់
- បង្ហាញប្រព័ន្ធបង្គារ និងពន្លត់អគ្គីភ័យ
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស (ថតចម្លង) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

**ខ. ការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណទេសចរណ៍**

ការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មទេសចរណ៍ (សម្រាប់អាជីវកម្មបន្តសុពលអាជ្ញាបណ្ណ) ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ដោយមានភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនដូចខាងក្រោម៖

១. សេវាកម្មស្នាក់នៅ ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍៖

- អាជ្ញាបណ្ណទេសចរណ៍ឆ្នាំចុងក្រោយ ឬ(ថតចម្លង) ចំនួន ១ច្បាប់

- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ( ករណីប្តូរម្ចាស់អាជ្ញាបណ្ណ) ចំនួន ១ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ ( ឆ្នាំចាស់ ) ឬលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ ( បើមាន) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

២. សេវាកម្មបៀហ្គាឌិនៈ
- អាជ្ញាបណ្ណទេសចរណ៍ឆ្នាំចុងក្រោយ ឬ (ថតចម្លង) ចំនួន ១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ( ករណីប្តូរម្ចាស់អាជ្ញាបណ្ណ) ចំនួន ១ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ ( ឆ្នាំចាស់ ) ឬលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ ( បើមាន ) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

៣. សេវាកម្មខារ៉ាអូខេ វង្គសាល និងឌីស្កូតែកៈ
- អាជ្ញាបណ្ណទេសចរណ៍ឆ្នាំចុងក្រោយ ឬ (ថតចម្លង) ចំនួន ១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- លិខិតបញ្ជាក់ស្តង់ដាចំណាត់ថ្នាក់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ ស្ថិតក្នុងសុពលភាព ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ( ករណីប្តូរម្ចាស់អាជ្ញាបណ្ណ) ចំនួន ១ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ ( ឆ្នាំចាស់ ) ឬលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ ( បើមាន ) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

៤. សេវាកម្មម៉ាស្សាសុខភាព និង ស្ប៉ាៈ
- អាជ្ញាបណ្ណទេសចរណ៍ឆ្នាំចុងក្រោយ ឬ (ថតចម្លង) ចំនួន ១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ( ករណីប្តូរម្ចាស់អាជ្ញាបណ្ណ) ចំនួន ១ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ ( ឆ្នាំចាស់ ) ឬលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ ( បើមាន ) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

៥. សេវាកម្មដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក និងផ្លូវគោក មិនមែនជាលក្ខណៈក្រុមហ៊ុនៈ
- អាជ្ញាបណ្ណទេសចរណ៍ឆ្នាំចុងក្រោយ ឬ (ថតចម្លង) ចំនួន ១ច្បាប់
- វិញ្ញាបនបត្រ ឬសៀវភៅត្រួតពិនិត្យបច្ចេកទេសយានយន្ត (សុពលភាព) ចំនួន ០១ច្បាប់
- វិញ្ញាបនបត្រធានារ៉ាប់រងអំពីភារៈទទួលខុសត្រូវសាធារណៈ ចំនួន ០១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ថតចម្លង) ចំនួន ០១ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ ( ឆ្នាំចាស់ ) ឬលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ ( បើមាន ) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

៦. សេវាកម្មកីឡាទេសចរណ៍ៈ
- អាជ្ញាបណ្ណទេសចរណ៍ឆ្នាំចុងក្រោយ ឬ (ថតចម្លង) ចំនួន ១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម ចំនួន ១ច្បាប់

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សម្រាប់ជនបរទេស (ថតចម្លង) ( ករណីប្តូរម្ចាស់អាជ្ញាបណ្ណ) ចំនួន ១ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ ( ឆ្នាំចាស់ ) ឬលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ ( បើមាន ) ចំនួន ១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ៤x៦ ចំនួន ៣សន្លឹក។

III - **ការគ្រប់គ្រង និងការបែងចែកចំណូល**

៣.១. អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ទទួល និងចាត់ចែងនូវចំណូលពីអាជ្ញាបណ្ណទេសចរណ៍ ដោយអនុវត្តតាមស្មារតីប្រកាសរួម រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ លេខ ៩៩៧ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍ ប្រកាស លេខ ២៦២ សហវ.ប្រក ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តស្តីពីទេសចរណ៍ និងប្រកាសលេខ ២៦៣ សហវ.ប្រក ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្តល់ថវិការង្វាន់លើកទឹកចិត្តលើការគ្រប់គ្រង និងការប្រមូលចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

៣.២. មន្ទីរទេសចរណ៍រាជធានី ខេត្ត មានភារកិច្ចសហការ និងសម្របសម្រួលជាមួយអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត លើការងារនេះ និងរាយការណ៍អំពីស្ថានភាពចំណូលប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនក្រសួងទេសចរណ៍។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងទេសចរណ៍ រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ថោង ខុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៩៧ សហវ.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០១៧

# ប្រកាសរួម
# ស្តីពី
# ការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងទេសចរណ៍



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥ ២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 793

៣[illegible]

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងទេសចរណ៍ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រសួងទេសចរណ៍ ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងទេសចរណ៍ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

**ប្រការ ៣** :

ក្រសួងទេសចរណ៍ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងផ្ញើសលាកប័ត្រចំណូល។

ប្រការ ៤ :

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាលនៃក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។ ក្រសួងទេសចរណ៍ ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

ប្រការ ៥ :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ៦ :

ក្រសួងទេសចរណ៍ ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

ប្រការ ៧ :

ក្រសួងទេសចរណ៍ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ប្រការ ៨ :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់ តាមរយៈប្រកាសរួម។

ប្រការ ៩ :

បុគ្គលណាដែលប្រកបអាជីវកម្មទេសចរណ៍ ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវទទួលពិន័យអន្តរការណ៍ តាមមាត្រា ៦៥ នៃច្បាប់ ស្តីពីទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ១០ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១១ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

"ដើម្បីជូនជ្រាប"

- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ៩៩៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ទីភ្នាក់ងារទេសចរណ៍ | | | |
| | - ស្នាក់ការកណ្តាល | 1,200,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ស្នាក់ការសាខា | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| 2 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ | | | |
| 2.1 | សណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វីត ឬសណ្ឋាគាររីសត ឬប៊ីងហ្កាឡូ ឬម៉ូតែល ឬឡដ៍ (Lodge) | | | |
| | - ចំណុះត្រឹម 10 បន្ទប់ | 300,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 11 ដល់ 20បន្ទប់ | 400,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 21 ដល់ 30បន្ទប់ | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 31 ដល់ 60បន្ទប់ | 1,100,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 61 ដល់ 100បន្ទប់ | 1,300,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 101 ដល់ 150បន្ទប់ | 2,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 151 ដល់ 200បន្ទប់ | 2,600,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 201 ដល់ 300បន្ទប់ | 3,300,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 301បន្ទប់ ឡើងទៅ | 4,000,000 | 28ថ្ងៃ | 1ឆ្នាំ |



៥៧ ១២

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 2.2 | ផ្ទះភ្ញៀវត្រូវបង់ថ្លៃអាជ្ញាប័ណ្ណទេសចរណ៍ក្នុង 01បន្ទប់ | 15,000 | 28ថ្ងៃ | 1ឆ្នាំ |
| 2.3 | កន្លែងបោះជំរុំ | | | |
| | - ទំហំត្រឹម 01ហិកតា | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ទំហំលើស 01ហិកតា | 1,300,000 | 28ថ្ងៃ | 1ឆ្នាំ |
| 3 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ | | | |
| | - ចំណុះត្រឹម 50នាក់ | 300,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 51 ដល់ 100នាក់ | 600,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 101 ដល់ 200នាក់ | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 201 ដល់ 300នាក់ | 1,300,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 301នាក់ ឡើងទៅ | 1,600,000 | 28ថ្ងៃ | 1ឆ្នាំ |
| 4 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់បៀរហ្គាឌិន | | | |
| | - ចំណុះត្រឹម 50នាក់ | 600,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 51 ដល់ 100នាក់ | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 101 ដល់ 200នាក់ | 1,100,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 201 ដល់ 300នាក់ | 1,300,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 301នាក់ ឡើងទៅ | 2,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| 5 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ខារ៉ាអូខេ | | | |
| | - ចំណុះត្រឹម 05បន្ទប់ | 400,000 | 28ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ចំណុះពី 06 ដល់ 10បន្ទប់ | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 11 ដល់ 20បន្ទប់ | 1,600,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 21 ដល់ 40បន្ទប់ | 3,00[illegible] | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 41បន្ទប់ ឡើងទៅ | 4,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| 6 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ម៉ាស្សាសុខភាព-ស្ប៉ា | | | |
| 6.1 | ម៉ាស្សាសុខភាព | | | |
| | - ចំណុះត្រឹម 05គ្រែ ឬកៅអី | 260,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 06 ដល់ 10គ្រែ ឬកៅអី | 520,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 11 ដល់ 15គ្រែ ឬកៅអី | 780,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 16 ដល់ 20គ្រែ ឬកៅអី | 1,040,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 21គ្រែ ឬកៅអី ឡើងទៅ | 1,300,000 | 28ថ្ងៃ | 1ឆ្នាំ |
| 6.2 | ស្ប៉ា | 520,000 | 28ថ្ងៃ | 1ឆ្នាំ |
| 7 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់រង្គសាលឌីស្កូតែក ឬរង្គសាល-ឌីស្កូតែក | | | |
| | - ចំណុះត្រឹម 50នាក់ | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 51 ដល់ 100នាក់ | 1,200,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 101 ដល់ 150នាក់ | 2,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 151 ដល់ 200នាក់ | 4,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 201នាក់ ឡើងទៅ | 6,000,000 | 28ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 8 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរណ៍តាមផ្លូវទឹក | | | |
| | - ចំណុះត្រឹម 10កៅអី | 80,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 11 ដល់ 30កៅអី | 150,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 31 ដល់ 50កៅអី | 350,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 51 ដល់ 100កៅអី | 600,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 101កៅអី ឡើងទៅ | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| 9 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរណ៍តាមផ្លូវគោក | | | |
| | - ចំណុះត្រឹម 05កៅអី | 100,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 06 ដល់ 15កៅអី | 150,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 16 ដល់ 45កៅអី | 200,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 46កៅអី ឡើងទៅ | 260,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់កីឡាទេសចរណ៍ | | | |
| 10.1 | កីឡាស្នូកឃ័រ | | | |
| | - ចំណុះត្រឹម 05តុ | 150,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 06តុ ឡើងទៅ | 400,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.2 | ម៉ាស៊ីនហ្គេម | | | |
| | - ចំណុះត្រឹម 10គ្រឿង | 300,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 11គ្រឿង ឡើងទៅ | 600,000 | 28ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 10.3 | ក្លឹបកំសាន្តប៊ូលីង | | | |
| | - ចំណុះត្រឹម 10ខ្សែ | 600,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 11ខ្សែ ឡើងទៅ | 1,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.4 | ក្លឹបហ្វឹកហាត់វាយកូនគោល | | | |
| | - ចំណុះត្រឹម 10កន្លែង | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 11 ដល់ 50កន្លែង | 2,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 51កន្លែង ឡើងទៅ | 4,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.5 | ក្លឹបកីឡាវាយកូនគោល | | | |
| | - 09រន្ធ | 4,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ចំណុះពី 18រន្ធ ឡើងទៅ | 8,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.6 | កីឡាប្រណាំងឡាន | 600,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.7 | កីឡាបាញ់ព្រួញ និងកាំភ្លើងគ្រាប់មិនពិត | 1,200,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.8 | កីឡាសៀក | 520,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.9 | កីឡាជិះកង់វង្វង់ | 260,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.10 | កីឡាជិះដំរី | 260,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.11 | កីឡាជិះសេះ | 500,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.12 | ថេយន្ត ឬថភ្លើងអគ្គិសនី | 600,000 | 28ថ្ងៃ | 1ឆ្នាំ |



៦ ១២

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 10.13 | កីឡាស្គីលើទឹក, កីឡាក្តារបណ្តែត-ទូកបណ្តែត, កីឡាហែលទឹក ឬកីឡាមុជទឹក | 600,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.14 | បាល់ឡេងបង្ហោះ រថយន្តខ្សែកាប | 800,000 | 28ថ្ងៃ | 1ឆ្នាំ |
| 10.15 | យន្តហោះ ឬឧទ្ធម្ភាចក្រជិះកំសាន្តក្នុងមួយគ្រឿង | 2,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| 11 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់មេណីយដ្ឋានទេសចរណ៍ | | | |
| | - មេណីយដ្ឋានថ្នាក់ជាតិ | 10,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - មេណីយដ្ឋានថ្នាក់ខេត្ត | 5,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - មេណីយដ្ឋានថ្នាក់ស្រុក | 3,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - មេណីយដ្ឋានថ្នាក់កែច្នៃ | 2,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| 12 | អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ | | | |
| | - ថ្នាក់សហគមន៍ | 50,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ថ្នាក់ក្រោមជាតិ | 100,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ថ្នាក់តំបន់ | 250,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ថ្នាក់ជាតិ | 300,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - ថ្នាក់ពិសេស | 300,000 | 28ថ្ងៃ | 1ឆ្នាំ |
| 13 | ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ | | | |
| | - សណ្ឋាគារមិនជាប់ចំណាត់ថ្នាក់ | 300,000 | 28ថ្ងៃ | 2ឆ្នាំ |
| | - ចំណាត់ថ្នាក់ផ្កាយ! | 800,000 | 28ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ចំណាត់ថ្នាក់ផ្កាយ2 | 1,000,000 | 28ថ្ងៃ | 2ឆ្នាំ |
| | - ចំណាត់ថ្នាក់ផ្កាយ3 | 2,000,000 | 28ថ្ងៃ | 2ឆ្នាំ |
| | - ចំណាត់ថ្នាក់ផ្កាយ4 | 3,000,000 | 28ថ្ងៃ | 2ឆ្នាំ |
| | - ចំណាត់ថ្នាក់ផ្កាយ5 | 4,000,000 | 28ថ្ងៃ | 2ឆ្នាំ |
| 14 | ស្តង់ដាអប្បរមារមណីយដ្ឋានទេសចរណ៍ | | | |
| | - គុណភាពមធ្យម (C) | 1,000,000 | 28ថ្ងៃ | 1ឆ្នាំ |
| | - គុណភាពមធ្យម (B) | 1,500,000 | 28ថ្ងៃ | [illegible]ឆ្នាំ |
| | - គុណភាពមធ្យម (A) | 2,000,000 | 28ថ្ងៃ | [illegible]ឆ្នាំ |
| 15 | អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ | 400,000 | 28ថ្ងៃ | ៦ខែ |

**សេចក្តីបញ្ជាក់:**

- រាល់ការស្នើសុំប្តូរម្ចាស់អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់អាជីវកម្មខាងលើទាំងអស់ ត្រូវបង់តម្លៃស្មើនឹង ៣០% នៃតម្លៃអាជ្ញាប័ណ្ណទេសចរណ៍។
- រាល់ការស្នើសុំបន្តអាជ្ញាប័ណ្ណទេសចរណ៍សម្រាប់អាជីវកម្មខាងលើទាំងអស់ ត្រូវបង់តម្លៃស្មើនឹងតម្លៃអាជ្ញាប័ណ្ណទេសចរណ៍ដែលស្នើសុំថ្មីដែរ។

សុពលភាពនៃការបន្តអាជ្ញាប័ណ្ណទេសចរណ៍ មានរយៈពេលស្មើនឹងសុពលភាពផ្តល់ជូនដំបូងដែរ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២៣២ សហវ.ប្រក

# ប្រកាសរួម

## ស្តីពី

## ការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



៤៩

ផ្ទះលេខ ៥២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៣៥៨

- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៩៩៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍
- យោងតាមការចាំបាច់របស់ក្រសួងទេសចរណ៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងទេសចរណ៍ អនុវត្តការប្រមូលចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

កម្រិតទឹកប្រាក់នៃការពិន័យអន្តរការណ៍ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ ត្រូវបានកំណត់ផ្អែកទៅតាមស្ថានទម្ងន់នៃអំពើល្មើសលើប្រភេទបទល្មើសនីមួយៗ ដែលមានចែងលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៣ .-**

ក្នុងករណីដែលអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ មិនបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬ មិនបានដាក់ពាក្យប្តឹងតវ៉ា ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានលិខិតអញ្ជើញឱ្យបង់ប្រាក់ពិន័យ នោះចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាពីរដង នៃកម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ដែលបានកំណត់នៅក្នុងប្រការ២ នៃប្រកាសរួមនេះ។

ករណីក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានលិខិតអញ្ជើញឱ្យបង់ប្រាក់ពិន័យ ហើយអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ នៅតែមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីជំនាញនៃក្រសួងទេសចរណ៍ត្រូវរៀបចំសំណុំឯកសារប្តឹងទៅសាលាជម្រះក្តី ដើម្បីចាត់ការទៅតាមច្បាប់ជាធរមាន ក្នុងការផ្តន្ទាទោសពិន័យជាប្រាក់ និងការដាក់ទោសទណ្ឌផ្សេងៗទៀត ដែលសម្រេចដោយសាលាជម្រះក្តី។

**ប្រការ៤ .-**

ក្រសួងទេសចរណ៍ ត្រូវផ្សព្វផ្សាយជាសាធារណៈនូវប្រកាសរួម និងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៥ .–**

នីតិវិធី និងលក្ខខណ្ឌនៃការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ ដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ៦ .–**

ការបែងចែកភារកិច្ចលើការគ្រប់គ្រង និងការប្រមូលចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ រវាងរដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។ ក្រសួងទេសចរណ៍ ត្រូវផ្ញើប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ៧ .–**

រាល់ការប្រមូល ឬ ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨ .–**

រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន, បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៩ .–**

ក្រសួងទេសចរណ៍ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងទេសចរណ៍ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

របាយការណ៍ស្តីពីការអនុវត្តចំណូលខាងលើនេះ ជាផ្នែកមួយនៃរបាយការណ៍រួមស្តីពីការអនុវត្តចំណូលរបស់រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត។

**ប្រការ១០ ._**

កម្រិតទឹកប្រាក់នៃការពិន័យអន្តរការណ៍ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ អាចកែប្រែបានតាមការចាំបាច់ ដែលកំណត់ដោយប្រកាសរួម រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ១១ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ ._**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ៣ ឆ្នាំ២០១៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងទេសចរណ៍

ថោង ខុន

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ..៦៦៤... សហវ.ប្រក ចុះថ្ងៃទី..២០.... ខែ..មីនា.. ឆ្នាំ២០១៧

ការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍

| ល.រ | បរិយាយ | ទឹកប្រាក់ពិន័យអន្តរការណ៍ (រៀល) | |
|---|---|---|---|
| | | គ្មានអាជ្ញាប័ណ្ណ | អាជ្ញាប័ណ្ណ ហួសសុពលភាព |
| ក. ប្រភេទបទល្មើសទូទៅ | | | |
| ១ | ការផ្សព្វផ្សាយព័ត៌មានមិនពិតពាក់ព័ន្ធនឹងការធ្វើអាជីវកម្មលើវិស័យទេសចរណ៍ | ៣០០ ០០០ | |
| ២ | គ្មានបញ្ជីតារាងដែលបញ្ជាក់ពីតម្លៃសេវាកម្ម ឬ មុខម្ហូបអាហារភេសជ្ជៈនីមួយៗ | ៣៥០ ០០០ | |
| ៣ | ការផ្លាស់ប្តូរទីតាំងដែលមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងទេសចរណ៍ ក្នុងអំឡុងរយៈពេលសុពលភាពនៃអាជ្ញាប័ណ្ណ | ៦០០ ០០០ | |
| ៤ | ការមិនសហការប្តឹង ឬ រាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចពីសកម្មភាពរបស់ភ្ញៀវទេសចរណ៍ ឬ សកម្មភាពផ្សេងដែលកើតមកលើភ្ញៀវទេសចរនូវសកម្មភាព ដែលច្បាប់បានហាមឃាត់ | ១ ០០០ ០០០ | |
| ៥ | ការធ្វើកិច្ចព្រមព្រៀងជាមួយរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលឋិតនៅក្រោមសមត្ថកិច្ចក្រសួងទេសចរណ៍ ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ | ១ ០០០ ០០០ | |
| ៦ | ការរារាំងដល់មន្ត្រីមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យសកម្មភាពអាជីវកម្ម | ១ ០០០ ០០០ | |
| ខ. ប្រភេទបទល្មើសដោយឡែក | | | |
| ៧ | ខ១- អាជីវកម្មទីភ្នាក់ងារទេសចរណ៍ (ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍) | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ខ២- អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅ | | |
| | ខ២.១- សណ្ឋាគារ ឬ សណ្ឋាគាររមណីយដ្ឋាន ឬ សណ្ឋាគារស្វ៊ីត ឬ សណ្ឋាគារវីឡា ឬ ប៊ីងហ្គាឡូ ឬ ម៉ូតែល ឬ ឡូដ៍ (Lodge) | | |
| ៨ | - ចំណុះត្រឹម ១០០ បន្ទប់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៩ | - ចំណុះពី ១០១ បន្ទប់ ដល់ ១៥០ បន្ទប់ | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| ១០ | - ចំណុះពី ១៥១ បន្ទប់ ដល់ ២០០ បន្ទប់ | ៣ ៩០០ ០០០ | ២ ៦០០ ០០០ |
| ១១ | - ចំណុះពី ២០១ បន្ទប់ ដល់ ៣០០ បន្ទប់ | ៤ ៩៥០ ០០០ | ៣ ៣០០ ០០០ |
| ១២ | - ចំណុះពី ៣០១ បន្ទប់ ឡើងទៅ | ៦ ០០០ ០០០ | ៤ ០០០ ០០០ |
| | ខ២.២- ផ្ទះភ្ញៀវ | | |
| ១៣ | - ចំណុះត្រឹម ៩០ បន្ទប់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ១៤ | - ចំណុះពី ៩១ បន្ទប់ ដល់ ១០០ បន្ទប់ | ២ ២៥០ ០០០ | ២ ០០០ ០០០ |
| ១៥ | - ចំណុះពី ១០១ បន្ទប់ ដល់ ឡើងទៅ | ៤ ៥០០ ០០០ | ៣ ០០០ ០០០ |
| ១៦ | ខ២.៣- កន្លែងបោះជំរុំ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ខ៣- អាជីវកម្មភោជនីយដ្ឋាន អាហារដ្ឋាន | | |
| ១៧ | - ចំណុះត្រឹម ៣០០ នាក់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ១៨ | - ចំណុះពី ៣០១ នាក់ឡើងទៅ | ២ ៤០០ ០០០ | ២ ០០០ ០០០ |

| ល.រ | បរិយាយ | ទឹកប្រាក់ពិន័យអន្តរការណ៍ (រៀល) | |
|---|---|---|---|
| | | គ្មានអាជ្ញាបណ្ណ | អាជ្ញាបណ្ណហួសសុពលភាព |
| | ១៤- អាជីវកម្មភោជនីយដ្ឋាន ខារ៉ាអូខេ ម៉ាស្សាសុខភាព-ស្ប៉ា និងរង្គសាលនិស្លូតែក | | |
| | ១៤.១- បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព | | |
| ១៩ | - មិនមានបញ្ជីឈ្មោះប្រភេទនៃសេវាកម្មដោយបញ្ជាក់ពីតម្លៃនីមួយៗដល់ភ្ញៀវ | ៥០០ ០០០ | |
| ២០ | - អនុញ្ញាតឱ្យនីតិជនចូលក្នុងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ | ១ ៥០០ ០០០ | |
| | ១៤.២- ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ ឬ អាជ្ញាបណ្ណហួសសុពលភាព | | |
| | ១៤.២.១- ភោជនីយដ្ឋាន | | |
| ២១ | - ចំណុះត្រឹម ៣០០ នាក់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ២២ | - ចំណុះពី ៣០១ នាក់ឡើងទៅ | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| | ១៤.២.២- ខារ៉ាអូខេ | | |
| ២៣ | - ចំណុះត្រឹម ១០ បន្ទប់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ២៤ | - ចំណុះពី ១១ បន្ទប់ ដល់ ២០ បន្ទប់ | ២ ៤០០ ០០០ | ២ ០០០ ០០០ |
| ២៥ | - ចំណុះពី ២១ បន្ទប់ ដល់ ៤០ បន្ទប់ | ៤ ៥០០ ០០០ | ៣ ០០០ ០០០ |
| ២៦ | - ចំណុះពី ៤១ បន្ទប់ ឡើងទៅ | ៦ ០០០ ០០០ | ៤ ០០០ ០០០ |
| ២៧ | ១៤.២.៣- ម៉ាស្សាសុខភាព និងស្ប៉ា | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ១៤.២.៥- រង្គសាលនិស្លូតែក ឬ រង្គសាល-និស្លូតែក | | |
| ២៨ | - ចំណុះត្រឹម ១០០ នាក់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ២៩ | - ចំណុះពី ១០១ នាក់ ដល់ ១៥០ នាក់ | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| ៣០ | - ចំណុះពី ១៥១ នាក់ ដល់ ២០០ នាក់ | ៦ ០០០ ០០០ | ៤ ០០០ ០០០ |
| ៣១ | - ចំណុះពី ២០១ នាក់ ឡើងទៅ | ៩ ០០០ ០០០ | ៦ ០០០ ០០០ |
| | ១៥- អាជីវកម្មដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក និងផ្លូវគោក | | |
| | ១៥.១- បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព | | |
| ៣២ | - សេវាដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកអត់ពោងសុវត្ថិភាព | ១០០ ០០០ | |
| ៣៣ | - ការដាក់ភ្ញៀវលើសចំណុះ | ២០០ ០០០ | |
| ៣៤ | - ការបោះបង់ចោលភ្ញៀវនៅពេលដែលមិនទាន់ពេញការធានារបស់ខ្លួន | ៤០០ ០០០ | |
| ៣៥ | ១៥.២- ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ ឬ អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ១៦- អាជីវកម្មកីឡាទេសចរណ៍ | | |
| ៣៦ | ១៦.១- កីឡាស្លូកឃ័រ, ម៉ាស៊ីនហ្គេម, ក្លឹបកំសាន្តប៊ូលីង | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ១៦.៤- ក្លឹបហ្វឹកហាត់វាយកូនគោល | | |
| ៣៧ | - ចំណុះត្រឹម ១០ កន្លែង | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៣៨ | - ចំណុះពី ១០ ដល់ ៥០ កន្លែង | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| ៣៩ | - ចំណុះពី ៥១ កន្លែង ឡើងទៅ | ៦ ០០០ ០០០ | ៤ ០០០ ០០០ |

| ល.រ | បរិយាយ | ពិន័យប្រាក់ពិន័យអន្តរការណ៍ (រៀល) | |
|---|---|---|---|
| | | គ្មានអាជ្ញាប័ណ្ណ | អាជ្ញាប័ណ្ណ ហួសសុពលភាព |
| | ១៦.៥- ក្លឹបកីឡាវាយកូនគោល | | |
| ៥០ | - ចំណុះត្រឹម ០៩ រន្ធ | ៦ ០០០ ០០០ | ៤ ០០០ ០០០ |
| ៥១ | - ចំណុះពី ១៨ រន្ធ ឡើងទៅ | ១២ ០០០ ០០០ | ៩ ០០០ ០០០ |
| | ១៦.៦- កីឡាទេសចរណ៍ផ្សេងៗទៀត | | |
| ៤៥ | - កីឡាប្រណាំងឡាន, កីឡាបាញ់ព្រួញ និងកាំភ្លើងគ្រាប់មិនពិត, កីឡាសៀក, កីឡាជិះកង់រង្វង់, កីឡាជិះដីរ៉ា, កីឡាជិះសេះ, រថយន្ត ឬ រទេះភ្លើងអគ្គិសនី, កីឡាស្គីលើទឹក, ក្តារបណ្តែត, ហែលទឹកមុជទឹក, បាល់ឡុងបង្ហោះ, រថយន្តខ្សែកាប | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៤៦ | - យន្តហោះ ឬ ឧទ្ធម្ភាគចក្រជិះកំសាន្ត | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| | ១៧- អាជីវកម្មភោជនីយដ្ឋានទេសចរណ៍ | | |
| | - ភោជនីយដ្ឋានថ្នាក់ជាតិ | ១៥ ០០០ ០០០ | ១០ ០០០ ០០០ |
| ៤៨ | - ភោជនីយដ្ឋានថ្នាក់ខេត្ត | ៧ ៥០០ ០០០ | ៥ ០០០ ០០០ |
| ៤៩ | - ភោជនីយដ្ឋានថ្នាក់ស្រុក | ៤ ៥០០ ០០០ | ៣ ០០០ ០០០ |
| ៥០ | - ភោជនីយដ្ឋានថ្នាក់កែវ | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| | ១៨- អាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ | | |
| | ១៨.១-បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព | | |
| ៥១ | - មគ្គុទ្ទេសក៍ទេសចរណ៍មិនពាក់ឯកសណ្ឋាន ឬ សញ្ញាសម្គាល់ដែលចេញដោយក្រសួងទេសចរណ៍ ឬ មន្ទីរទេសចរណ៍ | ២០ ០០០ | |
| ៥២ | - ការនាំភ្ញៀវចូលទៅកន្លែងដែលអាជ្ញាធរបានហាមឃាត់ | ៥០ ០០០ | |
| ៥៣ | - ការផ្តល់ព័ត៌មានមិនពិតក្នុងវិស័យទេសចរណ៍ដល់ភ្ញៀវទេសចរ | ៥០ ០០០ | |
| ៥៤ | - ការមិនគោរពទៅតាមក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ | ៥០ ០០០ | |
| | - ការពិសាគ្រឿងស្រវឹងក្នុងពេលបំពេញការងារ | ៦០ ០០០ | |
| | ១៨.២- ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ ឬ អាជ្ញាប័ណ្ណហួសសុពលភាព | | |
| ៥៦ | - ថ្នាក់សហគមន៍ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៥៧ | - ថ្នាក់ក្រោមជាតិ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៥៨ | - ថ្នាក់តំបន់ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៥៩ | - ថ្នាក់ជាតិ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៦០ | - ថ្នាក់ពិសេស | ២ ០០០ ០០០ | ២ ០០០ ០០០ |
| | ១៩- ចំណាត់ថ្នាក់សណ្ឋាគារ ឬ សេវាកម្មស្នាក់នៅទេសចរណ៍ | | |
| ៦១ | - ចំណាត់ថ្នាក់ក្រោមផ្កាយ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៦២ | - ចំណាត់ថ្នាក់ផ្កាយ ១ | ២ ០០០ ០០០ | ២ ០០០ ០០០ |

| ល.រ | បរិយាយ | ទឹកប្រាក់ពិន័យអន្តរការណ៍ (រៀល) | |
|---|---|---|---|
| | | គ្មានអាជ្ញាប័ណ្ណ | អាជ្ញាប័ណ្ណ ហួសសុពលភាព |
| ៦៣ | - ចំណាត់ថ្នាក់ផ្កាយ ២ | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៦៤ | - ចំណាត់ថ្នាក់ផ្កាយ ៣ | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| ៦៥ | - ចំណាត់ថ្នាក់ផ្កាយ ៤ | ៤ ៥០០ ០០០ | ៣ ០០០ ០០០ |
| ៦៦ | - ចំណាត់ថ្នាក់ផ្កាយ ៥ | ៦ ០០០ ០០០ | ៤ ០០០ ០០០ |
| | ១១០- ស្តង់ដារអប្បរមារមណីយដ្ឋានទេសចរណ៍ | | |
| ៦៧ | - គុណភាពមធ្យម ( C ) | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ៦៨ | - គុណភាពមធ្យម ( B ) | ២ ២៥០ ០០០ | ២ ០០០ ០០០ |
| ៦៩ | - គុណភាពមធ្យម ( A ) | ៣ ០០០ ០០០ | ២ ០០០ ០០០ |
| | ១១១- អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ | | |
| ៧០ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ ឬ អាជ្ញាប័ណ្ណហួសសុពលភាព | ២ ០០០ ០០០ | ២ ០០០ ០០០ |

<u>កំណត់សម្គាល់ ÷</u>

- ការពិន័យអន្តរការណ៍ជាប្រាក់ដែលអនុវត្តដោយក្រសួងទេសចរណ៍ ត្រូវបានកំណត់ទឹកប្រាក់ពិន័យអតិបរមាត្រឹម ២០លានរៀល។
- ការបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវបានចាត់ទុកថាជាករណីដោយឡែកសម្រាប់ការដោះបន្ទុកលើប្រភេទបទល្មើស ដែលសាមីជនបានប្រព្រឹត្តតែប៉ុណ្ណោះ។ ចំពោះការស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ថ្មី ឬ បន្តអាជ្ញាប័ណ្ណទេសចរណ៍ តម្រូវឱ្យម្ចាស់សេវាកម្ម ឬ ម្ចាស់អាជីវកម្ម ត្រូវបង់ថ្លៃអាជ្ញាប័ណ្ណទេសចរណ៍ ទៅតាមតម្លៃដែលបានកំណត់ដោយប្រកាសរួមរបស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ក្នុងករណីដែលអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ មិនបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬ មិនបានដាក់ពាក្យប្តឹងតវ៉ា ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានលិខិតអញ្ជើញឱ្យបង់ប្រាក់ពិន័យ នោះចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាពីរដង នៃកម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនេះ។ ករណីមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានលិខិតអញ្ជើញឱ្យបង់ប្រាក់ពិន័យ នោះមន្ត្រីជំនាញនៃក្រសួងទេសចរណ៍ត្រូវរៀបចំសំណុំឯកសារប្តឹងទៅសាលាជម្រះក្តី ដើម្បីដោះស្រាយទៅតាមនីតិវិធីតុលាការ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ០៩៣ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៦

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១._**

ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធានក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ដើម្បីបម្រើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២._**

ប្រកាសនេះ មានគោលដៅដូចតទៅៈ

- ពង្រឹងការគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិឱ្យទទួលបាននូវប្រសិទ្ធភាព និងគុណភាព
- ធានាឲ្យមានការគោរពត្រឹមត្រូវតាមក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
- ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ និងធានាដល់ការថែរក្សាវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ល្អរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣._**

បច្ចេកស័ព្ទដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចតទៅ ៖

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេសតំបន់ទេសចរណ៍ពិសេសដែលកំណត់ដោយប្រកាសដោយឡែករបស់ក្រសួងទេសចរណ៍។

បុគ្គល សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល។

ប្រតិបត្តិករទេសចរណ៍ សំដៅដល់បុគ្គលដែលប្រតិបត្តិ ប្រកបអាជីព ឬធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍។

## ជំពូកទី២

## សមត្ថកិច្ចក្នុងការគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ

**ប្រការ ៤._**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ។

ក្រសួងទេសចរណ៍មានសមត្ថកិច្ចក្នុងការផ្តល់ ការបន្តអាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ និងការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន។

**ប្រការ ៥._**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ត្រូវបានផ្តល់ឲ្យមគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់ប្រតិបត្តិការទូទៅតាមស្មារតីប្រការ ៣នៃប្រកាសនេះ។

**ប្រការ ៦._**

គ្មានបុគ្គលណាអាចប្រកបវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិបានទេ ប្រសិនបើបុគ្គលនោះមិនទទួលបានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិពីក្រសួងទេសចរណ៍។

## ជំពូកទី៣

## វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ

**ប្រការ ៧._**

បុគ្គលដែលស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិនៅទីស្តីការក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Online) (តាមរយៈគេហទំព័រទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាងនិងព័ត៌មានផ្សេងៗទៀតដូចខាងក្រោម៖

ក. ត្រូវមានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី១៨ឆ្នាំ ឡើងទៅ

ខ. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន(ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

គ. វិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍(ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ឃ. លិខិតបញ្ជាក់កិរិយាមាយាទដែលចេញដោយរដ្ឋបាលឃុំ សង្កាត់ ដែលខ្លួនរស់នៅ

ង. វិញ្ញាបនបត្រពិនិត្យសុខភាព និងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល

ច. កិច្ចសន្យាគោរពច្បាប់រដ្ឋ

ឆ. ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត

ជ. រូបថតទំហំ(៤x៦) ចំនួន០៣សន្លឹក។

**ប្រការ ៨._**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលស្នើសុំបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ត្រូវមកដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិនៅទីស្តីការក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Online) (តាមរយៈគេហទំព័រដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទដោយភ្ជាប់ឯកសារសំអាង និងព័ត៌មានផ្សេងៗទៀតដូចខាងក្រោម៖



៣

ក. អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)
ខ. ព្រឹត្តិបត្រព័ត៌មាន និងការវាយតម្លៃមគ្គុទ្ទេសក៍ទេសចរណ៍
គ. វិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ និងវិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍វិក្រឹតការ (ករណីបានឆ្លងកាត់វគ្គបណ្តុះបណ្តាល) ក្នុងសុពលភាពនៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ចុងក្រោយដែលការបណ្តុះបណ្តាល ត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)
ឃ. លិខិតបញ្ជាក់កិរិយាមាយាទដែលចេញដោយរដ្ឋបាលឃុំ សង្កាត់ ដែលខ្លួនរស់នៅ
ង. វិញ្ញាបនបត្រពិនិត្យសុខភាព និងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល
ច. រូបថតទំហំ(៤x៦) ចំនួន០៣សន្លឹក។

**ប្រការ ៩._**

កម្រៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិស្មើនឹង ៤០០.០០០ (បួនរយពាន់) រៀល។

**ប្រការ ១០._**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិមានសុពលភាពរយៈពេល០២ (ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍។

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ត្រូវមកដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិឱ្យបាន ៣០ (សាមសិប)ថ្ងៃ យ៉ាងតិចមុនថ្ងៃផុតសុពលភាព។

**ប្រការ ១១._**

ម្ចាស់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិត្រូវប្រើប្រាស់អាជ្ញាបណ្ណនេះឱ្យបានត្រឹមត្រូវតាមការណែនាំ និងបទប្បញ្ញត្តិនានារបស់ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ។

ក្នុងករណីមានការខូចខាត ឬបាត់បង់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិម្ចាស់អាជ្ញាបណ្ណត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចដើម្បីស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិទុតិយតាឡើងវិញក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានខូចខាត ឬបាត់បង់។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិត្រូវកាន់តាមខ្លួននូវលិខិតបញ្ជាក់ពីការដឹងឮរបស់សមត្ថកិច្ច មុនពេលទទួលបានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតា។

## ជំពូកទី៤

## ការស្នើសុំព្យួរអាជ្ញាបណ្ណទេសចរណ៍

ប្រការ ១២._

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិអាចស្នើសុំព្យួរអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍បាន។ ការស្នើសុំព្យួរអាជ្ញាបណ្ណនីមួយៗមានរយៈពេលកំណត់មិនលើសពី ០២(ពីរ) ឆ្នាំ។ ក្នុងករណីមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិបានស្នើសុំព្យួរអាជ្ញាបណ្ណទេសចរណ៍ចំនួន០២(ពីរ)ដង ជាប់គ្នាហើយមានបំណងដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិឡើងវិញ ត្រូវចូលរួមវគ្គវិក្រឹតការពិសេសមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិដែលរៀបចំដោយក្រសួងទេសចរណ៍។

## ជំពូកទី៥

## ភារកិច្ចរបស់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ

ប្រការ ១៣._

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនរាល់បទប្បញ្ញត្តិជាធរមានក្នុងវិស័យទេសចរណ៍ ពិសេសការអនុវត្តក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៦

## ទណ្ឌកម្ម

ប្រការ ១៤._

មគ្គុទ្ទេសក៍ទេសចរណ៍ដែលប្រើប្រាស់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិហួសសុពលភាព និងត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដែលអប្បបរមាស្មើនឹង ២.០០០.០០០ (ពីរលាន) រៀល។

ការពិន័យអន្តរការណ៍នេះ មិនទាន់គិតកម្រៃអាជ្ញាបណ្ណទេសចរណ៍ដែលត្រូវបង់។ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់អាជ្ញាបណ្ណ ដើម្បីចូលខ្លួនមកបង់ប្រាក់ពិន័យអន្តរការណ៍រយៈពេល៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលបានជូនដំណឹង។

បុគ្គលដែលប្រកបអាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិដោយគ្មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ស្មើនឹង ៣.០០០.០០០ (បីលាន) រៀល។

ការពិន័យអន្តរការណ៍មិនធ្វើឱ្យម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ ១៥._

ក្នុងករណីម្ចាស់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិផ្តល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ឬប្រព្រឹត្តរំលោភលើភារកិច្ចដូចមានចែងក្នុងប្រការ១៣ ជំពូកទី៥នៃប្រកាសនេះ អាចជាកម្មវត្ថុនៃការពិន័យដែលមានកំណត់ក្នុងប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ ១៦.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៧.**_

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធានគ្រប់នាយកដ្ឋាននៃក្រសួងទេសចរណ៍ និងប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្តត្រូវអនុវត្តប្រកាស នេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**<u>កន្លែងទទួល</u>**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-សាលារាជធានី -ខេត្ត
*"ដើម្បីជូនជ្រាប"*
-មន្ទីរទេសចរណ៍រាជធានី-ខេត្ត
*"ដើម្បីអនុវត្ត"*
-ដូចប្រការ ១៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

**ក្រសួងទេសចរណ៍**

លេខ ១៥៧ /ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៤

## ប្រកាស

## ស្តីពី

## ការផ្តល់រង្វាន់បណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ចនិងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

# ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

ប្រការ ១._

ប្រកាសនេះមានគោលបំណងកំណត់អំពីវិធានក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ដើម្បីបម្រើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២._

ប្រកាសនេះ មានគោលដៅដូចតទៅៈ

- ពង្រឹងការគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ឱ្យទទួលបាននូវប្រសិទ្ធភាព និងគុណភាព
- ធានាឱ្យមានការគោរពត្រឹមត្រូវតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
- ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ និងធានាដល់ការថែរក្សាវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ល្អរបស់ព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៣._

វាក្យស័ព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះមានដូចតទៅៈ

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍នៅក្នុងតំបន់។

បុគ្គល សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល។

ប្រតិបត្តិករទេសចរណ៍ សំដៅដល់បុគ្គលដែលប្រតិបត្តិប្រកបអាជីព ឬធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍។

# ជំពូកទី២
## សមត្ថកិច្ចក្នុងការគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

ប្រការ ៤._

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់។

ក្រសួងទេសចរណ៍មានសមត្ថកិច្ចក្នុងការផ្តល់ ការបន្តអាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ និងការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន។

ប្រការ ៥._

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ត្រូវបានផ្តល់ឱ្យមគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់ប្រតិបត្តិការទៅតាមគោលដៅទេសចរណ៍នៃតំបន់នីមួយៗ។

តំបន់ប្រតិបត្តិការសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៦.

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់បានទេ ប្រសិនបើបុគ្គលនោះមិនទទួលបានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ពីក្រសួងទេសចរណ៍។

## ជំពូកទី៣

## វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

**ប្រការ ៧.-**

បុគ្គលដែលស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់នៅមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Online) (តាមរយៈគេហទំព័រទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទ រួមទាំងឯកសារសំអាង និងព័ត៌មានផ្សេងៗទៀតដូចខាងក្រោម៖

ក. ត្រូវមានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី១៨ឆ្នាំ ឡើងទៅ

ខ. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

គ. វិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ឃ. លិខិតបញ្ជាក់កិរិយាមារយាទដែលចេញដោយរដ្ឋបាលឃុំ សង្កាត់ ដែលខ្លួនរស់នៅ

ង. វិញ្ញាបនបត្រពិនិត្យសុខភាព និងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងមានការឯកភាពពីក្រសួងទេសចរណ៍

ច. កិច្ចសន្យាគោរពច្បាប់រដ្ឋ

ឆ. ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត

ជ. រូបថតទំហំ (៤x៦) ចំនួន ០៣សន្លឹក។

**ប្រការ ៨.-**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលស្នើសុំបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ត្រូវមកដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់នៅមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Online) (តាមរយៈគេហទំព័រដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទ ដោយភ្ជាប់ឯកសារសំអាង និងព័ត៌មានផ្សេងៗទៀតដូចខាងក្រោម៖

ក. អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ខ. ព្រឹត្តបត្រព័ត៌មាន និងការវាយតម្លៃមគ្គុទ្ទេសក៍ទេសចរណ៍

គ. វិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ និងវិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍វិក្រឹតការក្នុងសុពលភាពនៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ចុងក្រោយ ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយ ក្រសួងទេសចរណ៍ (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ឃ. លិខិតបញ្ជាក់កិរិយាមារយាទដែលចេញដោយរដ្ឋបាលឃុំ សង្កាត់ ដែលខ្លួនរស់នៅ

ង. វិញ្ញាបនបត្រពិនិត្យសុខភាព និងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងមានការឯកភាពពីក្រសួងទេសចរណ៍

ច. រូបថតទំហំ (៤x៦) ចំនួន ០៣ សន្លឹក។

**ប្រការ ៩._**

កម្រៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ស្មើនឹង២៥០.០០០(ពីររយហាសិបពាន់) រៀល។

**ប្រការ ១០._**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់មានសុពលភាពរយៈពេល០២ (ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍។

ម្ចាស់អាជ្ញាបណ្ណត្រូវមកដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ឲ្យបាន ៣០ (សាមសិប) ថ្ងៃ យ៉ាងតិចមុនថ្ងៃផុតសុពលភាព។

ក្នុងកំឡុងពេលដែលបានដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់នៅតែមានសិទ្ធិប្រកបរបរវិជ្ជាជីវកម្មរហូតដល់ថ្ងៃដែលក្រសួងទេសចរណ៍ផ្តល់អាជ្ញាបណ្ណបន្ត។

**ប្រការ ១១._**

ម្ចាស់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ត្រូវប្រើប្រាស់អាជ្ញាបណ្ណនេះឲ្យបានត្រឹមត្រូវ តាមការណែនាំ និងបទប្បញ្ញត្តិនានារបស់ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ។

ក្នុងករណីមានការខូចខាត ឬបាត់បង់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ម្ចាស់អាជ្ញាបណ្ណត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ទុតិយតាឡើងវិញក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានខូចខាត ឬបាត់បង់។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ត្រូវកាន់តាមខ្លួននូវលិខិតបញ្ជាក់ពីការដឹងឮរបស់សមត្ថកិច្ច មុនពេលទទួលបានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតា។

## ជំពូកទី៤

## ការសុំព្យួរអាជ្ញាបណ្ណទេសចរណ៍

**ប្រការ ១២._**

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ អាចស្នើសុំព្យួរអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍បាន។ ការស្នើសុំព្យួរអាជ្ញាបណ្ណនីមួយៗមានរយៈពេលកំណត់មិនលើសពី ០២ (ពីរ) ឆ្នាំ។ ក្នុងករណីមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់បានស្នើសុំព្យួរអាជ្ញាបណ្ណទេសចរណ៍ចំនួន ០២ (ពីរ)ដង ជាប់គ្នាហើយមានបំណងដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ឡើងវិញ ត្រូវចូលរួមវគ្គវិក្រឹតការពិសេសមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ដែលរៀបចំដោយក្រសួងទេសចរណ៍។

## ជំពូកទី៥

## ភារកិច្ចរបស់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

**ប្រការ ១៣._**

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ត្រូវអនុវត្តតាមប្រកាសស្តីពី ការអនុវត្តក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៦

## ទណ្ឌកម្ម

ប្រការ ១៤._

មគ្គុទ្ទេសក៍ទេសចរណ៍ ដែលប្រើប្រាស់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ហួសសុពលភាព ចាត់ទុកថាធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ និងត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដែលអប្បបរមាស្មើនឹង ២.០០០.០០០ (ពីរលាន) រៀល។

ការពិន័យអន្តរការណ៍នេះ មិនទាន់គិតកម្រៃអាជ្ញាបណ្ណទេសចរណ៍ដែលត្រូវបង់។ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់អាជ្ញាបណ្ណ ដើម្បីចូលខ្លួនមកបង់ប្រាក់ពិន័យអន្តរការណ៍រយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលបានជូនដំណឹង។

ការពិន័យអន្តរការណ៍មិនធ្វើឱ្យម្ចាស់អាជ្ញាបណ្ណទេសចរណ៍ដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ ឬការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ ១៥._

បុគ្គលដែលប្រកបអាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ដោយគ្មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ស្មើនឹង ៣.០០០.០០០ (បីលាន) រៀល។ ការពិន័យអន្តរការណ៍មិនធ្វើឱ្យបុគ្គលដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ ឬ ការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ ១៦._

ក្នុងករណីម្ចាស់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ផ្តល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ឬប្រព្រឹត្តរំលោភលើកាតព្វកិច្ចដូចមានចែងក្នុងប្រការ ១៣ ជំពូកទី៥ នៃប្រកាសនេះអាចជាកម្មវត្ថុនៃការពិន័យ ដែលមានកំណត់ក្នុងប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

ប្រការ ១៧._

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ដែលចេញដោយក្រសួងទេសចរណ៍ ដែលមានសុពលភាពត្រូវបន្តអនុវត្តរហូតដល់អស់សុពលភាព។

មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានបំណងស្នើសុំអាជ្ញាបណ្ណថ្មី ឬបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ត្រូវអនុវត្តតាមលក្ខខណ្ឌ និងការកំណត់ដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ ១៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៩._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ក្រុមអ្នកច្បាប់ គ្រប់នាយកដ្ឋាននៃក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

កន្លែងទទួល
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត

  *"ដើម្បីជូនជ្រាប"*
- គ្រប់សហគមន៍មូលដ្ឋានទេសចរណ៍

  *"ដើម្បីអនុវត្ត"*
- ដូចប្រការ ១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ

ស្តីពី

# ការកំណត់តំបន់ប្រតិបត្តិការសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់

ប្រកាស លេខ..................ចុះថ្ងៃទី.........ខែ..........ឆ្នាំ ២០១៤

ការកំណត់តំបន់ប្រតិបត្តិការសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ត្រូវផ្តោតទៅលើរមណីយដ្ឋានបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ ទំនៀមទំលាប់ ប្រពៃណី ភាពញញឹមរាក់ទាក់ ព្រមទាំងភាពសម្បូរបែបនៃទេសភាពធម្មជាតិដ៏ស្រស់បំព្រងនៅលើទឹកដីកម្ពុជា។ ពិសេស ការទាក់ទាញនៃភាពទោលរបស់ឧទ្យានបេតិកភណ្ឌ អង្គរ រមណីយដ្ឋានសក្ការៈនៃប្រាសាទព្រះវិហារ បន្ទាប់មកមាន សត្វផ្សោតទន្លេមេគង្គ តំបន់ជីវចម្រុះ បឹងទន្លេសាប តំបន់ទាក់ទាញបែបធម្មជាតិ តំបន់ឆ្នេរ និងតំបន់អេកូទេសចរណ៍ នៅភូមិភាគឦសានភូមិភាគនិរតី និងបឹងទន្លេសាប។

តំបន់ប្រតិបត្តិការសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ត្រូវបានកំណត់ដូចខាងក្រោម៖

- តំបន់ភ្នំពេញ និងតំបន់ជុំវិញ រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង។
- តំបន់សៀមរាបអង្គរ និងតំបន់ជុំវិញ រួមមាន ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន និង ខេត្តពោធិ៍សាត់។
- តំបន់ឆ្នេរ រួមមាន ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និង ខេត្តកែប។
- ភូមិភាគឦសាន រួមមាន ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគីរី និង ខេត្តមណ្ឌលគីរី។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
*Kingdom of Wonder*

ក្រសួងទេសចរណ៍

លេខ ១៣៩ ទស.ក

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
ប្រភពលិខិត: ...
លេខ: 139 ... ថ្ងៃ 04/9/16
ឯកភាពតាមមតិដឹកនាំ: ...

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៦

ស្ដីពី

## ការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្រលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្ដីពីការកែសម្រួលមុខងារនិងភារកិច្ចនិងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្ដីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍។



អគារលេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website:www.mot.kh

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១._**

ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធានក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ដើម្បីបម្រើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២._**

ប្រកាសនេះ មានគោលដៅដូចតទៅ ៖

- ពង្រឹងការគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ឱ្យទទួលបាននូវប្រសិទ្ធភាព និងគុណភាព
- ធានាឱ្យមានការគោរពតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
- ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ និងធានាដល់ការថែរក្សាវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ល្អរបស់ព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ទំនុកចិត្តដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

**ប្រការ ៣._**

វាក្យស័ព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះមានដូចតទៅ ៖

**មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍** សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ដែលផ្តល់ដោយមន្ទីរទេសចរណ៍រាជធានី ខេត្ត ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍នៅក្នុងសហគមន៍របស់ខ្លួនតែប៉ុណ្ណោះ។

## ជំពូកទី ២

## សមត្ថកិច្ចក្នុងការគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍

**ប្រការ ៤._**

មន្ទីរទេសចរណ៍រាជធានី ខេត្ត ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍។

មន្ទីរទេសចរណ៍រាជធានី ខេត្ត មានសមត្ថកិច្ចក្នុងការផ្តល់ការបន្តអាជ្ញាបណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ និងលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន។

**ប្រការ ៥._**

អាជ្ញាបណ្ណទេសចរណ៍មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ត្រូវបានផ្តល់ឱ្យមគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់ប្រតិបត្តិការទៅតាមគោលដៅទេសចរណ៍ក្នុងសហគមន៍របស់ខ្លួន។

**ប្រការ ៦._**

គ្មានបុគ្គលណាអាចប្រកបវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍បានទេ ប្រសិនបើបុគ្គលនោះមិនទទួលបានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ពីមន្ទីរទេសចរណ៍រាជធានី ខេត្ត។

## ជំពូកទី ៣

## វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍

**ប្រការ ៧._**

បុគ្គលដែលស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍នៅមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Online) (តាមរយៈគេហទំព័រទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានផ្សេងៗទៀតដូចខាងក្រោម៖

ក. ត្រូវមានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី១៨ឆ្នាំ ឡើងទៅ

ខ. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

គ. វិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ ដោយមន្ទីរទេសចរណ៍រាជធានី ខេត្ត (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ឃ. លិខិតបញ្ជាក់កិរិយាមាយាទចេញដោយសហគមន៍ដែលខ្លួនរស់នៅ

ង. កិច្ចសន្យាគោរពច្បាប់រដ្ឋ

ច. ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត

ឆ. រូបថតទំហំ (៤x៦) ចំនួន០៣ សន្លឹក

**ប្រការ ៨._**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលស្នើសុំបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ត្រូវមកដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍នៅមន្ទីរទេសចរណ៍រាជធានី ខេត្ត ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានផ្សេងៗទៀតដូចខាងក្រោម ៖

ក. អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ (ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ខ. ព្រឹត្តបត្រព័ត៌មាន និងការវាយតម្លៃមគ្គុទ្ទេសក៍ទេសចរណ៍

គ. លិខិតបញ្ជាក់កិរិយាមាយាទដែលចេញដោយសហគមន៍ដែលខ្លួនរស់នៅ

ឃ. រូបថតទំហំ (៤x៦) ចំនួន០៣ សន្លឹក។

**ប្រការ ៩._**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍មិនត្រូវបានយកកម្រៃឡើយ។

**ប្រការ ១០._**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍មានសុពលភាពរយៈពេល០២ (ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍។

ម្ចាស់អាជ្ញាបណ្ណត្រូវមកដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ឱ្យបាន ៣០ (សាមសិប)ថ្ងៃ យ៉ាងតិចមុនថ្ងៃផុតសុពលភាព។

**ប្រការ ១១._**

ម្ចាស់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ត្រូវប្រើប្រាស់អាជ្ញាបណ្ណនេះឱ្យបានត្រឹមត្រូវតាមការណែនាំ និងបទប្បញ្ញត្តិនានារបស់មន្ទីរទេសចរណ៍រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធ។

ក្នុងករណីមានការខូចខាត ឬបាត់បង់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ម្ចាស់អាជ្ញាបណ្ណត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតាឡើងវិញក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានខូចខាត ឬបាត់បង់។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ត្រូវកាន់តាមខ្លួននូវលិខិតបញ្ជាក់ពីការដឹងឮរបស់សមត្ថកិច្ចមុនពេលទទួលបានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតា។

## ជំពូកទី ៤

## ការសុំព្យួរអាជ្ញាបណ្ណទេសចរណ៍

**ប្រការ ១២._**

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍អាចស្នើសុំព្យួរអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍បាន។ ការស្នើសុំព្យួរអាជ្ញាបណ្ណទេសចរណ៍នីមួយៗមានរយៈពេលកំណត់មិនលើសពី ០២ (ពីរ) ឆ្នាំ។ ក្នុងករណីមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍បានស្នើសុំព្យួរអាជ្ញាបណ្ណទេសចរណ៍ចំនួន ០២ (ពីរ) ដងជាប់គ្នា ហើយមានបំណងដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ឡើងវិញ ត្រូវចូលរួមវគ្គវិក្រឹតការមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ដែលរៀបចំដោយមន្ទីរទេសចរណ៍រាជធានី ខេត្ត។

## ជំពូកទី៥

## ភារកិច្ចរបស់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍

**ប្រការ ១៣._**

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ត្រូវអនុវត្តន៍ឲ្យបានខ្ជាប់ខ្ជួនរាល់បទប្បញ្ញត្តិជាធរមានក្នុងវិស័យទេសចរណ៍ ពិសេសការអនុវត្តក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៦

## ទណ្ឌកម្ម

**ប្រការ ១៤._**

មគ្គុទ្ទេសក៍ទេសចរណ៍ ដែលប្រើប្រាស់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ហួសសុពលភាព នឹងត្រូវទទួលពិន័យដោយការដកពិន្ទុចំនួន ០៥ ក្នុងករណីមិនរាងចាល និងបានប្រព្រឹត្តកំហុសលើកក្រោយនឹងទទួលរងការពិន័យតាមរយៈការព្យួរអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេល ០៦ខែ និងអាចឈានដល់ការលុបអាជ្ញាបណ្ណទេសចរណ៍តែម្តង ប្រសិនបើនៅតែប្រព្រឹត្តកំហុសនេះដដែល។

មន្ទីរទេសចរណ៍រាជធានី ខេត្ត នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់អាជ្ញាបណ្ណស្តីពីការដាក់ពិន័យនេះ។

បុគ្គលដែលប្រកបអាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ ដោយគ្មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ស្មើនឹង ២.០០០.០០០ (ពីរលាន)រៀល។

ការពិន័យអន្តរការណ៍មិនធ្វើឲ្យបុគ្គលដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ឬ ការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ១៥.-**

ក្នុងករណីម្ចាស់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ផ្តល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ឬប្រព្រឹត្តរំលោភលើកាតព្វកិច្ចដូចមានចែងក្នុងប្រការ១៣ ជំពូកទី៥នៃប្រកាសនេះ អាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍តាមច្បាប់។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៧.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធានគ្រប់នាយកដ្ឋាននៃក្រសួងទេសចរណ៍ និងប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

**ថោង ខុន**

**កន្លែងទទួល**
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- -សាលារាជធានី-ខេត្ត «ដើម្បីជូនជ្រាប»
- -មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ "ដើម្បីអនុវត្ត"
- -ដូចប្រការ ១៧
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១១៣ ប្រក

ថ្ងៃសុក្រ ៨ កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៩

# ប្រកាស
## ស្តីពី
## ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការិទេសចរណ៍ ភ្នាក់ងារទេសចរណ៍ និងសាខា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងប្រកាសលេខ១៤៥ ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍។

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងពង្រឹងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងលើកកម្ពស់គុណភាពសេវាកម្មការិទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ដើម្បីបង្កើនការទាក់ទាញទេសចរជាតិនិងអន្តរជាតិ។



អាគារ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ២ ._**

ប្រកាសនេះមានគោលដៅកំណត់អំពីវិធាន និងយន្តការគ្រប់គ្រងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយដែលធ្វើអាជីវកម្មកក់ ឬលក់សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ឬរៀបចំនិងបង្កើតខ្សែទស្សនកិច្ចជូនភ្ញៀវទេសចរណ៍ក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ._**

បច្ចេកសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមានន័យ ដូចខាងក្រោម ៖

- បុគ្គល សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល
- ប្រតិបត្តិករទេសចរណ៍ សំដៅដល់បុគ្គលដែលប្រតិបត្តិ ប្រកបអាជីព ឬធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍
- សាខា សំដៅដល់ការិយាល័យតំណាងឱ្យការីទេសចរណ៍ឬភ្នាក់ងារទេសចរណ៍ ដែលធ្វើសកម្មភាពក្នុងដែនកំណត់ដែលមានការយល់ព្រមតាមកិច្ចសន្យា
- ការីទេសចរណ៍ សំដៅដល់បុគ្គលដែលរៀបចំនិងលក់ខ្សែទស្សនកិច្ច ព្រមទាំងប្រមូលផ្តុំសេវាកម្មទេសចរណ៍ផ្សេងៗទៀតសម្រាប់លក់ដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា
- ភ្នាក់ងារទេសចរណ៍ សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀតរាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតឡើងដោយការីទេសចរណ៍ផងដែរ។
- ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ជាលក្ខណៈគ្រួសារ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មផ្សេងៗទៀតរាប់បញ្ចូលខ្សែទស្សនកិច្ច ដែលបង្កើតឡើងដោយការីទេសចរណ៍ដែលនាំភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៥ ._**

ការីទេសចរណ៍ (Tour Operators) ត្រូវបានបែងចែកជា០៣(បី)ប្រភេទ ដូចតទៅ៖

- ការីទេសចរណ៍ដែលនាំភ្ញៀវចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវនៅក្រៅប្រទេសចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា
- ការីទេសចរណ៍ដែលនាំភ្ញៀវទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators) សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា

- ការីទេសចរណ៍ដែលនាំភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators) សំដៅដល់បុគ្គលសញ្ជាតិខ្មែរដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

ភ្នាក់ងារទេសចរណ៍ (Travel Agent) ត្រូវបានចែកចេញជា០២(ពីរ)ប្រភេទ ដូចតទៅ៖

- ភ្នាក់ងារទេសចរណ៍ (Travel Agent) សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗរាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតដោយការីទេសចរណ៍ផងដែរ
- ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ជាលក្ខណៈគ្រួសារ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍និងសេវាកម្មផ្សេងៗទៀត រាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតឡើងដោយការីទេសចរណ៍ដែលនាំភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៦**

អាជ្ញាបណ្ណទេសចរណ៍ត្រូវបានផ្តល់ទៅតាមប្រភេទអាជីវកម្មសម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍រួមមាន៖

- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ដែលនាំភ្ញៀវចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators)
- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ដែលនាំភ្ញៀវទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators)
- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ដែលនាំភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators)
- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ភ្នាក់ងារទេសចរណ៍ (Travel Agent)
- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent)។

**ប្រការ៧**

លក្ខណៈវិនិច្ឆ័យនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) ត្រូវបានកំណត់ ដូចខាងក្រោម៖

ក. បុគ្គលដែលមានសញ្ជាតិខ្មែរ

ខ. ធ្វើប្រតិបត្តិការអាជីវកម្មក្នុងដែនកំណត់មួយក្នុងតំបន់ ឬរាជធានីខេត្តដែលខ្លួនរស់នៅ

គ. ធ្វើអាជីវកម្មទេសចរណ៍ខ្នាតតូច ជាលក្ខណៈគ្រួសារដែលមិនជាប់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

ឃ. ទទួលផលរបរប្រចាំឆ្នាំមិនលើសពី៥០.០០០.០០០(ហាសិបលាន)រៀល និងមានដើមទុនតិចជាង ឬស្មើ២០.០០០.០០០(ម្ភៃលាន)រៀល

ង. មានបុគ្គលិកបម្រើការងារតិចជាង៤នាក់ និងមានទីតាំងទីស្នាក់ការដែលមានទំហំមិនលើសពី៣(បី)ម៉ែត្រការ៉េ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍

**ប្រការ៨ .**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ការត្រួតពិនិត្យ វាយតម្លៃការផ្តល់ ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្នអាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខា។

ការធ្វើប្រតិភូកម្មមុខងារផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខា ឱ្យមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ៩ .**

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខាបានដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ដែលផ្តល់ដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

**ប្រការ១០ .**

បុគ្គលដែលប្រកបអាជីវកម្មទេសចរណ៍ច្រើនប្រភេទនៅលើទីតាំងតែមួយ ប្រភេទអាជីវកម្មនីមួយៗត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ផ្សេងៗគ្នា។

បុគ្គលដែលប្រកបអាជីវកម្មទេសចរណ៍មួយប្រភេទ ហើយមានសាខាច្រើនកន្លែង សាខានីមួយៗនោះត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ផ្សេងៗគ្នា។

## ជំពូកទី៣
## វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍

**ប្រការ១១ .**

បុគ្គលដែលប្រកបអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ឬបើកសាខាត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មាន(ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក. វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
ខ. លិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្មពីធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍
គ. លិខិតបញ្ជាក់ទីស្នាក់ការ ឬកិច្ចសន្យាជួលផ្ទះដោយមានបញ្ជាក់ពីភូមិ ឬឃុំ/សង្កាត់
ឃ. កិច្ចសន្យារបស់ប្រត្តិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម
ង. អត្តសញ្ញាណបណ្ណសញ្ញាតិខ្មែរ ឬលិខិតឆ្លងដែន(សម្រាប់ជនបរទេស)
ច. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ(៤x៦)ចំនួន៣សន្លឹក។

**ប្រការ១២ .**

បុគ្គលដែលស្នើសុំបន្តអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខាត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក. អាជ្ញាបណ្ណទេសចរណ៍(ថតចម្លង)

ខ. របាយការណ៍សកម្មភាពអាជីវកម្មឆ្នាំមុន

គ. កិច្ចសន្យារបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ក្នុងការប្រកបអាជីវកម្ម

ឃ. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ(៤x៦)ចំនួន៣សន្លឹក។

**ប្រការ១៣ .**

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ (ថ្មី បន្ត ឬបិទអាជីវកម្ម) ត្រូវបានកែសម្រួល និងបន្ថែមក្នុងករណី ដូចខាងក្រោម៖

ក. ករណីមានការផ្ទេរសិទ្ធិឈ្មោះ ឬប្តូរម្ចាស់អាជ្ញាបណ្ណទេសចរណ៍ អ្នកស្នើសុំអាជ្ញាបណ្ណការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ដែលជាអ្នកទទួលសិទ្ធិឈ្មោះ ឬម្ចាស់អាជ្ញាបណ្ណទេសចរណ៍នោះត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ១១ និងប្រការ១២ ដូចខាងក្រោម៖

១. លិខិតប្រគល់សិទ្ធិ

២. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់អ្នកផ្ទេរសិទ្ធិ (ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ចាស់ដែលត្រូវប្តូរ)

៣. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ (ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ថ្មី)

ខ. ករណីប្តូរនាមករណ៍ អ្នកស្នើសុំអាជ្ញាបណ្ណការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ១១ និងប្រការ១២ ដូចខាងក្រោម៖

១. លិខិតអនុញ្ញាតឲ្យប្តូរនាមករណ៍ថ្មីចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត

២. កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ទទួលខុសត្រូវចំពោះនាមករណ៍ចាស់។

**ប្រការ១៤ .**

បុគ្គលដែលប្រកបអាជីវកម្មភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) ឬមានសាខាត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍តាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក. វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មពីមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត ឬការិយាល័យច្រកចេញចូលតែមួយរបស់សាលារាជធានីខេត្ត

ខ. លិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្មពីធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍

គ. កិច្ចសន្យារបស់ប្រត្តិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម
ឃ. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន
ង. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ(៤x៦)ចំនួន៣សន្លឹក។

**ប្រការ១៥.–**

បុគ្គលដែលស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) រួមទាំងសាខា ត្រូវដាក់ពាក្យស្នើសុំពីក្រសួងទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួន ដូចខាងក្រោម៖

ក. អាជ្ញាបណ្ណទេសចរណ៍(ថតចម្លង)
ខ. កិច្ចសន្យារបស់ប្រត្តិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម
គ. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ(៤x៦)ចំនួន៣សន្លឹក។

ករណីមានការផ្ទេរសិទ្ធិឈ្មោះ ឬប្តូរម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬប្តូរនាមករណ៍របស់ភ្នាក់ងារទេសចរណ៍ក្នុងស្រុកត្រូវអនុវត្តដូចចែងក្នុងប្រការ១៣នៃប្រកាសនេះ។

**ប្រការ១៦.–**

ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងជូនដំណឹងទៅអ្នកស្នើសុំអំពីសេចក្តីសម្រេចឯកភាពផ្តល់ឲ្យ ឬមិនឯកភាពផ្តល់ឲ្យក្នុងរយៈពេល២៨(ម្ភៃប្រាំបី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកស្នើសុំបានបំពេញបែបបទត្រឹមត្រូវឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ១៧.–**

អាជ្ញាបណ្ណទេសចរណ៍មានសុពលភាពរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍ដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១៨.–**

ប្រសិនបើអ្នកស្នើសុំបានបំពេញបែបបទឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវនានាដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងចេញអាជ្ញាបណ្ណទេសចរណ៍ជូនអ្នកស្នើសុំមានសុពលភាពរយៈពេល០១(មួយ)ឆ្នាំ។ ក្នុងករណី អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពុំអាចបំពេញបែបបទឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវនានាដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចចេញអាជ្ញាបណ្ណបណ្តោះអាសន្នដែលមានសុពលភាពរយៈ៩០(កៅសិប)ថ្ងៃ ក្រោយពេលអ្នកស្នើសុំបានបង់កម្រៃអាជ្ញាបណ្ណទេសចរណ៍រួច ដោយតម្រូវឱ្យអ្នកស្នើសុំធ្វើកិច្ចសន្យាបំពេញបន្ថែមនូវលក្ខខណ្ឌដែលមិនពេញលេញជាលាយលក្ខណ៍អក្សរ។

ក្នុងរយៈពេលកំណត់នៃកិច្ចសន្យា បើម្ចាស់អាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នបានបំពេញតាមលក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងផ្តល់អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិដល់អ្នកស្នើសុំ។

ផ្ទុយទៅវិញក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញតាមលក្ខណវិនិច្ឆ័យនៃប្រកាសនេះ និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា អាជ្ញាបណ្ណបណ្តោះអាសន្នដែលចេញដោយក្រសួងទេសចរណ៍ ឬ

មន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិអស់សុពលភាពនឹងត្រូវចាត់ទុកថាជាការធ្វើអាជីវ-កម្មដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ១៩ ._**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ត្រូវដាក់ពាក្យសុំបន្តអាជ្ញាបណ្ណទេសចរណ៍ឲ្យបាន៣០(សាមសិប)ថ្ងៃ យ៉ាងតិច មុនថ្ងៃផុតកំណត់នៃសុពលភាពអាជ្ញាបណ្ណទេសចរណ៍ចាស់។

ក្នុងករណីដែលម្ចាស់អាជ្ញាបណ្ណទេសចរណ៍នៅតែបន្តអាជីវកម្មលើអាជ្ញាបណ្ណទេសចរណ៍ដែលអស់សុពលភាពនឹងត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ២០ ._**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍អាចធ្វើការផ្ទេរ ឬលក់អាជ្ញាបណ្ណទេសចរណ៍របស់ខ្លួនបាន ដោយត្រូវដាក់ពាក្យស្នើសុំមកក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានីខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្ទេរ ឬលក់អាជ្ញាបណ្ណទេសចរណ៍អាចប្រព្រឹត្តទៅបានដោយអនុវត្តតាមលក្ខខណ្ឌ ដែលមានចែងក្នុងវាក្យខណ្ឌទី២នៃមាត្រា៤៣ នៃច្បាប់ស្តីពីទេសចរណ៍។

**ប្រការ២១ ._**

ប្រតិបត្តិករទេសចរណ៍អាចដាក់ពាក្យស្នើសុំព្យួរអាជ្ញាបណ្ណទេសចរណ៍របស់ខ្លួន ជាបណ្តោះអាសន្នបានក្នុងរយៈពេល០១ឆ្នាំ ការស្នើសុំនេះមិនត្រូវលើសពី០២ ដោយមានការយល់ព្រមពីក្រសួងទេសចរណ៍ និង/ឬមន្ទីរទេសចរណ៍រាជធានីខេត្ត និង/ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៤
## លក្ខខណ្ឌនៃការប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍របស់ប្រតិបត្តិករទេសចរណ៍

**ប្រការ២២ ._**

ម្ចាស់អាជ្ញាបណ្ណការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ព្រមទាំងសាខាត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

ក. ត្រូវប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍ឲ្យបានត្រឹមត្រូវ ស្របតាមកម្មវត្ថុនៃអាជីវកម្មរបស់ខ្លួន និងត្រូវគោរពច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងអនុវត្តតាមការណែនាំនានារបស់ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ។

ខ. មិនត្រូវបានអនុញ្ញាតឲ្យបុគ្គល ឬការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ឬសាខាដទៃប្រើប្រាស់នាមករណ៍អាជ្ញាបណ្ណរបស់ខ្លួនឡើយ។

គ. មិនត្រូវបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការឈរឈ្មោះតំណាងឲ្យការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ ឬសាខាដទៃ ក្រៅពីការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ និងសាខារបស់ខ្លួនឡើយ។

ឃ. ត្រូវដាក់តាំងអាជ្ញាបណ្ណទេសចរណ៍នៅកន្លែងទទួលភ្ញៀវដែលងាយមើលឃើញច្បាស់។

ង. ក្នុងករណីមានការខូចខាត ឬបាត់បង់អាជ្ញាបណ្ណទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំអាជ្ញាបណ្ណទសចរណ៍ទុតិយតាក្នុងរយៈពេល៣០(សាបសិប)ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់។

# ជំពូកទី៥
## ប្រាក់តម្កល់ និងអាជ្ញាបណ្ណទេសចរណ៍សម្រាប់
## ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍

**ប្រការ២៣ .**

ប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ត្រូវបានកំណត់ទៅតាមវិសាលភាពនិងទំហំអាជីវកម្ម ដូចខាងក្រោម ៖

ក. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ ដែលអាចធ្វើអាជីវកម្មរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក។

ខ. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ ដែលអាចធ្វើអាជីវកម្មរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៧.០០០(ប្រាំពីរពាន់)ដុល្លារអាមេរិក។

គ. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ភ្នាក់ងារទេសចរណ៍ (Travel Agent) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក។

ឃ. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ ដែលអាចធ្វើអាជីវកម្មរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា កម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន២.០០០(ពីរពាន់)ដុល្លារអាមេរិក។

ង. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៥០០(ប្រាំរយ)ដុល្លារអាមេរិក។

ច. ចំពោះប្រតិបត្តិករទេសចរណ៍ ដែលមានអាជ្ញាបណ្ណទេសចរណ៍ជាការីទេសចរណ៍ច្រើនប្រភេទ រួមមាន អាជ្ញាបណ្ណជាការីទេសចរណ៍ផង និងភ្នាក់ងារទេសចរណ៍ផង ហើយស្ថិតក្រោមឈ្មោះតែមួយត្រូវតម្កល់ប្រាក់ក្នុងកម្រិតទឹកប្រាក់ខ្ពស់ជាងគេ។

ឆ. សាខាមិនត្រូវឱ្យតម្កល់ប្រាក់ធានាអាជីវកម្មដោយឡែកឡើយ ក្នុងករណីដែលការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍(ស្នាក់ការកណ្តាល) របស់ខ្លួនបានអនុវត្តនីតិវិធីនៃការដាក់ប្រាក់តម្កល់ធានាអាជីវកម្មរួចរាល់ហើយ។

ក្រសួងទេសចរណ៍ទទួលបន្ទុកគ្រប់គ្រងលើប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍។

**ប្រការ២៤ .**

ប្រតិបត្តិករទេសចរណ៍អាចដាក់ពាក្យសុំដកប្រាក់តម្កល់ធានាអាជីវកម្មរបស់ខ្លួនមកវិញបាន នៅពេលបិទអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍។ ក្នុងករណីនេះ ប្រតិបត្តិករទេសចរណ៍ត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ និងធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈជាមុនក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃបិទអាជីវកម្មរបស់ខ្លួន។

ការបិទអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវបានអនុញ្ញាត ក្នុងករណីដែលការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ដំណើរការអាជីវកម្មបានយ៉ាងហោចណាស់៩០ថ្ងៃ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍។

ប្រតិបត្តិករទេសចរណ៍ដែលជាម្ចាស់អាជីវកម្មត្រូវធ្វើកិច្ចសន្យាជានា និងទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងករណីមានការពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុជាមួយនឹងដៃគូផ្សេងៗរបស់ខ្លួនកន្លងមក។ ក្រសួងទេសចរណ៍នឹងពិនិត្យសម្រេចអនុញ្ញាតលើការបិទអាជីវកម្ម ក្នុងរយៈពេលមិនលើសពី២៨(ម្ភៃប្រាំបី)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។

**ប្រការ២៥ ._**

កម្រៃអាជ្ញាបណ្ណទេសចរណ៍ ឬការអនុញ្ញាឱ្យបន្តអាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ត្រូវអនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងទេសចរណ៍។

## ជំពូកទី៦
## ភារកិច្ចរបស់ប្រតិបត្តិករទេសចរណ៍

**ប្រការ២៦ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវមានកាតព្វកិច្ចដែលមានចែងក្នុងមាត្រា៤៨ នៃច្បាប់ស្តីពីទេសចរណ៍ និងអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ដែលរៀបចំដោយក្រសួងទេសចរណ៍ ឬសមាគមឧស្សាហកម្មទេសចរណ៍ ឬអង្គការទេសចរណ៍ពិភពលោកឲ្យបានល្អ។

**ប្រការ២៧ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវមានផែនការ និងមានសកម្មភាពបណ្តុះបណ្តាល និងហ្វឹកហ្វឺនដល់បុគ្គលិកបម្រើការងារអំពីជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ស្របតាមការណែនាំរបស់ក្រសួងទេសចរណ៍។

**ប្រការ២៨ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវផ្តល់របាយការណ៍ និងស្ថិតិពីអាជីវកម្មរបស់ខ្លួនជូនក្រសួងទេសចរណ៍រៀងរាល់០៣ខែម្តង និងទៅតាមការស្នើសុំរបស់ក្រសួងទេសចរណ៍។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**ប្រការ២៩ ._**

ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ រួមទាំងសាខា ដែលប្រកបអាជីវកម្មដោយប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍ហួសសុពលភាព ឬប្រព្រឹត្តខុសក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់អនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងទេសចរណ៍។

**ប្រការ៣០ ._**

ជនណាដែលក្លែងអាជ្ញាបណ្ណការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ឬឯកសារសាធារណៈផ្សេងៗ ត្រូវផ្តន្ទាទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ៣១ ._**

ប្រកាសលេខ០៤១ ប្រក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣២ ._**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣៣ ._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គាធិការ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ និងប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

**ថោង ខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
- សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា (PATA)
- ដូចប្រការ៣៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០៤០ ប្រក

ថ្ងៃសុក្រ ៨ រោចខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០១៨

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស ៩០៣/០៩១៣/រកត/ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២ ៩៤/នស/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស១៥/០១៩៦/រកម/ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៤៥ ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ



អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ១._**

ប្រកាសនេះមានគោលបំណងកំណត់អំពីធានក្នុងការគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹករបស់ក្រុមហ៊ុនដឹកជញ្ជូន មធ្យោបាយដឹកជញ្ជូនផ្ទាល់ខ្លួន និងរាល់សេវាកម្មដឹកជញ្ជូនតាមផ្លូវទឹកដទៃទៀតដែលបម្រើឱ្យវិស័យទេសចរណ៍។

**ប្រការ២._**

ប្រកាសនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកឱ្យកាន់តែមានប្រសិទ្ធិភាព
- ធានាឱ្យបាននូវគុណភាពសេវាកម្មទេសចរណ៍ដ៏ល្អប្រសើរជូនដល់ទេសចរជាតិ និងអន្តរជាតិ ។
- ចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ រក្សាឱ្យបាននូវសណ្តាប់ធ្នាប់ សុវត្ថិភាព ព្រមទាំងធានាដល់ការរក្សាវប្បធម៌ប្រពៃណី និងសេចក្តីថ្លៃថ្នូររបស់ជាតិ ។

**ប្រការ៣._**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើសកម្មភាពអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹករបស់ក្រុមហ៊ុនដឹកជញ្ជូន មធ្យោបាយដឹកជញ្ជូនផ្ទាល់ខ្លួន និងរាល់សេវាកម្មដឹកជញ្ជូនតាមផ្លូវទឹកក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤._**

វាក្យស័ព្ទនៅក្នុងប្រកាសនេះត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក** ៖ សំដៅដល់អាជីវកម្មដែលប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមនាវាទេសចរណ៍ កាណូតទេសចរណ៍ ដែលមានគោលបំណងបម្រើការកម្សាន្តដល់ទេសចរជាតិ និងអន្តរជាតិ ឬបម្រើឱ្យវិស័យទេសចរណ៍។

## ជំពូកទី ២

## សមត្ថកិច្ចគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក

**ប្រការ៥._**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ការត្រួតពិនិត្យ និងវាយតម្លៃការផ្តល់អាជ្ញាបណ្ណដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក។

ការធ្វើប្រតិភូកម្មអំណាចក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកដល់មន្ទីរទេសចរណ៍រាជធានី ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ៦._**

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ដែលផ្តល់ដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

ប្រការ៧._

ការផ្តល់ ឬការបន្តអាជ្ញាបណ្ណទេសចរណ៍ ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ មកជាអាជ្ញាបណ្ណបណ្ដោះអាសន្នជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី ៣

## វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក

ប្រការ៨._

បុគ្គលដែលមានបំណងប្រកបអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នៅក្រសួងទេសចរណ៍តាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ជាផ្លូវការដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក.វិញ្ញាបនប័ត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ខ.សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសផ្តល់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូន

គ.អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកគ្រប់គ្រង (សម្រាប់ជនបរទេស)

ឃ.ប័ណ្ណធានារ៉ាប់រងលើអ្នកដំណើររបស់ក្រុមហ៊ុនដឹកជញ្ជូនទេសចរណ៍ (ប្រសិនបើមាន)

ង.កិច្ចសន្យាគោរពច្បាប់រដ្ឋ និងអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់រដ្ឋជាធរមាន

ច.រូបថតជលយាន្ត (១០cm x ១៥cm)ចំនួន ០២ សន្លឹក

ឆ.រូបថត(៤ x ៦) របស់អ្នកគ្រប់គ្រង ចំនួន ០៣សន្លឹក។

ប្រការ៩._

បុគ្គលដែលស្នើសុំបន្តអាជ្ញាបណ្ណដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកត្រូវដាក់ពាក្យស្នើសុំ នៅក្រសួងទេសចរណ៍តាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ជាផ្លូវការដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក.អាជ្ញាបណ្ណទេសចរណ៍ឆ្នាំចាស់ (ថតចម្លងមានត្រាក្រហម)

ខ.កិច្ចសន្យាគោរព និងអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់រដ្ឋនានាជាធរមាន

គ.រូបថត (៤ x ៦) របស់អ្នកគ្រប់គ្រងចំនួន ០៣ សន្លឹក។

ប្រការ១០._

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក (ផ្ទេរសិទ្ធិអ្នកគ្រប់គ្រង ប្តូរឈ្មោះអាជីវកម្ម បិទ ឬផ្អាកអាជីវកម្ម) ត្រូវបានកែសម្រួល និងបន្ថែមក្នុងករណីដូចខាងក្រោម៖

ក. ករណីមានការផ្ទេរសិទ្ធិអ្នកឈរឈ្មោះ ឬប្តូរម្ចាស់អាជ្ញាបណ្ណទេសចរណ៍ អ្នកស្នើសុំអាជ្ញាបណ្ណដែលជាអ្នកទទួលសិទ្ធិឈរឈ្មោះ ឬម្ចាស់អាជ្ញាបណ្ណទេសចរណ៍នោះ ត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ ដូចខាងក្រោម៖

១. លិខិតប្រគល់សិទ្ធិ

២. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់អ្នកផ្ទេរសិទ្ធិ និងអ្នកទទួលសិទ្ធិ

ខ. ករណីប្តូរនាមករណ៍ អ្នកស្នើសុំអាជ្ញាបណ្ណដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក ត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នូវ៖

១. លិខិតអនុញ្ញាតឱ្យប្តូរនាមករណ៍ថ្មីដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត

គ. ករណីសុំផ្អាក ឬបិទអាជីវកម្មត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ ៖

១.ម្ចាស់អាជីវកម្មត្រូវជូនដំណឹងសុំបិទ ឬផ្អាកមកក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់មកជាមួយនូវអាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើមក្នុងសុពលភាព

២.ប្រតិបត្តិករទេសចរណ៍អាចដាក់ពាក្យស្នើសុំព្យួរអាជ្ញាទេសចរណ៍ជាបណ្តោះអាសន្នក្នុងរយៈពេល ០១ (មួយ)ឆ្នាំ ការស្នើសុំនេះមិនត្រូវលើសពី០២ (ពីរ)ដង ដោយមានការយល់ព្រមពីក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១១.**_

ការយកកម្រៃលើការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ឬការអនុញ្ញាតឲ្យបន្តអាជ្ញាបណ្ណទេសចរណ៍សំរាប់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកត្រូវអនុលោមតាមប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍។

**ប្រការ១២.**_

នៅពេលអ្នកស្នើសុំអាជ្ញាបណ្ណបានបំពេញឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវទៅតាមបែបបទដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍នឹងចេញអាជ្ញាបណ្ណទេសចរណ៍ជូនអ្នកស្នើសុំសម្រាប់ធ្វើអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកក្នុងរយៈពេល២៨(ម្ភៃប្រាំបី)ថ្ងៃ នៃថ្ងៃធ្វើការ។

ប្រសិនបើអ្នកស្នើសុំពុំអាចបំពេញតាមបែបបទ និងលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍អាចអនុញ្ញាតឱ្យអ្នកស្នើសុំធ្វើកិច្ចសន្យាបំពេញបន្ថែមនូវលក្ខខណ្ឌដែលមិនពេញលេញជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ ក្រសួងទេសចរណ៍នឹងចេញអាជ្ញាបណ្ណបណ្តោះអាសន្នដែលមានសុពលភាព ៩០(កៅសិប)ថ្ងៃ ក្រោយពេលអ្នកស្នើសុំបានបង់ប្រាក់កម្រៃអាជ្ញាបណ្ណទេសចរណ៍រួច។

ក្នុងរយៈពេលកំណត់នៃកិច្ចសន្យា បើម្ចាស់អាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នអាចបំពេញតាមលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍នឹងផ្តល់អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិដល់អ្នកស្នើសុំ។

ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃប្រកាសនេះ និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ហើយនៅតែបន្តអាជីវកម្មលើអាជ្ញាបណ្ណបណ្តោះអាសន្នដែលអស់សុពលភាពនឹងត្រូវចាត់ទុកថាការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ១៣.**_

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍អាចធ្វើការផ្ទេរ ឬលក់អាជ្ញាបណ្ណទេសចរណ៍របស់ខ្លួនបានដោយត្រូវដាក់ពាក្យស្នើសុំមកក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្ទេរ ឬការលក់អាជ្ញាបណ្ណ



៧/៤

អាចប្រព្រឹត្តទៅបានដោយគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី២ នៃមាត្រា៤៣ នៃច្បាប់ស្តីពីទេសចរណ៍។

## ជំពូកទី៤

## ភារកិច្ចរបស់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក

**ប្រការ១៤._**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ត្រូវប្រើប្រាស់អាជ្ញាបណ្ណនេះឱ្យបានត្រឹមត្រូវតាមកម្មវត្ថុនៃអាជីវកម្មរបស់ខ្លួន ហើយត្រូវគោរពអនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិនានារបស់ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ។

អាជ្ញាបណ្ណទេសចរណ៍ត្រូវដាក់តាំងនៅទីតាំងដែលងាយមើលឃើញច្បាស់។ ក្នុងករណីមានការខូចខាត ឬបាត់បង់អាជ្ញាបណ្ណទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចដើម្បីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ទុតិយតាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់។

**ប្រការ១៥._**

ប្រតិបត្តិករទេសចរណ៍ត្រូវអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងមាត្រា៤៨ នៃច្បាប់ស្តីពីទេសចរណ៍ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកដែលរៀបចំដោយក្រសួងទេសចរណ៍ ឬសមាគមឧស្សាហកម្មទេសចរណ៍។

**ប្រការ១៦._**

ប្រតិបត្តិករទេសចរណ៍ត្រូវមានផែនការ និងមានសកម្មភាពបណ្តុះបណ្តាល និងហ្វឹកហ្វឺនដល់បុគ្គលិកបម្រើការងារនូវជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ស្របតាមការណែនាំរបស់ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្ត។

**ប្រការ១៧._**

ប្រតិបត្តិករទេសចរណ៍ត្រូវផ្តល់របាយការណ៍ និងស្ថិតិពីអាជីវកម្មរបស់ខ្លួនជូនក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិរៀងរាល់បីខែម្តង និងទៅតាមការស្នើសុំរបស់ស្ថាប័នមានសមត្ថកិច្ច។

## ជំពូកទី៥

## ទោសបញ្ញត្តិ

**ប្រការ១៨._**

អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកដែលប្រកបអាជីវកម្មដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ ឬអាជ្ញាបណ្ណទេសចរណ៍ហួសសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា៦៥ នៃច្បាប់ស្តីពីទេសចរណ៍។ ទំហំទឹកប្រាក់នៃការពិន័យអន្តរការណ៍សំរាប់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍។

ការពិន័យអន្តរការណ៍នេះមិនធ្វើឱ្យម្ចាស់អាជីវកម្មរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

ជនណាដែលក្លែងអាជ្ញាបណ្ណដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក ឬឯកសារសាធារណៈផ្សេងៗត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១៩._**

ករណីដែលប្រតិបត្តិករទេសចរណ៍មិនអនុវត្តតាមប្រការដូចមានចែងក្នុងជំពូកទី៤ និងជំពូកទី៥ នៃប្រកាសនេះ ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងអនុវត្តនីតិវិធីតាមផ្លូវតុលាការ។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**ប្រការ២០._**

អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកដែលចេញដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិកន្លងមកដែលមានសុពលភាពនៅបន្តអនុវត្តរហូតដល់អស់សុពលភាព ។

ប្រតិបត្តិករទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកបន្តទៀត ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មដឹកជញ្ជូនតាមផ្លូវទឹកស្របតាមលក្ខខណ្ឌ និងការកំណត់ដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ២១._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងខ្លឹមសារនៃសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ២២._**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយដ្ឋាននីតិកម្ម ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត គ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**កន្លែងទទួល÷**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-សាលារាជធានី-ខេត្ត
-សមាគមដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក
-សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
-ដូចប្រការ ២២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ថោង ខុន**

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ០៣៤ ស.ជ.ក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧

# ប្រកាស
## ស្តីពី
## ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់មធ្យោបាយធ្វើអាជីវកម្ម ដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ / នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ដែលប្រកាសអោយប្រើប្រាស់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក. ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក. ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និងភារកិច្ច និង ការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួង ទេសចរណ៍
- យោងសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១ :** រាល់ការធ្វើអាជីវកម្មដោយប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវគោក របស់ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ របស់ក្រុមហ៊ុនដឹកជញ្ជូនទេសចរណ៍ និង មធ្យោបាយដឹកជញ្ជូនផ្ទាល់ខ្លួន សំរាប់ដឹកជញ្ជូនទេសចរជាតិ និង អន្តរជាតិ ធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក ត្រូវមានអាជ្ញាប័ណ្ណទេសចរណ៍ចេញដោយក្រសួងទេសចរណ៍ ។

**ប្រការ ២ :** ការផ្តល់ ឬ ការដកហូតអាជ្ញាប័ណ្ណទេសចរណ៍ ដល់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរ ធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក ជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។

**ប្រការ ៣ :** ការសុំអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ដោយអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួន :

ក- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកបើកបរ (ចំពោះរូបវន្តបុគ្គល) ។

ខ- ប័ណ្ណសំគាល់យានយន្ត ចេញដោយក្រសួង ឬមន្ទីរសាធារណៈការ និងដឹកជញ្ជូន ។

គ- ប័ណ្ណបើកបររថយន្ត (របស់អ្នកបើកបរ) ចេញដោយក្រសួង ឬមន្ទីរសាធារណៈការ និងដឹកជញ្ជូន ។

ឃ- សៀវភៅត្រួតពិនិត្យពីលក្ខណៈបច្ចេកទេសរបស់ក្រសួង ឬមន្ទីរសាធារណៈការ និងដឹកជញ្ជូន (មានសុពលភាព) ។

ង- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (របស់ក្រុមហ៊ុនដឹកជញ្ជូនទេសចរ) ។

ច- ប័ណ្ណធានារ៉ាប់រងភារៈទទួលខុសត្រូវអ្នកដំណើរ (របស់ក្រុមហ៊ុនដឹកជញ្ជូនទេសចរ) ។

ឆ- សញ្ញាប័ត្រ ឬ វិញ្ញាបនប័ត្ររបស់ម្ចាស់មធ្យោបាយដឹកជញ្ជូនទេសចរ ឬ អ្នកបើកបរ ដែលបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ។

**ប្រការ ៤ :** អាជ្ញាប័ណ្ណទេសចរណ៍ ត្រូវបានចេញអោយប្រើប្រាស់ ក្រោយពីអាជីវករបានបំពេញសំណុំឯកសារក្នុងការដាក់ពាក្យសុំធ្វើអាជីវកម្មគ្រប់គ្រាន់ និងត្រឹមត្រូវយ៉ាងយូរក្នុងរយៈពេល ២៨ ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានដាក់ពាក្យ ។ ក្នុងករណីដែលក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុងបដិសេធមិនផ្តល់ ឬ មិនបន្តអាជ្ញាប័ណ្ណទេសចរណ៍ ក្រសួង ឬ មន្ទីរទេសចរណ៍ នឹងបញ្ជាក់ហេតុផលជាលាយលក្ខ័អក្សរជូនដល់អាជីវករ មិនលើសពី ១០ថ្ងៃគិតពីថ្ងៃទទួលពាក្យ ។

**ប្រការ ៥ :** - នៅពេលអ្នកស្នើសុំអាជ្ញាប័ណ្ណ បានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវទៅតាមបែបបទដូចបានកំណត់ក្នុងប្រការ ៣ ក្រសួង ឬ មន្ទីរទេសចរណ៍ខេត្ត-ក្រុង នឹងចេញអាជ្ញាប័ណ្ណទេសចរណ៍សំរាប់ធ្វើអាជីវកម្ម ដែលមានសុពលភាពរយៈពេល ០១ឆ្នាំ ។

- ក្នុងករណីអាជីវករមិនអាចបំពេញបែបបទអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលា នោះអ្នកស្នើសុំអាចស្នើសុំដោយធ្វើកិច្ចសន្យាសុំជំពាក់ឯកសារជាបណ្តោះអាសន្ន និងធានាបំពេញក្នុងរយៈពេល ០៣ខែ ។ ស្ថិតក្នុងករណីនេះ ក្រសួង ឬ មន្ទីរទេសចរណ៍ នឹងចេញអាជ្ញាប័ណ្ណទេសចរណ៍សំរាប់ធ្វើអាជីវកម្មជាបណ្តោះអាសន្ន នឹងមានសុពលភាពរយៈពេល ០៣ ខែ ។ បន្ទាប់ពីបានបំពេញឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមកិច្ចសន្យា នោះក្រសួង ឬមន្ទីរទេសចរណ៍ នឹងផ្តល់អាជ្ញាប័ណ្ណដែលមានសុពលភាពរយៈពេល ០១ ឆ្នាំ ជូនដល់អាជីវករ ។

**ប្រការ ៦ :** អាជ្ញាប័ណ្ណទេសចរណ៍ មានសុពលភាពប្រើប្រាស់សំរាប់រយៈពេល ០១ឆ្នាំ គិតចាប់ពីថ្ងៃចេញច្បាប់អនុញ្ញាត ។ មុនពេលផុតសុពលភាពអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវដាក់ពាក្យសុំបន្ត ដោយភ្ជាប់មកជាមួយនូវអាជ្ញាប័ណ្ណចាស់ និងប័ណ្ណពន្ធប៉ាតង់អោយបាន ០១ ខែ មុនថ្ងៃផុតកំណត់ ។ ក្នុងរយៈពេលដែលបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករនៅតែមានសិទ្ធិធ្វើអាជីវកម្មរហូតដល់ថ្ងៃដែលក្រសួងឬមន្ទីរទេសចរណ៍ ពិនិត្យសំរេចលើលក្ខណៈសម្បត្តិ ក្នុងការផ្តល់អាជ្ញាប័ណ្ណបន្តអាជីវកម្ម ។

**ប្រការ ៧ :** ពេលមានការផ្ទេរ ជួល បិទអាជីវកម្ម ផ្លាស់ប្តូរអ្នកគ្រប់គ្រង អាជីវករត្រូវដាក់ពាក្យសុំទៅក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុង អោយបានមុន ០៣ ខែ ។

**ប្រការ ៨ :** ការបង់ប្រាក់សុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីសុំបើកអាជីវកម្មដំបូង ឬ បន្តត្រូវបានកំណត់ដូចខាងក្រោម :

ក- ប្រភេទរថយន្តទេសចរណ៍

| | | |
|---|---|---|
| - ចំណុះ | ៥ កៅអី | ត្រូវបង់ ៨០.០០០ រៀល |
| - ចំណុះ | ៦ កៅអី ទៅ ១៧ កៅអី | ត្រូវបង់ ១២០.០០០ រៀល |
| - ចំណុះ | ១៨ កៅអី ទៅ ៤៥ កៅអី | ត្រូវបង់ ១៦០.០០០ រៀល |

- ចំណុះចាប់ពី ៤៥ កៅអីឡើងទៅ ត្រូវបង់ ២០០.០០០ រៀល

ខ- ចំពោះក្រុមហ៊ុនដែលមានយានយន្តចាប់ពី ១១ គ្រឿងឡើងទៅ ត្រូវបង់ ៥០ % នៃចំណុច " ៨-ក " ។

គ- ការផ្ទេរឈ្មោះអ្នកគ្រប់គ្រងត្រូវបង់ ១០ % នៃទឹកប្រាក់ដែលបានកំណត់ក្នុងប្រការ " ៨-ក " ។

ប្រការ ៩ : - ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មត្រូវដាក់ពាក្យសុំដំបូង ឬបន្តអាជ្ញាប័ណ្ណ ព្រមទាំងទទួលយកអាជ្ញាប័ណ្ណទេសចរណ៍ នៅក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុង ។

- អាជ្ញាប័ណ្ណទេសចរណ៍ ដែលត្រូវពិនិត្យ និងសំរេចដោយមន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវកំណត់រយៈពេល ១២ថ្ងៃ នៃថ្ងៃធ្វើការ ។

- ចំពោះអាជ្ញាប័ណ្ណដែលត្រូវពិនិត្យនិងសំរេចដោយក្រសួងទេសចរណ៍ នាយកដ្ឋានឧស្សាហកម្មទេសចរណ៍ជាអ្នកទទួលពាក្យសុំ និងចុះត្រួតពិនិត្យយានយន្ត ហើយស្នើសុំការសំរេចចេញអាជ្ញាប័ណ្ណទេសចរណ៍ ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ។

ប្រការ ១០ : - អាជីវករដែលទទួលបានអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវប្រើប្រាស់អាជ្ញាប័ណ្ណនេះអោយបានត្រឹមត្រូវនិងត្រូវគោរពអនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ ។

- ករណីមានការខូចខាត ឬបាត់បង់អាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវធ្វើលិខិតជាលាយល័ក្ខអក្សរបញ្ជាក់អំពីមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍បណ្តោះអាសន្នឡើងវិញក្នុងក្នុងរយៈពេល ៣០ ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់ ។

ប្រការ ១១ : ករណីការធ្វើអាជីវកម្មដោយ :

ក- ប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ឬអនុវត្តមិនបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងទេសចរណ៍ អាជីវករនឹងត្រូវទទួលនូវការផាកពិន័យមានចំនួនទឹកប្រាក់ ២០០ភាគរយ (ពីររយភាគរយ) នៃថ្លៃបង់ ។ ប្រសិនបើអាជីវករមិនអនុវត្តលើការផាកពិន័យនេះ ក្នុងរយៈពេល ០៣ ខែ ក្រសួងទេសចរណ៍នឹងផ្អាកការធ្វើអាជីវកម្ម ឬ ដកហូតអាជ្ញាប័ណ្ណទេសចរណ៍ និងបិទអាជីវកម្ម ។

ខ- គ្មានអាជ្ញាប័ណ្ណទេសចរណ៍ នឹងត្រូវទទួលការព្រមានជាលាយល័ក្ខអក្សរ និងបិទអាជីវកម្ម ។

គ- អាជីវករបានផ្តល់ព័ត៌មានមិនពិត ឬ ប្រឌិតឯកសារពាក់ព័ន្ធនឹងពាក្យសុំធ្វើអាជីវកម្ម ក្រសួងទេសចរណ៍មានសិទ្ធិដកអាជ្ញាប័ណ្ណទេសចរណ៍ ឬផ្អាកអាជីវកម្ម ។

ឃ-ប្រព្រឹត្តល្មើសនឹងច្បាប់បញ្ញត្តិទាំងឡាយរបស់រដ្ឋនឹងត្រូវដកហូតអាជ្ញាប័ណ្ណ បិទអាជីវកម្មព្រមទាំងត្រូវទទួលទោសតាមច្បាប់រដ្ឋជាធរមាន ។

ប្រការ ១២ : នៅពេលអាជីវកម្មត្រូវទទួលការផ្អាក ឬ ដកហូតអាជ្ញាប័ណ្ណ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយ លក្ខ័អក្សរផ្ញើដល់ម្ចាស់ ឬ អ្នកគ្រប់គ្រងដើម្បីទទួលប្រតិបត្តិតាម។ ក្នុងករណីសេចក្តីជូនដំណឹងមិនអាចផ្ញើបានទៅដល់ម្ចាស់ ឬអ្នកគ្រប់គ្រងដោយប្រការណាមួយ ឬក៏សាមីខ្លួនជាម្ចាស់ ឬអ្នកគ្រប់គ្រងបដិសេធមិនព្រមទទួលស្គាល់នោះសេចក្តីជូនដំណឹងនឹងត្រូវបិទនៅខាងមុខក្រុមហ៊ុន ឬមូលដ្ឋានអាជីវកម្ម ហើយត្រូវផ្ញើដល់សមាគមទេសចរណ៍ក្នុងស្រុក ដើម្បីទុកជាព័ត៌មាន ។

ប្រការ ១៣: ការផ្អាក ឬ ដកហូតអាជ្ញាប័ណ្ណទេសចរណ៍ មានរយៈពេលកំណត់មិនលើសពី ០៦ខែ។ ក្នុងរយៈពេលនេះ ការធ្វើអាជីវកម្មមិនត្រូវបានអនុញ្ញាតអោយធ្វើអាជីវកម្មឡើយ។ ក្រោយពីផុតកំណត់ពេលនៃការផ្អាក ឬដកហូតម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវធ្វើលិខិតស្នើសុំមកក្រសួងទេសចរណ៍ ដើម្បីសុំដំណើរការអាជីវកម្មឡើងវិញ ។

**ប្រការ ១៤ :** បុគ្គលណាមួយដែលរារាំងដល់ការងារត្រួតពិនិត្យ ឬ ផ្តល់អាជ្ញាប័ណ្ណក្លែងបន្លំមិនត្រឹមត្រូវ ផ្ទុយទៅនឹងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ នឹងត្រូវទទួលនូវវិធានការរដ្ឋបាល ឬ ទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ១៥ :** ០៣ខែក្រោយពីការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍នឹងមិនអនុញ្ញាតអោយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោកដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ទៀតឡើយ ។

**ប្រការ ១៦ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៧ :** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការ គណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលា ខេត្ត-ក្រុង
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ ខេត្ត-ក្រុង (ដើម្បីមុខការ)
- គ្រប់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ...០០៤...ទសណន

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ២០០៧

## សារាចរណែនាំ

## ស្តីពី

## ការគ្រប់គ្រងមធ្យោបាយធ្វើអាជីវកម្ម

## ដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក

ដើម្បីគ្រប់គ្រងការធ្វើអាជីវកម្មមធ្យោបាយដឹកជញ្ជូនទេសចរ ធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក អោយមានសណ្តាប់ធ្នាប់ របៀបរៀបរយ ប្រកបដោយសន្តិសុខ សុវត្ថិភាព មានសុជីវធម៌ជូនទេសចរជាតិ-អន្តរជាតិ និង ក្នុងគោលបំណងធានាការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ថែរក្សាការពារវប្បធម៌ ប្រពៃណីជាតិ តាមគោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីអនុវត្តប្រកាសលេខ ០៦៤ ប្រ.ក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ក្រសួងទេសចរណ៍ សូមធ្វើការណែនាំដូចខាងក្រោម:

១: - រាល់ការធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរកំសាន្តតាមផ្លូវគោក អាជីវករត្រូវមានអាជ្ញាប័ណ្ណទេសចរណ៍ ពីក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុង ។ ទំរង់បែបបទនៃការសុំធ្វើអាជីវកម្ម ត្រូវបានបំពេញឡើងដោយម្ចាស់ ឬ អ្នកគ្រប់គ្រងយានយន្ត និងត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងទេសចរណ៍ ។

- ឯកសារផ្សេងៗទៀត ដែលក្រសួងទេសចរណ៍ត្រូវការ រួមមាន :

  - កិច្ចសន្យារបស់ម្ចាស់អាជីវកម្មចំពោះក្រសួងទេសចរណ៍ ក្នុងការប្រកបអាជីវកម្ម
  - កិច្ចសន្យាជំពាក់ឯកសារ ដែលត្រូវបំពេញឡើងវិញក្នុងរយៈពេល ០៣ខែ
  - ត្រូវបំពេញតារាងត្រួតពិនិត្យយានយន្ត

២: ក្នុងការធ្វើអាជីវកម្ម អាជីវករត្រូវគោរពអនុវត្តតាមសារាចរណែនាំ និង បទប្បញ្ញត្តិ ស្តីអំពីការធ្វើអាជីវកម្ម ដឹកជញ្ជូនទេសចរទស្សនាកំសាន្តតាមផ្លូវគោក ច្បាប់ការងារ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋ ដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មទេសចរណ៍ ដើម្បីជាកិច្ចធានាដល់សន្តិសុខ សុវត្ថិភាព សុខុមាលភាពជូនទេសចរ ។

៣: រាល់ការធ្វើអាជីវកម្មដឹកជញ្ជូនទេសចរ ត្រូវធានាថាមិនធ្វើអោយប៉ះពាល់ដល់វប្បធម៌ ប្រពៃណីជាតិ សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន និង របៀបរៀបរយសង្គម ។

៤: ត្រូវផ្តល់ដំណឹងជាលាយល័ក្ខអក្សរជូនក្រសួងទេសចរណ៍ពេលមានការបិទអាជីវកម្ម ផ្លាស់ប្តូរឈ្មោះម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម លេខទូរស័ព្ទ ទូរសារ ព្រមទាំងពត៌មានអំពីចំនួនអ្នកដំណើរ ថ្លៃឈ្នួល ដែលក្រសួង ឬមន្ទីរទេសចរណ៍ត្រូវការ ។

៥: ដើម្បីពង្រឹងនូវលក្ខណៈសម្បត្តិ គុណភាពសេវាកម្ម អាជីវករត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស និងស្តង់ដាដូចខាងក្រោម:

- កៅអីពូក ត្រូវធានាគុណភាព ស្អាត និងមានបង់លេខសំគាល់ ។
- មិនអនុញ្ញាតអោយដឹកជញ្ជូនអ្នកទេសចរ លើសពីចំនួនកៅអីដែលបានកំណត់ ។
- ចំពោះយានយន្ត ដែលមានចំណុះចាប់ពី ១៨ កៅអីឡើងទៅ ត្រូវបំពាក់ឧបត្ថម្ភសនស័ព្ទ ដើម្បីឧទ្ទេសនាមជូនទេសចរ ។
- សំបុត្រជិះយានយន្តត្រូវមានដាក់ថ្លៃ លេខកៅអី និងពេលវេលាចេញដំណើរច្បាស់លាស់ ។
- ក្នុងយានយន្ត ត្រូវមានបទបញ្ជា ឬការណែនាំអំពីអនាម័យ ថែទាំបរិស្ថាន សុវត្ថិភាព និងវិធីបង្ការគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ។ បន្ទប់ទឹកក្នុងយានយន្ត ត្រូវស្អាត និងមានអនាម័យគ្រប់គ្រាន់ ។
- យានយន្ត ត្រូវបំពាក់គ្រឿងឧបករណ៍ពន្លត់អគ្គីភ័យ និងមានវិទ្យុទាក់ទង ( ICOM ) ឬទូរស័ព្ទប្រចាំការ ដើម្បីបង្ការពេលមានគ្រោះថ្នាក់កើតឡើង ព្រមទាំងត្រូវមានប្រអប់ថ្នាំសង្គ្រោះបន្ទាន់សំរាប់តំរូវការប្រើប្រាស់ នៅពេលចាំបាច់ ។
- យានយន្ត ត្រូវមានកន្លែងទុកដាក់ឥវ៉ាន់ភ្ញៀវអោយបានសមរម្យ មិនត្រូវផ្ទុកឥវ៉ាន់ក្រៅពីឥវ៉ាន់អ្នកដំណើរ និងលើសចំណុះផ្ទុករបស់យានយន្ត ។
- ហាមមានអាវុធជាតិផ្ទុះនៅលើយានយន្ត ។
- អាជ្ញាប័ណ្ណទេសចរណ៍ និងវិញ្ញាបនប័ត្របច្ចេកទេសយានយន្ត ត្រូវថែរក្សាអោយបានល្អ និងដាក់ជាប់តាមយានយន្ត ។
- អ្នកបើកបរមិនត្រូវមានសារធាតុញៀន ឬស្រវឹងក្នុងខ្លួន ។
- អ្នកបើកបរ និងបុគ្គលិកបំរើលើយានយន្ត ត្រូវស្លៀកពាក់ឯកសណ្ឋាន មានផ្លាកឈ្មោះសំគាល់ មានអាកប្បកិរិយាថ្លៃថ្នូរ សុជីវធម៌ និងគោរពសិទ្ធិ ផលប្រយោជន៍របស់ភ្ញៀវ ។
- អ្នកបើកបរ និងបុគ្គលិកបំរើលើយានយន្តទាំងអស់ ត្រូវមានលិខិតបញ្ជាក់សុខភាព ដែលចេញដោយនាយកដ្ឋានពេទ្យការងារ ឬមន្ទីរសុខាភិបាលខេត្ត-ក្រុង ។
- ដើម្បីជៀសវាងការរំខានដល់ភ្ញៀវ ការចាក់កាសែតម៉ាញ៉េ កាសែតវីដេអូ ស៊ីឌី វីស៊ីឌី ឬ ឌីវីឌី ត្រូវរក្សាសំលេងមធ្យម ឬបំពាក់ឧបករណ៍ ( កាស ) ស្តាប់សំលេងដោយផ្ទាល់ ។ ហាមចាក់កាសែតវីដេអូ ស៊ីឌី វីស៊ីឌី ឬឌីវីឌី ដែលរដ្ឋហាមឃាត់ ។

៦: រាល់សកម្មភាពធ្វើអាជីវកម្ម ជួញដូរគ្រឿងញៀន ត្រូវហាមឃាត់ ។

៧: ត្រូវរាយការណ៍ជូនភ្នាក់ងារមានសមត្ថកិច្ចជាបន្ទាន់ នូវរាល់បាតុភាពអសកម្ម ដែលអាចកើតមានឡើង ឬនៅពេលមានគ្រោះថ្នាក់ចរាចរ ដែលធ្វើអោយប៉ះពាល់ដល់សុវត្ថិភាពទេសចរ ។

៨: ម្ចាស់អាជីវកម្ម អ្នកបើកបរត្រូវទទួលខុសត្រូវការពារ សន្តិសុខ សុវត្ថិភាព បរិស្ថាន អនាម័យ នៅលើយានយន្តអោយបានល្អជានិច្ច ។

៩: ក្នុងករណីមិនគោរពតាមបទប្បញ្ញត្តិ ស្តីអំពីការធ្វើអាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោក អាជីវករត្រូវទទួលនូវការផាកពិន័យ ឬទទួលទោសតាមច្បាប់រដ្ឋកំណត់ ។ ករណីធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរ ដល់សុវត្ថិភាពភ្ញៀវ ឬបង្កអោយមានគ្រោះថ្នាក់ដល់ទេសចរ ត្រូវទទួលទោសតាមច្បាប់រដ្ឋជាធរមាន ។

១០: ក្រុមហ៊ុនយានយន្តផ្ទាល់ខ្លួន ដែលបំរើសេវាកម្មទេសចរណ៍ ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីប្រកបអាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោក ដែលត្រូវត្រួតពិនិត្យ និងអនុញ្ញាតដោយមន្ទីរទេសចរណ៍ ខេត្ត-ក្រុង ។

១១: ម្ចាស់យានយន្តរបស់ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ និង របស់ក្រុមហ៊ុនដឹកជញ្ជូនទេសចរណ៍ ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីប្រកបអាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោក ដែលត្រូវត្រួតពិនិត្យ និងអនុញ្ញាតដោយក្រសួងទេសចរណ៍ ។

១២ : ក្នុងករណីចាំបាច់ ក្រសួងនឹងមានវិធានការចាត់តាំងអធិការ និង មន្ត្រីជំនាញ ចុះធ្វើអធិការកិច្ចលើការអនុវត្តន៍លិខិតបទដ្ឋានស្តីពីអាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោករបស់ក្រសួង ។

១៣ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធត្រួតពិនិត្យលើអាជីវកម្មដែលប្រព្រឹត្តិផ្ទុយនឹងបទប្បញ្ញត្តិ របស់ក្រសួងទេសចរណ៍ និងរបស់រដ្ឋ និងរាយការណ៍មកក្រសួងទេសចរណ៍ ។

១៤: មន្ទីរទេសចរណ៍ ខេត្ត-ក្រុងត្រូវអនុវត្តអោយបានម៉ឺងម៉ាត់តាមគោលការណ៍កំណត់របស់ក្រសួងទេសចរណ៍ ។

ទទួលបាននូវសារាចរណែនាំនេះ មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីចាត់តាំងផ្សព្វផ្សាយដល់ម្ចាស់អាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោក ដើម្បីអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។

រដ្ឋមន្ត្រី

ថោង ខុន

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
  " ដើម្បីជូនជ្រាប "
- មន្ទីរទេសចរណ៍ខេត្ត-ក្រុង " ដើម្បីមុខការ "
- គ្រប់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរកំសាន្តតាមផ្លូវគោក ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

ក្រសួងទេសចរណ៍

លេខ ០៩២ ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ៣ ឆ្នាំ២០១២

## ប្រកាស
## ស្ដីពី
## ការគ្រប់គ្រងអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ/នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍

បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍

បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក. ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក. ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០០០ ស្ដីពីការកែសម្រួលមុខងារ និង ភារកិច្ច និង ការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន នៃក្រសួងទេសចរណ៍

បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១១ ស្ដីពីមគ្គុទ្ទេសក៍ទេសចរណ៍

យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍។

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

ប្រការ ១ :

ប្រកាសនេះមានគោលបំណងកំណត់វិធាននៃការគ្រប់គ្រងអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់បម្រើវិស័យទេសចរណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៩៨

**ប្រការ ២ :**

ប្រកាសនេះមានគោលដៅដូចតទៅ ៖

- ដោះស្រាយជាបណ្ដោះអាសន្ននូវបញ្ហាមគ្គុទ្ទេសក៍ទេសចរណ៍ដែលពុំចេះភាសារបស់ភ្ញៀវ

- ទប់ស្កាត់ការខុសឆ្គងក្នុងការប្រើប្រាស់អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ។

**ប្រការ ៣ :**

បច្ចេកស័ព្ទដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចតទៅ៖

**អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍** សំដៅដល់បុគ្គលជាជនបរទេស ដែលធ្វើជាអ្នកបកប្រែបន្តផ្ទាល់មាត់នូវអ្វីដែលមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជាកំពុងនិយាយទៅជាភាសាមួយផ្សេងទៀតជូនភ្ញៀវទេសចរ ។

**មគ្គុទ្ទេសក៍ទេសចរណ៍** សំដៅដល់បុគ្គលប្រកបអាជីពជាអ្នកទទួលជូន ថែរក្សាភ្ញៀវជាតិ អន្តរជាតិ និងធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ និងសេដ្ឋកិច្ចសង្គមនៃទីកន្លែងទស្សនា ។

## ជំពូកទី២

## សមត្ថកិច្ចក្នុងការផ្ដល់បណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍

**ប្រការ ៤ :**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងការផ្ដល់បណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ។

**ប្រការ ៥ :**

ការផ្ដល់ ឬការបន្តបណ្ណអនុញ្ញាតឱ្យធ្វើជាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ និង ការលុបចោល ការព្យួរ ជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។

**ប្រការ ៦ :**

គ្មានបុគ្គលណាម្នាក់អាចធ្វើជាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍បានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្ដល់បណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ពីក្រសួងទេសចរណ៍ ។

## ជំពូកទី៣

## វិធាន និងនីតិវិធី

## នៃការផ្ដល់បណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍

**ប្រការ ៧ :**

បុគ្គលដែលមានបំណងធ្វើជាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំបណ្ណអនុញ្ញាតនៅក្រសួងទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍រាជធានី-ខេត្ត ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសម្អាង និងព័ត៌មានផ្សេងៗទៀតដូចខាងក្រោម ៖

ក. លិខិតឆ្លងដែន ( ថតចម្លងតាមច្បាប់ដើម ) ។

ខ. វិញ្ញាបនបត្របញ្ជាក់ការសិក្សាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ដែលការបណ្ដុះបណ្ដាលត្រូវបាន

ទទួលស្គាល់ដោយក្រសួងទេសចរណ៍ (ថតចម្លងតាមច្បាប់ដើម) ។

គ. វិញ្ញាបណ្ណបត្រពិនិត្យសុខភាព និងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងមានការឯកភាពពីក្រសួងទេសចរណ៍។

ឃ. លិខិតស្នើសុំរបស់ទីភ្នាក់ងារទេសចរណ៍ ឬ សមាគមទេសចរណ៍

ង. កិច្ចសន្យាគោរពច្បាប់រដ្ឋ ។

ច. ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត ។

ឆ. រូបថត (៤ x ៦) ថតថ្មីចំនួន ០២សន្លឹក ។

## ប្រការ ៨ :

កម្រៃបណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវបង់ ៣០០.០០០ (បីរយពាន់) រៀល ។

## ប្រការ ៩ :

មន្ទីរទេសចរណ៍រាជធានី -ខេត្ត ដែលបានទទួលពាក្យស្នើសុំបណ្ណអនុញ្ញាតត្រូវពិនិត្យលើពាក្យស្នើសុំ ហើយ[illegible]ញូនសំណុំបែបបទមកក្រសួងទេសចរណ៍ ដោយមានការបញ្ជាក់ឯកភាពពីរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការតាមរយៈក្រុមអាជ្ញាបណ្ណទេសចរណ៍របស់ក្រសួង។ នាយកដ្ឋានឧស្សាហកម្មទេសចរណ៍ ត្រូវទទួលពិនិត្យវិនិច្ឆ័យលើពាក្យស្នើសុំនេះតាមនីតិវិធី ដើម្បីចេញបណ្ណអនុញ្ញាតក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ ។ ក្នុងករណី មិនឯកភាពផ្តល់ឱ្យក្រសួងទេសចរណ៍នឹងបញ្ជាក់ពីមូលហេតុច្បាស់លាស់ជូនទៅអ្នកស្នើសុំ ។

## ប្រការ ១០ :

នៅពេលអ្នកស្នើសុំបណ្ណអនុញ្ញាតបានបំពេញបែបបទត្រឹមត្រូវឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍នឹងចេញបណ្ណអនុញ្ញាតជូនទៅអ្នកស្នើសុំសម្រាប់ធ្វើជាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍។

## ប្រការ ១១ :

បណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍មានសុពលភាពប្រើប្រាស់សម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែ គិតពីថ្ងៃចេញបណ្ណអនុញ្ញាត ។ ក្រសួងទេសចរណ៍អាចផ្តល់បណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ជាថ្មីតាមតម្រូវការចាំបាច់នៃទីផ្សារទេសចរណ៍ ។

## ប្រការ ១២ :

បណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍មិនអាចធ្វើការផ្ទេរ ឬការលក់បានទេ ដោយសារតែបណ្ណអនុញ្ញាតនេះផ្អែកលើគុណវុឌ្ឍិបុគ្គល និងបទពិសោធរបស់ម្ចាស់បណ្ណ ។

## ប្រការ ១៣ :

អ្នកកាន់បណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវប្រើប្រាស់បណ្ណអនុញ្ញាតនេះឱ្យបានត្រឹមត្រូវតាមកម្មវត្ថុនៃអាជីពរបស់ខ្លួន ហើយត្រូវគោរពអនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិនានារបស់ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ ។

ក្នុងករណីមានការខូចខាត ឬបាត់បង់បណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ម្ចាស់បណ្ណត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីសុំបណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្តទុតិយតាឡើងវិញក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់។ អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវកាន់តាមខ្លួននូវលិខិតបញ្ជាក់ពីការដឹងឮរបស់សមត្ថកិច្ច មុនពេលទទួលបានបណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្តទុតិយតា។

**ប្រការ ១៤ :**

ក្រសួងទេសចរណ៍ធ្វើការជ្រើសរើស បណ្តុះបណ្តាល វិក្រឹតការ និងផ្តល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍តាមតម្រូវការចាំបាច់។ លក្ខខណ្ឌ និងនីតិវិធីនៃការជ្រើសរើស បណ្តុះបណ្តាល និងវិក្រឹតការត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី៤

## ភារកិច្ចរបស់អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍

**ប្រការ ១៥ :**

អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវមានកាតព្វកិច្ចដូចតទៅ៖

ក. អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវស្លៀកពាក់ឯកសណ្ឋានដោយឡែកខុសពីឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ ពាក់អត្តលេខ និងពាក់បណ្ណអនុញ្ញាតក្នុងពេលបំពេញភារកិច្ច។

ខ. អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវបំពេញភារកិច្ចជាមួយមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជា ដោយធ្វើការបកប្រែជូនទេសចរនូវអ្វីដែលមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជាបានអធិប្បាយពន្យល់។

គ. ត្រូវគោរពអនុវត្តឱ្យបានត្រឹមត្រូវតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឱ្យបានល្អ។

ឃ. អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍មិនត្រូវទាមទារកម្រៃ ឬផលប្រយោជន៍ពីអ្នកលក់ ឬពីអ្នកផ្តល់សេវាកម្មទេសចរណ៍ផ្សេងៗ។

ង. មិនត្រូវសេពគ្រឿងញៀន សារធាតុស្រវឹង និងសារធាតុញៀននៅក្នុងខ្លួន។ ហាមមានអាវុធជាតិផ្ទុះនៅជាប់ខ្លួន។

ច. ជៀសវាងការធ្វើសកម្មភាពដែលប៉ះពាល់ជាអវិជ្ជមានដល់គោលនយោបាយជាតិលើវិស័យទេសចរណ៍។

ឆ. ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់ និងទទួលខុសត្រូវផ្តល់សេវាកម្មដូចដែលបានសន្យា ព្រមទាំងមានវិធានការសមស្រប ដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាព ក្នុងពេលដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ជ. ប្តឹង ឬរាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ដែលនៅជិតបំផុតក្នុងករណីដឹង ឬមានការសង្ស័យថា មានការប្រព្រឹត្តិបទល្មើស ការជួញដូរវត្ថុបុរាណ និងបទល្មើសបេតិកភណ្ឌ ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ និងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និងសម្ភារៈអាសអាភាស ឬប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត។

ឈ. ចូលរួមចំណែកនៅក្នុងការថែរក្សាធនធានធម្មជាតិ លម្អបៃតង មិនបំពុល ឬមិនបំផ្លាញបរិស្ថាន ការពារ និងអភិរក្សមរតកវប្បធម៌ ការពារសម្បត្តិវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរ ក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន ។

ញ. ពេលឈប់ធ្វើជាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ សាមីខ្លួនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងប្រគល់បណ្ណអនុញ្ញាតមកក្រសួងទេសចរណ៍យ៉ាងយូរ ១ (មួយ) ខែ ក្រោយថ្ងៃឈប់ធ្វើជាអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍។ ក្រោយការសុំឈប់ និងប្រគល់បណ្ណអនុញ្ញាតមកក្រសួងទេសចរណ៍វិញ អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍នៅតែមានសិទ្ធិស្នើសុំប្រកបអាជីវកម្មឡើងវិញស្របតាមគោលការណ៍កំណត់របស់ក្រសួងទេសចរណ៍ ។

ដ. សហការជាមួយមន្ត្រីជំនាញ និងមន្ត្រីអធិការកិច្ចទេសចរណ៍ក្នុងការផ្តល់ព័ត៌មាន និងការធ្វើអធិការកិច្ច ។

ឋ. គាំទ្រ និងចូលរួមយុទ្ធនាការឃោសនាផ្សព្វផ្សាយ **កម្ពុជា : ព្រះរាជាណាចក្រអច្ឆរិយៈ** និងចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ**" និងជំរុញចលនាទេសចរក្នុងស្រុកឱ្យមានកំណើនខ្ពស់ ។

ឌ. ចូលរួមក្នុងយុទ្ធនាការទេសចរណ៍បៃតង "**ទេសចរម្នាក់ដាំដើមឈើ១ដើម**" ដើម្បីគាំទ្រការកាត់បន្ថយផលប៉ះពាល់នៃការកើនឡើងកំដៅលើផែនដី ។

ឍ. ចូលរួមវគ្គបណ្តុះបណ្តាល និងវិក្រឹតការដែលរៀបចំដោយក្រសួងទេសចរណ៍ ។

## ជំពូកទី៥

## ទណ្ឌកម្ម

### ប្រការ ១៦ :

អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ដែលប្រើប្រាស់បណ្ណអនុញ្ញាត ហួសសុពលភាព រយៈពេល ១០ (ដប់) ថ្ងៃ ចាត់ទុកថា ធ្វើអាជីវកម្មដោយគ្មានបណ្ណអនុញ្ញាត នឹងត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ស្មើនឹង ២.០០០.០០០ (ពីរលាន) រៀល ។

ការពិន័យអន្តរការណ៍នេះ មិនទាន់គិតកម្រៃអាជ្ញាបណ្ណដែលត្រូវបង់ ។ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បណ្ណ ដើម្បីចូលខ្លួនបង់ប្រាក់នៃការពិន័យអន្តរការណ៍ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ។

ក្នុងករណីផុតកាលកំណត់នៃសេចក្តីជូនដំណឹង ប្រសិនបើម្ចាស់បណ្ណមិនព្រមទទួលការពិន័យអន្តរការណ៍នេះទេ នឹងត្រូវទទួលការលុបចោលបណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ ។

ការពិន័យអន្តរការណ៍មិនធ្វើឱ្យម្ចាស់បណ្ណដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីឬការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ ។

### ប្រការ ១៧ :

បុគ្គលដែលប្រកបអាជីវកម្មទេសចរណ៍ដោយគ្មានបណ្ណអនុញ្ញាត ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដែលអប្បបរមាស្មើនឹង ២.០០០.០០០ (ពីរលាន) រៀល និងអតិបរមាមិនលើសពី ៤.០០០.០០០ (បួនលាន) រៀល ។ ចំពោះការបង់ប្រាក់ពិន័យអន្តរការណ៍នេះ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បណ្ណក្នុង រយៈពេល ៣០ (សាមសិប) ថ្ងៃ ។ ក្នុងករណីដែលម្ចាស់បណ្ណមិនមកបង់ប្រាក់ពិន័យអន្តរការណ៍តាមសេចក្តីជូនដំណឹងទេ ក្រសួងទេសចរណ៍នឹងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

**ប្រការ ១៨ :**

បុគ្គលដែលផ្តល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យស្នើសុំបណ្ណអនុញ្ញាត ឬ ខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងអស់ ឬលក្ខខណ្ឌណាមួយនៃបណ្ណអនុញ្ញាត ក្រសួងទេសចរណ៍អាចលុបចោលបណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍។

ក្នុងករណីដែលបណ្ណអនុញ្ញាតត្រូវបានលុបចោល ក្រសួងទេសចរណ៍នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បណ្ណក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃជាមុន ដោយបញ្ជាក់ហេតុផលច្បាស់លាស់។ សេចក្តីជូនដំណឹងនេះត្រូវបិទនៅខាងមុខក្រុមហ៊ុនទេសចរណ៍ និងសមាគមឧស្សាហកម្មទេសចរណ៍ក្នុងស្រុកទុកជាព័ត៌មាន។

**ប្រការ ១៩ :**

ក្នុងករណីម្ចាស់បណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ប្រព្រឹត្តរំលោភលើកាតព្វកិច្ច ដូចមានចែងក្នុងប្រការ ១៥ ជំពូកទី៤ នៃប្រកាសនេះ អាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ជាប្រាក់ដែលអប្បបរមាស្មើនឹង ១.០០០.០០០ (មួយលាន) រៀល និងអតិបរមាមិនលើសពី ១០.០០០.០០០ (ដប់លាន) រៀល។

ការពិន័យអន្តរការណ៍នេះ មិនធ្វើឱ្យម្ចាស់បណ្ណអនុញ្ញាតរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ឬ ការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ ២០ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២១ :**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ក្រុមអ្នកច្បាប់ ប្រធាននាយកដ្ឋានពាក់ព័ន្ធនៃក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

<u>ចម្លងជូន:</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- សមាគមឧស្សាហកម្មទេសចរណ៍
- អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ "ដើម្បីអនុវត្ត"
- ដូចប្រការ ២១ "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

**ក្រសួងទេសចរណ៍**

លេខ ០៤៧ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ២០១៦

# ប្រកាស
## ស្តីពី
## ការអនុវត្តក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០២ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៤ ស្តីពីការបង្កើតនាយកដ្ឋានស្ថិតិ ព័ត៌មានទេសចរណ៍នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ



E-mail admin@mot.gov.kh Website:www.mot.kh

# សម្រេច

**ប្រការ ១._**

ត្រូវបានដាក់ឲ្យអនុវត្តក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ដើម្បីចូលរួមពង្រឹង និងលើកស្ទួយវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ពិសេសការអនុវត្ត និងប្រតិបត្តិវិជ្ជាជីវៈជាមគ្គុទ្ទេសក៍ទេសចរណ៍ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពចំពោះភ្ញៀវកំពុងធ្វើដំណើរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជាទទួលបាននូវភាពរីករាយ និងកក់ក្ដៅ។

**ប្រការ ២._**

មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ដើម្បីធានាបាននូវសេចក្ដីថ្លៃថ្នូរ និងការជឿទុកចិត្តពីសំណាក់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

ក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

ក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន អធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

*កន្លែងទទួល៖*

- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងពាណិជ្ជកម្ម*
- *ក្រសួងអប់រំ យុវជន និងកីឡា*
- *ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *សាលារាជធានី ខេត្ត*
- *ដូចប្រការ ៤*
- *រាជកិច្ច*

*ឯកសារ កាលប្បវត្តិ*

ឧបសម្ព័ន្ធនៃប្រកាសលេខ០៤៧ ចុះថ្ងៃទី ១៧ ខែកុម្ភៈឆ្នាំ២០១៤ ស្តីពីការអនុវត្តក្រម ប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា

# ឧបសម្ព័ន្ធទី១
# ក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
# នៃព្រះរាជាណាចក្រកម្ពុជា

# មាតិកា


**ជំពូកទី១._ ខចានទូទៅ**

មាត្រា ១._ គោលបំណង

មាត្រា ២._ វិសាលភាព

មាត្រា ៣._ គោលការណ៍គ្រឹះ

មាត្រា ៤._ បេសកកម្ម

មាត្រា ៥._ សុចរិតភាព និងភាពស្មោះត្រង់

មាត្រា ៦._ អាជ្ញាបណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍

មាត្រា ៧._ ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍

មាត្រា ៨._ ការផ្សព្វផ្សាយអំពីមុខងារ

មាត្រា ៩._ នាមប័ណ្ណរបស់មគ្គុទ្ទេសក៍ទេសចរណ៍

**ជំពូកទី២._ មគ្គុទ្ទេសក៍ទេសចរណ៍ និងភ្ញៀវ**

មាត្រា ១០._ ទំនាក់ទំនងរវាងមគ្គុទ្ទេសក៍ទេសចរណ៍ និងភ្ញៀវ

មាត្រា ១១._ទំនាក់ទំនងរវាងមគ្គុទ្ទេសក៍ទេសចរណ៍ក្រោមកិច្ចសន្យា និងការគ្រប់គ្រងរបស់ក្រុមហ៊ុន ឬភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ និងភ្ញៀវ

**ជំពូកទី៣._ វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍**

មាត្រា ១២._ ការប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងសកម្មភាពដែលត្រូវហាមឃាត់

**ជំពូកទី៤._ ទំនាក់ទំនងរវាងមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

មាត្រា ១៣._ ការសង្កេតលើការអនុវត្តវិជ្ជាជីវៈ និងបទប្បញ្ញត្តិនានា

មាត្រា ១៤._ បេសកកម្មប្រគល់ដោយក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

មាត្រា ១៥._ ការពង្រឹងគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍

មាត្រា ១៦._ មគ្គុទ្ទេសក៍ទេសចរណ៍ដែលត្រូវបានគេប្តឹង

មាត្រា ១៧._ ទណ្ឌកម្ម និងការព្រមាន

មាត្រា ១៨._ អន្តរប្បញ្ញត្តិ

**ជំពូកទី៥._ អវសានប្បញ្ញត្តិ**

មាត្រា ១៩._ និរាករណ៍

មាត្រា ២០._ ការអនុវត្ត

# ក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
# នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី១
## ខ្ចានទូទៅ

**មាត្រា ១._ គោលបំណង**

ក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍មានគោលបំណងការពារ និងពង្រឹងប្រសិទ្ធភាពនៃការប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងធានានូវសេចក្តីថ្លៃថ្នូររបស់មគ្គុទ្ទេសក៍ទេសចរណ៍ក្នុងការប្រកបរបរវិជ្ជាជីវៈ ដើម្បីបង្កើននូវជំនឿទុកចិត្តពីភ្ញៀវ។

**មាត្រា ២._ វិសាលភាព**

ក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នេះ មានវិសាលភាពអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣._ គោលការណ៍គ្រឹះ**

នៅគ្រប់កាលៈទេសៈ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវគោរពតាមវិធាននៃវិជ្ជាជីវៈ គោលការណ៍សម្បជញ្ញៈ មនុស្សធម៌ និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈ។

មគ្គុទ្ទេសក៍ទេសចរណ៍ មិនត្រូវចូលរួមសកម្មភាពនយោបាយ ឬសកម្មភាពទាំងឡាយណាដែលផ្ទុយនឹងច្បាប់ បទប្បញ្ញត្តិជាធរមាន វិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួនឡើយ។

**មាត្រា ៤._ បេសកកម្ម**

មគ្គុទ្ទេសក៍ទេសចរណ៍ មានបេសកកម្មចូលរួមអត្ថាធិប្បាយ ពន្យល់ និងលើកស្ទួយអំពីភូមិសាស្ត្រធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទំលាប់ និងសេដ្ឋកិច្ចសង្គមនៅតាមទីតាំងភូមិសាស្ត្រដែលខ្លួនទទួលបានអាជ្ញាបណ្ណទេសចរណ៍ក្នុងការបំពេញមុខងារជាមគ្គុទ្ទេសក៍ទេសចរណ៍។

**មាត្រា ៥._ សុចរិតភាព និងភាពស្មោះត្រង់**

មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវគោរព និងប្រតិបត្តិតាមគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់។

**មាត្រា ៦._ អាជ្ញាបណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍**

មគ្គុទ្ទេសក៍ទេសចរណ៍ បញ្ជាក់ពីភាពត្រឹមត្រូវនៃការប្រកបវិជ្ជាជីវៈរបស់ខ្លួនតាមរយៈអាជ្ញាបណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍។

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវដកហូតមកវិញក្នុងករណីមគ្គុទ្ទេសក៍ទេសចរណ៍ [illegible] ត្រូវហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដោយក្រសួងទេសចរណ៍ និងក្រសួង ស្ថាប័នសាមី (ករណីអាជ្ញាបណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ជាតិ

ពិសេស) នៅពេលអាជ្ញាបណ្ណទេសចរណ៍អស់សុពលភាព ឬក្នុងរយៈពេលកំណត់ណាមួយស្របតាមបទដ្ឋាន ឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា ៧._ ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍**

មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវពាក់ឯកសណ្ឋានមគ្គុទ្ទេសក៍នៅក្នុងពេលបំពេញវិជ្ជាជីវៈជាមគ្គុទ្ទេសក៍ទេសចរណ៍ ដើម្បីបង្កភាពស្និទ្ធស្នាល និងភាពជឿជាក់ដល់ភ្ញៀវទេសចរ វៀរលែងតែករណីចាំបាច់ផ្ទុយពីនេះ។

មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវពាក់ឯកសណ្ឋានមគ្គុទ្ទេសក៍នៅក្នុងកម្មវិធី ឬពិធីផ្លូវការ ឬតម្រូវការចាំបាច់នានា។

**មាត្រា ៨._ ការផ្សព្វផ្សាយអំពីមុខងារ**

សមាគមមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់ថ្នាក់ (ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍) ត្រូវធានាផ្សព្វផ្សាយអំពីមុខងារនៃវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ទៅតាមថ្នាក់ ឬកម្រិតដែលបានកំណត់ដោយបទដ្ឋានជាធរមានទាក់ទងនឹងមគ្គុទ្ទេសក៍ទេសចរណ៍។

**មាត្រា ៩._ នាមប័ណ្ណរបស់មគ្គុទ្ទេសក៍ទេសចរណ៍**

នាមប័ណ្ណរបស់មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវចុះនិទ្ទេសដូចតទៅ៖

- នាមត្រកូល ឬនាមករណ៍របស់ក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ដែលខ្លួនកំពុងបំពេញការងារ
- រូបសញ្ញា (Logo) ប្រសិនបើមាន
- អត្តលេខ
- លេខកូដ QR
- លេខកូដប្រៃសណីយ៍ ទូរគមនាគមន៍ និងបែបបទនៃទំនាក់ទំនងដទៃទៀត ប្រសិនបើមាន។

## ជំពូកទី២
## មគ្គុទ្ទេសក៍ទេសចរណ៍ និងភ្ញៀវ

**មាត្រា ១០._ ទំនាក់ទំនងរវាងមគ្គុទ្ទេសក៍ទេសចរណ៍ និងភ្ញៀវ**

ទំនាក់ទំនងរវាងមគ្គុទ្ទេសក៍ទេសចរណ៍ និងភ្ញៀវកើតមាននៅពេលមានភ្ញៀវណាម្នាក់បង្ហាញពីបំណងចង់ឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ផ្តល់នូវសេវាកម្មជាអ្នកទទួលជូន ថែរក្សាភ្ញៀវ និងធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទំលាប់ និងសេដ្ឋកិច្ចសង្គមនៃទីកន្លែងកម្សាន្ត។

មគ្គុទេសក៍ទេសចរណ៍ មានជំនាញវិជ្ជាជីវៈទាំងអស់ ត្រូវមានឆន្ទៈផ្តល់នូវសេវាកម្មល្អបំផុតសម្រាប់ភ្ញៀវ និងត្រូវផ្តល់ឱ្យភ្ញៀវនូវឱកាសដើម្បីទទួលបាននូវភាពរីករាយ។

## មាត្រា ១១._ ទំនាក់ទំនងរវាងមគ្គុទ្ទេសក៍ទេសចរណ៍ក្រោមកិច្ចសន្យា និងការគ្រប់គ្រងរបស់ក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ និងភ្ញៀវ

គ្រប់ការអនុវត្ត និងប្រតិបត្តិវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ដែលស្ថិតក្រោមកិច្ចសន្យា និងការគ្រប់គ្រងរបស់ក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ទាំងនោះ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ អំពីដំណើរទស្សនកិច្ច និងសេវាកម្មជាមួយភ្ញៀវ។

ទំនាក់ទំនងខាងលើ ត្រូវកំណត់ឲ្យបានច្បាស់លាស់តាមរយៈកិច្ចសន្យារវាងភាគីទាំងសងខាង និង/ឬភាគីពាក់ព័ន្ធ។

## ជំពូកទី៣
## វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍

## មាត្រា ១២._ ការប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងសកម្មភាពដែលត្រូវហាមឃាត់

១. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

២. មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវមានជំនាញវិជ្ជាជីវៈច្បាស់លាស់ និងគោរពនូវសម្បត្តិបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ និងបរិស្ថានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា។

៣. មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវគោរព និងអនុវត្តនូវបទប្បញ្ញត្តិ ក៏ដូចជាគោលការណ៍របស់ក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ដែលខ្លួនបានបម្រើការងារ។

៤. មគ្គុទ្ទេសក៍ទេសចរណ៍ មិនអាចទទួលការងារពីក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ដទៃទៀត ដរាបណាគ្មានការយល់ព្រមពីក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍របស់ខ្លួន។

៥. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវអនុវត្តគ្រប់កិច្ចការដែលក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍បានប្រគល់ជូន។ ករណីមិនអាចទទួលយកការងារបាន ឬមានកត្តាផ្សេងៗដែលនាំឲ្យរាំងស្ទះដល់ការងារ ត្រូវផ្ដល់ដំណឹងជាមុនដល់ក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍។

៦. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវតែអនុវត្តតាមកម្មវិធីធ្វើដំណើរដែលក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ឬសមាគមមគ្គុទ្ទេសក៍ទេសចរណ៍បានរៀបចំសម្រាប់ភ្ញៀវ ហើយត្រូវបំពេញភារកិច្ចក៏ដូចជាក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនឲ្យបានល្អបំផុត។

៧. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវមានភាពទៀងទាត់ អាចជឿទុកចិត្តបាន ស្មោះត្រង់ យកចិត្តទុកដាក់ចំពោះការងារ និងមានភាពប៉ិនប្រសព្វគ្រប់ពេលវេលា។

៨. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវមានទំនាក់ទំនងល្អ សីលធម៌ល្អ និងសុជីវធម៌ល្អជាមួយក្រុមឬដៃគូសហការ ក៏ដូចជាសហការីដទៃទៀតដែលរួមការងារជាមួយ។

៩. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវគោរពនូវកម្មសិទ្ធិបញ្ញា និងសម្ភារៈ និងទ្រព្យសម្បត្តិរបស់មគ្គុទ្ទេសក៍ទេសចរណ៍ដទៃទៀតដោយមិនត្រូវថតចំលងដោយគ្មានការអនុញ្ញាត ឬយកវាមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនជាដាច់ខាត។

១០. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវផ្ដល់នូវការអត្ថាធិប្បាយ និងពន្យល់ឲ្យស័ក្ដិសមនឹងជំនាញ និងប្រកបដោយចំណេះដឹង ព្រមទាំងធ្វើការបកប្រែ និងបញ្ជាក់ជុំវិញព័ត៌មានណាដែលពិត ហើយបង្ហាញនូវបំណង និងភាពរីករាយក្នុងការចូលរួម។

១១. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវមានការរៀបចំ និងត្រៀមខ្លួនទុកជាមុនរាល់ការធ្វើដំណើរនីមួយៗ។

១២. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវតែមានការយល់ដឹង មិនត្រូវយកទស្សនៈ ឬក៏ការគិតរបស់ខ្លួនមកនិយាយដូចជាទាក់ទងបញ្ហាការរើសអើង សាសនា និងនយោបាយជាដើម។

១៣. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវរក្សាអនាម័យផ្ទាល់ខ្លួន និងស្លៀកពាក់ឲ្យបានសមរម្យស័ក្ដិសមនឹងតួនាទីរបស់ខ្លួន។

១៤. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ មិនត្រូវប្រើប្រាស់គ្រឿងស្រវឹង សារធាតុញៀន ជក់បារី ទំពា ឬបរិភោគអ្វីមួយ ខណៈពេលកំពុងបំពេញភារកិច្ចចំពោះភ្ញៀវទេសចរ។

១៥. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ មិនត្រូវរើសអើង ពណ៌សម្បុរ ជាតិសាសន៍ សញ្ជាតិ រូបរាង ឬក៏អាយុឡើយ។

១៦. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវតែឲ្យតម្លៃទៅលើជាតិសាសន៍ទាំងអស់ រួមទាំងវប្បធម៌ និងបរិស្ថានឲ្យបានខ្ជាប់ខ្ជួន។

១៧. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវធានាឲ្យបាននូវការទទួលខុសត្រូវផ្នែកច្បាប់ សុវត្ថិភាពរបស់ភ្ញៀវ និងទ្រព្យសម្បត្តិទាំងអស់របស់ពួកគេ។

១៨. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវមានការគោរពលើជំនឿ សាសនានៃតំបន់ទេសចរណ៍នីមួយៗ។

១៩. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ ត្រូវមានការគោរព សុជីវធម៌ ក៏ដូចជាសីលធម៌ដល់អាជ្ញាធរនៃតំបន់ទេសចរណ៍នីមួយៗ។

២០. មគ្គុទ្ទេសក៍ទេសចរណ៍មានជំនាញវិជ្ជាជីវៈ មិនត្រូវនាំភ្ញៀវទៅកាន់ទីតាំងអាជីវកម្មណាមួយដែលផ្ដល់នូវសេវាកម្ម ឬធ្វើអាជីវកម្មបោកប្រាស់ ឬក្លែងបន្លំ ឬរំលោភលើសេចក្ដីទុកចិត្តដល់ភ្ញៀវ ឬធ្វើការឃុបឃិតជាមួយឈ្មួញ ឬទីតាំងអាជីវកម្មណាមួយ ដោយជូនភ្ញៀវទៅទិញទំនិញ ឬវត្ថុអនុស្សាវរីយ៍ដោយតម្លៃមិនសមរម្យ ដែលអាចបង្កជារូបភាពអវិជ្ជមានដល់វិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាឡើយ។

២១. មគ្គុទ្ទេសក៍ទេសចរណ៍ គួររៀបចំដំណើរទស្សនាកម្សាន្តដល់ភ្ញៀវទៅកាន់ទីតាំង ឬមជ្ឈមណ្ឌលពាណិជ្ជកម្មទាំងឡាយណាដែលទទួលបានការសហការ ទទួលស្គាល់ និងគាំទ្រពីក្រសួងទេសចរណ៍ ឬស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ ឬក៏តំបន់ទេសចរណ៍ទាំងឡាយណាដែលមានការអនុញ្ញាតដោយក្រសួងទេសចរណ៍ ឬក្រសួង ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធដើម្បីរក្សានូវសន្តិសុខ សុវត្ថិភាព សេចក្ដីទុកចិត្ត និងភាពកក់ក្ដៅដល់ភ្ញៀវ។

## ជំពូកទី៤
## ទំនាក់ទំនងរវាងមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ១៣._ ការសង្កេតលើការអនុវត្តវិជ្ជាជីវៈ និងបទប្បញ្ញត្តិនានា**

សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវចូលរួមសង្កេតអំពីប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិជាធរមាននានាដែលពាក់ព័ន្ធនឹងមគ្គុទ្ទេសក៍ទេសចរណ៍របស់ក្រសួងទេសចរណ៍។

**មាត្រា ១៤._ បេសកកម្មប្រគល់ដោយក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវទទួលរ៉ាប់រងដោយវៀងវៃ និងហ្មត់ចត់នូវបេសកកម្ម និងសេវារួម ព្រមទាំងចូលរួមការពារ និងលើកស្ទួយនូវតម្លៃនៃសម្បត្តិបេតិកភ័ណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ ភូមិសាស្ត្រ និងសេដ្ឋកិច្ចសង្គមនៅតាមទីតាំង ឬរមណីយដ្ឋានទេសចរណ៍ដែលខ្លួនធ្លាប់បាន និងកំពុងអនុវត្តវិជ្ជាជីវៈជាមគ្គុទ្ទេសក៍ទេសចរណ៍។

**មាត្រា ១៥._ ការពង្រឹងគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍**

ស្របតាមការសម្រេចរបស់ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវទទួល និងចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា ឬកម្មវិធីដែលមានលក្ខណៈជាការបញ្ជ្រាបការយល់ដឹងបន្ថែម ឬព័ត៌មាន ដែលទាក់ទងនឹងការពង្រឹងដល់ការអភិវឌ្ឍសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍។

ករណីដែលមគ្គុទ្ទេសក៍ទេសចរណ៍ណាមិនបានចូលរួមក្នុងកម្មវិធី ឬវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាខាងលើ ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុឲ្យបានសមរម្យ រួចបញ្ជូនមកក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល១សប្តាហ៍មុន ឬក្រោយកម្មវិធី ឬវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា។

**មាត្រា ១៦._ មគ្គុទ្ទេសក៍ទេសចរណ៍ដែលត្រូវបានគេប្តឹង**

សមាគមមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់ថ្នាក់ (ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍) ត្រូវជូនដំណឹងដល់ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិចំពោះរាល់ករណីទាំងឡាយណាដែលពាក់ព័ន្ធនឹងការមិនពេញចិត្ត ឬបណ្តឹងទាក់ទងនឹងមគ្គុទ្ទេសក៍ទេសចរណ៍អំពីកំហុស ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលទាក់ទិននឹងការប្រកបវិជ្ជាជីវៈ ឬក្រៅការប្រកបវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ឬដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍។

**មាត្រា ១៧._ ទណ្ឌកម្ម និងការព្រមាន**

រាល់ការអនុវត្តវិជ្ជាជីវៈ មគ្គុទ្ទេសក៍ទេសចរណ៍ទាំងឡាយណាដែលមិនគោរពតាមបទប្បញ្ញត្តិដែលមានចែងក្នុងក្រមប្រតិបត្តិវិជ្ជាជីវៈនេះ អាចត្រូវបានស៊ើបអង្កេតដោយអធិការរបស់ក្រសួងទេសចរណ៍។

ក្រោយពីការស៊ើបអង្កេត ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរដល់មគ្គុទ្ទេសក៍ទេសចរណ៍ដែលបានប្រព្រឹត្តខុស។

ករណីទទួលបានលិខិតព្រមានចំនួន០៣ដង ហើយមិនរាងចាល ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី៥ នៃអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ និងបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៨._ អន្តរប្បញ្ញត្ត**

សមាគមមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់ថ្នាក់ (ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍) អាចរៀបចំក្រមប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួនដោយផ្អែកតាមស្ថានភាព ទីតាំងភូមិសាស្ត្រ និងគោលដៅទេសចរណ៍នីមួយៗ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នេះ។

## ជំពូកទី៥

## អវសានប្បញ្ញត្ត

**មាត្រា ១៩._ និរាករណ៍**

ក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នេះត្រូវទុកជានិរាករណ៍។

**មាត្រា ២០._ ការអនុវត្ត**

សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវគោរពតាមក្រមប្រតិបត្តិវិជ្ជាជីវៈនេះឲ្យមានប្រសិទ្ធភាព។

# ឧបសម្ព័ន្ធទី២
# ក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
# នៃព្រះរាជាណាចក្រកម្ពុជា

# ក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
# នៃព្រះរាជាណាចក្រកម្ពុជា

រាល់ពេលបំពេញការងារ ឬប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ឬដឹកនាំដំណើរទស្សនកិច្ចកម្សាន្តដល់ភ្ញៀវ មគ្គុទ្ទេសក៍ទេសចរណ៍គួរប្រកាន់ខ្ជាប់នូវសីលធម៌វិជ្ជាជីវៈ ដូចតទៅ៖

- ប្រតិបត្តិការងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ
- មានអត្តចរិតថ្លៃថ្នូរ រួសរាយរាក់ទាក់ចំពោះភ្ញៀវ
- ចេះបង្កើតបរិយាកាសរីករាយ និងស្និទ្ធស្នាល
- ចេះគោរព ដោយមិនប្រកាន់នូវនិន្នាការសាសនា ជំនឿ ឬនយោបាយរបស់ភ្ញៀវ
- ស្វែងយល់ពីតម្រូវការផ្ទាល់របស់ភ្ញៀវ
- បង្ការ និងស្វែងយល់អំពីសុខសុវត្ថិភាពរបស់ភ្ញៀវ
- គោរពពេលវេលា
- រក្សាបាននូវភាពស្អាត និងអនាម័យផ្ទាល់ខ្លួនជានិច្ច
- ស្លៀកពាក់ឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ឲ្យបានសមរម្យ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ១៨៤ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១៤

## ប្រកាស
## ស្តីពី
## នីតិវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈរបស់ មគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមការងារចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.**_

ប្រកាសនេះ មានគោលបំណងបង្កើតនីតិវិធីក្នុងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានា និងបង្កើនប្រសិទ្ធភាព និងគុណភាពសេវាកម្ម



ផ្ទះលេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website:www.mot.kh

ទេសចរណ៍ឲ្យកាន់តែប្រសើរឡើង។

**ប្រការ ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ដែលកំពុងប្រកបវិជ្ជាជីវៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ច និងនីតិវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍

**ប្រការ ៣._**

ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ជាសមត្ថកិច្ចរបស់ក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍។

**ប្រការ ៤._**

ការព្រមាន និងការពិន័យផ្សេងៗត្រូវធ្វើឡើងដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ តាមរយៈការស្នើសុំរបស់ក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ ដោយផ្អែកតាមរបាយការណ៍របស់ក្រុមត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍ និងមន្ត្រីទទួលបន្ទុកត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍រាជធានី ខេត្ត។

**ប្រការ ៥._**

ការចុះត្រួតពិនិត្យ និងវាយតម្លៃសកម្មភាព និងការអនុវត្តវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវធ្វើឡើងដោយមន្ត្រីក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍ និង/ឬ មន្ត្រីទទួលបន្ទុកត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍រាជធានី ខេត្ត។

ករណីពិនិត្យឃើញថា មគ្គុទ្ទេសក៍ទេសចរណ៍ណាមួយបានអនុវត្តផ្ទុយពីគោលការណ៍ និងការណែនាំដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ មន្ត្រីក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍ និង/ឬមន្ត្រីទទួលបន្ទុកត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍រាជធានី ខេត្ត ត្រូវរាយការណ៍ជាបន្ទាន់មកក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍។

មន្ត្រីក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍ និង/ឬមន្ត្រីទទួលបន្ទុកត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍រាជធានី ខេត្ត ត្រូវបង្ហាញអត្តសញ្ញាណបណ្ណមុខងារ និងលិខិតអនុញ្ញាតឲ្យបំពេញបេសកកម្មរាល់ពេលចុះត្រួតពិនិត្យតាមគោលដៅ។

**ប្រការ ៦._**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលទទួលបានអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបានពិន្ទុ ដូចខាងក្រោម៖

- អាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្ន មានពិន្ទុសរុបចំនួន ០៥
- អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិដែលទទួលបានលើកដំបូង មានពិន្ទុសរុបចំនួន ០៨
- អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិ មានពិន្ទុសរុបចំនួន ១០។

**ប្រការ ៧._**

ពិន្ទុសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ អាចនឹងត្រូវបានដកជាបន្តបន្ទាប់រហូតឈានដល់ការព្រមាន ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកលើសកម្មភាព និងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៨._**

រាល់ការព្រមាន ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ និងបញ្ជាក់អំពីមូលហេតុច្បាស់លាស់អំពីកំហុសដែលមគ្គុទ្ទេសក៍ទេសចរណ៍នោះបានប្រព្រឹត្តិ។

**ប្រការ ៩._**

ក្រោយទទួលបានលិខិតព្រមាន ឬសេចក្តីសម្រេចជាលាយល័ក្ខអក្សរក្នុងការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ដែលមិនសុខចិត្តអាចធ្វើការតវ៉ាមកក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិវិញក្នុងរយៈពេល ១៤ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតព្រមាន ឬសេចក្តីសម្រេចជាលាយល័ក្ខអក្សរក្នុងការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍។

## ជំពូកទី៣
## ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍

**ប្រការ ១០._**

ការព្រមានចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវបានអនុវត្តដូចខាងក្រោម៖

- មគ្គុទ្ទេសក៍ទេសចរណ៍ទទួលបានអាជ្ញាបណ្ណទេសចរណ៍ (បណ្តោះអាសន្ន ឬពេញសិទ្ធិ) បានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៣ នឹងត្រូវទទួលការព្រមានលើកទី០១។
- ករណីដែលបានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៤ នឹងត្រូវទទួលការព្រមានលើកទី០២។

- ករណីមិនរាងចាល និងបានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៥ នឹងត្រូវទទួលរងការព្រមានលើកទី ០៣។ ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ដែលទទួលបានអាជ្ញាបណ្ណទេសចរណ៍បណ្ដោះអាសន្ន នឹងមិនអាចទទួលបានអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិឡើយ។

**ប្រការ ១១._**

ការបញ្ចុះថ្នាក់ និងការព្យួរអាជ្ញាបណ្ណទេសចរណ៍ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ទទួលបានអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិ ត្រូវបានអនុវត្តដូចខាងក្រោម៖

- មគ្គុទ្ទេសក៍ទេសចរណ៍ទទួលបានអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិ បានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៦ អាចនឹងត្រូវទទួលការពិន័យតាមរយៈការបញ្ចុះថ្នាក់ពីអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិមកជាអាជ្ញាបណ្ណទេសចរណ៍បណ្ដោះអាសន្ន ក្រោយមានការពិនិត្យលើស្ថានភាពកំហុសជាក់ស្ដែងពីក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍។
- ករណីបានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៧ នឹងត្រូវទទួលការពិន័យតាមរយៈការព្យួរអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេល ០៣ខែ ដោយមិនអនុញ្ញាតឲ្យប្រកបអាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ឡើយ។
- ករណីមិនរាងចាល និងបានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៨ នឹងត្រូវទទួលការពិន័យតាមរយៈការព្យួរអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេល ០៦ខែ ដោយមិនអនុញ្ញាតឲ្យប្រកបអាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ឡើយ។

**ប្រការ ១២._**

ការលុបអាជ្ញាបណ្ណទេសចរណ៍ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ទទួលបានអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិត្រូវបានអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ទាំងឡាយណាដែលបានប្រព្រឹត្តិកំហុសហួតឈានដល់ការដកពិន្ទុលើសពី ០៨ឡើងទៅ។

## ជំពូកទី៤
## ការទទួលបានពិន្ទុដែលបាត់បង់ និងការលើកទឹកចិត្ត

**ប្រការ ១៣._**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលបានអនុវត្តវិជ្ជាជីវៈត្រឹមត្រូវ និងមិនបានប្រព្រឹត្តិនូវកំហុសឆ្គងណាមួយដូចបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ អាចនឹងទទួលបានការលើកទឹកចិត្តតាមរយៈការផ្ដល់ជូនជារង្វាន់ មេដាយ ឬប័ណ្ណសរសើរដែលចេញដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

យន្តការនៃការលើកទឹកចិត្តដល់មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ ១៤._**

ក្នុងរយៈពេល ០៦ខែ បន្ទាប់ពីទទួលបានលិខិតព្រមាន ឬសេចក្តីសម្រេចដកពិន្ទុពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រសិនបើមគ្គុទ្ទេសក៍ទេសចរណ៍នោះ ពុំបានអនុវត្តខុសនឹងអ្វីដែលបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះទេ មគ្គុទ្ទេសក៍ទេសចរណ៍នោះនឹងទទួលបានពិន្ទុ ០១វិញ ទៅក្នុងអាជ្ញាបណ្ណទេសចរណ៍របស់ខ្លួន។

ការផ្តល់ពិន្ទុ ០១ វិញនេះ នឹងត្រូវបានអនុវត្តជារៀងរាល់ ០៦ខែម្តង រហូតទទួលបានពិន្ទុពេលពេញ ប្រសិនបើ មគ្គុទ្ទេសក៍ទេសចរណ៍នោះមិនបានប្រព្រឹត្តខុសតាមការកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**ប្រការ ១៥._**

ពិន្ទុដែលបានបាត់បង់ដោយសារការអនុវត្តមិនបានត្រឹមត្រូវតាមការកំណត់ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ មិនត្រូវបានផ្តល់ជូនវិញទេ ទោះបីមានការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មីឡើងវិញក៏ដោយ។

**ប្រការ ១៦._**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលអាជ្ញាបណ្ណទេសចរណ៍ត្រូវបានលុប ហើយមានបំណងបន្តវិជ្ជាជីវៈជាមគ្គុទ្ទេសក៍ទេសចរណ៍វិញ ត្រូវមកដាក់ពាក្យសុំចូលសិក្សាវគ្គវិក្រឹត្យការមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងរយៈពេល ០៦ខែ យ៉ាងតិចក្រោយពីដកអាជ្ញាបណ្ណទេសចរណ៍រួច។

**ប្រការ ១៧._**

ការព្រមាន ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ដែលសម្រេចដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអាចធ្វើឲ្យមគ្គុទ្ទេសក៍ទេសចរណ៍រួចផុតពីពិន័យអន្តរកាល និងការទទួលខុសត្រូវព្រហ្មទណ្ឌ ឬការទទួលខុសត្រូវរដ្ឋប្បវេណីនោះទេ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ ១៨._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៩.**_

វដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៏ទេសចរណ៍ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន អធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត សមាគមមគ្គុទ្ទេសក៏ទេសចរណ៍ មគ្គុទ្ទេសក៏ទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

ទេសចរណ៍

**ថោង ខុន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ

-សាលារាជធានី ខេត្ត

-ដូចប្រការ១៩

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៤

## ស្តីពី

## នីតិវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈ របស់មគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា

| ល.រ | សកម្មភាពពិន័យអប្បរមា | ពិន្ទុ |
|---|---|---|
| ១ | មគ្គុទេសក៍ទេសចរណ៍មិនអនុវត្តតាមបទបញ្ញត្តិ និងច្បាប់ជាធរមាន។ | ៥ |
| ២ | មគ្គុទ្ទេសក៍ទេសចរណ៍មិនស្លៀកពាក់ឯកសណ្ឋាន ឬអាវផ្ទាបណ្ណក្នុងពេលបំពេញការងារ។ | ៣ |
| ៣ | មគ្គុទ្ទេសក៍ទេសចរណ៍មិនបានពាក់ស្លាកឈ្មោះក្នុងពេលបំពេញការងារ។ | ១ |
| ៤ | មគ្គុទ្ទេសក៍ទេសចរណ៍មានអាកប្បកិរិយា ឬសម្តីមិនថ្លៃថ្នូរ ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬមុខមាត់ប្រទេសជាតិ។ | ២ |
| ៥ | មគ្គុទ្ទេសក៍ទេសចរណ៍ដែលនិយាយប៉ះពាល់ ឬប្រមាថដល់ការគោរពលើជំនឿសាសនានៃប្រជាពលរដ្ឋ ឬជាតិសាសន៍ណាមួយ។ | ២ |
| ៦ | មគ្គុទ្ទេសក៍ទេសចរណ៍បោះ ឬពង្រាយសម្រាមខណៈពេលកំពុងបំពេញការងារ។ | ១ |
| ៧ | មគ្គុទ្ទេសក៍ទេសចរណ៍បណ្តែតបណ្តោយឲ្យទេសចរធ្វើការបំផ្លិចបំផ្លាញធនធានទេសចរណ៍ ដូចជាតំបន់បេតិកភណ្ឌវប្បធម៌ ធម្មជាតិ និងតំបន់ទាក់ទាញទេសចរណ៍។ | ៣ |
| ៨ | មគ្គុទ្ទេសក៍ទេសចរណ៍ផ្តល់ព័ត៌មានដល់ភ្ញៀវដោយមធ្យោបាយផ្សេងៗ ឆ្ពោះទៅរកសេវាកម្ម ឬប្រព្រឹត្តិសកម្មភាពដែលមានការហាមឃាត់ដោយអាជ្ញាធរមូលដ្ឋាន ឬអ្នកគ្រប់គ្រងតំបន់។ | ២ |
| ៩ | មគ្គុទ្ទេសក៍ទេសចរណ៍ទាក់ទាញ ឬបញ្ចុះបញ្ចូលភ្ញៀវដោយមធ្យោបាយ ផ្សេងៗឆ្ពោះទៅរកសេវាកម្ម ឬប្រព្រឹត្តិសកម្មភាពដែលមានការហាមឃាត់ដោយអាជ្ញាធរមូលដ្ឋាន ឬអ្នកគ្រប់គ្រងតំបន់។ | ៣ |
| ១០ | មគ្គុទ្ទេសក៍ទេសចរណ៍នាំភ្ញៀវដោយមធ្យោបាយផ្សេងៗទៅរកសេវាកម្មឬប្រព្រឹត្តិសកម្មភាពដែលមានការហាមឃាត់ដោយអាជ្ញាធរមូលដ្ឋាន ឬអ្នកគ្រប់គ្រងតំបន់។ | ៥ |
| ១១ | មគ្គុទ្ទេសក៍ទេសចរណ៍នាំភ្ញៀវទៅកាន់ទីតាំងអាជីវកម្មណាមួយដែលផ្តល់នូវសេវាកម្មឬធ្វើអាជីវកម្មបោកប្រាស់ ឬក្លែងបន្លំ ឬរំលោភលើសេចក្តីទុកចិត្តរបស់ភ្ញៀវ ឬធ្វើការឃុបឃិតជាមួយឈ្មួញឬទីតាំងអាជីវកម្មណាមួយដោយជូនភ្ញៀវទៅទិញទំនិញ ឬវត្ថុអនុស្សាវរីយ៍ដោយតម្លៃមិនសមរម្យ។ | ៥ |
| ១២ | មគ្គុទ្ទេសក៍ទេសចរណ៍បង្ខិតបង្ខំភ្ញៀវទៅកាន់ទីតាំងអាជីវកម្មណាមួយដើម្បីទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួនដោយភ្ញៀវមិនពេញចិត្ត។ | |
| ១៣ | មគ្គុទ្ទេសក៍ទេសចរណ៍ស្នើសុំភ្ញៀវឲ្យផ្តល់កម្រៃឲ្យខ្លួនតាមគ្រប់មធ្យោបាយឬក៏ផ្តល់សេវាកម្មឲ្យភ្ញៀវមិនគ្រប់តាមស្តង់ដាដោយសារភ្ញៀវមិនផ្តល់កម្រៃបន្ថែមឲ្យខ្លួន។ | [illegible] |
| ១៤ | មគ្គុទ្ទេសក៍ទេសចរណ៍បំភិតបំភ័យឬបោកបញ្ឆោតទេសចរដើម្បីឲ្យពួកគាត់បង់ប្រាក់បន្ថែម។ | ៣ |

| | | |
|---|---|---|
| | ទៅលើសេវាកម្មណាមួយ។ | |
| ១៥ | មគ្គុទ្ទេសក៍ទេសចរណ៍ចាកចោល ឬបោះបង់ភ្ញៀវដោយមិនទាន់បានបញ្ចប់ការកិច្ច ឬគេចវេសមិនទទួលខុសត្រូវក្នុងស្ថានភាពគ្រោះថ្នាក់ ឬហានិភ័យ ណាមួយ។ | ៥ |
| ១៦ | មគ្គុទ្ទេសក៍ទេសចរណ៍លេងល្បែងស៊ីសង ឬនាំភ្ញៀវលេងល្បែងស៊ីសងខុសច្បាប់ខណៈពេលកំពុងបំពេញការងារ។ | ៣ |
| ១៧ | មគ្គុទ្ទេសក៍ទេសចរណ៍មានជម្លោះជាមួយអ្នកបើកបររថយន្តដឹកភ្ញៀវ ឬភ្ញៀវ ឬអាជ្ញាធរមានសមត្ថកិច្ច ឬបុគ្គលផ្សេងៗនៅចំពោះមុខភ្ញៀវខណៈពេលកំពុងបំពេញការងារ។ | ២ |
| ១៨ | មគ្គុទ្ទេសក៍ទេសចរណ៍ជក់បារីនៅចំពោះមុខភ្ញៀវ ខណៈពេលកំពុងបំពេញការងារ។ | ១ |
| ១៩ | មគ្គុទ្ទេសក៍ទេសចរណ៍ប្រើប្រាស់គ្រឿងស្រវឹង ខណៈពេលកំពុងបំពេញការងារ។ | ៤ |
| ២០ | មគ្គុទ្ទេសក៍ទេសចរណ៍មានការពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុញៀន ឬផ្តល់ព័ត៌មាន ឬធ្វើការទាក់ទាញ ឬបញ្ចុះបញ្ចូលដល់ភ្ញៀវឆ្ពោះទៅរកកន្លែងប្រើប្រាស់សារធាតុញៀនខុសច្បាប់។ | ១០ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១១៩ /ប្រក

ថ្ងៃពុធ ១៥កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៩

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍និង ភ្នាក់ងារទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងប្រកាសលេខ១៤៥ ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍។

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.**

ប្រកាសនេះមានគោលបំណង៖

- ពង្រឹងការគ្រប់គ្រងការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ឱ្យមានប្រសិទ្ធភាព



E-mail: admin@mot.gov.kh Website: www.tourismcambodia.org

- លើកកម្ពស់គុណភាពសេវាកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍
- បង្កើនទំនុកចិត្តដល់ប្រតិបត្តិករទេសចរណ៍ ភ្ញៀវទេសចរជាតិអន្តរជាតិ និងភាគីពាក់ព័ន្ធក្នុងការប្រកបអាជីវកម្មនិងប្រើប្រាស់សេវាកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់វិធានគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មរបស់ការីទេសចរណ៍និង ភ្នាក់ងារទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មានន័យដូចខាងក្រោម៖

- **ការីទេសចរណ៍** (Tour Operators) សំដៅដល់បុគ្គលដែលរៀបចំ និងលក់ខ្សែទស្សនកិច្ចព្រមទាំងប្រមូលផ្តុំ សេវាកម្មទេសចរណ៍ផ្សេងៗទៀត សម្រាប់លក់ដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា
- **ការីទេសចរណ៍នាំភ្ញៀវចេញក្រៅប្រទេស** (Outbound Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវទេសចរដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា
- **ការីទេសចរណ៍នាំភ្ញៀវចូលក្នុងប្រទេស** (Inbound Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវទេសចរនៅក្រៅប្រទេសចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា
- **ការីទេសចរណ៍ក្នុងស្រុក** (Domestic Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវទេសចរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា
- **ភ្នាក់ងារទេសចរណ៍** (Travel Agent) សំដៅដល់បុគ្គលសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មផ្សេងៗទៀតរាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតដោយការីទេសចរណ៍ផងដែរ
- **ប្រាក់តម្កល់ធានាអាជីវកម្ម** សំដៅដល់ទឹកប្រាក់បម្រុងកាតព្វកិច្ចកំណត់ដោយក្រសួងទេសចរណ៍សម្រាប់ធានាអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ក្នុងធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍

**ប្រការ៥ .-**

ក្រសួងទេសចរណ៍ជាស្ថាប័នទទួលបន្ទុកគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៦ .-**

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍បាន ដោយគ្មានការតម្កល់ប្រាក់ធានាអាជីវកម្មជាមុននោះទេ។

## ជំពូកទី៣
## នីតិវិធីនៃការគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍

**ប្រការ៧ .-**

ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មនៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា Foreign Trade Bank of Cambodia (FTB) ឬធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍។

**ប្រការ៨ .-**

ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មទៅតាមប្រភេទអាជ្ញាបណ្ណទេសចរណ៍ដែលបានស្នើសុំដូចខាងក្រោម៖

- ក. ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។
- ខ. ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរចូលកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៥០០០(ប្រាំពាន់) ដុល្លារអាមេរិក។
- គ. ភ្នាក់ងារទេសចរណ៍ (Travel Agent) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក។
- ឃ. ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន២០០០(ពីរពាន់)ដុល្លារអាមេរិក។
- ង. ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៥០០(ប្រាំរយ)ដុល្លារអាមេរិក។
- ច. ចំពោះប្រតិបត្តិករទេសចរណ៍ដែលមានអាជ្ញាបណ្ណទេសចរណ៍ជាការីទេសចរណ៍ច្រើនប្រភេទរួមមាន អាជ្ញាបណ្ណទេសចរណ៍ជាការីទេសចរណ៍ផង និងភ្នាក់ងារទេសចរណ៍ផង ស្ថិតក្រោមឈ្មោះតែមួយត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។
- ឆ. ចំពោះសាខារបស់ការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍មិនតម្រូវឱ្យតម្កល់ប្រាក់ធានាអាជីវកម្មដោយឡែកឡើយ។

**ប្រការ៩ .-**

ប្រតិបត្តិករទេសចរណ៍ ដែលមានបំណងកែប្រែប្រភេទអាជីវកម្មជាការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ ឬបន្តអាជ្ញាបណ្ណទេសចរណ៍ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ៨នៃប្រកាសនេះ។

## ជំពូកទី៤
## ការផ្លាស់ប្តូរនាមករណ៍ និង/ឬឈ្មោះម្ចាស់អាជីវកម្មការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍

**ប្រការ១០.**

ករណីមានការកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន ប្រតិបត្តិករទេសចរណ៍ត្រូវស្នើសុំការអនុញ្ញាតកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មជាមុនសិន ហើយទើបអាចមកស្នើសុំកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍ជំនួសនាមករណ៍ចាស់នៅក្រសួងទេសចរណ៍បាន។

ប្រសិនបើប្រតិបត្តិករទេសចរណ៍ស្នើសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មថ្មី ដោយមិនបានកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុនលើអាជ្ញាបណ្ណទេសចរណ៍ចាស់ ការកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍លើអាជ្ញាបណ្ណទេសចរណ៍មិនអាចអនុញ្ញាតបានទេ។

**ប្រការ១១.**

ករណីប្តូរឈ្មោះម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬអ្នកគ្រប់គ្រង ប្រតិបត្តិករទេសចរណ៍ត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

- លិខិតផ្ទេរ និងប្រគល់សិទ្ធិរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬអ្នកគ្រប់គ្រង
- កំណត់ហេតុនៃសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន ឬថ្នាក់ដឹកនាំស្តីពីការសម្រេចឱ្យបុគ្គលតំណាងក្រុមហ៊ុនដើម្បីគ្រប់គ្រងគណនីបន្តនៅធនាគារ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនមានសុពលភាព។

## ជំពូកទី៥
## ការដកប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍

**ប្រការ១២.**

ប្រតិបត្តិករទេសចរណ៍អាចដាក់ពាក្យសុំដកប្រាក់តម្កល់ធានាអាជីវកម្មរបស់ខ្លួនវិញបាន ក្នុងករណីបិទអាជីវកម្មការីទេសចរណ៍ និង/ឬភ្នាក់ងារទេសចរណ៍។ ករណីនេះ ក្រសួងទេសចរណ៍នឹងពិនិត្យសម្រេចអនុញ្ញាតផ្តល់ឱ្យ៖

- លិខិតអនុញ្ញាតឱ្យបិទសកម្មភាពអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍
- លិខិតអនុញ្ញាតឱ្យដកប្រាក់តម្កល់ធានាអាជីវកម្មនេះវិញ។

ចំពោះបុគ្គលដែលបានដាក់ប្រាក់តម្កល់ធានាអាជីវកម្មរួចហើយ តែផ្លាស់ប្តូរមិនធ្វើអាជីវកម្មជាការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍អាចសុំដកប្រាក់តម្កល់វិញបាន ដោយត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងទេសចរណ៍ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់។ ក្រសួងទេសចរណ៍នឹងពិនិត្យសម្រេចផ្តល់លិខិតអនុញ្ញាតឱ្យដកប្រាក់តម្កល់ធានាអាជីវកម្មវិញតាមការស្នើសុំ។

**ប្រការ១៣.**

ករណីមានពាក្យប្តឹង បុការតវ៉ារបស់ភ្ញៀវ ឬប្រតិបត្តិករទេសចរណ៍ជាដៃគូ ឬសមត្ថកិច្ចពាក់ព័ន្ធចំពោះការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ទាក់ទងនឹងការបាត់បង់សម្ភារ ឬគ្រោះថ្នាក់ផ្សេងៗ ឬជំពាក់ប្រាក់ក្នុងដំណើរការអាជីវកម្ម ឬបញ្ហាពាក់ព័ន្ធនានា ហើយការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍នោះគេចវេះមិនព្រមចូលមកដោះស្រាយ ប្រាក់តម្កល់ធានាអាជីវកម្មនោះនឹងត្រូវបានដកដើម្បីដោះស្រាយបញ្ហាដែលមានការពាក់ព័ន្ធផ្សេងៗ។ ០៥ (ប្រាំ) ភាគរយនៃប្រាក់តម្កល់ធានាអាជីវកម្មដែលត្រូវបានដកនេះ ត្រូវចាត់ចែងសម្រាប់ទូទាត់ចំណាយក្នុងប្រតិបត្តិការតាមនីតិវិធីដោះស្រាយបញ្ហាពាក់ព័ន្ធផ្សេងៗ។

ការដកប្រាក់តម្កល់ធានាអាជីវកម្មនេះត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ១៤.-**

ក្រសួងទេសចរណ៍នឹងផ្សព្វផ្សាយតាមរយៈសារព័ត៌មានអំពីការតវ៉ារបស់ភ្ញៀវ ការបាត់បង់សម្ភារ ឬគ្រោះថ្នាក់ផ្សេងៗ ឬជំពាក់ប្រាក់ក្នុងដំណើរការអាជីវកម្ម ឬបញ្ហាពាក់ព័ន្ធនានា ដោយទុកឱកាសរយៈពេល ៣០ (សាមសិប)ថ្ងៃ សម្រាប់ទទួលពាក្យស្នើសុំការដោះស្រាយលើការបាត់បង់សម្ភារ ឬគ្រោះថ្នាក់ផ្សេងៗ ឬការជំពាក់ប្រាក់ ឬបញ្ហាពាក់ព័ន្ធនានាពីភាគីពាក់ព័ន្ធ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៥.-**

ប្រកាសលេខ២១២ ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវចាត់ជានិរាករណ៍។

**ប្រការ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១៧.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គាធិការ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ និងប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**ចម្លងជូន:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
- សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា (PATA)
- ដូចប្រការ១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍
លេខ ០៩៧/[illegible] ទក.

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ[illegible] ឆ្នាំ ២០០[illegible]

## ប្រកាស
## ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍
## ដល់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ / នស/ រកម / ០១៩៦ / ~~១៥~~ ចុះថ្ងៃទី ~~២៤ ខែ មករា ឆ្នាំ ១៩៩៦~~ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក. ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក.ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និងភារកិច្ចនិងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការណ៍អន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍។
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍។

## សម្រេច

ប្រការ ១ : អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន រួមមាន:
- ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍
- ភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក

១- ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍

ក. ភោជនីយដ្ឋានទេសចរណ៍ គឺជាអាជីវកម្មបំរើសេវាម្ហូបអាហារ និងភេសជ្ជៈដែលមានអ្នកបំរើ មានដំណើរការច្រើនពេល និងរាល់ថ្ងៃនៅគ្រប់ទីកន្លែង ដែលបំរើអោយទេសចរជាធំ ហើយមានប្រភេទដូចជា : ភោជនីយដ្ឋានខ្នាតធំ ភោជនីយដ្ឋានខ្នាតមធ្យម Barbistro ភោជនីយដ្ឋានខ្នាតតូច និងភោជនីយដ្ឋានបៀរហ្គាឌិន :



[illegible] ភ្នំពេញ ១២២៥៨ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : +៨៥៥ ២៣ [illegible] ទូរសារ : +៨៥៥ ២៣ [illegible] Email [illegible]

- ភោជនីយដ្ឋានខ្នាតធំ : គឺជាអាជីវកម្មបំរើសេវាម្ហូបអាហារ ភេសជ្ជៈ ដែលមានអ្នកបំរើ និងមានម្ហូបអាហារភេសជ្ជៈច្រើនមុខសំរាប់ជ្រើសរើស សំភារៈទំនើប ការបំរើសេវាកំរិតខ្ពស់តាមលក្ខណៈស្តង់ដា មានបំរើអាហារច្រើនពេល និងរៀបចំបំរើក្នុងពិធីផ្សេងៗ មានការប្រគុំតន្ត្រីកំដរនៅពេលល្ងាច និងពេលយប់ ឬគ្មានការប្រគុំតន្ត្រី ។
- ភោជនីយដ្ឋានខ្នាតមធ្យម Barbistro : មានបំរើម្ហូបអាហារជាលក្ខណៈចំអិនស្រាប់ បំរើដោយសេរី (buffet) មានលក់នំនិង ភេសជ្ជៈគ្មានជាតិស្រវឹង ឬមានជាតិស្រវឹងតិច ដែលរៀបចំនៅក្បែរអតិថិជន ការបំរើតាម លក្ខណៈស្តង់ដាកំរិតខ្ពស់ ។
- ភោជនីយដ្ឋានខ្នាតតូច : មានផ្តល់ម្ហូបអាហារ ភេសជ្ជៈ គ្មានជាតិស្រវឹង ឬមានជាតិស្រវឹងតិចដែលមុខម្ហូបអាហារមានកំណត់ទៅតាមអាហារប័ណ្ណ ហើយពុំមានសំភារៈទំនើប និងពុំមានការប្រគុំតន្ត្រីកំដរ ដែលមានចំនួនកៅអីក្រោម ១០០ ។
- ភោជនីយដ្ឋាន ហ្សៀរហ្គាឌិនៈ គឺជាភោជនីយដ្ឋានដែលបំរើភេសជ្ជៈគ្រប់ប្រភេទ និងមុខម្ហូបអាហារមានកំណត់ ព្រមទាំងមានប្រគុំតន្ត្រីកំដរសំរាប់ភ្ញៀវជាតិ និងអន្តរជាតិ ច្រៀងនិងស្តាប់កំសាន្ត ។

ខ. អាហារដ្ឋានទេសចរណ៍ គឺជាអាជីវកម្ម ផ្តល់សេវាម្ហូបអាហារ ភេសជ្ជៈ ដែលមានអ្នកបំរើ ឬបំរើដោយខ្លួនឯង និងការផ្តល់សេវាម្ហូបអាហារ ភេសជ្ជៈមានកំណត់ មានបំរើសេវាម្ហូបអាហារក្រៅពេល អាហារវេចខ្ចប់ និងសាច់អាំង។ អាហារដ្ឋានខ្លះ មានបំរើច្រើនពេល ខ្លះមានតែមួយពេល ឬពីរពេល ។

❖ អាហារដ្ឋានខ្លះបំរើភេសជ្ជៈជាធំ មានដូចជាៈ

- Pub : ជាប្រភេទអាជីវកម្ម ដែលបំរើភេសជ្ជៈជាធំ និងអាហារមានកំណត់ដូចជាអាហារត្រជាក់ អាហារវេចខ្ចប់ ជាទូទៅតំលៃសមរម្យ ។
- Hotelbar : ជាប្រភេទអាជីវកម្ម ដែលមានដំណើរការនៅតាមសណ្ឋាគារ ។ អាជីវកម្មប្រភេទនេះមានបំរើភេសជ្ជៈជាធំ និងអាហារមានកំណត់ ដែលតំរូវអោយអ្នកលាយស្រាដើម្បីលក់ភេសជ្ជៈគ្រប់ប្រភេទ និងមានគុណភាពកំរិតខ្ពស់ ហើយដំណើរការក្នុងរយៈពេលមានកំណត់ ។
- Coffeebar : ជាប្រភេទអាជីវកម្ម ដែលបំរើភេសជ្ជៈជាធំ មានបច្ចេកទេសកំរិតខ្ពស់ ដូចជា កាហ្វេ និងមានបំរើជាមួយអាហារបន្ទាប់បន្សំ។
- Coffee House : ជាហាងកាហ្វេ ដែលមានលក់កាហ្វេទៅតាមបច្ចេកទេសផ្សេងៗ និងមានលក្ខណៈតុបតែងផ្សេងៗគ្នា ។ ក្រៅពីកាហ្វេក៏មានផ្តល់ភេសជ្ជៈកំរិតខ្ពស់ ដែលមានជាតិស្រវឹង និងមានដំណើរការ ចាប់ពីពេលបើករហូតដល់អស់ភ្ញៀវ ។
- Drink bar : ជាប្រភេទអាជីវកម្ម ដែលបំរើភេសជ្ជៈលាយ និងមានបំរើអាហារត្រជាក់ក្រៅពេល មានបំរើបន្ថែមនូវកាហ្វេ តែ និងភេសជ្ជៈផ្សេងៗទៀត ។

❖ អាហារដ្ឋានបំរើសេវាម្ហូបអាហារជាធំៈ

- Self Service bar: ជាប្រភេទអាជីវកម្មដែលបំរើសេវាដោយខ្លួនឯងមានបំរើម្ហូបអាហារក្តៅ (ស៊ុប) ម្ហូបអាហារដែលចំអិនស្រាប់ ម្ហូបអាហារត្រជាក់ ម្ហូបវេចខ្ចប់ដាក់នៅក្នុងទូកញ្ចក់ មានបំរើភេសជ្ជៈដែលគ្មានជាតិស្រវឹង ឬមានជាតិស្រវឹងតិច ។

- Universal bar: ជាប្រភេទអាជីវកម្ម ដែលបំរើសេវាដោយខ្លួនឯង មានអាហារដ្ឋានតូចៗជាច្រើន រួមគ្នាបង្កើតបានជាភោជនីយដ្ឋាន ហៅថាសហភោជនីយដ្ឋាន ដែលមានម្ហូបអាហារច្រើនមុខសំរាប់ជ្រើសរើសទៅតាមការនិយមរបស់អតិថិជន ។
- Fast food bar: ជាប្រភេទអាជីវកម្ម ដែលបំរើសេវាដោយខ្លួនឯង មានបំរើអាហារក្រៅពេល អាហារត្រជាក់ អាហារវេចខ្ចប់ ដូចជា Hamburger Pizza ។ល។
- Snack bar: ជាអាជីវកម្មម្ហូបអាហារ ដែលមានអ្នកបំរើ មានបំរើអាហារត្រជាក់ស្រស់ អាហារក្តៅ អាហារក្រៅពេល ភេសជ្ជៈគ្មានជាតិស្រវឹង និងមានជាតិស្រវឹងតិច និងមានបង្អែម។ ចាប់បើកពីពេលព្រឹករហូតដល់ពេលយប់ ។
- Grill bar: ជាប្រភេទអាជីវកម្ម ដែលបំរើអាហារ ដូចជា សាច់អាំង នំប៉័ងសាច់ ជំឡូងចៀន ត្រីចៀន ។ល។

∻Catering bar: ជាប្រភេទអាជីវកម្ម ដែលផលិតម្ហូបអាហារសំរាប់គ្រឹះស្ថានណាមួយ ឬទីកន្លែងកំសាន្តសាធារណៈ ដូចជាអាហារបំរុងទុក អាហារវេចខ្ចប់ ។ល។

២- ភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក

ភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក គឺជាអាជីវកម្មបំរើសេវាម្ហូបអាហារ និងភេសជ្ជៈមានកំណត់ ពុំមានសំភារៈទំនើប មានដំណើរការតែមួយពេល ឬពីរពេល។ ភោជនីយដ្ឋាន និងអាហារដ្ឋានប្រភេទនេះ មិនឋិតនៅតាមតំបន់ទេសចរណ៍ និងបំរើអតិថិជនក្នុងស្រុកជាធំ ដែលមានចំនួនកៅអីក្រោម ១០០ ដូចជា ហាងលក់គុយទាវ ហាងលក់បាយ ហាងកាហ្វេ។

ប្រការ ២ : - ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ អោយប្រកបអាជីវកម្ម ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ និង ការផ្អាក ការដកហូត បិទអាជីវកម្ម គឺជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។

ប្រការ ៣ : - ការផ្តល់អាជ្ញាប័ណ្ណ អោយប្រកបអាជីវកម្ម ភោជនីយដ្ឋាន អាហារដ្ឋានក្នុងស្រុក និង ការផ្អាក ការដកហូត បិទអាជីវកម្ម គឺជាសមត្ថកិច្ចរបស់អាជ្ញាធរដែនដី តាមរយៈការិយាល័យទេសចរណ៍ ខណ្ឌ ស្រុក ។

ប្រការ ៤ : - ការរៀបចំសុំអាជ្ញាប័ណ្ណភោជនីយដ្ឋាន និងអាហាដ្ឋានទេសចរណ៍ ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មដោយអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួន:

ក- លិខិតអនុញ្ញាតដាក់ទីតាំងធ្វើអាជីវកម្ម ចេញដោយអាជ្ញាធរដែនដីសំរាប់សំណង់កែច្នៃ ឬជួសជុល ។ ចំពោះលិខិតអនុញ្ញាតសាងសង់សំណង់ថ្មី សំរាប់មុខសញ្ញាអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន ត្រូវចេញដោយក្រសួង ឬ មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។
ខ- វិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
គ- លិខិតបញ្ជាក់លើប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព និងអគ្គិភ័យ ចេញដោយក្រសួងមហាផ្ទៃ ឬស្នងការដ្ឋាននគរបាលខេត្ត-ក្រុង

ឃ- លិខិតបញ្ជាក់លើអនាម័យចេញដោយក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាល

ង- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

ច- វិញ្ញាបនប័ត្រធានារ៉ាប់រង អំពីភារៈទទួលខុសត្រូវសាធារណៈ

ឆ- លិខិតយល់ព្រមជាលាយលក្ខអក្សររបស់ម្ចាស់ បើសិនអ្នកគ្រប់គ្រងមិនមែនជាម្ចាស់កម្មសិទ្ធិ

ជ- សញ្ញាប័ត្រ ឬ វិញ្ញាបនប័ត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬ គ្រប់គ្រងទេសចរណ៍។

ប្រការ ៥ : - ការរៀបចំសុំអាជ្ញាប័ណ្ណភោជនីយដ្ឋាន អាហារដ្ឋានក្នុងស្រុក ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ដោយអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនៈ

ក- លិខិតអនុញ្ញាតដាក់ទីតាំងធ្វើអាជីវកម្ម ចេញដោយអាជ្ញាធរដែនដី សំរាប់សំណង់កែច្នៃ ឬជួសជុល ។ ចំពោះលិខិតអនុញ្ញាតសាងសង់សំណង់ថ្មី សំរាប់មុខសញ្ញាអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន ត្រូវចេញដោយក្រសួង ឬមន្ទីររៀបចំដែនដីនគរូបនីយកម្ម-និងសំណង់ ។

ខ- វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចេញដោយមន្ទីរពាណិជ្ជកម្ម

គ- លិខិតបញ្ជាក់លើប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព និងអគ្គីភ័យ ចេញដោយស្នងការដ្ឋាននគរបាលខេត្ត-ក្រុង

ឃ- លិខិតបញ្ជាក់លើអនាម័យ ចេញដោយមន្ទីរសុខាភិបាលខេត្ត-ក្រុង

ង- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

ច- វិញ្ញាបនបត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ចេញដោយមន្ទីរទេសចរណ៍។

ប្រការ ៦ : ការដាក់ទីតាំងអាជីវកម្មភោជនីយដ្ឋានបៀរហ្គាឌិន ត្រូវស្ថិតនៅចំងាយយ៉ាងតិច ២០០ម៉ែត្រ ពីសាលារៀន មន្ទីរពេទ្យ វត្តអារ៉ាម ស្ថានទូត និងកន្លែងស្ថាប័នរដ្ឋបាលសំខាន់ៗ។

ប្រការ ៧ : - អាជ្ញាប័ណ្ណភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ត្រូវបានចេញអោយប្រើប្រាស់ក្រោយពីអាជីវករបានបំពេញសំណុំឯកសារ ក្នុងការដាក់ពាក្យសុំធ្វើអាជីកម្មបានគ្រប់គ្រាន់និងត្រឹមត្រូវ យ៉ាងយូរក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានដាក់ពាក្យ។ ក្នុងករណីដែលក្រសួង មន្ទីរទេសចរណ៍ខេត្ត-ក្រុង បដិសេធមិនផ្តល់ ឬមិនបន្តអាជ្ញាប័ណ្ណភោជនីយដ្ឋាន និងអាហារដ្ឋាន ក្រសួង មន្ទីរទេសចរណ៍ នឹងបញ្ជាក់ហេតុផលជាលាយល័ក្ខអក្សរជូនដល់អាជីវករ មិនលើសពី ១០ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យ។

- អាជ្ញាប័ណ្ណភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក ត្រូវបានចេញអោយប្រើប្រាស់ក្រោយពីអាជីវករបានបំពេញសំណុំឯកសារដូចបានកំណត់ខាងលើ ក្នុងការដាក់ពាក្យសុំធ្វើអាជីកម្មបានគ្រប់គ្រាន់និងត្រឹមត្រូវ យ៉ាងយូរក្នុងរយៈពេល ១២ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានដាក់ពាក្យ។ ក្នុងករណីដែលអាជ្ញាធរដែនដី បដិសេធមិនផ្តល់ឬមិនបន្ត អាជ្ញាប័ណ្ណភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក អាជ្ញាធរដែនដី នឹងបញ្ជាក់ហេតុផលជាលាយល័ក្ខអក្សរជូនដល់អាជីវករ មិនលើសពី ០៥ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យ។

ប្រការ ៨ : - នៅពេលអ្នកស្នើសុំអាជ្ញាប័ណ្ណ បានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវតាមបែបបទ ដូចមានកំណត់ក្នុងប្រការ៤ ក្រសួង មន្ទីរទេសចរណ៍ខេត្ត-ក្រុង ឬ អាជ្ញាធរដែនដី នឹងចេញអាជ្ញាប័ណ្ណ សំរាប់ធ្វើអាជីវកម្ម ដែលមានសុពលភាពរយៈពេល ០១ឆ្នាំ។

- ក្នុងករណីអាជីវករមិនអាចបំពេញបែបបទអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលានោះ អ្នកស្នើ អាចស្នើសុំដោយធ្វើកិច្ចសន្យាសុំដាក់ឯកសារជាបណ្តោះអាសន្ននិងធានាបំពេញក្នុងរយៈពេល០៣ខែ។ ស្ថិតក្នុងករណីនេះក្រសួង មន្ទីរទេសចរណ៍ ឬ អាជ្ញាធរដែនដី នឹងចេញអាជ្ញាប័ណ្ណ សំរាប់ធ្វើអាជីវកម្មជាបណ្តោះអាសន្ន និងមានសុពលភាពរយៈពេល ០៣ខែ។ បន្ទាប់ពីបានបំពេញឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមកិច្ចសន្យា ក្រសួង មន្ទីរទេសចរណ៍ ឬអាជ្ញាធរដែនដី នឹងផ្តល់អាជ្ញាប័ណ្ណ ដែលមានសុពលភាពរយៈពេល ០១ឆ្នាំ ជូនដល់អតិថិជន។

ប្រការ ៩ : អាជ្ញាប័ណ្ណមានសុពលភាពសំរាប់រយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃចេញច្បាប់អនុញ្ញាត។ មុនពេលផុតសុពលភាពអាជ្ញាប័ណ្ណ អាជីវករត្រូវដាក់ពាក្យសុំបន្ត ដោយភ្ជាប់ជាមួយនូវអាជ្ញាប័ណ្ណចាស់ និងប័ណ្ណពន្ធប៉ាតង់អោយបាន០១ខែ មុនថ្ងៃផុតកំណត់ ក្នុងរយៈពេលដែលបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណ អាជីវករនៅតែមានសិទ្ធិធ្វើអាជីវកម្ម រហូតដល់ថ្ងៃដែលក្រសួង មន្ទីរទេសចរណ៍ ឬអាជ្ញាធរដែនដី ពិនិត្យសំរេចលើលក្ខណៈសម្បត្តិក្នុងការផ្តល់អាជ្ញាប័ណ្ណបន្តអាជីវកម្ម។

ប្រការ ១០ : ពេលមានការផ្ទេរ លក់ ជួល បិទ អាជីវកម្ម ការផ្លាស់ប្តូរទីតាំងអាជីវកម្ម ផ្លាស់ប្តូរអ្នកគ្រប់គ្រងអាជីវករ ត្រូវដាក់ពាក្យតាមរយៈមន្ទីរទេសចរណ៍ខេត្ត-ក្រុង ឬអាជ្ញាធរដែនដីអោយបានមុន ០៣ខែ ។

ប្រការ ១១ :

- ការបង់ប្រាក់សុំអាជ្ញាប័ណ្ណភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ដើម្បីសុំបើកដំណើរការអាជីវកម្មដំបូង ឬបន្តត្រូវបានកំណត់ដូចខាងក្រោម:

ក- ការបង់ប្រាក់បើកអាជីវកម្មឆ្នាំដំបូង:

| | | | |
|---|---|---|---|
| - ភោជនីយដ្ឋាន ខ្នាតធំ: | - ចំណុះ ១០១នាក់-២០០នាក់ | = | ៦០០.០០០ រៀល |
| | - ចំណុះ ២០១នាក់-៣០០នាក់ | = | ១.០០០.០០០ រៀល |
| | - ចំណុះ ៣០១នាក់ ឡើងទៅ | = | ១.២០០.០០០ រៀល |
| - ភោជនីយដ្ឋាន ខ្នាតមធ្យម Barbistro : | | = | ៦០០.០០០ រៀល |
| - ភោជនីយដ្ឋាន ខ្នាតតូច | - ចំណុះ ៥០នាក់-១០០នាក់ | = | ៤០០.០០០ រៀល |
| | - ចំណុះ ក្រោម ៥០នាក់ | = | ២០០.០០០ រៀល |
| - ភោជនីយដ្ឋាន បៀរហ្គាឌិន : | | | ៨០០.០០០ រៀល |
| - អាហារដ្ឋាន : | - ចំណុះ ៥១នាក់ឡើង | = | ៤០០.០០០ រៀល |
| | - ចំណុះ ៥០នាក់ចុះ | = | ២០០.០០០ រៀល |

ខ-ការផ្លាស់ប្តូរទីតាំង ឬប្តូរអ្នកគ្រប់គ្រង ត្រូវបង់ ១០ភាគរយ នៃទឹកប្រាក់ដែលបានកំណត់ក្នុងប្រការ ១១ ក ។

- ការបង់ប្រាក់សុំអាជ្ញាប័ណ្ណភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក ការបើកអាជីវកម្មដំបូង បន្ត ផ្លាស់ប្តូរទីតាំង ផ្លាស់ប្តូរអ្នកគ្រប់គ្រង ត្រូវកំណត់ដោយអាជ្ញាធរដែនដី។

ប្រការ ១២ :-ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មត្រូវដាក់ពាក្យសុំដំបូង ឬបន្តអាជ្ញាប័ណ្ណ ព្រមទាំងទទួលយកអាជ្ញាប័ណ្ណ នៅមន្ទីរទេសចរណ៍ខេត្ត-ក្រុង ឬការិយាល័យទេសចរណ៍ខណ្ឌ ស្រុក។

-អាជ្ញាប័ណ្ណ ដែលត្រូវពិនិត្យ និងសំរេចដោយមន្ទីរទេសចរណ៍ខេត្ត-ក្រុង ឬអាជ្ញាធរដែនដី ត្រូវកំណត់រយៈពេល ១២ថ្ងៃ នៃថ្ងៃធ្វើការ ។

-ចំពោះអាជ្ញាប័ណ្ណដែលត្រូវពិនិត្យ និងសំរេចដោយក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ ត្រូវទទួលពាក្យសុំ និងចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម ហើយបញ្ជូនមកក្រសួងទេសចរណ៍ ក្នុងរយៈពេល០៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រសួងទេសចរណ៍ (នាយកដ្ឋាន ឧស្សាហកម្មទេសចរណ៍) ត្រូវទទួលនិងពិនិត្យពាក្យសុំនេះ ហើយស្នើសុំការសំរេចចេញអាជ្ញាប័ណ្ណទេសចរណ៍ ក្នុងរយៈពេល ១២ថ្ងៃនៃថ្ងៃធ្វើការ ។ ករណីចាំបាច់ក្រសួងទេសចរណ៍ អាចចុះត្រួតពិនិត្យឡើងវិញលើមូលដ្ឋានអាជីវកម្មនោះ ក្នុងរយៈពេល ០៥ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យសុំ។ ក្រសួងទេសចរណ៍នឹងបញ្ជូនអាជ្ញាប័ណ្ណទេសចរណ៍ ដែលរួចជាស្ថាពរ ទៅមន្ទីរទេសចរណ៍ ក្នុងរយៈពេល ០៣ថ្ងៃ ។

ប្រការ ១៣ :- អាជីវករដែលទទួលបានអាជ្ញាប័ណ្ណ ត្រូវប្រើប្រាស់អាជ្ញាប័ណ្ណនេះអោយបានត្រឹមត្រូវ និងត្រូវគោរពអនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍។

- ករណីមានការខូចខាត ឬបាត់បង់អាជ្ញាប័ណ្ណ អាជីវករត្រូវធ្វើលិខិតជាលាយល័ក្ខអក្សរ បញ្ជាក់ពីមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍បណ្តោះអាសន្នឡើងវិញ ក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់។

ប្រការ ១៤ : ក្នុងករណីការធ្វើអាជីវកម្មដោយ :

ក-ការធ្វើអាជីវកម្ម ដោយប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ឬអនុវត្តមិនបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងទេសចរណ៍ អាជីវករនឹងត្រូវទទួលនូវការផាកពិន័យ ចំនួនទឹកប្រាក់ ២០០ ភាគរយ (ពីររយភាគរយ) នៃថ្លៃបង់ ។ ប្រសិនបើអាជីវករមិនអនុវត្តលើការផាកពិន័យនេះ ក្នុងរយៈពេល០៣ខែ ក្រសួង មន្ទីរទេសចរណ៍ ឬអាជ្ញាធរដែនដី នឹងផ្អាកការធ្វើអាជីវកម្ម ឬដកហូតអាជ្ញាប័ណ្ណ និងបិទអាជីវកម្ម។

ខ-ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ នឹងត្រូវទទួលការព្រមានជាលាយល័ក្ខអក្សរ និងបិទអាជីវកម្ម។

គ-ក្នុងករណីក្រសួង មន្ទីរទេសចរណ៍ ឬអាជ្ញាធរដែនដីរកឃើញថា អាជីវករបានផ្តល់ព័ត៌មានមិនពិត ឬប្រឌិតឯកសារពាក់ព័ន្ធនឹងពាក្យសុំធ្វើអាជីវកម្ម ក្រសួង មន្ទីរទេសចរណ៍ ឬអាជ្ញាធរដែនដី មានសិទ្ធិដកអាជ្ញាប័ណ្ណ ឬ ផ្អាកអាជីវកម្ម។ ✓

ឃ-ករណីអាជីវករប្រព្រឹត្តល្មើសនឹងច្បាប់បញ្ញត្តិទាំងឡាយរបស់រដ្ឋ នឹងត្រូវដកហូតអាជ្ញាប័ណ្ណ បិទអាជីវកម្ម ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។

ប្រការ ១៥ : -នៅពេលមូលដ្ឋានអាជីវកម្ម ត្រូវទទួលការផ្អាកឬដកហូតអាជ្ញាប័ណ្ណ ក្រសួង-មន្ទីរទេសចរណ៍ ឬអាជ្ញាធរដែនដី នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ផ្ញើរដល់ម្ចាស់ឬអ្នកគ្រប់គ្រង ដើម្បីទទួលប្រតិបត្តិតាម។ ក្នុងករណីសេចក្តីជូនដំណឹងមិនអាចផ្ញើបានដល់ម្ចាស់ ឬអ្នកគ្រប់គ្រងដោយប្រការណាមួយ ឬក៏សាមីខ្លួនជាម្ចាស់ ឬអ្នកគ្រប់គ្រងបដិសេធមិនព្រមទទួលស្គាល់ នោះសេចក្តីជូនដំណឹងនឹងត្រូវបិទនៅខាងមុខក្រុមហ៊ុន ឬមូលដ្ឋានអាជីវកម្ម ហើយត្រូវបានថតចំលងផ្ញើដល់សមាគមទេសចរណ៍ក្នុងស្រុក និងភ្នាក់ងារមានសមត្ថកិច្ច ដើម្បីទុកជាព័ត៌មាន ។

ប្រការ ១៦ : ការផ្អាក ការដកហូតអាជ្ញាប័ណ្ណមានរយៈពេលកំណត់មិនលើសពី ០៦ ខែ ។ ក្នុងរយៈពេលផ្អាក ឬដកហូតអាជ្ញាប័ណ្ណនេះ មូលដ្ឋានអាជីវកម្មមិនត្រូវបានអនុញ្ញាតអោយធ្វើសកម្មភាពឡើយ។ ក្រោយពីផុតកំណត់ពេលនៃការផ្អាក ឬដកហូត ម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវធ្វើលិខិតស្នើសុំមកក្រសួង មន្ទីរទេសចរណ៍ ឬអាជ្ញាធរដែនដី ដើម្បីសុំដំណើរការអាជីវកម្មឡើងវិញ ។

ប្រការ ១៧ : បុគ្គលណាមួយដែលរារាំងដល់ការងារត្រួតពិនិត្យ ឬផ្តល់អាជ្ញាប័ណ្ណក្លែងបន្លំ មិនត្រឹមត្រូវផ្ទុយទៅនឹងបទបញ្ញត្តិរបស់ក្រសួងទេសចរណ៍នឹងត្រូវទទួលនូវវិធានការរដ្ឋបាល ឬទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ១៨ : ០៣ ខែ ក្រោយពីការចុះហត្ថលេខាលើប្រកាសនេះ ក្រសួង មន្ទីរទេសចរណ៍ ឬអាជ្ញធរដែនដីនឹងមិនអនុញ្ញាតអោយធ្វើអាជីវកម្ម ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ ឬភោជនីយដ្ឋាន អាហារដ្ឋានក្នុងស្រុក ដោយគ្មានអាជ្ញាប័ណ្ណទៀតឡើយ ។

ប្រការ ១៩ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ២០ : ប្រកាសនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថោង ខុន

<u>កន្លែងទទួល</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលា ខេត្ត-ក្រុង " ដើម្បីជូនជ្រាប "
- គ្រប់មន្ទីរទេសចរណ៍ ខេត្ត-ក្រុង " ដើម្បីមុខការ "
- គ្រប់អាជីវកម្មភោជនីយដ្ឋាន និង អាហារដ្ឋាន " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ..០០៣..សរណន

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០០៨

# សារាចរណែនាំ
## ស្ដីពីការគ្រប់គ្រងអាជីវកម្ម
## ភោជនីយដ្ឋាន និងអាហារដ្ឋាន

ដើម្បីគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋានអោយមាន សណ្ដាប់ធ្នាប់ របៀបរៀបរយសន្តិសុខ សុវត្ថិភាព ធានសុជីវធម៌ជូន ភ្ញៀវជាតិ និងអន្តរជាតិ និងក្នុងគោលបំណងធានាការ អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ថែរក្សាការពារវប្បធម៌ ប្រពៃណីជាតិ ស្របទៅតាមគោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីអនុវត្តប្រកាសលេខ ០៧៦ ប្រ.ក. ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨ ស្ដីពីការផ្ដល់អាជ្ញាប័ណ្ណទេសចរណ៍ ដល់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន ក្រសួងទេសចរណ៍ សូមធ្វើការណែនាំដូចខាងក្រោម :

១ : - រាល់ការធ្វើអាជីវកម្ម ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ និងភោជនីយដ្ឋាន អាហារដ្ឋានក្នុងស្រុក អាជីវករត្រូវមានច្បាប់អនុញ្ញាតពីក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ ឬអាជ្ញាធរដែនដី។ ទំរង់បែបបទនៃការសុំធ្វើអាជីវកម្មត្រូវ អនុវត្ត តាមប្រកាសរបស់ក្រសួងទេសចរណ៍ ។

- ឯកសារផ្សេងៗទៀតដែលក្រសួង មន្ទីរទេសចរណ៍ អាជ្ញាធរដែនដីត្រូវការ រួមមាន:
  + កិច្ចសន្យារបស់ម្ចាស់អាជីវកម្ម ក្នុងការប្រកបអាជីវកម្ម ។
  + កិច្ចសន្យាជំពាក់ឯកសារដែលត្រូវបំពេញឡើងវិញ ក្នុងរយៈពេល០៣ខែ ។
  + បើសិនការធ្វើអាជីវកម្មនេះ មានការប៉ះពាល់ដល់ផ្នែកបរិស្ថាន ម្ចាស់អាជីវកម្មចាំបាច់ត្រូវសុំលិខិតបញ្ជាក់លើកិច្ចការពារបរិស្ថាន ចេញដោយក្រសួង ឬមន្ទីរបរិស្ថាន ។
  + ត្រូវបំពេញតារាងត្រួតពិនិត្យលើមូលដ្ឋានអាជីវកម្ម ។

២ : ក្នុងការធ្វើអាជីវកម្ម អាជីវករត្រូវគោរពអនុវត្តតាមប្រកាស សារាចរណែនាំ បទប្បញ្ញត្តិផ្សេងៗរបស់រដ្ឋក្នុងការគ្រប់គ្រងលើអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋានដូចជា ច្បាប់ការងារ អនាម័យម្ហូបអាហារ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗរបស់រដ្ឋ ដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មទេសចរណ៍ ដើម្បីជាកិច្ចធានាដល់សន្តិសុខ សុវត្ថិភាព សុខុមាលភាពជូនភ្ញៀវ ។

៣ : រាល់ការធ្វើអាជីវកម្ម ភោជនីយដ្ឋាន និងអាហារដ្ឋាន ត្រូវធានាថាមិនធ្វើអោយប៉ះពាល់ដល់វប្បធម៌ ប្រពៃណីជាតិ សុខភាពភ្ញៀវ សណ្ដាប់ធ្នាប់សាធារណៈ បរិស្ថាន និងរបៀប រៀបរយសង្គម ។

៤ : ពេលមានការជួសជុល កែលំអកន្លែងអាជីវកម្ម ផ្លាស់ប្ដូរទីតាំង បិទអាជីវកម្ម ផ្លាស់ប្ដូរឈ្មោះម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ឈ្មោះទីតាំង លេខទូរស័ព្ទ ទូរសារ និងព័ត៌មានលំអិតផ្សេងៗទៀត ត្រូវជូនដំណឹងដល់ក្រសួង មន្ទីរទេសចរណ៍ ឬអាជ្ញាធរដែនដី ។



# ៣ មហាវិថីព្រះមុនីវង្ស ភ្នំពេញ ១២២៥៨ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : +៨៥៥ ២៣ ២១៣៧៤១ ទូរសារ : +៨៥៥ ២៣ ២២០៧០៤; Email: admin@mot.gov.kh, Website: www.mot.gov.kh

៥ : ដើម្បីពង្រឹងនូវលក្ខណៈសម្បត្តិ និងគុណភាពអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន អាជីវករត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស និងស្តង់ដាដូចខាងក្រោម :

- ត្រូវរៀបចំអោយបានល្អត្រឹមត្រូវសមស្របដោយធានានូវសុវត្ថិភាពភ្ញៀវ ។
- កន្លែងធ្វើអាជីវកម្ម ត្រូវមានប្រព័ន្ធប្រកាសអាសន្ន ប្រព័ន្ធគ្រប់គ្រងអគ្គីភ័យ ច្រកទ្វារសង្គ្រោះ និងប្រអប់ថ្នាំពេទ្យសង្គ្រោះបន្ទាន់ ពិសេសផ្នែកចង្ក្រានបាយត្រូវរៀបចំត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស មានអនាម័យខ្យល់អាកាសល្អ និងមានច្រកចេញចូលដាច់ដោយឡែកពីបន្ទប់ទឹក ។
- ទីកន្លែង និងបន្ទប់ភោជនីយដ្ឋាន និងអាហារដ្ឋាន ត្រូវមានអនាម័យ និងមានបរិយាកាសល្អ ប្រកបដោយផាសុកភាព ។
- កន្លែងរៀបចំតុ កៅអី និងម្ហូបអារហារ ភេសជ្ជៈ ត្រូវរៀបចំអោយបានសមស្របទៅនឹងចំនួនភ្ញៀវ ។
- មានកន្លែងចត រថយន្តសមស្រប ។
- សម្ភារៈប្រើប្រាស់ ចាន កែវ សម ស្លាបព្រា និងសម្ភារៈចង្ក្រាន ត្រូវធានាគុណភាព និងមានអនាម័យស្អាតបាតជានិច្ច ព្រមទាំងទុកដាក់អោយបានត្រឹមត្រូវ ។
- កន្លែងលាងចានត្រូវរៀបចំអោយបានត្រឹមត្រូវតាមក្បួនអនាម័យ និងធានាការការពារបរិស្ថានអោយបានល្អ
- ម្ហូបអាហារ ភេសជ្ជៈ ត្រូវធានាគុណភាព និងអនាម័យ ត្រូវមានអាហារប័ណ្ណរាយមុខម្ហូប ភេសជ្ជៈ និងថ្លៃហើយសរសេរជាភាសាខ្មែរ និងបរទេស ។
- រាល់ភេសជ្ជៈ ត្រី សាច់ បន្លែ ផ្លែឈើ ដែលបំរុងទុកត្រូវមានឧបករណ៍ និងបរិក្ខារសំរាប់ទុកដាក់ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។
- ត្រូវមានបន្ទប់ទឹកភ្ញៀវ សំរាប់បុរស-នារីប្រើប្រាស់ដាច់ដោយឡែក និងមានអ្នកសំអាតជាប្រចាំ ។
- មានបន្ទប់ទឹកសំរាប់បុគ្គលិកធ្វើការក្នុងភោជនីយដ្ឋាន និងអាហារដ្ឋានត្រូវដាច់ផ្សេងពីបន្ទប់ទឹកភ្ញៀវ ។
- បុគ្គលិកបំរើការងារត្រូវមានអាយុ ១៨ ឆ្នាំឡើងទៅ និងមានប័ណ្ណពិនិត្យសុខភាព ចេញដោយនាយកដ្ឋានពេទ្យការងារ ឬមន្ទីរសុខាភិបាល ខេត្ត-ក្រុង ។ មានឯកសណ្ឋានសមរម្យ និងពាក់ផ្លាកឈ្មោះសំគាល់ មានអាកប្បកិរិយាថ្លៃថ្នូរ សុជីវធម៌ ព្រមទាំងត្រូវគោរពសិទ្ធិផលប្រយោជន៍របស់ភ្ញៀវ ។ បុគ្គលិកបំរើការងារចាំបាច់ត្រូវទទួលការបណ្តុះបណ្តាលផ្នែកបដិសណ្ឋារកិច្ច ។
- ប្រធានផ្នែកបំរើម្ហូបអាហារ ត្រូវឆ្លងវគ្គបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈដែលក្រសួងទេសចរណ៍ទទួលស្គាល់ ។
- រាល់ការប្រគុំតន្ត្រី ឬចាក់បទភ្លេង និងចំរៀង ត្រូវសំដៅការពារ លើកស្ទួយសិល្បៈវប្បធម៌ជាតិ ។
- ហាមចាក់កាសែតវីដេអូ ឬ វីស៊ីឌី ឌីវីឌី ដែលរដ្ឋហាមឃាត់ ។
- ចំពោះការប្រគុំតន្ត្រី ត្រូវធានាមិនអោយមានសំលេងប៉ះពាល់ រំខានដល់អ្នកជិតខាង ។

៦ : រាល់សកម្មភាពធ្វើអាជីវកម្មជួញដូរគ្រឿងញៀន ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ អំពើពេស្យាចារគ្រប់ប្រភេទ ការបើកបនល្បែងស៊ីសងជ្រកក្រោមរូបភាពអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន ត្រូវហាមឃាត់ជាដាច់ខាត ។ ហាមមានអាវុធជាតិផ្ទុះនៅទីកន្លែងអាជីវកម្ម ។

៧ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មត្រូវសហការ និងរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច និងមន្ទីរទេសចរណ៍នូវរាល់បាតុភាពមិនប្រក្រតីដែលអាចកើតមានឡើង ឬបានកើតឡើងនៅទីកន្លែងអាជីវកម្ម ។

៨ : ក្នុងករណីមិនគោរពតាមបទប្បញ្ញត្តិ ស្តីពីការធ្វើអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន អាជីវករត្រូវទទួលការផាកពិន័យ ឬទទួលទោសតាមច្បាប់កំណត់ ។ ករណីធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់សុវត្ថិភាព ឬ បង្កអោយមានគ្រោះថ្នាក់ដល់ភ្ញៀវ ត្រូវទទួលទោសតាមច្បាប់រដ្ឋជាធរមាន ។

៩ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋានខ្នាតតូច និងភោជនីយដ្ឋានបៀរហ្គាឌិន ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ដើម្បីប្រកបអាជីវកម្ម ដែលត្រូវពិនិត្យសម្រេចដោយមន្ទីរទេសចរណ៍ខេត្ត-ក្រុង ។

១០ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ភោជនីយដ្ឋានខ្នាតធំ ភោជនីយដ្ឋានមធ្យម Bar Bistro និងអាហារដ្ឋាន ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីប្រកបអាជីវកម្មតាមរយៈមន្ទីរទេសចរណ៍ខេត្ត-ក្រុង ដែលត្រូវពិនិត្យ និងអនុញ្ញាតដោយក្រសួងទេសចរណ៍ ។

១១ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ភោជនីយដ្ឋាន អាហារដ្ឋានក្នុងស្រុក ត្រូវមកបំពេញបែបបទ ដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណដើម្បីប្រកបអាជីវកម្ម ដែលត្រូវពិនិត្យសម្រេចដោយអាជ្ញាធរដែនដី ។

១២ : ក្នុងករណីចាំបាច់ ក្រសួងនឹងមានវិធានការចាត់តាំងអធិការ និងមន្ត្រីជំនាញចុះធ្វើអធិការកិច្ចលើការអនុវត្តន៍លិខិតបទដ្ឋាន ស្តីពីអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន ។

១៣ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ត្រួតពិនិត្យទៅលើអាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋានជាប្រចាំ និងក្នុងករណីពិសេសដែលប្រព្រឹត្តផ្ទុយនឹងគោលការណ៍របស់ក្រសួងទេសចរណ៍ និងច្បាប់របស់រដ្ឋ ហើយរាយការណ៍មកក្រសួងទេសចរណ៍ ។

១៤ : មន្ទីរទេសចរណ៍ ខេត្ត-ក្រុង ត្រូវសហការជាមួយអាជ្ញាធរដែនដី អោយបានល្អប្រសើរតាមគោលការណ៍កំណត់របស់ក្រសួងទេសចរណ៍ ។

ទទួលបាននូវសារាចរណែនាំនេះមន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីធ្វើការផ្សព្វផ្សាយណែនាំដល់ម្ចាស់អាជីវកម្ម ទទួលអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ក្នុងការរួមចំណែកបំរើវិស័យទេសចរណ៍កម្ពុជា អោយអភិវឌ្ឍន៍កាន់តែល្អប្រពៃ ។

ថោង ខុន

កន្លែងទទួល

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលា ខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ ខេត្ត-ក្រុង "ដើម្បីមុខការ"
- គ្រប់អាជីវកម្មភោជនីយដ្ឋានខ្នាតធំ ភោជនីយដ្ឋាន និងអាហារដ្ឋាន "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍
លេខ ០០៣ ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍
## ដល់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ / នស/ រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ .បក. ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក.ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន នៃក្រសួងទេសចរណ៍
- អនុក្រឹត្យលេខ ១៦ អនក្រ. បក. ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១** :- អាជីវកម្មសណ្ឋាគារ គឺជាការយកអាគារ សំរាប់ធ្វើអាជីវកម្មផ្គត់ផ្គង់បន្ទប់ស្នាក់នៅ ដែលមានបំពាក់នូវសំភារៈបរិក្ខារជូនភ្ញៀវ និងមានសេវាកម្មមួយចំនួនដូចជា ភោជនីយដ្ឋាន បានីយដ្ឋាន ហាងលក់ទំនិញ វត្ថុអនុស្សាវរីយ៍ កន្លែងហាត់ប្រាណ លេងកីឡា សាលប្រជុំ ព្រមទាំងមានសេវាកម្មពេញលេញទៅតាមតំរូវការរបស់ភ្ញៀវ ។ ទីតាំងសណ្ឋាគារស្ថិតនៅតាមទីប្រជុំជន ជាយក្រុង តំបន់រមណីយដ្ឋានទេសចរណ៍ និងតំបន់ដែលមានចលនាទេសចរណ៍ ។

- អាជីវកម្ម សេវាកម្មស្នាក់នៅទេសចរណ៍ផ្សេងទៀត ដូចជា ៖
  - សណ្ឋាគារអាផាតម៉ិន (Apartment Hotel) ជាសណ្ឋាគារដែលមានបន្ទប់ស្នាក់នៅ និងបន្ទប់ស្វ៊ីតដោយបំពាក់គ្រឿងសង្ហារឹម សំភារៈបរិក្ខារ និងផ្តល់នូវសេវាកម្មដូចសណ្ឋាគារដែរ ហើយបំរើអោយការស្នាក់នៅរយៈពេលវែង ។ បន្ទប់ស្វ៊ីតមានបន្ទប់ស្នាក់នៅមួយ ឬច្រើន មានបំពាក់គ្រឿងសំភារៈផ្ទះបាយ និងមានបន្ទប់សំរាប់ទទួលភ្ញៀវ ។
  - សណ្ឋាគារ ស្វ៊ីត (Suite Hotel) ជាសណ្ឋាគារដែលមានបន្ទប់ស្នាក់នៅទាំងអស់សុទ្ធតែជាបន្ទប់ស្វ៊ីត ។
  - សណ្ឋាគាររីសត (Resort Hotel) គឺជាសណ្ឋាគារដែលមានទីតាំងស្ថិតនៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ឆ្ងាយពីទីប្រជុំជន មានកន្លែងលំហែកាយសំរាកយកខ្យល់អាកាស មានផ្តល់សេវាកម្មម្ហូបអាហារភេសជ្ជៈ និងសេវាកម្មផ្សេងទៀតដែលធ្វើអោយចំរើនសុខភាព ដូចជា៖ វាយកូនគោល វាយតេនីស ស្ទូចត្រី ជិះសេះ ។
  - ម៉ូតែល (Motel) ជាអាគារមានមួយជាន់ ឬពីរជាន់ ដែលស្ថិតនៅតាមតំបន់ជាយក្រុង ឬតំបន់ដែលមានចលនាទេសចរណ៍ និងតាមបណ្តោយផ្លូវសំខាន់ៗ ផ្តល់នូវសម្បទា និងសេវាកម្មមានកំរិតសំរាប់បំរើអោយការស្នាក់នៅជាលក្ខណៈសំចតរយៈពេលខ្លី ។ មានភោជនីយដ្ឋានខ្នាតតូច មានចំណតរថយន្តធំទូលាយ និងអាចមានផ្តល់នូវសេវាកម្មសំរាប់កំសាន្តមួយចំនួន ។
  - ឡូដ៍ (Lodge) គឺជាអាគារ ដែលមានទីតាំងស្ថិតនៅតាមតំបន់សំរាកវិស្សមកាល ជនបទ ឬតំបន់ទាក់ទាញទេសចរសំរាប់បំរើអោយការស្នាក់នៅដល់ទេសចរមានលក្ខណៈជាពួក ឬ ជាក្រុមដែលមានគោលបំណងសំរាកលំហែកាយ និងកំសាន្តក្នុងសកម្មភាពនេសាទ បរបាញ់ កីឡា មានបំរើសេវាម្ហូបអាហារ និងភេសជ្ជៈ មានចំណតរថយន្ត ព្រមទាំងមានបំពាក់គ្រឿងសំភារៈផ្ទះបាយ ។
  - ប៊ឹងហ្គាឡូ (Bungalow) គឺជាអាគារមួយជាន់មានលក្ខណៈជាភូមិគ្រឹះដាច់ៗពីគ្នា និងអាចមានច្រើនយូនីត (Units) នៅក្នុងអាគារតែមួយ ។ យូនីត (Units) នីមួយៗ មានបន្ទប់ដេកមួយ ឬច្រើន មានបន្ទប់ទទួលភ្ញៀវដាច់ដោយឡែក មានផ្ទះបាយ មានចំណតរថយន្ត ។ ប៊ឹងហ្គាឡូ អាចជាអាគារសំណង់រឹង ឬស្រាល ។
  - ផ្ទះភ្ញៀវ (Guest House) គឺជាអាគារដែលមានចំនួនបន្ទប់ពី ៥ ទៅ ១៥ បន្ទប់ មានបំពាក់ឧបករណ៍សំភារៈបរិក្ខារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសេវាបំរើភ្ញៀវមានកំរិត ។
  - ផ្ទះស្នាក់នៅ (Homestay) គឺជាសេវាកម្មស្នាក់នៅទេសចរណ៍ ដោយការរៀបចំលំនៅដ្ឋានរបស់ខ្លួនអោយទៅជាបន្ទប់មិនលើសពី ០៥ បន្ទប់ ឬជាគ្រែចល័ត ដូចជា ពៅអ៊ី ឬអង្រឹង មានបំពាក់សំភារៈបរិក្ខារ សាមញ្ញ និងសេវាមានកំរិត សំរាប់ទទួលបំរើការស្នាក់នៅរបស់ភ្ញៀវដែលមានបំណងមកសិក្សា និងស្វែងយល់ពីសកម្មភាពនៃជីវភាពរស់នៅរបស់ប្រជាជនក្នុងសហគមន៍ និងរមណីយដ្ឋានក្នុងតំបន់ ។
  - កន្លែងបោះជំរុំទេសចរណ៍ (Tourist Camping) គឺជាមូលដ្ឋានសេវាកម្មស្នាក់នៅទេសចរណ៍ ដោយប្រើប្រាស់តង់ (Tent) ដែលមានទីតាំងស្ថិតនៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ ឆ្នេរសមុទ្រ មានហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មចាំបាច់មួយចំនួនដើម្បីបំរើទេសចរ ។

**ប្រការ ២ ៖** ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍អោយប្រកបអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងការផ្អាក ការដកហូតបិទអាជីវកម្ម គឺជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។

២៥៦

ប្រការ ៣ ៖ ការរៀបចំសុំអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដោយអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់ដូចខាងក្រោម ៖

ក - លិខិតអនុញ្ញាតដាក់ទីតាំងធ្វើអាជីវកម្មចេញដោយអាជ្ញាធរដែនដី

ខ - លិខិតអនុញ្ញាតសាងសង់ ឬជួសជុល ចេញដោយក្រសួង ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គ - វិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ឃ - លិខិតបញ្ជាក់លើប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព និងអគ្គីភ័យ ចេញដោយក្រសួងមហាផ្ទៃ ឬស្នងការដ្ឋាននគរបាលខេត្ត-ក្រុង

ង - លិខិតបញ្ជាក់លើអនាម័យចេញដោយក្រសួងសុខាភិបាល ឬ មន្ទីរសុខាភិបាល

ច - អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

ឆ - លិខិតយល់ព្រមជាលាយល័ក្ខអក្សររបស់ម្ចាស់ បើសិនជាអ្នកគ្រប់គ្រងមិនមែនជាម្ចាស់កម្មសិទ្ធិ

ជ - សញ្ញាប័ត្រ ឬវិញ្ញាបនប័ត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ពីការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍

ប្រការ ៤ ៖ អាជ្ញាប័ណ្ណទេសចរណ៍ ត្រូវបានចេញអោយប្រើប្រាស់ ក្រោយពីអាជីវករបានបំពេញសំណុំឯកសារក្នុងការដាក់ពាក្យសុំធ្វើអាជីវកម្មគ្រប់គ្រាន់ និងត្រឹមត្រូវយ៉ាងយូរក្នុងរយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានដាក់ពាក្យ។ ក្នុងករណីដែលក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុងបដិសេធមិនផ្តល់ ឬមិនបន្តអាជ្ញាប័ណ្ណទេសចរណ៍ ក្រសួង ឬ មន្ទីរទេសចរណ៍នឹងបញ្ជាក់ហេតុផលជាលាយល័ក្ខអក្សរជូនដល់អាជីវករ មិនលើសពី ១០ ថ្ងៃ គិតពីថ្ងៃបានទទួលពាក្យ ។

ប្រការ ៥ ៖ - នៅពេលអ្នកស្នើសុំអាជ្ញាប័ណ្ណបានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវទៅតាមបែបបទដូចមានកំណត់ក្នុងប្រការ ៣ ក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុង នឹងចេញអាជ្ញាប័ណ្ណទេសចរណ៍សំរាប់ធ្វើអាជីវកម្ម ដែលមានសុពលភាពរយៈពេល ០១ ឆ្នាំ។

- ក្នុងករណីអាជីវករមិនបានបំពេញបែបបទអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលា នោះអាចស្នើសុំដោយធ្វើកិច្ចសន្យាសុំជំពាក់ឯកសារជាបណ្តោះអាសន្ននិងធានាបំពេញវិញក្នុងរយៈពេល ០៣ខែ។ បន្ទាប់ពីបានបំពេញឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមកិច្ចសន្យា នោះក្រសួង ឬមន្ទីរទេសចរណ៍នឹងផ្តល់អាជ្ញាប័ណ្ណដែលមានសុពលភាព ០១ ឆ្នាំ ជូនដល់អាជីវករ ។

ប្រការ ៦ ៖ អាជ្ញាប័ណ្ណទេសចរណ៍មានសុពលភាពប្រើប្រាស់សំរាប់រយៈពេល០១ឆ្នាំគិតពីថ្ងៃចេញច្បាប់អនុញ្ញាត។ មុនពេលផុតសុពលភាពអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវដាក់ពាក្យសុំបន្ត ដោយភ្ជាប់ជាមួយនូវអាជ្ញាប័ណ្ណចាស់ និងប័ណ្ណពន្ធប៉ាតង់អោយបាន ០១ ខែ មុនថ្ងៃផុតកំណត់ ។ ក្នុងរយៈពេលដែលបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករនៅតែមានសិទ្ធិធ្វើអាជីវកម្មរហូតដល់ថ្ងៃដែលក្រសួង ឬ មន្ទីរទេសចរណ៍ពិនិត្យសំរេចលើលក្ខណៈសម្បត្តិក្នុងការផ្តល់អាជ្ញាប័ណ្ណបន្តអាជីវកម្ម ។

ប្រការ ៧ ៖ ពេលមានការផ្ទេរ លក់ ជួល ជួសជុល បិទអាជីវកម្ម ផ្លាស់ប្តូរអ្នកគ្រប់គ្រង អាជីវករត្រូវដាក់ពាក្យសុំតាម

រយៈមន្ទីរទេសចរណ៍ខេត្ត-ក្រុង អោយបានមុន ០៣ខែមកក្រសួងទេសចរណ៍ ។

**ប្រការ ៨ :** ការបង់ប្រាក់ក្នុងការចេញអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីសុំបើកអាជីវកម្មដំបូង ឬបន្តត្រូវបានកំណត់ដូចខាងក្រោម :

**ក-** **សណ្ឋាគារ ឬសណ្ឋាគារអាផាតម៉ិន ឬសណ្ឋាគារស្វ៊ីត ឬសណ្ឋាគាររីសត ឬប៊ឹងហ្គាឡូ ឬម៉ូតែល ឬឡូជ៍ ត្រូវបង់ថ្លៃអាជ្ញាប័ណ្ណសំរាប់១ឆ្នាំ ។**

- ពី ១០ បន្ទប់ចុះ ១៥០.០០០ រៀល
- ពី ១១ ដល់ ២០ បន្ទប់ ២៥០.០០០ រៀល
- ពី ២១ ដល់ ៣០ បន្ទប់ ៤០០.០០០ រៀល
- ពី ៣១ ដល់ ៦០ បន្ទប់ ៦០០.០០០ រៀល
- ពី ៦១ ដល់ ១០០ បន្ទប់ ៨០០.០០០ រៀល
- ពី ១០១ ដល់ ១៥០ បន្ទប់ ១.២០០.០០០ រៀល
- ពី ១៥១ ដល់ ២០០ បន្ទប់ ១.៦០០.០០០ រៀល
- ពី ២០១ ដល់ ៣០០ បន្ទប់ ២.០០០.០០០ រៀល
- ពី ៣០០ បន្ទប់ឡើងទៅ ២.៤០០.០០០ រៀល

**ខ-** **ផ្ទះភ្ញៀវត្រូវបង់ថ្លៃអាជ្ញាប័ណ្ណ ១០.០០០រៀល ក្នុង ០១បន្ទប់ សំរាប់១ឆ្នាំ**

**គ-** **កន្លែងបោះជំរុំត្រូវបង់ថ្លៃអាជ្ញាប័ណ្ណសំរាប់១ឆ្នាំ**

- ទំហំក្រោម ៤ហិកតា ៦០០.០០០ រៀល
- ទំហំលើស ៤ហិកតា ១.០០០.០០០ រៀល

**ឃ-** ការបន្តអាជីវកម្មត្រូវបង់ ៥០% នៃចំនុច ៨ក- ៨ខ និង៨គ ។

**ង-** ការផ្លាស់ប្តូរអ្នកគ្រប់គ្រងដើម្បីបន្តសកម្មភាពអាជីវកម្មត្រូវបង់ ១០% នៃទឹកប្រាក់ដែលចែងក្នុងប្រការ ៨ ក- ៨ខ និង៨គ ។

**ប្រការ ៩ :**

- ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណដំបូង ឬអាជ្ញាប័ណ្ណបន្ត ព្រមទាំងទទួលយកអាជ្ញាប័ណ្ណទេសចរណ៍នៅមន្ទីរទេសចរណ៍ខេត្ត-ក្រុង ។
- មន្ទីរទេសចរណ៍ខេត្ត-ក្រុងត្រូវចេញអាជ្ញាប័ណ្ណទេសចរណ៍តាមដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២ថ្ងៃនៃថ្ងៃធ្វើការដោយអនុលោមតាមប្រការ៣នៃប្រកាសនេះ ។
- ចំពោះអាជ្ញាប័ណ្ណដែលត្រូវពិនិត្យនិងសំរេចដោយក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ត្រូវទទួលពាក្យសុំ និងចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម ហើយបញ្ជូនមកក្រសួងទេសចរណ៍ក្នុងរយៈពេល ០៥ថ្ងៃ នៃថ្ងៃធ្វើការ ។ ក្រសួងទេសចរណ៍ (នាយកដ្ឋានឧស្សាហកម្មទេសចរណ៍) ត្រូវទទួល និងពិនិត្យពាក្យសុំនេះ ហើយស្នើសុំការសំរេចចេញអាជ្ញាប័ណ្ណទេសចរណ៍ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ។ ករណីចាំបាច់ ក្រសួងទេសចរណ៍អាចចុះត្រួតពិនិត្យឡើងវិញលើមូលដ្ឋានអាជីវកម្មនោះក្នុងរយៈពេល ០៥ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យសុំ ។ ក្រសួងទេសចរណ៍នឹងបញ្ជូនអាជ្ញាប័ណ្ណទេសចរណ៍ ដែលរួចជាស្ថាពរទៅមន្ទីរទេសចរណ៍ក្នុងរយៈពេល ០៣ ថ្ងៃ ។

ប្រការ ១០: - អាជីវករដែលទទួលបានអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវប្រើប្រាស់អាជ្ញាប័ណ្ណនេះអោយបានត្រឹមត្រូវ និងត្រូវគោរពអនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ ។

- ករណីមានការខូចខាត ឬបាត់បង់អាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវធ្វើលិខិតជាលាយល័ក្ខអក្សរបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ដើម្បីស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍បណ្តោះអាសន្ន ក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់ ។

ប្រការ ១១: - ករណីការធ្វើអាជីវកម្មដោយ :

ក ) ប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ឬ អនុវត្តមិនបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងទេសចរណ៍ អាជីវករនឹងត្រូវទទួលការផាកពិន័យមានចំនួនទឹកប្រាក់ ២០០% ( ពីររយភាគរយ ) នៃថ្លៃបង់។ ប្រសិនបើអាជីវករមិនបង់ប្រាក់ផាកពិន័យនេះ ក្នុងរយៈពេល ០៣ខែ ក្រសួង ឬមន្ទីរទេសចរណ៍ខេត្តក្រុងនឹងផ្អាកការធ្វើអាជីវកម្ម ឬ ដកហូតអាជ្ញាប័ណ្ណទេសចរណ៍ បិទអាជីវកម្ម ។

ខ ) គ្មានអាជ្ញាប័ណ្ណទេសចរណ៍ នឹងត្រូវទទួលការព្រមានជាលាយល័ក្ខអក្សរ ។ ក្នុងករណីអាជីវករមិនអនុវត្តតាមការណែនាំក្រោយពីការព្រមាន នោះនឹងត្រូវបិទអាជីវកម្ម ។

គ) អាជីវករបានផ្តល់ព័ត៌មានមិនពិត ឬប្រឌិតឯកសារពាក់ព័ន្ធទៅនឹងពាក្យសុំធ្វើអាជីវកម្ម ក្រសួងទេសចរណ៍មានសិទ្ធិដកអាជ្ញាប័ណ្ណទេសចរណ៍ ឬ ផ្អាកអាជីវកម្ម ។

ឃ) ក្នុងករណីអាជីវករប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងច្បាប់បញ្ញត្តិទាំងឡាយរបស់រដ្ឋ នឹងត្រូវដកហូតអាជ្ញាប័ណ្ណបិទអាជីវកម្ម ព្រមទាំងត្រូវទទួលទោសតាមច្បាប់រដ្ឋជាធរមាន ។

ប្រការ ១២: នៅពេលមូលដ្ឋានអាជីវកម្មត្រូវទទួលការផ្អាក ឬ ដកហូតអាជ្ញាប័ណ្ណ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខ័អក្សរផ្ញើដល់ម្ចាស់ ឬ អ្នកគ្រប់គ្រងដើម្បីទទួលប្រតិបត្តិតាម ។ ក្នុងករណីសេចក្តីជូនដំណឹងមិនអាចផ្ញើបានទៅដល់ម្ចាស់ ឬអ្នកគ្រប់គ្រងដោយប្រការណាមួយ ឬក៏សាមីខ្លួនជាម្ចាស់ ឬអ្នកគ្រប់គ្រងបដិសេធមិនព្រមទទួលស្គាល់ សេចក្តីជូនដំណឹងនេះនឹងត្រូវបិទនៅខាងមុខក្រុមហ៊ុន ឬមូលដ្ឋានអាជីវកម្ម ហើយត្រូវផ្ញើដល់សមាគមទេសចរណ៍ក្នុងស្រុក និងភ្នាក់ងារមានសមត្ថកិច្ចដើម្បីទុកជាព័ត៌មាន។

ប្រការ ១៣: ការផ្អាក ដកហូតអាជ្ញាប័ណ្ណទេសចរណ៍មានរយៈពេលកំណត់មិនលើសពី ០៦ខែ។ ក្នុងករណីអាជ្ញាប័ណ្ណត្រូវបានផ្អាក ឬដកហូត មូលដ្ឋានអាជីវកម្មមិនត្រូវបានអនុញ្ញាតអោយធ្វើសកម្មភាពឡើយ។ ក្រោយពីផុតកំណត់ពេលនៃការផ្អាក ឬដកហូតនេះ ម្ចាស់អ្នកគ្រប់គ្រង ត្រូវធ្វើលិខិតស្នើសុំមកក្រសួងទេសចរណ៍ដើម្បីសុំដំណើរការអាជីវកម្មឡើងវិញ។

ប្រការ ១៤: បុគ្គលណាមួយដែលរារាំងដល់ការងារត្រួតពិនិត្យ ឬ ផ្តល់អាជ្ញាប័ណ្ណក្លែងបន្លំមិនត្រឹមត្រូវផ្ទុយទៅនឹងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ នឹងត្រូវទទួលទណ្ឌកម្មវិធានការរដ្ឋបាល ឬទទួលទោសតាមច្បាប់ជាធរមាន។

ប្រការ ១៥: ០៣ ខែក្រោយពីការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍នឹងមិនអនុញ្ញាតអោយធ្វើអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ទៀតឡើយ។

**ប្រការ១៦:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១៧:** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**<u>កន្លែងទទួល:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការ គណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលា ខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ ខេត្ត-ក្រុង (ដើម្បីមុខការ)
- គ្រប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ.០០៣.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០០៧

# សារាចរណែនាំ
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្ម
## សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

ដើម្បីគ្រប់គ្រងសេវាកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍អោយមានសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ សុវត្ថិភាព និងសុជីវធម៌ ជូនទេសចរជាតិ-អន្តរជាតិ និងក្នុងគោលបំណងធានាដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ថែរក្សាការពារវប្បធម៌ ប្រពៃណីជាតិ តាមគោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីអនុវត្តប្រកាសលេខ ០៦៣ ប្រ.ក. ចុះថ្ងៃ ទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដូចខាងក្រោម :

១ :- រាល់ការធ្វើអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ អាជីវករត្រូវមានច្បាប់អនុញ្ញាតពីក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុង។ ទំរង់បែបបទនៃការសុំធ្វើអាជីវកម្មត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងទេសចរណ៍។

- ការដាក់ទីតាំងធ្វើអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវគោរពតាមការណែនាំរបស់សមត្ថកិច្ចជំនាញ និងមិនធ្វើអោយប៉ះពាល់ដល់សាធារណ:ជន ។
- ឯកសារផ្សេងៗទៀតដែលក្រសួងទេសចរណ៍ត្រូវការ រួមមាន:
  - កិច្ចសន្យារបស់ម្ចាស់អាជីវកម្មចំពោះក្រសួងទេសចរណ៍ក្នុងការប្រកបអាជីវកម្ម
  - កិច្ចសន្យាជំពាក់ឯកសារ ដែលត្រូវបំពេញវិញក្នុងរយ:ពេល ០៣ ខែ
  - ត្រូវបំពេញតារាងត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
  - បើសិនជាការធ្វើអាជីវកម្មនេះ មានការប៉ះពាល់ដល់បរិស្ថាន ម្ចាស់អាជីវកម្មចាំបាច់ត្រូវសុំលិខិតបញ្ជាក់លើកិច្ចការពារបរិស្ថានដែលចេញដោយក្រសួង ឬមន្ទីរបរិស្ថាន។

២ : ក្នុងការធ្វើអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ អាជីវករត្រូវគោរពអនុវត្តតាមសារាចរណែនាំ និងបទប្បញ្ញត្តិស្តីអំពីការធ្វើអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងច្បាប់ ការងារ ពន្ធដារ អនាម័យ ព្រមទាំងច្បាប់ និង បទប្បញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មទេសចរណ៍



# ៣ មហាវិថីព្រះមុនីវង្ស ភ្នំពេញ ១២២៥៨ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: ៨៥៥-២៣ ២១៣ ៩៧១ ទូរសារ: ៨៥៥-២៣ ២១០ ៨០៨ អ៊ីមែល: info@mot.gov.kh Website: www.mot.gov.kh

ដើម្បីជាកិច្ចធានាដល់សន្តិសុខ សុវត្ថិភាព សុខុមាលភាព ភាពសប្បាយរីករាយ និងភាពកក់ក្តៅជូនទេសចរ ។

៣ : រាល់ការធ្វើអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវធានាថាមិនធ្វើអោយប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណីជាតិ វប្បធម៌សង្គម សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន ។

៤ : ពេលមានការជួសជុលកែលំអ កន្លែងអាជីវកម្ម បិទអាជីវកម្ម ផ្លាស់ប្តូរឈ្មោះម្ចាស់ ឬអ្នកគ្រប់គ្រង ឈ្មោះទីតាំង ចំនួនបន្ទប់ គ្រែ លេខទូរស័ព្ទ ទូរសារ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរជូនក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុង ។

៥ : ត្រូវផ្តល់នូវស្ថិតិស្តីពីស្ថានភាពទេសចរដែលបានស្នាក់នៅជូនក្រសួង ឬ មន្ទីរទេសចរណ៍ខេត្ត-ក្រុងតាមការកំណត់របស់ក្រសួងទេសចរណ៍ ។

៦ : ដើម្បីពង្រឹងនូវលក្ខណៈសម្បត្តិ និងគុណភាពសេវាកម្ម មូលដ្ឋានអាជីវកម្មត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស និងស្តង់ដាសេវាកម្ម ដូចខាងក្រោម :

- អាគារសណ្ឋាគារ ទីតាំងអាជីវកម្ម ទីធ្លា និងសួនច្បារ ត្រូវមានការថែទាំ កែលំអសោភ័ណភាពមានអនាម័យ បរិស្ថានល្អ បំរើអោយការស្នាក់នៅ និងទាក់ទាញភ្ញៀវ ។
- ត្រូវមានច្រកចេញ និងចូលរបស់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍អោយបានសមរម្យ មិនត្រូវអោយមានការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ។
- ចំណតរថយន្តរបស់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវមានចំនួនសមស្របទៅនឹងបន្ទប់ស្នាក់នៅ។ ត្រូវធានានូវសុវត្ថិភាពពីគ្រោះអគ្គីភ័យ ព្រមទាំងលក្ខណៈបច្ចេកទេសទាក់ទងទៅនឹងការបំពាក់ឧបករណ៍បរិក្ខារនៅក្នុងសណ្ឋាគារ ហើយត្រូវមានគំនូសបំព្រួញអំពីប្លង់បន្ទប់ ច្រកចេញពេលមានអាសន្ន ដោយបិទនៅកន្លែងទទួលភ្ញៀវ និងតាមជញ្ជាំងនៃជាន់នីមួយៗ ។
- សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវតែមានការបំពាក់ឧបករណ៍ និងសំភារៈបរិក្ខារអោយបានគ្រប់គ្រាន់ និងត្រឹមត្រូវ និងមានការអភិវឌ្ឍន៍អោយស្របទៅតាមស្តង់ដាចំណាត់ថ្នាក់ ។
- ឧបករណ៍ និងសំភារៈបរិក្ខារបំពាក់នៅក្នុងបន្ទប់ស្នាក់នៅរបស់ភ្ញៀវ និងបន្ទប់ទឹកត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមកំរិតអប្បបរិមានៃស្តង់ដាចំណាត់ថ្នាក់ និងប្រភេទសេវាកម្មស្នាក់នៅទេសចរណ៍។
- ត្រូវមានការតុបតែងលំអផ្ទៃកខាងក្នុងបន្ទប់ស្នាក់នៅ កន្លែងរង់ចាំ និងកន្លែងភោជនីយដ្ឋានរបស់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍។
- សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវធានាអោយបានដាច់ខាតនូវសន្តិសុខ និងសុវត្ថិភាពសំរាប់ភ្ញៀវ ទាំងទ្រព្យសម្បត្តិ និងអាយុជីវិតអំឡុងពេលស្នាក់នៅ។
- ត្រូវមានប្រពន្ធ័ប្រកាសព័ត៌មាន ឬភេរវៈសញ្ញា និងសេវាសង្គ្រោះបន្ទាន់សំរាប់ភ្ញៀវ ។
- រាល់ភ្ញៀវដែលចូលមកស្នាក់នៅក្នុងសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវមានការចុះឈ្មោះ អាយុ សញ្ជាតិ មុខរបរតាមលិខិតសំគាល់ខ្លួន ឬលិខិតឆ្លងដែនក្នុងបញ្ជីប្រចាំថ្ងៃ និងរក្សាទុកអោយបានគង់វង់។
- បុគ្គលិកបំរើការនៅក្នុងសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវមានសុខភាពល្អ និងមានប័ណ្ណពិនិត្យសុខភាពចេញដោយនាយកដ្ឋានពេទ្យការងារ ឬមន្ទីរសុខាភិបាលខេត្ត-ក្រុង ហើយត្រូវមានឯកសណ្ឋាន

សមរម្យ មានពាក់ផ្លាកឈ្មោះសំគាល់ មានអត្តចរិតថ្លៃថ្នូរ សុជីវធម៌ និងបំរើភ្ញៀវអោយបានល្អ ត្រូវគោរព សិទ្ធិ និងផលប្រយោជន៍របស់ភ្ញៀវ ។

- បុគ្គលិកដែលធ្វើការនៅក្នុងសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ត្រូវមានចំណេះដឹង សមត្ថភាព និងមុខជំនាញសំរាប់បំពេញការងារនៅក្នុងមូលដ្ឋានអាជីវកម្ម។ បុគ្គលិករបស់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ត្រូវឆ្លងវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដូចបានកំណត់ដោយក្រសួងទេសចរណ៍ ។

៧ : អ្នកគ្រប់គ្រងសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវហាមឃាត់អនីតិជនដែលមានអាយុក្រោម១៨ឆ្នាំ ប្រើប្រាស់បន្ទប់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ លើកលែងតែក្រុមគ្រួសារ ឬអាណាព្យាបាលស្របច្បាប់មកជាមួយ ។

៨ : រាល់សកម្មភាពធ្វើអាជីវកម្ម ជួញដូរគ្រឿងញៀន ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ អំពើពេស្យាចារគ្រប់ប្រភេទត្រូវហាមឃាត់ជាដាច់ខាត ។ ហាមមានអាវុធជាតិផ្ទុះនៅទីកន្លែងអាជីវកម្ម ។ ការបើកបនល្បែងស៊ីសងត្រូវតែមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ។

៩ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មត្រូវសហការ និងរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច និងមន្ទីរទេសចរណ៍នូវរាល់បាតុភាពមិនប្រក្រតីដែលអាចកើតឡើង ឬបានកើតឡើងនៅទីកន្លែងអាជីវកម្ម ឬតាមរយៈបណ្តាញទូរស័ព្ទពិសេសដែលរៀបចំដោយស្ថាប័នមានសមត្ថកិច្ច ។

១០ : ក្នុងករណីមិនគោរពតាមសារាចរណែនាំ ច្បាប់ និងបទប្បញ្ញត្តិស្តីពីការធ្វើអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ អាជីវករត្រូវទទួលនូវការផាកពិន័យ ឬទទួលទោសតាមច្បាប់។ ករណីធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់សុវត្ថិភាព ឬបង្កអោយមានគ្រោះថ្នាក់ដល់ភ្ញៀវ ត្រូវទទួលទោសតាមច្បាប់រដ្ឋ ។

១១ : ម្ចាស់ឬ អ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ ម៉ូតែល ឡូដ ប៊ីងហ្គាឡូ ចាប់ពី ២០ បន្ទប់ចុះក្រោម និងអាជីវកម្មផ្ទះផ្ទះសំណាក់គឺពី០៥ទៅ១៥បន្ទប់ ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ដើម្បីប្រកបអាជីវកម្មដែលត្រូវពិនិត្យអនុញ្ញាតដោយមន្ទីរទេសចរណ៍ខេត្ត-ក្រុង ។

១២ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ ម៉ូតែល ឡូដ និងប៊ីងហ្គាឡូចាប់ពី ២១បន្ទប់ឡើង និងសណ្ឋាគារអាផាតម៉ិន សណ្ឋាគាររ៉ីសត សណ្ឋាគាររីសត កន្លែងបោះជំរុំទេសចរណ៍ និងអាជីវកម្មផ្ទះសំណាក់គិតចាប់ពី១៦បន្ទប់ឡើងទៅដែលកន្លងមកមន្ទីរទេសចរណ៍បានផ្តល់អាជ្ញាប័ណ្ណ ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍តាមរយៈមន្ទីរទេសចរណ៍ខេត្ត-ក្រុងដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងទេសចរណ៍ ។

១៣ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវជំរុញលើកទឹកចិត្ត ណែនាំប្រជាជនក្នុងសហគមន៍មូលដ្ឋាន រៀបចំលំនៅដ្ឋានមានលក្ខណៈទទួលបំរើការស្នាក់នៅទេសចរណ៍ (Homestay) តាមស្តង់ដា និងមានការចុះបញ្ជីត្រឹមត្រូវដោយពុំមានបង់ថ្លៃអាជ្ញាប័ណ្ណ ហើយត្រូវស្រង់ព័ត៌មានស្ថិតិផ្តល់ជារបាយការណ៍មកក្រសួងទេសចរណ៍ ។ ការចុះបញ្ជីសេវាកម្មស្នាក់នៅតាមផ្ទះរបស់ប្រជាពលរដ្ឋអាចធ្វើឡើងក្នុងក៏រិតអាជ្ញាធរឃុំសង្កាត់ ដែលត្រូវរាយការណ៍មកមន្ទីរទេសចរណ៍ខេត្ត-ក្រុង។

១៤ : ក្នុងករណីចាំបាច់ក្រសួងនឹងមានវិធានការចាត់តាំងអធិការ និងមន្ត្រីជំនាញចុះធ្វើអធិការកិច្ចលើការអនុវត្តន៍លិខិតបទដ្ឋានស្តីពីអាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍របស់ក្រសួង។

១៥ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ និងត្រួតពិនិត្យទៅលើអាជីវកម្មដែលប្រព្រឹត្តផ្ទុយ នឹងបទដ្ឋាន និងគោលការណ៍ របស់ក្រសួងទេសចរណ៍ហើយរាយការណ៍មកក្រសួងទេសចរណ៍ ។

១៦ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវអនុវត្តអោយបានម៉ឺងម៉ាត់តាមគោលការណ៍ កំណត់របស់ក្រសួងទេសចរណ៍ ។

ទទួលបាននូវសារាចរណែនាំនេះ មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីធ្វើការផ្សព្វផ្សាយដល់ម្ចាស់មូលដ្ឋានអាជីវកម្ម ទទួលអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ក្នុងការរួមចំណែកបំរើវិស័យទេសចរណ៍កម្ពុជាអោយមានការអភិវឌ្ឍន៍កាន់តែល្អប្រពៃ ។

កន្លែងទទួល
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការ គណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលា ខេត្ត-ក្រុង
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ ខេត្ត-ក្រុង
  "ដើម្បីមុខការ"
- គ្រប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រី

ថោង ខុន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**
លេខ ០៧៥៨ ឋ.ក.

រាជធានីភ្នំពេញ ថ្ងៃ១៣ ខែមិនា ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍
## ដល់អាជីវកម្មសេវាកម្ម ម៉ាស្សាសុខភាព-ស្ប៉ា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ / នស / រកម / ០១៩៦. ១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ៣៤ អនក្រស / បក /ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ / បក / ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសំរួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការណ៍អន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍ ។

## សម្រេច

**ប្រការ ១:** - សេវាកម្ម ម៉ាស្សាសុខភាព-ស្ប៉ា គឺជាប្រភេទសេវាសំរួលសរសៃនៃរាងកាយ ឬបាតជើង ឬមួយផ្នែកនៃសារពាង្គកាយ តាមលក្ខណៈក្បួនខ្នាត និងប្រពៃណី ដែលធ្វើឱ្យមានភាពធូរស្រាលនូវអាការៈចុករោយឆ្អឹងឆ្អែង ឈឺសាច់ដុំ និងបន្ធូរអារម្មណ៍នឿយហត់ អស់កំលាំងក្នុងសារពាង្គកាយដើម្បីបង្កើនសុខភាព ។

- ស្ប៉ា (Spa) គឺ ជាការងូតទឹក ត្រាំទឹក ការស្តុងដោយប្រើចំហាយទឹក (សាវណា sauna ឬស្ទីម steam) ការបញ្ចុះទំងន់បង្កើនសម្ផស្ស តាមលក្ខណៈក្បួនខ្នាតនិងប្រពៃណី ។

**ប្រការ ២:** ប្រតិបត្តិការអាជីវកម្មសេវាកម្មម៉ាស្សាសុខភាព -ស្ប៉ា ត្រូវស្ថិតនៅក្នុងមូលដ្ឋានអាជីវកម្មជាអាគារឬសណ្ឋាគារ ឬជាទីកន្លែងក្នុងរមណីយដ្ឋាន ដែលបំពាក់នូវសំភារៈបរិក្ខារមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សំរាប់ផ្គត់ផ្គង់សេវាកម្មម៉ាស្សាសុខភាព-ស្ប៉ាដល់ទេសចរ ។៤-



# ៣ មហាវិថីព្រះមុនីវង្ស ភ្នំពេញ ១២២៥៨ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : +៨៥៥ ២៣ ២១៣៧៤១ ទូរសារ : +៨៥៥ ២៣ ២២០៧០៤; Email: admin@mot.gov.kh, Website: www.mot.gov.kh

**ប្រការ ៣ :** ការផ្តល់អាជ្ញាបណ្ណ័ធ្វើអាជីវកម្មសេវាកម្មម៉ាស្សាសុខភាព-ស្ប៉ា ការផ្អាក និងការដកហូត បិទអាជីវកម្ម គឺជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។

**ប្រការ ៤ :** ការរៀបចំសុំអាជ្ញាបណ្ណ័ទេសចរណ៍ ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសេវាកម្មម៉ាស្សាសុខភាព-ស្ប៉ា ដោយអនុវត្តតាមបែបបទដែលបានកំណត់ ព្រមទាំងត្រូវភ្ជាប់មកនូវឯកសារចាំបាច់ដូចខាងក្រោម :

ក - លិខិតអនុញ្ញាតដាក់ទីតាំងធ្វើអាជីវកម្មចេញដោយអាជ្ញាធរដែនដីសំរាប់សំណង់កែច្នៃឬជួសជុល ។ ចំពោះលិខិតអនុញ្ញាតសាងសង់សំណង់ថ្មីសំរាប់មុខសញ្ញាអាជីវកម្មម៉ាស្សាសុខភាព-ស្ប៉ា ត្រូវចេញដោយក្រសួង ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ខ - វិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

គ - លិខិតបញ្ជាក់លើប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព និងអគ្គីភ័យ ចេញដោយក្រសួងមហាផ្ទៃ ឬស្នងការដ្ឋាននគរបាលខេត្ត-ក្រុង

ឃ - លិខិតបញ្ជាក់លើអនាម័យចេញដោយក្រសួងសុខាភិបាល ឬ មន្ទីរសុខាភិបាល

ង - អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

ច - វិញ្ញាបនប័ត្រធានារ៉ាប់រង អំពីភារៈទទួលខុសត្រូវសាធារណៈ

ឆ - លិខិតយល់ព្រមជាលាយល័ក្ខអក្សររបស់ម្ចាស់ បើសិនជាអ្នកគ្រប់គ្រងមិនមែនជាម្ចាស់កម្មសិទ្ធិ

ជ - សញ្ញាប័ត្រ ឬវិញ្ញាបនប័ត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ពីការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ។

**ប្រការ ៥ :** ក្នុងករណីអាជីវកម្មដែលមិនឋិតនៅក្នុងសណ្ឋាគារ ការរៀបចំសុំអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវអនុវត្តតាមប្រការ៤ ។ ចំពោះអាជីវកម្មដែលឋិតនៅក្នុងសណ្ឋាគារមានម្ចាស់តែមួយត្រូវអនុវត្តទៅតាមបែបបទរបស់សណ្ឋាគារ ក្នុងករណីអាជីវកម្មដែលមានម្ចាស់ផ្សេងពីសណ្ឋាគារ ការរៀបចំសុំអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវភ្ជាប់មកជាមួយនូវ :

ក - វិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ខ - លិខិតបញ្ជាក់លើអនាម័យចេញដោយក្រសួងសុខាភិបាល ឬ មន្ទីរសុខាភិបាល

គ - អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

ឃ - វិញ្ញាបនប័ត្រធានារ៉ាប់រង អំពីភារៈទទួលខុសត្រូវសាធារណៈ

ង - លិខិតយល់ព្រមជាលាយល័ក្ខអក្សររបស់ម្ចាស់ បើសិនជាអ្នកគ្រប់គ្រងមិនមែនជាម្ចាស់កម្មសិទ្ធិ

ច - សញ្ញាប័ត្រ ឬវិញ្ញាបនប័ត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ពីការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ។

**ប្រការ ៦ :** អាជ្ញាបណ្ណ័ទេសចរណ៍ ត្រូវបានចេញអោយប្រើប្រាស់ក្រោយពីអាជីវករបានបំពេញសំណុំឯកសារនៅក្នុងការដាក់ពាក្យសុំធ្វើអាជីវកម្មគ្រប់គ្រាន់ហើយត្រឹមត្រូវ យ៉ាងយូរក្នុងរយៈពេល៣០ថ្ងៃនៃថ្ងៃធ្វើការងារ គិតពីថ្ងៃបានដាក់ពាក្យ ។ ក្នុងករណី ដែលក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុងបដិសេធមិនផ្តល់ ឬមិនបន្តអាជ្ញាប័ណ្ណទេសចរណ៍ ក្រសួង ឬ មន្ទីរទេសចរណ៍នឹងបញ្ជាក់ហេតុផលជាលាយល័ក្ខអក្សរជូនដល់អាជីវករមិនលើសពី ១០ថ្ងៃ គិតពីថ្ងៃដែលទទួលពាក្យ ។

ប្រការ ៧ : - នៅពេលអ្នកស្នើសុំអាជ្ញាបណ្ណ័បានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវទៅតាមបែបបទដូចមានកំណត់ក្នុងប្រការ ៤ ក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុងនឹងចេញអាជ្ញាប័ណ្ណទេសចរណ៍សំរាប់ធ្វើអាជីវកម្មដែលមានសុពលភាពរយៈពេល ០១ ឆ្នាំ ។

-ក្នុងករណីអាជីវករមិនបានបំពេញបែបបទអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលា នោះអ្នកស្នើសុំត្រូវធ្វើកិច្ចសន្យាសុំជំពាក់ឯកសារជាបណ្តោះអាសន្ន និងធានាបំពេញវិញក្នុងរយៈពេល០៣ខែ ។ ស្ថិតក្នុងករណីនេះ ក្រសួង ឬមន្ទីរទេសចរណ៍នឹងចេញអាជ្ញាប័ណ្ណទេសចរណ៍ សំរាប់ធ្វើអាជីវកម្មបណ្តោះអាសន្នដែលមានសុពលភាពរយៈពេល ០៣ខែ។ បន្ទាប់ពីបានបំពេញឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមកិច្ចសន្យា នោះក្រសួង ឬមន្ទីរទេសចរណ៍នឹងផ្តល់អាជ្ញាប័ណ្ណដែលមានសុពលភាព ០១ឆ្នាំ ជូនដល់អាជីវករ ។

ប្រការ ៨ : អាជ្ញាប័ណ្ណទេសចរណ៍មានសុពលភាពប្រើប្រាស់សំរាប់រយៈពេល ០១ឆ្នាំគិតចាប់ពីថ្ងៃចេញច្បាប់អនុញ្ញាត ។ មុនពេលផុតសុពលភាពអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវដាក់ពាក្យសុំបន្តដោយភ្ជាប់ជាមួយអាជ្ញាប័ណ្ណចាស់ និងប័ណ្ណពន្ធប៉ាតង់អោយបាន០១ខែមុនថ្ងៃផុតកំណត់ ។ ក្នុងរយៈពេលដែលបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករនៅតែមានសិទ្ធិធ្វើអាជីវកម្មរហូតដល់ថ្ងៃដែលក្រសួង ឬមន្ទីរទេសចរណ៍ពិនិត្យសំរេចមើលគុណៈសម្បត្តិក្នុងការផ្តល់អាជ្ញាប័ណ្ណបន្តអាជីវកម្ម ។

ប្រការ ៩ : ពេលមានការផ្ទេរ ជួសជុល បិទអាជីវកម្ម ផ្លាស់ប្តូរទីតាំងអាជីវកម្ម ផ្លាស់ប្តូរអ្នកគ្រប់គ្រង អាជីវករត្រូវដាក់ពាក្យសុំតាមរយៈមន្ទីរទេសចរណ៍ខេត្ត-ក្រុង អោយបានមុន ០៣ ខែ ។

ប្រការ ១០ : ការបង់ប្រាក់ក្នុងការចេញអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីសុំបើកអាជីវកម្មដំបូងឬបន្តត្រូវបានកំណត់ដូចខាងក្រោម :

ក. ម៉ាស្សា :

| | |
|---|---|
| - តិចជាង ឬស្មើ ០៥ គ្រែ ឬកៅអី | ២០០ ០០០ រៀល |
| - ពី ០៦ ដល់ ១០ គ្រែ | ៤០០ ០០០ រៀល |
| - ពី ១១ ដល់ ១៥ គ្រែ | ៦០០ ០០០ រៀល |
| - ពី ១៦ ដល់ ២០ គ្រែ | ៨០០ ០០០ រៀល |
| - ពី ២១ គ្រែឡើងទៅ | ១ ០០០ ០០០ រៀល |

ខ. ស្ប៉ា :

- ត្រូវបង់ ៤០០.០០០ រៀល

- ក្នុងករណីមានស្ប៉ាចូលជាមួយម៉ាស្សាការបង់ថ្លៃអាជ្ញាប័ណ្ណត្រូវគិតតែតម្លៃម៉ាស្សាដូចក្នុងចំណុច ក ។

គ. ការផ្លាស់ប្តូរអ្នកគ្រប់គ្រង អាជីវករត្រូវបង់ប្រាក់ ៣០%នៃទឹកប្រាក់ដែលមានចែងក្នុងប្រការ ១០ "ក" និង ១០ "ខ" ។

ប្រការ ១១ : - ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណដំបូង ឬអាជ្ញាប័ណ្ណបន្ត ព្រមទាំងទទួលយកអាជ្ញាប័ណ្ណទេសចរណ៍នៅមន្ទីរទេសចរណ៍ខេត្ត-ក្រុង ។

- មន្ទីរទេសចរណ៍ខេត្ត-ក្រុងត្រូវចេញអាជ្ញាប័ណ្ណទេសចរណ៍តាមដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២ ថ្ងៃ នៃថ្ងៃធ្វើការដោយអនុលោមតាមប្រការ ៤ ។៤-៥

- ចំពោះអាជ្ញាប័ណ្ណដែលត្រូវពិនិត្យនិងសំរេចដោយក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ត្រូវទទួលពាក្យសុំ និងចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម ហើយបញ្ជូនមកក្រសួងទេសចរណ៍ក្នុងរយៈពេល០៥ ថ្ងៃ នៃថ្ងៃធ្វើការ ។ ក្រសួងទេសចរណ៍ (នាយកដ្ឋានឧស្សាហកម្មទេសចរណ៍) ត្រូវទទួល និងពិនិត្យពាក្យសុំនេះ ហើយស្នើសុំការសំរេចចេញអាជ្ញាប័ណ្ណទេសចរណ៍ក្នុងរយៈពេល ១២ថ្ងៃ នៃថ្ងៃធ្វើការ ។ ករណីចាំបាច់ក្រសួងទេសចរណ៍ អាចចុះត្រួតពិនិត្យឡើងវិញលើមូលដ្ឋានអាជីវកម្មនោះក្នុងរយៈពេល ០៥ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យសុំ ។ ក្រសួងទេសចរណ៍នឹងបញ្ជូនអាជ្ញាប័ណ្ណទេសចរណ៍ ដែលរួចជាស្ថាពរទៅមន្ទីរទេសចរណ៍ ក្នុងរយៈពេល ០៣ ថ្ងៃ ។

**ប្រការ ១២ :** - អាជីវករដែលទទួលបានអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវប្រើប្រាស់អាជ្ញាប័ណ្ណនេះអោយបានត្រឹមត្រូវ និងត្រូវគោរព អនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ ។
- ករណីមានការខូចខាត ឬបាត់បង់អាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវធ្វើលិខិតជាលាយល័ក្ខអក្សរបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ដើម្បីស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ទុតិយតាក្នុងរយៈពេល៣០ថ្ងៃគិតពីថ្ងៃដែលខូចខាត ឬបាត់បង់ ។

**ប្រការ ១៣ :** ករណីការធ្វើអាជីវកម្មដោយ :

ក / ប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ឬ អនុវត្តមិនបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងទេសចរណ៍ អាជីវករនឹងត្រូវទទួលការផាកពិន័យមានចំនួនទឹកប្រាក់ ២០០% ( ពីររយភាគរយ )នៃថ្លៃបង់ ។ ប្រសិនបើអាជីវករមិនបង់ប្រាក់ផាកពិន័យនេះ ក្នុងរយៈពេល ០៣ខែ ក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុងនឹងផ្អាកការធ្វើអាជីវកម្ម ឬ ដកហូតអាជ្ញាប័ណ្ណទេសចរណ៍ បិទអាជីវកម្ម ។

ខ / ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ នឹងត្រូវទទួលការព្រមានជាលាយល័ក្ខអក្សរ ។ បើអាជីវករមិនអនុវត្តតាមការណែនាំក្រោយពីការព្រមាននឹងបិទអាជីវកម្ម ។

គ / ករណីអាជីវករបានផ្តល់ព័ត៌មានមិនពិត ឬ ប្រឌិតឯកសារពាក់ព័ន្ធទៅនឹងពាក្យសុំធ្វើអាជីវកម្ម ក្រសួងទេសចរណ៍មានសិទ្ធិដកអាជ្ញាប័ណ្ណទេសចរណ៍ ឬ ផ្អាកអាជីវកម្ម ។

ឃ/ ក្នុងករណីអាជីវករប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងច្បាប់បញ្ញត្តិទាំងឡាយរបស់រដ្ឋ នឹងត្រូវដកហូតអាជ្ញាប័ណ្ណបិទអាជីវកម្ម ព្រមទាំងត្រូវទទួលទោសតាមច្បាប់រដ្ឋជាធរមាន ។

**ប្រការ ១៤ :** នៅពេលមូលដ្ឋានអាជីវកម្មត្រូវទទួលការផ្អាក ឬ ដកហូតអាជ្ញាប័ណ្ណ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខ័អក្សរផ្ញើដល់ម្ចាស់ ឬ អ្នកគ្រប់គ្រងដើម្បីទទួលប្រតិបត្តិតាម ។ សេចក្តីជូនដំណឹងនេះចាត់ទុកជាបានការ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា ។ ក្នុងករណីសេចក្តីជូនដំណឹងមិនអាចផ្ញើបានទៅដល់ម្ចាស់ ឬអ្នកគ្រប់គ្រងដោយប្រការណាមួយ ឬក៏សាមីខ្លួនជាម្ចាស់ ឬអ្នកគ្រប់គ្រងបដិសេធមិនព្រមទទួលស្គាល់ សេចក្តីជូនដំណឹងនេះនឹងត្រូវបិទនៅខាងមុខក្រុមហ៊ុន ឬមូលដ្ឋានអាជីវកម្ម ហើយត្រូវផ្ញើដល់សមាគមទេសចណ៍ក្នុងស្រុក និងភ្នាក់ងារមានសមត្ថកិច្ចដើម្បីទុកជាព័ត៌មាន ។

**ប្រការ ១៥ :** ការផ្អាក ដកហូតអាជ្ញាប័ណ្ណទេសចរណ៍មានរយៈពេលកំណត់ មិនលើសពី០៦ខែ ក្នុងករណីនេះការធ្វើអាជីវកម្មមិនត្រូវបានអនុញ្ញាតអោយធ្វើសកម្មភាពឡើយ ។ ក្រោយពីផុតកំណត់ពេលនៃការផ្អាក ឬដកហូតនេះ ម្ចាស់ ឬអ្នកគ្រប់គ្រង ត្រូវធ្វើលិខិតស្នើសុំមកក្រសួងទេសចរណ៍ដើម្បីសុំដំណើរការអាជីវកម្មឡើងវិញ ។ ✓

**ប្រការ ១៦ :** បុគ្គលណាមួយដែលរារាំងដល់ការងារត្រួតពិនិត្យ ឬ ផ្តល់អាជ្ញាប័ណ្ណក្លែងបន្លំមិនត្រឹមត្រូវផ្ទុយទៅនឹងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ នឹងត្រូវទទួលទណ្ឌកម្មវិធានការរដ្ឋបាល ឬទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ១៧ :** ០៣ខែ ក្រោយពីការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍នឹងមិនអនុញ្ញាតអោយធ្វើអាជីវកម្មម៉ាស្សាសុខភាព និងស្ប៉ាដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ទៀតឡើយ ។

**ប្រការ ១៨ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៩ :** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ខេត្ត-ក្រុង "ដើម្បីមុខការ"
- គ្រប់អាជីវកម្មសេវាកម្មម៉ាស្សាសុខភាព-ស្ប៉ា "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ថោង ខុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១៥១ ប្រក

ថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០១៩

# ប្រកាស
## ស្តីពី
## ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មកីឡាទេសចរណ៍ ម៉ូតូទឹក និងអូប៉រជិះលេងកម្សាន្ត

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងប្រកាសលេខ១៤៦ ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់គុណភាពសេវាកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប៉រជិះលេងកម្សាន្តគ្រប់ប្រភេទ គ្រប់ទម្រង់ ស្របតាមលក្ខណៈបច្ចេកទេសកីឡា និងធានាសន្តិសុខ សុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

១៤៤ ៥៩០

E-mail admin@mot.gov.kh Website www.tourismcambodia.org

**ប្រការ២ ._**

ប្រកាសនេះ មានគោលដៅកំណត់វិធាន និងយន្តការគ្រប់គ្រងសកម្មភាពអាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប៉ីជិះលេងកម្សាន្តគ្រប់ប្រភេទ គ្រប់ទម្រង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តរាល់សកម្មភាពកីឡាទេសចរណ៍ម៉ូតូទឹក និងអូប៉ីជិះលេងកម្សាន្តគ្រប់ប្រភេទ គ្រប់ទម្រង់ដែលធ្វើអាជីវកម្មដើម្បីរកប្រាក់កម្រៃ។

ប្រកាសនេះ មិនអនុវត្តចំពោះ៖

- ប្រភេទក្លឹបកីឡាម៉ូតូទឹក ដែលជាសមាជិករបស់សហព័ន្ធកីឡាម៉ូតូទឹកកម្ពុជា ដែលរៀបចំឡើងក្នុងគោលបំណងអភិវឌ្ឍ ផ្សព្វផ្សាយ ហ្វឹកហាត់ អប់រំបណ្តុះបណ្តាល និងការប្រកួតក្របខណ្ឌថ្នាក់ជាតិ អន្តរជាតិ ដោយមិនធ្វើអាជីវកម្មដើម្បីរកប្រាក់កម្រៃ
- ម៉ូតូទឹក និងអូប៉ីដែលជាកម្មសិទ្ធឯកជនផ្ទាល់ខ្លួនជិះលេងកម្សាន្ត។

**ប្រការ៤ ._**

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មានន័យដូចខាងក្រោម៖

- **បុគ្គល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល
- **ប្រតិបត្តិករទេសចរណ៍** សំដៅដល់បុគ្គលដែលប្រតិបត្តិ ប្រកបអាជីវកម្ម ឬធ្វើអាជីវកម្មសេវាកម្មទេសចរណ៍
- **កីឡាទេសចរណ៍** សំដៅដល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងកីឡារបស់បុគ្គលដែលធ្វើដំណើរទៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់ពួកគេក្នុងគោលបំណងទស្សនា កម្សាន្តសប្បាយ និងចូលរួម លេងកម្សាន្ត ឬប្រកួតប្រជែងក្នុងសកម្មភាពកីឡាទេសចរណ៍
- **ម៉ូតូទឹក** សំដៅដល់យានយន្តតូចៗ គ្រប់ប្រភេទ គ្រប់ទម្រង់ ដែលមានលក្ខណៈដូចម៉ូតូសម្រាប់បើកបរលេងកម្សាន្តលើផ្ទៃទឹក
- **អូប៉ី** សំដៅដល់ទូកតូចៗគ្រប់ប្រភេទ គ្រប់ទម្រង់ ដែលប្រើម៉ាស៊ីនល្បឿនលឿនសម្រាប់បើកបរលេងកម្សាន្តលើផ្ទៃទឹក។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍

**ប្រការ៥ ._**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ត្រួតពិនិត្យ វាយតម្លៃក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប៉ីជិះលេងកម្សាន្ត ដែលធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការធ្វើប្រតិភូកម្មមុខងារផ្តល់អាជ្ញាបណ្ណទេសចរណ៍ ការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃក្នុងការផ្តល់អាជ្ញាបណ្ណកីឡាទេសចរណ៍ម៉ូតូទឹក និងអូប៉ីជិះលេងកម្សាន្តឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ៦ ._**

គ្មានបុគ្គលណាម្នាក់អាចប្រកបអាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្តបានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដែលចេញដោយក្រសួងទេសចរណ៍។ ក្នុងករណីដែលអាជីវកម្មម៉ូតូទឹក និងអូប័រជិះលេងកម្សាន្ត ត្រូវបានប្រតិបត្តិដោយបុគ្គលតែម្នាក់ចេញពីទីតាំងផ្សេងគ្នាត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ផ្សេងៗគ្នា។ ក្នុងករណីដែលអាជីវកម្មច្រើនប្រភេទត្រូវបានប្រតិបត្តិដោយបុគ្គលតែម្នាក់ចេញពីទីតាំងតែមួយប្រភេទ អាជីវកម្មនីមួយៗ ត្រូវតែមានអាជ្ញាបណ្ណផ្សេងៗគ្នា ប្រៀបដូចជាអាជីវកម្មផ្សេងគ្នាដែលប្រតិបត្តិចេញពីទីតាំងផ្សេងគ្នាយ៉ាងដូច្នោះដែរ។

## **ជំពូកទី ៣**
## **ការកំណត់ប្រភេទ និងទីតាំងអាជីវកម្មកីឡាទេសចរណ៍**

**ប្រការ៧ ._**

ប្រភេទអាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្តរួមមាន៖

- ប្រភេទក្លឹបម៉ូតូទឹក និងអូប័រ ដែលផ្តល់សេវាហ្វឹកហាត់ជំនាញដល់កីឡាករ កីឡាការិនីដែលជួយទ្រទ្រង់ដល់សហព័ន្ធកីឡាម៉ូតូទឹកកម្ពុជា
- ប្រភេទក្លឹបម៉ូតូទឹក និងអូប័រ ដែលផ្តល់សេវាហ្វឹកហាត់ជំនាញដល់កីឡាករ កីឡាការិនីដែលជួយទ្រទ្រង់ដល់សហព័ន្ធកីឡាម៉ូតូទឹកកម្ពុជា និងធ្វើអាជីវកម្មដើម្បីរកប្រាក់កម្រៃ
- ប្រភេទអាជីវកម្មម៉ូតូទឹក និងអូប័រជិះលេងកម្សាន្ត ដែលផ្តល់សេវាកម្មបម្រើភ្ញៀវជិះលេងកម្សាន្តសប្បាយក្នុងគោលបំណងធ្វើអាជីវកម្មដើម្បីរកប្រាក់កម្រៃ
- ម៉ូតូទឹក និងអូប័រ ដែលភ្ញៀវជិះកម្សាន្តជាលក្ខណៈឯកជន។

**ប្រការ៨ ._**

រដ្ឋបាលថ្នាក់ក្រោមជាតិជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំ និងកំណត់ទីតាំងអាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ការកំណត់ទីតាំងធ្វើសកម្មភាពរបស់អាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្តត្រូវស្ថិតនៅទីតាំងសមស្របតាមប្រភេទអាជីវកម្មកីឡាទេសចរណ៍នីមួយៗ ដោយជានារក្សាប្រពៃណី ទំនៀមទម្លាប់ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឱ្យបានល្អ។

## **ជំពូកទី ៤**
## **នីតិវិធី និងលក្ខណៈវិនិច្ឆ័យនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្ត**

**ប្រការ៩ ._**

បុគ្គលដែលប្រកបអាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្តគ្រប់ប្រភេទ គ្រប់ទម្រង់ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នៅក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍រាជធានីខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធ Online ទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទឯកសារ និងលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

ក. វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ខ. ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ដើម្បីប្រកបអាជីវកម្ម និងកិច្ចសន្យា

គ. លិខិតអនុញ្ញាតទីតាំងអាជីវកម្ម (ប្រកបអាជីវកម្មក្នុងទីតាំងដែលអាជ្ញាធរមូលដ្ឋានបានកំណត់)

ឃ. វិញ្ញាបនបត្រជំនាញរបស់អ្នកគ្រប់គ្រង ឬផ្ទាំងដែលទទួលស្គាល់ដោយសហព័ន្ធកីឡាម៉ូតូទឹកកម្ពុជា

ង. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស)

ច. រូបថតបច្ចុប្បន្នភាពរបស់អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ (៤X៦ស.ម) ចំនួន ០៣សន្លឹក។

**ប្រការ១០ ._**

ប្រតិបត្តិករទេសចរណ៍ ដែលមានបំណងបន្តអាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្តគ្រប់ប្រភេទ គ្រប់ទម្រង់ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នៅក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍រាជធានីខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធ Online ទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទឯកសារ និងលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

ក. ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ដើម្បីប្រកបអាជីវកម្ម និងកិច្ចសន្យា

ខ. អាជ្ញាបណ្ណទេសចរណ៍ (ច្បាប់ដើម ឬច្បាប់ថតចម្លងត្រាក្រហម)

គ. រូបថតបច្ចុប្បន្នភាពរបស់អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ (៤X៦ស.ម) ចំនួន ០៣សន្លឹក។

**ប្រការ១១ ._**

ករណីប្តូរម្ចាស់អាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្តត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ៩ ដូចខាងក្រោម៖

ក. លិខិតផ្ទេរសិទ្ធិ

ខ. អាជ្ញាបណ្ណទេសចរណ៍ (ច្បាប់ដើម ឬច្បាប់ថតចម្លងត្រាក្រហម)

គ. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស (ម្ចាស់ ឬអ្នកគ្រប់គ្រងថ្មី)

ឃ. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ (៤X៦ស.ម) ចំនួន ០៣សន្លឹក

ករណីប្តូរឈ្មោះអាជីវកម្ម ប្រតិបត្តិករទេសចរណ៍ត្រូវភ្ជាប់ជាមួយវិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។

**ប្រការ១២ ._**

ការបង់កម្រៃ អាជ្ញាបណ្ណទេសចរណ៍សម្រាប់អាជីវកម្មកីឡាទេសចរណ៍ ដូចខាងក្រោម៖

- ម៉ូតូទឹក ១គ្រឿង ត្រូវបង់ ២០០,០០០រៀល
- អូប័រ ១គ្រឿង ត្រូវបង់ ៣០០,០០០រៀល។

ករណីប្តូរម្ចាស់ អាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្តត្រូវបង់កម្រៃស្មើនឹង៣០%នៃតម្លៃអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ១៣ ._**

អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មកីឡាទេសចរណ៍ម៉ូតូទឹក និងអូប័រជិះលេងកម្សាន្តមានសុពលភាពអប្បបរមារយៈពេល០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍ដោយក្រសួងទេសចរណ៍។

ប្រតិបត្តិករទេសចរណ៍ត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ឱ្យបាន ៣០ (សាមសិប)ថ្ងៃយ៉ាងតិចមុនថ្ងៃផុតកំណត់នៃសុពលភាពអាជ្ញាបណ្ណទេសចរណ៍ចាស់។

**ប្រការ១៤ ._**

ក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិនឹងជូនដំណឹងទៅអ្នកស្នើសុំអំពីសេចក្តីសម្រេចឯកភាពផ្តល់ឱ្យ ឬមិនផ្តល់ឱ្យក្នុងរយៈពេល២៨(ម្ភៃប្រាំបី)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីអ្នកស្នើសុំបានបំពេញសំណុំបែបបទត្រឹមត្រូវតាមលក្ខខណ្ឌ និងការតម្រូវដូចមានចែងក្នុងប្រកាសនេះ។

ប្រសិនបើអ្នកស្នើសុំមិនអាចបំពេញបែបបទទាន់ពេលវេលាទៅតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍អាចអនុញ្ញាតឱ្យអ្នកស្នើសុំធ្វើកិច្ចសន្យាបំពេញបន្ថែមនូវលក្ខខណ្ឌដែលមិនទាន់គ្រប់គ្រាន់ជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះក្រសួងទេសចរណ៍នឹងផ្តល់អាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នដែលមានសុពលភាពរយៈពេល៩០(កៅសិប)ថ្ងៃ ក្រោយពេលអ្នកស្នើសុំអាជ្ញាបណ្ណបានបង់កម្រៃអាជ្ញាបណ្ណទេសចរណ៍រួច។

ក្នុងរយៈពេលកំណត់នៃកិច្ចសន្យា បើម្ចាស់អាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នអាចបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍នឹងផ្តល់អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិដល់អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍។ ផ្ទុយទៅវិញក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ហើយនៅតែបន្តអាជីវកម្មលើអាជ្ញាបណ្ណបណ្តោះអាសន្នដែលអស់សុពលភាព ត្រូវចាត់ទុកជាការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ១៥ ._**

ប្រតិបត្តិករទេសចរណ៍អាចធ្វើការស្នើសុំផ្អាក ឬបិទអាជីវកម្មរបស់ខ្លួនជាបណ្តោះអាសន្ន ឬបិទអាជីវកម្មដោយត្រូវដាក់ពាក្យស្នើសុំមកក្រសួងទេសចរណ៍ឱ្យបានមុន៦០(ហុកសិប)ថ្ងៃ។ ក្នុងអំឡុងពេលផ្អាកសកម្មភាពអាជីវកម្មកីឡាទេសចរណ៍ ម្ចាស់ ឬអ្នកគ្រប់គ្រងមិនត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពអាជីវកម្មឡើយ។

នៅពេលដែលបើកដំណើរការអាជីវកម្មឡើងវិញម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវធ្វើលិខិតមកក្រសួងទេសចរណ៍ឱ្យបានមុន ៣០(សាមសិប)ថ្ងៃ ដើម្បីស្នើសុំដំណើរការអាជីវកម្មឡើងវិញ។

## ជំពូកទី ៥
## ភារកិច្ចរបស់ប្រតិបត្តិករទេសចរណ៍

**ប្រការ១៦ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងមាត្រា៤៨ នៃច្បាប់ស្តីពីទេសចរណ៍ និងប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវកិច្ចសន្យានៅពេលស្នើសុំអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ១៧ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវផ្តល់របាយការណ៍ និងស្ថិតិពីអាជីវកម្មរបស់ខ្លួនជូនក្រសួងទេសចរណ៍រៀងរាល់ ៦(ប្រាំមួយ)ខែម្តង និងទៅតាមការស្នើសុំរបស់ក្រសួងទេសចរណ៍។



១៥៥

១៩៤

**ប្រការ១៨ ._**

បុគ្គលដែលប្រកបអាជីវកម្មកីឡាទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ ឬប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍ហួសសុពលភាពត្រូវទទួលពិន័យអន្តរការណ៍អនុលោមតាម ប្រកាសរួមរវាងក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការដាក់ពិន័យអន្តរការណ៍ មិនធ្វើឱ្យអ្នកប្រព្រឹត្តអំពើនោះរួចផុតពីការទទួលខុសត្រូវខាងរដ្ឋប្បវេណី និង/ឬការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលមានចែងដោយច្បាប់ និងបទបញ្ញត្តិជាធរមាន។

**ប្រការ១៩ ._**

ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍សម្រាប់ដំណើរការអាជីវកម្មកីឡាទេសចរណ៍ ឬឯកសារសាធារណៈផ្សេងៗត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ២០ ._**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ២១ ._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គាធិការ គ្រប់ប្រធានអង្គភាព ក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុក អនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ថោង ខុន**

**កន្លែងទទួល:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- ដូចប្រការ២១
- រាជកិច្ច កាលប្បវត្តិ



១៥៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ១៥៧ ប្រ.ក

ថ្ងៃ សុក្រ ៥កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងសកម្មភាពកីឡាទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងប្រកាសលេខ១៤៦ ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១ ._**

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម៖

- លើកកម្ពស់គុណភាពសេវាកម្មកីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ ប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា
- ធានាសន្តិសុខ សុវត្ថិភាពជូនភ្ញៀវជាតិ និងអន្តរជាតិ។

**ប្រការ២ ._**

ប្រកាសនេះ មានគោលដៅកំណត់វិធាន និងយន្តការគ្រប់គ្រងសកម្មភាពកីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទំព័រ ១៦០

E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ៣ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសកម្មភាពកីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ ដូចខាងក្រោម៖

ក. **ការរៀបចំព្រឹត្តិការណ៍កីឡាទេសចរណ៍** (Sport Tourism Event)។

ខ. **ប្រភេទអាជីវកម្មកីឡាទេសចរណ៍ស្គី** (Skiing) មានដូចជា៖
- ខ្សែកែអូសស្គីលើទឹក (Cable Skiing)
- កីឡាជិះស្គីរលកសិប្បនិម្មិត (Flow Riding)
- ស្គីអូសដោយអូប៉ ឬម៉ូតូទឹក (Knee Boarding)
- ឆ័ត្រទាញទូក ឬទាញស្គីបណ្តែត (Kite Boating and Kite Boarding)
- កីឡាជិះស្គី (លើទឹកកក និងផ្ទៃរាប) (Ice Skating)
- ស្គីលើទឹក (Wave Skiing)
- ស្គីប្រើក្តោង (Wind Surfing)។

គ. **ប្រភេទអាជីវកម្មកីឡាទេសចរណ៍សកម្ម** (Active Sport Tourism) មានដូចជា៖
- កីឡាប៊ូលីង (Bowling)
- កីឡាវាយកូនគោល (Golf Course)
- កីឡាហាត់វាយកូនគោល (Golf Driving Range)
- កីឡាបាញ់ព្រួញ (Archery)
- កីឡាបាញ់កាំភ្លើងគ្រាប់មិនពិត (Paintball)
- អាជីវកម្មក្លឹបហាត់ប្រាណ (Fitness Center, Gym)
- កីឡាយោគៈ (Yoga)
- កីឡាក្តារបណ្តែត (Paddle Boarding)
- កីឡាជិះអូប៉ (Speed Boat)
- អូប៉ទាញឆ័ត្របង្ហោះ (Parasailing)
- ពោងបណ្តែត (Floating Water Park)
- សួនទឹកកម្សាន្ត (Water Park)
- កីឡាម៉ូតូទឹក (Jet Ski)
- អាងហែលទឹក (Swimming Pool)
- កីឡាស្ទូចត្រី ឬស្ទូចបង្កង (Fishing)
- កីឡាអូប៉អូសពោងបណ្តែត (Banana boat)
- កីឡាទូកក្តោង (Sailing)
- កីឡាជិះលេងកម្សាន្តលើផ្លូវដែក (Roller Coaster)។

ឃ. **ប្រភេទកីឡាទេសចរណ៍បែបផ្សងព្រេង** (Adventure Sport Tourism) មានដូចជា៖
- កីឡាលោតទំលាក់ខ្លួនពីលើទីខ្ពស់ (Bungee Jumping)
- កីឡាប្រណាំងម៉ូតូឆ្លងឧបសគ្គ (Dirt Biking)
- ការប្រណាំងយានយន្តកម្សាន្តលើផ្ទៃរាប (Go Kart)
- កីឡាមុជទឹក (Scuba Diving and snorkeling)
- កីឡាពោងបង្វិល (Zorbing)
- កីឡាជិះកង់ក្នុងព្រៃ ឬលើភ្នំ (Mountain Biking)

- កីឡាឡើងជញ្ជាំងភ្នំ ឬជញ្ជាំងសិប្បនិម្មិត (Rock Climbing)
- កីឡាពាក់ស្លាបហោះ (Hang Gliding)
- កីឡាហោះហើរលើទឹក (Fly Board)
- កីឡាដើរក្នុងព្រៃ ឬឡើងភ្នំ (Hiking)
- ទូកជិះកម្សាន្ត កៃយ៉ាក់ កានូ រ៉ូវីង (Kayaking Canoeing and Rowing)
- កីឡាចូលក្នុងរូងភ្នំ (Caving)
- កីឡាបោះជំរុំ (Camping)
- បាឡុងបង្ហោះ (Balloon)
- កីឡាហោះហើរលើអាកាស (Fly Board Air)
- ខ្សែកែ រថយន្តខ្សែកាប (Cable car)
- កីឡាលោតឆ័ត្រយោង (Parachuting)
- កីឡាហោះបណ្តែតខ្លួន (Sky Diving)។

ង. **ប្រភេទកីឡាទេសចរណ៍ដែលមានឧបនិស្ស័យនឹងកីឡាដែលបម្រើការកម្សាន្តសប្បាយរបស់ភ្ញៀវ។**

ប្រកាសនេះ មិនអនុវត្តចំពោះ៖

- ប្រភេទក្លឹបអាជីវកម្ម ដែលជាសមាជិករបស់សហព័ន្ធកីឡា កម្ពុជា ដែលរៀបចំឡើងក្នុងគោលបំណងអភិវឌ្ឍ ផ្សព្វផ្សាយ ហ្វឹកហាត់ អប់រំបណ្តុះបណ្តាល និងការប្រកួតគ្រប់ខណ្ឌថ្នាក់ជាតិ អន្តរជាតិ ដោយមិនធ្វើអាជីវកម្មដើម្បីរកប្រាក់កម្រៃ។

**ប្រការ៤ _**

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មានន័យដូចខាងក្រោម៖

- **បុគ្គល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល
- **កីឡាទេសចរណ៍** សំដៅដល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងកីឡារបស់បុគ្គលដែលធ្វើដំណើរទៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់ពួកគេក្នុងគោលបំណងទស្សនា កម្សាន្តសប្បាយ និងចូលរួម លេងកម្សាន្ត ឬប្រកួតប្រជែងក្នុងសកម្មភាពកីឡាទេសចរណ៍
- **សកម្មភាពកីឡាទេសចរណ៍** សំដៅដល់ការធ្វើអាជីវកម្មកីឡាទេសចរណ៍ និងការរៀបចំព្រឹត្តិការណ៍កីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ ដែលបម្រើដល់វិស័យទេសចរណ៍
- **ព្រឹត្តិការណ៍កីឡាទេសចរណ៍** សំដៅដល់ការរៀបចំព្រឹត្តិការណ៍កីឡាគ្រប់ប្រភេទ គ្រប់ទម្រង់ដើម្បីផ្សព្វផ្សាយអំពីសក្តានុពលទេសចរណ៍ និងទាក់ទាញភ្ញៀវឱ្យចូលរួមទស្សនា និងលេងកម្សាន្តសប្បាយ
- **កីឡាទេសចរណ៍ប្រភេទស្តី** សំដៅដល់ប្រភេទកីឡាទេសចរណ៍ ដែលភ្ញៀវទេសចរចូលរួមជិះលេងកម្សាន្តសប្បាយ ឬប្រកួតប្រជែងតាមចំណង់ចំណូលចិត្ត ក្នុងសកម្មភាពកីឡាស្តី
- **កីឡាទេសចរណ៍សកម្ម (Active Sport Tourism)** សំដៅដល់ប្រភេទកីឡាទេសចរណ៍ទាំងឡាយដែលភ្ញៀវធ្វើសកម្មភាពប្រើកំលាំងកាយ បច្ចេកទេស ទេពកោសល្យ និងភាពប៉ិនប្រសព្វរបស់ខ្លួនដើម្បីចូលរួមលេងកម្សាន្តសប្បាយ ឬប្រកួតប្រជែងតាមចំណង់ចំណូលចិត្តក្នុងសកម្មភាពកីឡា
- កីឡាទេសចរណ៍បែបផ្សងព្រេង សំដៅដល់ប្រភេទកីឡា ដែលភ្ញៀវទេសចរចូលរួមលេងកម្សាន្តសប្បាយ ឬប្រកួតប្រជែងតាមចំណង់ចំណូលចិត្តក្នុងសកម្មភាពកីឡាបែបផ្សងព្រេង។

**ប្រការ៥ ._**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ត្រួតពិនិត្យ ផ្តល់អាជ្ញាបណ្ណទេសចរណ៍ និងចេញលិខិតអនុញ្ញាតឱ្យធ្វើសកម្មភាពកីឡាទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការធ្វើប្រតិភូកម្មមុខងារកីឡាទេសចរណ៍ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ៦ ._**

នីតិវិធី និងលក្ខណៈវិនិច្ឆ័យនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ និង/ឬលិខិតអនុញ្ញាតឱ្យធ្វើសកម្មភាពកីឡាទេសចរណ៍ និងការរៀបចំព្រឹត្តិការណ៍កីឡាទេសចរណ៍ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ៧ ._**

គ្មានបុគ្គលណាម្នាក់អាចធ្វើសកម្មភាពកីឡាទេសចរណ៍ និងការរៀបចំព្រឹត្តិការណ៍កីឡាទេសចរណ៍បានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ឬលិខិតអនុញ្ញាតដែលចេញដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៨ ._**

បុគ្គលដែលធ្វើសកម្មភាពកីឡាទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ ឬលិខិតអនុញ្ញាតដែលចេញដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលពិន័យអន្តរការណ៍អនុលោមតាមប្រកាសរួមរវាងក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៩ ._**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១០ ._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គាធិការ គ្រប់ប្រធានអង្គភាព ក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុក អនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

Kingdom of Wonder

ក្រសួងទេសចរណ៍

លេខ ១៧៤/ប.ក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មខារ៉ាអូខេ
# រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងការកិច្ចនិងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- យោងតាមតម្រូវការចាំបាច់នៃការងារ

សម្រេច

១៦៤

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១._**

ប្រកាសនេះមានគោលដៅកំណត់វិធាននិងយន្តការគ្រប់គ្រងអាជីវកម្មខារ៉ាអូខេដែលបម្រើឲ្យវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២._**

ប្រកាសនេះ មានគោលបំណងដូចតទៅ ៖

- ពង្រឹងការគ្រប់គ្រងអាជីវកម្មខារ៉ាអូខេឲ្យកាន់តែមានប្រសិទ្ធភាពនិងធានាបាននូវគុណភាពសេវាកម្មទេសចរណ៍
- ចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍រក្សាបាននូវសណ្តាប់ធ្នាប់សុវត្ថិភាពព្រមទាំងធានាដល់ការថែរក្សាវប្បធម៌ ប្រពៃណី និងសេចក្តីថ្លៃថ្នូររបស់ជាតិ ។

**ប្រការ ៣._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចតទៅ ៖

**អាជីវកម្មខារ៉ាអូខេ** សំដៅដល់អាជីវកម្មនៅក្នុងបន្ទប់នៃអាគារដោយប្រើប្រាស់ឧបករណ៍សម្លេងនិងរូបភាព និងអក្សរសម្រាប់បម្រើភ្ញៀវច្រៀងកម្សាន្ត ព្រមទាំងមានការផ្តល់សេវាភេសជ្ជៈ និងអាហារបន្ទាប់បន្សំ។

## ជំពូកទី ២
## ការកំណត់ប្រភេទ ទីតាំង និងពេលវេលា

**ប្រការ ៤._**

ទីតាំងអាជីវកម្មខារ៉ាអូខេ ត្រូវបានអនុញ្ញាតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ការកំណត់ទីតាំងអាជីវកម្មខារ៉ាអូខេត្រូវស្ថិតនៅទីតាំងសមរម្យ និងសមស្របតាមប្រភេទអាជីវកម្មនីមួយៗផ្អែកលើលក្ខខណ្ឌដូចខាងក្រោម ៖

- មានចម្ងាយយ៉ាងតិច ២០០ (ពីររយ) ម៉ែត្រពីបរិវេណក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូតមន្ទីរពេទ្យ សាលារៀន វត្តអារ៉ាម ប្រាង្គប្រាសាទ ទីតាំងបេតិកភណ្ឌវប្បធម៌
- មិនបង្កការរំខានដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន វត្តអារ៉ាម និងការរស់នៅរបស់ប្រជាពលរដ្ឋ
- ធានារក្សាសន្តិសុខ សុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឲ្យបានល្អ ។

**ប្រការ ៥._**

អាជីវកម្មខារ៉ាអូខេ ត្រូវកំណត់ជាគោលការណ៍នូវពេលវេលាដំណើរការអាជីវកម្មចាប់ពីម៉ោង១៤:០០នាទីព្រឹក ដល់ម៉ោង ២៤:០០នាទី។

ការកំណត់ពេលវេលាដំណើរការអាជីវកម្មហួសពីម៉ោង២៤:០០នាទីត្រូវបានអនុញ្ញាតចំពោះតែតំបន់អភិវឌ្ឍន៍ និងគោលដៅទេសចរណ៍សំខាន់ៗ និងត្រូវកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

# ជំពូកទី ៣
# សមត្ថកិច្ចគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍

ប្រការ ៦._

ក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចក្នុងការគ្រប់គ្រងការត្រួតពិនិត្យ និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេ។

ការធ្វើប្រតិភូកម្មអំណាច ក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ប្រការ ៧._

ក. ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅថ្នាក់ជាតិ (ចេញដោយក្រសួងទេសចរណ៍)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅក្រសួងទេសចរណ៍ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. លិខិតអនុញ្ញាតទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២. ~~វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជ~~ កម្មរាជធានី ខេត្ត

៣. លិខិតបញ្ជាក់ពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យចេញដោយការិយាល័យអគ្គីភ័យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

៤. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ

៥. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៦. អ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រកំរិតឧត្តមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាប័ត្រ សមមូល (ឬខ្ពស់ជាងនេះ)។

៧. បុគ្គលិកបម្រើការត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍(យ៉ាងតិច ៣០%នៃចំនួនបុគ្គលិកសរុប)

៨. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៩. បង្កាន់ដៃបង់ប្រាក់

ខ. ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅថ្នាក់ជាតិ (ចេញដោយក្រសួងទេសចរណ៍)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅក្រសួងទេសចរណ៍ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. លិខិតអនុញ្ញាតទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម ឬទុតិយតាគ្រាក្រហម

៣. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ

៤. បណ្ណពន្ធប៉ាតង់

៥. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៦. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៧. បង្កាន់ដៃបង់ប្រាក់ ។

ប្រការ ៨._

ក. ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅថ្នាក់ក្រោមជាតិ (ចេញដោយសាលារាជធានី ខេត្ត)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. លិខិតបញ្ជាក់ទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ

២. វិញ្ញាបនបត្រឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត

៣. លិខិតបញ្ជាក់ពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យចេញដោយការិយាល័យអគ្គីភ័យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

៤. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ

៥. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៦. អ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រកំរិតឧត្តមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាប័ត្រ សមមូល (ឬខ្ពស់ជាងនេះ) ។

៧. បុគ្គលិកបម្រើការត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ដែល ទទួលស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច ៣០ %នៃចំនួនបុគ្គលិកសរុប)

៨. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៩. បង្កាន់ដៃបង់ប្រាក់

ខ.ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅថ្នាក់ក្រោមជាតិ (ចេញដោយសាលារាជធានី ខេត្ត)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម ឬទុតិយតាត្រាក្រហម

២. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ

៣. បណ្ណពន្ធប៉ាតង់

៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៥. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៦. បង្កាន់ដៃបង់ប្រាក់ ។

ប្រការ ៩._

ក.ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅថ្នាក់ក្រោមជាតិ (ចេញដោយសាលាក្រុង ស្រុក ខណ្ឌ)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. វិញ្ញាបនបត្រឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត

២. លិខិតបញ្ជាក់ពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យចេញដោយការិយាល័យអគ្គីភ័យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

៣. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ

៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៥. អ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រកំរិតឧត្ដមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាប័ត្រ សមមូល (ឬខ្ពស់ជាងនេះ) ។

៦. បុគ្គលិកបម្រើការត្រូវវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច ៣០ %នៃចំនួនបុគ្គលិកសរុប)

៧. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៨. បង្កាន់ដៃបង់ប្រាក់

ខ.ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅថ្នាក់ក្រោមជាតិ (ចេញដោយសាលាក្រុង ស្រុក ខណ្ឌ)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម ឬទុតិយតាក្រាក្រហម

២. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្ដីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ

៣. បណ្ណពន្ធប៉ាតង់

៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៥. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៦. បង្កាន់ដៃបង់ប្រាក់ ។

ប្រការ ១០.-

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេ (ថ្មីនិងបន្ត) គ្រប់ថ្នាក់នឹងត្រូវបានកែសម្រួល និងបន្ថែមក្នុងករណីដូចខាងក្រោម ៖

ក. ករណីមានការផ្ទេរសិទ្ធិឈរឈ្មោះ ឬប្ដូរអ្នកគ្រប់គ្រង អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេដែលជាអ្នកទទួលសិទ្ធិឈរឈ្មោះ ឬអ្នកទទួលគ្រប់គ្រងនោះត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ៧ ប្រការ៨ និងប្រការ៩ ដូចខាងក្រោម៖

១. លិខិតប្រគល់សិទ្ធិ

២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកផ្ទេរសិទ្ធិ (ម្ចាស់អាជីវកម្ម ឬអ្នកគ្រប់គ្រងចាស់ដែលត្រូវប្ដូរ)

៣. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ (អ្នកឈរឈ្មោះស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ឬអ្នកគ្រប់គ្រងថ្មី)។

ខ. ករណីទីតាំងអាជីវកម្មខារ៉ាអូខេស្ថិតនៅក្នុងទីតាំងផ្សារទំនើប អគារពាណិជ្ជកម្ម ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេថ្មី ឬបន្តអាចបំពេញជំនួសលិខិតអនុញ្ញាតទីតាំងប្រកបអាជីវកម្ម ដោយកិច្ចសន្យាជួលទីតាំងពីម្ចាស់ផ្សារទំនើប ឬអគារពាណិជ្ជកម្មដែលអាជីវកម្មខារ៉ាអូខេតាំងនៅ។

គ. ករណីប្ដូរឈ្មោះអាជីវកម្ម អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទ ដូចមានចែងក្នុងប្រការ៧ ប្រការ៨ និងប្រការ៩ នូវ៖

១. វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ឈ្មោះថ្មី) ដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត។

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេ (ថ្មី និងបន្ត) គ្រប់ថ្នាក់អាចនឹងត្រូវបានជំនួសដោយឯកសារ ដោយឡែកដែលមានតម្លៃស្មើ យោងតាមការកំណត់របស់បទដ្ឋានខ្ពស់ជាង។

ប្រការ ១១._

កម្រៃសេវាសាធារណៈអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេថ្មីនិងបន្តត្រូវបានកំណត់ដូចតទៅៈ

ក. កម្រៃអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេត្រូវបង់៖

| | | | |
|---|---|---|---|
| ១. ចំណុះត្រឹម | ០៥បន្ទប់ | ត្រូវបង់ | ៤០០,០០០(បួនរយពាន់)រៀល |
| ២. ចំណុះពី | ០៦ ដល់ ១០បន្ទប់ | ត្រូវបង់ | ៨០០,០០០(ប្រាំបីមួយរយពាន់)រៀល |
| ៣. ចំណុះពី | ១១ ដល់ ២០បន្ទប់ | ត្រូវបង់ | ១,៦០០,០០០(មួយលានប្រាំមួយរយពាន់) រៀល |
| ៤.ចំណុះពី | ២១ ដល់ ៤០ បន្ទប់ | ត្រូវបង់ | ៣,០០០,០០០(បីលាន)រៀល |
| ៥. ចំណុះពី | ៤១បន្ទប់ ឡើងទៅ | ត្រូវបង់ | ៤,០០០,០០០(បួនលាន)រៀល ។ |

ខ. កម្រៃសេវាសាធារណៈសម្រាប់ការប្តូរម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មខារ៉ាអូខេត្រូវបង់៣០ % នៃកម្រៃអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេ ដូចមានកំណត់ ក្នុងចំណុច "ក" នៃប្រការនេះ។

ប្រការ ១២._

អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេ មានសុពលភាពអប្បបរមា រយៈពេល០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញ អាជ្ញាបណ្ណទេសចរណ៍ ។

## ជំពូកទី ៤
## ការប្រតិបត្តិអាជីវកម្ម

ប្រការ ១៣._

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មខារ៉ាអូខេបានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រការ ១៤._

ប្រតិបត្តិករទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេ ត្រូវមានកាតព្វកិច្ចគោរពតាមតាមច្បាប់និងបទប្បញ្ញត្តិនានាព្រមទាំងក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈអាជីវកម្មខារ៉ាអូខេ ។

ប្រការ ១៥._

អនីតិជនអាចចូលទៅកម្សាន្តក្នុងបរិវេណទីតាំងអាជីវកម្មខារ៉ាអូខេបាន លុះត្រាតែមានឪពុកម្តាយឬអាណាព្យាបាលទៅជាមួយនិង ដោយមានការធានាអះអាងត្រឹមត្រូវ។

ប្រការ ១៦._

អ្នកគ្រប់គ្រង និងម្ចាស់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេត្រូវធ្វើបញ្ជរត្រួតពិនិត្យអត្តសញ្ញាណបណ្ណអតិថិជនវ័យក្មេងទាំងអស់ ដើម្បីធានាឲ្យមានការប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន។

## ជំពូកទី ៥
## អធិការកិច្ច

ប្រការ ១៧._

ក្រសួងទេសចរណ៍ត្រូវដឹកនាំការងារអធិការកិច្ចដោយចាត់តាំងមន្ត្រីជំនាញចុះត្រួតពិនិត្យសកម្មភាពអាជីវកម្មខារ៉ាអូខេ នៅក្នុងរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការធ្វើអធិការកិច្ចក្រសួងទេសចរណ៍អាចសហការ និងសម្របសម្រួលជាមួយមន្ត្រីនៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងករណីមានការប្រព្រឹត្តបទល្មើសចាប់ពីបទមជ្ឈឹមជាក់ស្តែងឡើងទៅរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តនីតិវិធីច្បាប់ ដើម្បីផ្អាកសកម្មភាពអាជីវកម្មបណ្តោះអាសន្នជាបន្ទាន់និងត្រូវសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងទេសចរណ៍ដើម្បីបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

ប្រការ ១៨._

បុគ្គលណាដែលធ្វើអាជីវកម្មខារ៉ាអូខេដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា ៦៥ នៃច្បាប់ស្តីពីទេសចរណ៍។ ទំហំទឹកប្រាក់ នៃការពិន័យអន្តរការណ៍សម្រាប់អាជីវកម្មខារ៉ាអូខេ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេ ឬឯកសារសាធារណៈផ្សេងៗត្រូវផ្តន្ទាទោសតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

ប្រការ ១៩._

អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេ ដែលចេញដោយក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិកន្លងមកដែលនៅមានសុពលភាពត្រូវនៅបន្តអនុវត្តរហូតដល់អស់សុពលភាព។

ប្រតិបត្តិករទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មខារ៉ាអូខេបន្តទៀតត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មខារ៉ាអូខេស្របតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍និងប្រកាសនេះ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

ប្រការ ២០._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ២១._

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកដ្ឋាននិងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធាននាយកដ្ឋានពាក់ព័ន្ធនៃក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថោង ខុន

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត "ដើម្បីជូនជ្រាប"
- ដូចប្រការ ២១ "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
*Kingdom of Wonder*

ក្រសួងទេសចរណ៍
លេខ ៣៧៥ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៦

# ប្រកាស
## ស្ដីពី
## ការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មប៊ៀរហ្គាឌិន
## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្ដីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- យោងតាមតម្រូវការចាំបាច់នៃការងារ

**សម្រេច**

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

ប្រការ ១._

ប្រកាសនេះមានគោលដៅកំណត់វិធាននិងយន្តការគ្រប់គ្រងអាជីវកម្មបៀរហ្គាឌិនដែលបម្រើឲ្យវិស័យទេសចរណ៍នៅ ក្នុង ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២._

ប្រកាសនេះ មានគោលបំណងដូចតទៅ ៖

- ពង្រឹងការគ្រប់គ្រងអាជីវកម្មបៀរហ្គាឌិន ឲ្យកាន់តែមានប្រសិទ្ធភាពនិងធានាបាននូវគុណភាពសេវាកម្មទេសចរណ៍
- ចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍រក្សាបាននូវសណ្តាប់ធ្នាប់សុវត្ថិភាពព្រមទាំងធានាដល់ការថែរក្សាវប្បធម៌ ប្រពៃណី និងសេចក្តីថ្លៃថ្នូររបស់ជាតិ ។

ប្រការ ៣._

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចតទៅ ៖

អាជីវកម្មបៀរហ្គាឌិន សំដៅដល់អាជីវកម្មដែលមានការប្រគុំតន្ត្រី និងការច្រៀងកំដរជូនភ្ញៀវដោយមានការបម្រើភេសជ្ជៈ និងម្ហូបអាហារគ្រប់ប្រភេទ។

## ជំពូកទី ២
## ការកំណត់ប្រភេទ ទីតាំង និងពេលវេលា

ប្រការ ៤._

ទីតាំងអាជីវកម្មបៀរហ្គាឌិន ត្រូវបានអនុញ្ញាតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ការកំណត់ទីតាំងអាជីវកម្មខាងលើត្រូវស្ថិតនៅទីតាំងសមរម្យ និងសមស្របតាមប្រភេទអាជីវកម្មនីមួយៗផ្អែកលើលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានចម្ងាយយ៉ាងតិច ២០០ (ពីររយ) ម៉ែត្រពីបរិវេណក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូតមន្ទីរពេទ្យ សាលារៀន វត្តអារាម ប្រាង្គប្រាសាទ ទីតាំងបេតិកភណ្ឌវប្បធម៌
- មិនបង្កការរំខានដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន វត្តអារាម និងការរស់នៅរបស់ប្រជាពលរដ្ឋ
- ធានារក្សាសន្តិសុខ សុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឲ្យបានល្អ ។

ប្រការ ៥._

អាជីវកម្មបៀរហ្គាឌិន ត្រូវកំណត់ជាគោលការណ៍នូវពេលវេលាដំណើរការអាជីវកម្មចាប់ពីម៉ោង១៨:០០នាទី ដល់ម៉ោង ២៤:០០នាទី។

ការកំណត់ពេលវេលាដំណើរការអាជីវកម្មហួសពីម៉ោង២៤:០០នាទីត្រូវបានអនុញ្ញាតចំពោះតែតំបន់អភិវឌ្ឍន៍ និងគោលដៅទេសចរណ៍សំខាន់ៗ និងត្រូវកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ជំពូកទី ៣
## សមត្ថកិច្ចគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍

១៧២

ប្រការ ៦._

ក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចក្នុងការគ្រប់គ្រងការត្រួតពិនិត្យ និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន។

ការធ្វើប្រតិភូកម្មអំណាច ក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ប្រការ ៧._

ក. ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅថ្នាក់ជាតិ (ចេញដោយក្រសួងទេសចរណ៍)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅក្រសួងទេសចរណ៍ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. លិខិតអនុញ្ញាតទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
២. វិញ្ញាបនបត្រឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
៣. លិខិតបញ្ជាក់ពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យចេញដោយការិយាល័យអគ្គីភ័យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
៤. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
៥. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
៦. អ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រកំរិតឧត្តមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាប័ត្រ សមមូល (ឬខ្ពស់ជាងនេះ)។
៧. បុគ្គលិកបម្រើការត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច ៣០ %នៃចំនួនបុគ្គលិកសរុប)
៨. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក
៩. បង្កាន់ដៃបង់ប្រាក់

ខ. ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅថ្នាក់ជាតិ (ចេញដោយក្រសួងទេសចរណ៍)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅក្រសួងទេសចរណ៍ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. លិខិតអនុញ្ញាតទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
២. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម ឬទុតិយតាត្រាក្រហម
៣. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
៤. បណ្ណពន្ធប៉ាតង់
៥. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
៦. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក
៧. បង្កាន់ដៃបង់ប្រាក់ ។

ប្រការ ៨._

ក. ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅថ្នាក់ក្រោមជាតិ (ចេញដោយសាលារាជធានី ខេត្ត)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. លិខិតបញ្ជាក់ទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ
២. វិញ្ញាបនបត្រឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្ម រាជធានី ខេត្ត
៣. លិខិតបញ្ជាក់ពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យចេញដោយការិយាល័យអគ្គីភ័យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
៤. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
៥. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
៦. អ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រកំរិតឧត្តមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាប័ត្រ សមមូល (ឬខ្ពស់ជាងនេះ)។
៧. បុគ្គលិកបម្រើការត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ដែលទទួល ស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច ៣០%នៃចំនួនបុគ្គលិកសរុប)
៨. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក
៩. បង្កាន់ដៃបង់ប្រាក់

ខ.ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅថ្នាក់ក្រោមជាតិ (ចេញដោយសាលារាជធានី ខេត្ត)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម ឬទុតិយតាត្រាក្រហម
២. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
៣. បណ្ណពន្ធប៉ាតង់
៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
៥. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក
៦. បង្កាន់ដៃបង់ប្រាក់។

ប្រភេទ ៩._

ក.ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅថ្នាក់ក្រោមជាតិ (ចេញដោយសាលាក្រុង ស្រុក ខណ្ឌ)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្ម បៀរហ្គាឌិននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. វិញ្ញាបនបត្រឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
២. លិខិតបញ្ជាក់ពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យចេញដោយការិយាល័យអគ្គីភ័យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
៣. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៥. អ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រកំរិតឧត្តមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាប័ត្រ សមមូល (ឬខ្ពស់ជាងនេះ)។

៦. បុគ្គលិកបម្រើការត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច ៣០ %នៃចំនួនបុគ្គលិកសរុប)

៧. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៨. បង្កាន់ដៃបង់ប្រាក់

ខ.ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅថ្នាក់ក្រោមជាតិ (ចេញដោយសាលាក្រុង ស្រុក ខណ្ឌ)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម ឬទុតិយតាត្រាក្រហម

២. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ

៣. បណ្ណពន្ធប៉ាតង់

៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៥. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៦. បង្កាន់ដៃបង់ប្រាក់ ។

ប្រការ ១០._

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន (ថ្មីនិងបន្ត) គ្រប់ថ្នាក់នឹងត្រូវបានកែសម្រួល និងបន្ថែមក្នុងករណីដូចខាងក្រោម ៖

ក. ករណីមានការផ្ទេរសិទ្ធិឈរឈ្មោះ ឬប្តូរអ្នកគ្រប់គ្រង អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិនដែលជាអ្នកទទួលសិទ្ធិឈរឈ្មោះ ឬអ្នកទទួលគ្រប់គ្រងនោះត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទ ដូចមានចែងក្នុងប្រការ៧ ប្រការ៨ និងប្រការ៩ ដូចខាងក្រោម៖

១. លិខិតប្រគល់សិទ្ធិ

២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកផ្ទេរសិទ្ធិ (ម្ចាស់អាជីវកម្ម ឬអ្នកគ្រប់គ្រងចាស់ដែលត្រូវប្តូរ)

៣. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ (អ្នកឈរឈ្មោះស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ឬអ្នកគ្រប់គ្រងថ្មី)។

ខ. ករណីទីតាំងអាជីវកម្មបៀរហ្គាឌិនស្ថិតនៅក្នុងទីតាំងផ្សារទំនើប អគារពាណិជ្ជកម្ម ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិនថ្មី ឬបន្តអាចបំពេញជំនួសលិខិតអនុញ្ញាតទីតាំងប្រកបអាជីវកម្ម ដោយកិច្ចសន្យាជួលទីតាំងពីម្ចាស់ផ្សារទំនើប ឬអគារពាណិជ្ជកម្មដែលអាជីវកម្មបៀរហ្គាឌិនតាំងនៅ។

គ. ករណីប្តូរឈ្មោះអាជីវកម្ម អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន ត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទ ដូចមានចែងក្នុងប្រការ៧ ប្រការ៨ និងប្រការ៩ នូវ៖

១. វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ឈ្មោះថ្មី) ដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត។

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន (ថ្មី និងបន្ត) គ្រប់ថ្នាក់អាចនឹងត្រូវបានជំនួសដោយឯកសារ ដោយឡែកដែលមានតម្លៃស្មើ យោងតាមការកំណត់របស់បទដ្ឋានខ្ពស់ជាង។

ប្រការ ១១._

តម្លៃសេវាសាធារណៈអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិនថ្មី និងបន្តត្រូវបានកំណត់ដូចតទៅ៖

ក. តម្លៃអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិនត្រូវបង់៖

| | | | |
|---|---|---|---|
| ១. ចំណុះត្រឹម | ៥០នាក់ | ត្រូវបង់ | ៦០០,០០០ (ប្រាំមួយរយពាន់) រៀល |
| ២. ចំណុះពី | ៥១ ដល់ ១០០នាក់ | ត្រូវបង់ | ៨០០,០០០ (ប្រាំបីរយពាន់) រៀល |
| ៣. ចំណុះពី | ១០១ ដល់ ២០០នាក់ | ត្រូវបង់ | ១,១០០,០០០ (មួយលានមួយរយពាន់) រៀល |
| ៤. ចំណុះពី | ២០១ ដល់ ៣០០ នាក់ | ត្រូវបង់ | ១,៣០០,០០០ (មួយលានបីរយពាន់) រៀល |
| ៥. ចំណុះពី | ៣០១នាក់ ឡើងទៅ | ត្រូវបង់ | ២,០០០,០០០ (ពីរលានរៀល)។ |

ខ. តម្លៃសេវាសាធារណៈសម្រាប់ការប្តូរម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មបៀរហ្គាឌិន ត្រូវបង់៣០% នៃតម្លៃអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន ដូចមានកំណត់ក្នុងចំណុច "ក" នៃប្រការនេះ។

ប្រការ ១២._

អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន មានសុពលភាពរយៈពេល០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍។

## ជំពូកទី ៤
## ការប្រតិបត្តិអាជីវកម្ម

ប្រការ ១៣._

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មបៀរហ្គាឌិនបានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រការ ១៤._

ប្រតិបត្តិករទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន ត្រូវមានកាតព្វកិច្ចគោរពតាមច្បាប់និងបទប្បញ្ញត្តិនានាព្រមទាំងក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈអាជីវកម្មបៀរហ្គាឌិន។

ប្រការ ១៥._

អនីតិជនអាចចូលទៅកម្សាន្តក្នុងបរិវេណទីតាំងអាជីវកម្មបៀរហ្គាឌិនបាន លុះត្រាតែមានឪពុកម្តាយឬអាណាព្យាបាលទៅជាមួយ និងដោយមានការធានាអះអាងត្រឹមត្រូវ។

ប្រការ ១៦._

អ្នកគ្រប់គ្រង និងម្ចាស់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាឌិន ត្រូវធ្វើបញ្ជីត្រួតពិនិត្យអត្តសញ្ញាណបណ្ណអតិថិជនវ័យក្មេងទាំងអស់ ដើម្បីធានាឲ្យមានការប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន។

## ជំពូកទី ៥
## អធិការកិច្ច

ប្រការ ១៧._

ក្រសួងទេសចរណ៍ត្រូវដឹកនាំការងារអធិការកិច្ចដោយចាត់តាំងមន្ត្រីជំនាញចុះត្រួតពិនិត្យសកម្មភាពអាជីវកម្មបៀរហ្គាឌិននៅក្នុងរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការធ្វើអធិការកិច្ចក្រសួងទេសចរណ៍អាចសហការ និងសម្របសម្រួលជាមួយមន្ត្រីនៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។

១៧៦ ១៦៨

ក្នុងករណីមានការប្រព្រឹត្តបទល្មើសចាប់ពីបទមជ្ឈិមជាក់ស្តែងឡើងទៅរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តនីតិវិធីច្បាប់ដើម្បីផ្អាកសកម្មភាពអាជីវកម្មបណ្តោះសន្ទជាបន្ទាន់និងត្រូវសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងទេសចរណ៍ដើម្បីបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

ប្រការ ១៨._

បុគ្គលណាដែលធ្វើអាជីវកម្មបៀរហ្គាខិនដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា ៦៥ នៃច្បាប់ស្តីពីទេសចរណ៍។ ទំហំទឹកប្រាក់ នៃការពិន័យអន្តរការណ៍សម្រាប់អាជីវកម្មបៀរហ្គាខិន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋ មន្ត្រីក្រសួងទេសចរណ៍ ។

ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាខិន ឬឯកសារសាធារណៈផ្សេងៗត្រូវផ្តន្ទាទោសតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

ប្រការ ១៩._

អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មបៀរហ្គាខិនដែលចេញដោយក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិកន្លងមកដែលនៅមានសុពលភាពត្រូវនៅបន្តអនុវត្តរហូតដល់អស់សុពលភាព។

ប្រតិបត្តិករទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មបៀរហ្គាខិនបន្តទៀត ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេស-ចរណ៍ប្រកបអាជីវកម្មបៀរហ្គាខិនស្របតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍និងប្រកាសនេះ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

ប្រការ ២០._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ២១._

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកដ្ឋាននិងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធាននាយកដ្ឋានពាក់ពន្ធ័នៃក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថោង ខុន

<u>កន្លែងទទួល</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត "ដើម្បីជូនជ្រាប"
- ដូចប្រការ ២១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ១៧៦ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៨

# ប្រកាស
## ស្តីពី
## ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មរង្គសាល និងឌីស្កូតែក
## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- យោងតាមតម្រូវការចាំបាច់នៃការងារ

**សម្រេច**



E-mail: admin@mot.gov.kh Website: www.mot.gov.kh

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.**_

ប្រកាសនេះមានគោលដៅកំណត់វិធាន និងយន្តការគ្រប់គ្រងអាជីវកម្មរង្គសាល និងឌីស្កូតែកដែលបម្រើឱ្យវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.**_

ប្រកាសនេះ មានគោលបំណងដូចតទៅ ៖

- ពង្រឹងការគ្រប់គ្រងអាជីវកម្មរង្គសាល និងឌីស្កូតែកឱ្យកាន់តែមានប្រសិទ្ធភាព និងធានាបាននូវគុណភាពសេវាកម្មទេសចរណ៍
- ចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍រក្សាបាននូវសណ្តាប់ធ្នាប់សុវត្ថិភាពព្រមទាំងធានាដល់ការថែរក្សាវប្បធម៌ ប្រពៃណី និងសេចក្តីថ្លៃថ្នូររបស់ជាតិ ។

**ប្រការ ៣.**_

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចតទៅ ៖

**អាជីវកម្មរង្គសាល** សំដៅដល់អាជីវកម្មនៅក្នុងអាគារដោយមានការប្រគុំតន្ត្រី និងច្រៀងសម្រាប់ភ្ញៀវកំសាន្ត ព្រមទាំងមានការផ្តល់សេវាភេសជ្ជៈ និងម្ហូបអាហារបន្ទាប់បន្សំ។

**អាជីវកម្មឌីស្កូតែក** សំដៅដល់អាជីវកម្មក្នុងអាគារដោយមានប្រើប្រាស់ឧបករណ៍ចាក់បទភ្លេងច្រៀងសម្រាប់ភ្ញៀវរាំកម្សាន្ត ព្រមទាំងមានការផ្តល់សេវាភេសជ្ជៈ និងម្ហូបអាហារបន្ទាប់បន្សំ។

## ជំពូកទី ២
## ការកំណត់ប្រភេទ ទីតាំង និងពេលវេលា

**ប្រការ ៤.**_

ទីតាំងអាជីវកម្មរង្គសាល និងឌីស្កូតែកត្រូវបានអនុញ្ញាតដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ការកំណត់ទីតាំងអាជីវកម្មរង្គសាល និងឌីស្កូតែកត្រូវស្ថិតនៅទីតាំងសមរម្យ និងសមស្របតាមប្រភេទអាជីវកម្មនីមួយៗផ្អែកលើលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានចម្ងាយយ៉ាងតិច ២០០ (ពីររយ)ម៉ែត្រពីបរិវេណក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូតមន្ទីរពេទ្យ សាលារៀន វត្តអារ៉ាម ប្រាង្គប្រាសាទ ទីតាំងបេតិកភណ្ឌវប្បធម៌
- មិនបង្កការរំខានដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ ស្ថានទូត មន្ទីរពេទ្យ សាលារៀន វត្តអារ៉ាម និងការរស់នៅរបស់ប្រជាពលរដ្ឋ
- ធានារក្សាសន្តិសុខ សុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឱ្យបានល្អ ។

**ប្រការ ៥.**_

អាជីវកម្មរង្គសាល និងឌីស្កូតែកត្រូវកំណត់ជាគោលការណ៍នូវពេលវេលាដំណើរការអាជីវកម្មចាប់ពីម៉ោង១៨ :០០នាទីដល់ម៉ោង ២៤:០០នាទី។

ការកំណត់ពេលវេលាដំណើរការអាជីវកម្មហួសពីម៉ោង២៤:០០នាទីត្រូវបានអនុញ្ញាតចំពោះតែតំបន់អភិវឌ្ឍន៍ និងគោលដៅទេសចរណ៍សំខាន់ៗ និងត្រូវកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

# ជំពូកទី ៣
## សមត្ថកិច្ចគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍

ប្រការ ៦._

ក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចក្នុងការគ្រប់គ្រងការត្រួតពិនិត្យ និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក

ការធ្វើប្រតិភូកម្មអំណាច ក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ប្រការ ៧._

ក.ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅថ្នាក់ជាតិ ចេញដោយក្រសួងទេសចរណ៍៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅក្រសួងទេសចរណ៍ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. លិខិតអនុញ្ញាតទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
២. វិញ្ញាបនបត្រឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
៣. លិខិតបញ្ជាក់ពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យចេញដោយការិយាល័យអគ្គីភ័យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
៤. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
៥. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
៦. អ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រក្រិតឧត្តមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាប័ត្រ សមមូល (ឬខ្ពស់ជាងនេះ) ។
៧. បុគ្គលិកបម្រើការត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច ៣០ %នៃចំនួនបុគ្គលិកសរុប)
៨. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក
៩. បង្កាន់ដៃបង់ប្រាក់

ខ.ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅថ្នាក់ជាតិ (ចេញដោយក្រសួងទេស ចរណ៍)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅក្រសួងទេសចរណ៍ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. លិខិតអនុញ្ញាតទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
២. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម ឬទុតិយតាត្រាក្រហម
៣. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
៤. បណ្ណពន្ធប៉ាតង់
៥. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
៦. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក
៧. បង្កាន់ដៃបង់ប្រាក់ ។

ប្រការ ៨._

ក.ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅថ្នាក់ក្រោមជាតិ (ចេញដោយសាលារាជធានី ខេត្ត)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. លិខិតបញ្ជាក់ទីតាំងប្រកបអាជីវកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ

២. វិញ្ញាបនបត្រឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត

៣. លិខិតបញ្ជាក់ពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យចេញដោយការិយាល័យអគ្គីភ័យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

៤. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ

៥. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៦. អ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រកំរិតឧត្តមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាប័ត្រ សមមូល (ឬខ្ពស់ជាងនេះ)។

៧. បុគ្គលិកបម្រើការត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច ៣០%នៃចំនួនបុគ្គលិកសរុប)

៨. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៩. បង្កាន់ដៃបង់ប្រាក់

ខ.ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅថ្នាក់ក្រោមជាតិ (ចេញដោយសាលារាជធានី ខេត្ត)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម ឬទុតិយតាត្រាក្រហម

២. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ

៣. បណ្ណពន្ធប៉ាតង់

៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ

៥. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក

៦. បង្កាន់ដៃបង់ប្រាក់ ។

ប្រការ ៩._

ក.ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅថ្នាក់ក្រោមជាតិ (ចេញដោយ សាលាក្រុង ស្រុក ខណ្ឌ)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. វិញ្ញាបនបត្រឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្ម រាជធានី ខេត្ត
២. លិខិតបញ្ជាក់ពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យចេញដោយការិយាល័យអគ្គីភ័យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
៣. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
៥. អ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រកំរិតឧត្តមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាប័ត្រ សមមូល (ឬខ្ពង់ជាងនេះ)។
៦. បុគ្គលិកបម្រើការត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច ៣០%នៃចំនួនបុគ្គលិកសរុប)
៧. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក
៨. បង្កាន់ដៃបង់ប្រាក់

ឌ.ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកនៅថ្នាក់ក្រោមជាតិ (ចេញដោយ សាលាក្រុង ស្រុក ខណ្ឌ)៖

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) និងត្រូវបំពេញសំណុំបែបបទរួមទាំងព័ត៌មាន ឯកសារសំអាងផ្សេងៗទៀតដូចខាងក្រោម៖

១. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម ឬទុតិយតាត្រាក្រហម
២. កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
៣. បណ្ណពន្ធប៉ាតង់
៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
៥. រូបថតអ្នកគ្រប់គ្រង (៤x៦) ចំនួន ០៣ សន្លឹក
៦. បង្កាន់ដៃបង់ប្រាក់ ។

**ប្រការ ១០._**

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក (ថ្មី និងបន្ត) គ្រប់ថ្នាក់នឹងត្រូវបានកែសម្រួល និងបន្ថែមក្នុងករណីដូចខាងក្រោម ៖

ក. ករណីមានការផ្ទេរសិទ្ធិឈរឈ្មោះ ឬប្តូរអ្នកគ្រប់គ្រង អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកដែលជាអ្នកទទួលសិទ្ធិឈរឈ្មោះ ឬអ្នកទទួលគ្រប់គ្រងនោះត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទ ដូចមានចែងក្នុងប្រការ៧ ប្រការ៨ និងប្រការ៩ ដូចខាងក្រោម៖

១. លិខិតប្រគល់សិទ្ធិ
២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកផ្ទេរសិទ្ធិ (ម្ចាស់អាជីវកម្ម ឬអ្នកគ្រប់គ្រងចាស់ដែលត្រូវប្តូរ)
៣. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ (អ្នកឈរឈ្មោះស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ឬអ្នកគ្រប់គ្រងថ្មី)។

ខ. ករណីទីតាំងអាជីវកម្មវង្គសាល និងឌីស្កូតែក ស្ថិតនៅក្នុងទីតាំងផ្សារទំនើប អគារពាណិជ្ជកម្ម ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកថ្មី ឬបន្តអាចបំពេញជំនួសលិខិតអនុញ្ញាតទីតាំងប្រកបអាជីវកម្ម ដោយកិច្ចសន្យាជួលទីតាំងពីម្ចាស់ផ្សារទំនើប ឬអគារពាណិជ្ជកម្មដែលអាជីវកម្មវង្គសាល និងឌីស្កូតែក តាំងនៅ។

គ. ករណីប្តូរឈ្មោះអាជីវកម្ម អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក ត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទ ដូចមានចែងក្នុងប្រការ៧ ប្រការ៨ និងប្រការ៩ នូវ៖

១. វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ឈ្មោះថ្មី) ដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត។

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក (ថ្មី និងបន្ត) គ្រប់ថ្នាក់អាចនឹងត្រូវ បានជំនួសដោយឯកសារ ដោយឡែកដែលមានតម្លៃស្មើ យោងតាមការកំណត់របស់បទដ្ឋានខ្ពស់ជាង។

ប្រការ ១១._

កម្រៃសេវាសាធារណៈអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកថ្មី និងបន្តត្រូវបានកំណត់ដូចតទៅ៖

ក. កម្រៃអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែកត្រូវបង់៖

| | | | |
|---|---|---|---|
| ១. ចំណុះត្រឹម | ៥០នាក់ | ត្រូវបង់ | ៨០០,០០០ (ប្រាំបីរយពាន់) រៀល |
| ២. ចំណុះពី | ៥១ ដល់ ១០០នាក់ | ត្រូវបង់ | ១,២០០,០០០ (មួយលានពីររយពាន់) រៀល |
| ៣. ចំណុះពី | ១០១ ដល់ ១៥០នាក់ | ត្រូវបង់ | ២,០០០,០០០ (ពីរលាន) រៀល |
| ៤. ចំណុះពី | ១៥១ ដល់ ២០០ នាក់ | ត្រូវបង់ | ៤,០០០,០០០ (បួនលាន) រៀល |
| ៥. ចំណុះពី | ២០១ នាក់ ឡើងទៅ | ត្រូវបង់ | ៦,០០០,០០០ (ប្រាំមួយលាន) រៀល។ |

ខ. កម្រៃសេវាសាធារណៈសម្រាប់ការប្តូរម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មវង្គសាល និងឌីស្កូតែក ត្រូវបង់៣០% នៃកម្រៃអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក ដូចមានកំណត់ ក្នុងចំណុច "ក" នៃប្រការនេះ។

ប្រការ ១២._

អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក មានសុពលភាពអប្បបរមារយៈពេល០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញ អាជ្ញាបណ្ណទេសចរណ៍ ។

## ជំពូកទី ៤
## ការប្រតិបត្តិអាជីវកម្ម

ប្រការ ១៣._

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក បានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលអាជ្ញាបណ្ណទេសចរណ៍ពីក្រសួង ទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រការ ១៤._

ប្រតិបត្តិករទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក ត្រូវមានកាតព្វកិច្ចគោរពតាមតាមច្បាប់និងបទប្បញ្ញត្តិនានា ព្រមទាំងក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈអាជីវកម្មវង្គសាល និងឌីស្កូតែក។

ប្រការ ១៥._

អនីតិជនមិនត្រូវបានអនុញ្ញាតឱ្យចូលទៅកម្សាន្តក្នុងបរិវេណទីតាំងអាជីវកម្មវង្គសាល និងឌីស្កូតែកឡើយ។

ប្រការ ១៦._

អ្នកគ្រប់គ្រង និងម្ចាស់អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក ត្រូវធ្វើបញ្ជរត្រួតពិនិត្យអត្តសញ្ញាណបណ្ណអតិថិជនវ័យក្មេងទាំងអស់ ដើម្បីធានាឲ្យមានការប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន។

# ជំពូកទី ៥
# អធិការកិច្ច

**ប្រការ ១៧.-**

ក្រសួងទេសចរណ៍ត្រូវដឹកនាំការងារអធិការកិច្ចដោយចាត់តាំងមន្ត្រីជំនាញចុះត្រួតពិនិត្យសកម្មភាពអាជីវកម្មវង្គសាល និងឌីស្កូតែក នៅក្នុងរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការធ្វើអធិការកិច្ចក្រសួងទេសចរណ៍អាចសហការ និងសម្របសម្រួលជាមួយមន្ត្រីនៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងករណីមានការប្រព្រឹត្តបទល្មើសចាប់ពីបទមជ្ឈិមជាក់ស្តែងឡើងទៅរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តនីតិវិធីច្បាប់ដើម្បីផ្អាកសកម្មភាពអាជីវកម្មបណ្តោះអាសន្នជាបន្ទាន់និងត្រូវសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងទេសចរណ៍ដើម្បីបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

# ជំពូកទី ៦
# ទោសប្បញ្ញត្តិ

**ប្រការ ១៨.-**

បុគ្គលណាដែលធ្វើអាជីវកម្មវង្គសាល និងឌីស្កូតែក ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា ៦៥ នៃច្បាប់ស្តីពីទេសចរណ៍។ ទំហំទឹកប្រាក់ នៃការពិន័យអន្តរការណ៍សម្រាប់អាជីវកម្មវង្គសាល និងឌីស្កូតែកត្រូវកំណត់ដោយប្រកាសរបស់រដ្ឋ មន្ត្រីក្រសួងទេសចរណ៍ ។

ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក ឬឯកសារសាធារណៈផ្សេងៗត្រូវផ្តន្ទាទោសតាម ច្បាប់និងបទប្បញ្ញត្តិជាធរមាន។

# ជំពូកទី ៧
# អន្តរប្បញ្ញត្តិ

**ប្រការ ១៩.-**

អាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក ដែលចេញដោយក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិកន្លងមកដែលនៅមានសុពលភាពត្រូវនៅបន្តអនុវត្តរហូតដល់អស់សុពលភាព។

ប្រតិបត្តិករទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក បន្តទៀតត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មវង្គសាល និងឌីស្កូតែក ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍និងប្រកាសនេះ។

# ជំពូកទី ៨
# អវសានប្បញ្ញត្តិ

**ប្រការ ២០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២១._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកដ្ឋាននិងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិកា ប្រធានក្រុមអ្នកច្បាប់ ប្រធាននាយកដ្ឋានពាក់ព័ន្ធនៃក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**<u>កន្លែងទទួល</u>**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលារាជធានី ខេត្ត "ដើម្បីជូនជ្រាប"
-ដូចប្រការ ២១ "ដើម្បីមុខការ"
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder

ក្រសួងទេសចរណ៍
លេខ ០៦២ ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០៥ ៧

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍
# ដល់អាជីវកម្មរមណីយដ្ឋានទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក. ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសំរួលមុខងារ និង ភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- យោងសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍ ។

៣៤

# សម្រេច

**ប្រការ ១ :** អាជីវកម្មរមណីយដ្ឋានទេសចរណ៍ គឺជាការប្រកបអាជីវកម្មសេវាកម្មទេសចរណ៍មួយ លើតំបន់ទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានជ្រើសរើសរៀបចំគ្រប់គ្រង និងធ្វើការអភិវឌ្ឍ ដើម្បីបំរើអោយទេសចរជាតិ និងអន្តរជាតិ សំរាប់សំរាកលំហែ បំប៉នសុខភាព កំសាន្តសប្បាយរីករាយ និងការស្វែងយល់ពី ធម្មជាតិ ប្រពៃណី ទំនៀមទំលាប់ សាសនារបស់ជាតិសាសន៍នីមួយៗក្នុងតំបន់ និងទូទាំងប្រទេស ព្រមទាំងផ្តល់សេវាកម្មទេសចរណ៍ផ្សេងៗទៀត ។ រមណីដ្ឋានទេសចរណ៍រួមមាន : រមណីយដ្ឋានវប្បធម៌-ប្រវត្តិ សាស្ត្រ រមណីយដ្ឋានធម្មជាតិ និងឆ្នេរ និងរមណីយដ្ឋានកែច្នៃ ។

**ប្រការ ២ :** ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍អោយប្រកបអាជីវកម្មរមណីយដ្ឋាន ការផ្អាក ការដកហូតបិទអាជីវកម្ម គឺជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។

**ប្រការ៣ :** ការរៀបចំសុំអាជ្ញាប័ណ្ណទេសចរណ៍រមណីយដ្ឋានបែបវប្បធម៌ប្រវត្តិសាស្ត្រ ធម្មជាតិ និងឆ្នេរ និងរមណីយដ្ឋាន កែច្នៃ ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងដោយ អនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងត្រូវភ្ជាប់ មកជាមួយនូវឯកសារចាំបាច់មួយចំនួន :

ក- លិខិតអនុញ្ញាតិដាក់ទីតាំងធ្វើអាជីវកម្ម ចេញដោយអាជ្ញាធរ ដែនដី

ខ- លិខិតបញ្ជាក់ពីការយល់ព្រមរបស់ :

- ក្រសួងបរិស្ថាន ចំពោះរមណីយដ្ឋានធម្មជាតិ
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចំពោះរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ
- លិខិតអនុញ្ញាតសាងសង់ ជួសជុល ចេញដោយក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ ចំពោះរមណីយដ្ឋាន កែច្នៃ

គ- របាយការណ៍សេដ្ឋកិច្ចបច្ចេកទេសនៃការងារអាជីវកម្ម និងគំរោងអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍

ឃ-សញ្ញាប័ត្រ ឬវិញ្ញាបនប័ត្ររបស់អ្នកគ្រប់គ្រង ដែលបញ្ជាក់ការសិក្សាលើ មុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍

ង- វិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ច- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

ឆ- វិញ្ញាបនប័ត្រធានារ៉ាប់រងអំពីភារៈទទួលខុសត្រូវសារធារណៈ

ជ- លិខិតបញ្ជាក់លើប្រព័ន្ធការពារសុខភាព សុវត្ថិភាព និងអគ្គីភ័យ ចេញដោយក្រសួងមហាផ្ទៃ ឬ ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង

ឈ-លិខិតយល់ព្រមជាលាយលក្ខ័អក្សររបស់ម្ចាស់អាជីវកម្ម

**ប្រការ ៤ :** អាជ្ញាប័ណ្ណទេសចរណ៍ ត្រូវបានចេញអោយ ប្រើប្រាស់ក្រោយពីអាជីវករបានបំពេញសំណុំឯកសារ ក្នុងការ ដាក់ពាក្យសុំធ្វើអាជីវកម្មគ្រប់គ្រាន់និងត្រឹមត្រូវយ៉ាងយូរ ក្នុងរយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដាក់ពាក្យ ។ ក្នុងករណីដែលក្រសួងបដិសេធមិនផ្តល់ ឬមិនបន្តអាជ្ញាប័ណ្ណទេសចរណ៍ ក្រសួងនឹងបញ្ជាក់ហេតុផលជាលាយលក្ខ័អក្សរជូន ដល់អាជីវករមិនលើសពី១០ថ្ងៃ គិតពីថ្ងៃបានទទួពាក្យ ។

**ប្រការ ៥ :** នៅពេលអ្នកស្នើសុំធ្វើអាជ្ញាប័ណ្ណ បានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវទៅតាមបែបបទ ដូចមានកំណត់ ក្នុងប្រការ៣ ក្រសួងនឹងចេញអាជ្ញាប័ណ្ណទេសចរណ៍សំរាប់ធ្វើអាជីវកម្ម ដែលមានសុពលភាពរយៈពេញ១ឆ្នាំ ។ ក្នុងករណីអាជីវករមិនអាចបំពេញ បែបបទអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលានោះអាចស្នើសុំដោយធ្វើកិច្ច សន្យាជំពាក់ឯកសារជាបណ្តោះអាសន្ន និងធានាបំពេញក្នុងរយៈពេល ០៣ខែ ។ ស្ថិតក្នុងករណីនេះក្រសួងទេសចរណ៍នឹងចេញអាជ្ញាប័ណ្ណទេសចរណ៍ សំរាប់ធ្វើអាជីវកម្ម ជាបណ្តោះអាសន្ន និងមានសុពលភាពរយៈ ពេល ០៣ខែ ។ បន្ទាប់ពី បានបំពេញឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមកិច្ចសន្យានោះក្រសួងទេសចរណ៍នឹង ផ្តល់អាជ្ញាប័ណ្ណដែលមានសុពលភាព ០១ឆ្នាំជូនដល់អាជីវករ ។

**ប្រការ៦ :** អាជ្ញាប័ណ្ណទេសចរណ៍ មានសុពលភាពប្រើប្រាស់សំរាប់រយៈពេល ០១ឆ្នាំគិតចាប់ ពីថ្ងៃចេញច្បាប់អនុញ្ញាត ។ មុនផុតកំណត់សុពលភាពអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវដាក់ពាក្យសុំបន្តដោយភ្ជាប់ជាមួយនូវអាជ្ញាប័ណ្ណចាស់ និងប័ណ្ណពន្ធប៉ាតង់អោយបាន ០១ ខែ មុនថ្ងៃផុតកំណត់ ។ ក្នុងរយៈពេលដែលបានដាក់ពាក្យសុំបន្ត អាជ្ញាប័ណ្ណទេសចរណ៍ អាជីវករនៅតែមានសិទ្ធិធ្វើអាជីវកម្មរហូតដល់ថ្ងៃដែលក្រសួងពិនិត្យសំរេចលើលក្ខណៈសម្បត្តិក្នុងការផ្តល់អាជ្ញាប័ណ្ណបន្តអាជីវកម្ម ។

**ប្រការ៧** : ពេលមានការ ផ្ទេរ ដូល បិទអាជីវកម្ម ឬប្តូរឈ្មោះអ្នកគ្រប់គ្រងអាជីវកម្ម ត្រូវដាក់ពាក្យសុំមក ក្រសួងទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍ រាជធានី-ខេត្តអោយបានមុន ០៣ ខែ។

**ប្រការ៨** : ការបង់ប្រាក់សុំអាជ្ញាប័ណ្ណទេសចរណ៍ដើម្បីសុំបើកអាជីវកម្មរមណីយដ្ឋានទេសចរណ៍ ដំបូង ត្រូវបានកំណត់ :

- រមណីយដ្ឋានថ្នាក់ជាតិ : ជារមណីយដ្ឋានដែលមានវិសាលភាពធំទូលំទូលាយនិងវិនិយោគទុនធ្វើអាជីវកម្ម មានទឹកប្រាក់លើសពី ២.០០០.០០០ ដុល្លារ (ពីរលានដុល្លារអាមេរិក) ត្រូវបង់ប្រាក់ ៨.០០០.០០០ រៀល (ប្រាំបីលានរៀល) ។
- រមណីយដ្ឋានថ្នាក់ខេត្ត : ជារមណីយដ្ឋានដែលមានទ្រង់ទ្រាយមធ្យម និងវិនិយោគ ទុនធ្វើអាជីវកម្ម មានទឹកប្រាក់តិចជាង ២.០០០.០០០ ដុល្លារ (ពីរលាន ដុល្លារអាមេរិក) ត្រូវបង់ប្រាក់ ៤.០០០.០០០ រៀល (បួនលានរៀល) ។
- រមណីយដ្ឋានថ្នាក់ស្រុក : ជារមណីយដ្ឋានដែលទេសចរត្រូវការសំរាកលំហែ កំសាន្ត តាមទំនប់ទឹក មាត់ទន្លេ សមុទ្រ ស្ទឹង បឹង ព្រៃក ទឹកធ្លាក់ ត្រូវបង់ប្រាក់ ចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) ។
- រមណីយដ្ឋានកែច្នៃ : ជារមណីយដ្ឋានដែលរៀបចំបង្កើតឡើងដោយគំនិតច្នៃ ប្រឌិត ដោយបុគ្គលផ្ទាល់ ឬវិនិយោគិន ត្រូវបង់ប្រាក់ ១.០០០.០០០ រៀល (មួយលានរៀល) ។
- សេវាកម្មសហគមន៍ទេសចរណ៍មូលដ្ឋានត្រូវបានលើកទឹកចិត្តដោយលើកលែង ថ្លៃបង់អាជ្ញាប័ណ្ណទេសចរណ៍ តែត្រូវចុះបញ្ជីអាជីវកម្ម។
- ចំពោះការបង់ប្រាក់សុំបន្តអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវបង់ ៥០% នៃទឹកប្រាក់ ដែលបានកំណត់ខាងលើ ។
- ការ ផ្ទេរ ផ្លាស់ប្តូរ អ្នកគ្រប់គ្រង ឬផ្លាស់ប្តូរឈ្មោះអាជីវកម្ម ត្រូវបង់ប្រាក់ ១០០.០០០រៀល (មួយសែនរៀល) ។
- ក្នុងករណីរមណីយដ្ឋានទេសចរណ៍មានប្រកបអាជីវកម្ម សណ្ឋាគារ ផ្ទះភ្ញៀវ ភោជនីយដ្ឋាន កីឡា ទេសចរណ៍ ក្លឹបកំសាន្ត ឬប្រភេទអាជីវកម្មទេសចរណ៍ ផ្សេងៗទៀត ម្ចាស់អាជីវកម្មត្រូវបង់ប្រាក់សុំ

អាជ្ញាប័ណ្ណទេសចរណ៍ ទៅតាមប្រភេទ អាជីវកម្មទាំងនោះ តែត្រូវបាន បញ្ចុះថ្លៃ ៥០% ដោយគិតតាម ប្រកាសស្តីពី ការផ្តល់អាជ្ញា ប័ណ្ណ អាជីវកម្ម សេវាកម្មទេសចរណ៍ របស់ក្រសួងទេសចរណ៍ ។

**ប្រការ ៩ :** ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មត្រូវដាក់ពាក្យសុំដំបូង ឬបន្តអាជ្ញាប័ណ្ណព្រមទាំងទទួលយកអាជ្ញាប័ណ្ណ ទេសចរណ៍នៅមន្ទីរទេសចរណ៍រាជធានី-ខេត្ត ។

- អាជ្ញាប័ណ្ណទេសចរណ៍ដែលត្រួតពិនិត្យ និងសំរេចដោយមន្ទីរទេសចរណ៍ រាជធានី-ខេត្ត ត្រូវកំណត់១២ថ្ងៃ នៃថ្ងៃធ្វើការ ។
- ចំពោះអាជ្ញាប័ណ្ណដែលត្រូវត្រួតពិនិត្យ និងសំរេដោយក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ត្រូវទទួល ពាក្យសុំ និងចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម ហើយ បញ្ជូនមកក្រសួងទេសចរណ៍ក្នុងរយៈពេល ០៥ ថ្ងៃនៃថ្ងៃធ្វើការ ។ ក្រសួងទេសចរណ៍ (នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌) ត្រូវទទួល និងត្រួតពិនិត្យពាក្យសុំនេះហើយស្នើសុំការសំរេចចេញអាជ្ញាប័ណ្ណ ទេសចរណ៍ ក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃ ធ្វើការ ។ ករណីចាំបាច់ ក្រសួងទេសចរណ៍អាចចុះ ត្រួតពិនិត្យឡើងវិញលើមូលដ្ឋានអាជីវកម្ម នោះ ក្នុង រយៈពេល ០៥ថ្ងៃ នៃថ្ងៃ ធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួល ពាក្យសុំ ។ ក្រសួងទេសចរណ៍នឹងបញ្ជូនអាជ្ញាប័ណ្ណទេសចរណ៍ដែលរួច ជាស្ថាពរ ទៅមន្ទីរទេសចរណ៍ ក្នុងរយៈពេល ០៣ថ្ងៃ ។

**ប្រការ១០ :** អាជីវករដែលទទួលបានអាជ្ញាប័ណ្ណទេសចរណ៍ត្រូវប្រើប្រាស់អាជ្ញាប័ណ្ណនេះ អោយបាន ត្រឹមត្រូវ និងត្រូវគោរព អនុវត្តតាមការណែនាំ និងបទបញ្ញត្តិរបស់ ក្រសួងទេសចរណ៍ ។

- ករណីមានការខូចខាត ឬបាត់បង់អាជ្ញាប័ណ្ណទេសចរណ៍ អាជីវករត្រូវធ្វើ លិខិតជាលាយល័ក្ខអក្សរបញ្ជាក់ អំពីមូលហេតុច្បាស់លាស់ និងមានការ បញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ បណ្តោះ អាសន្នឡើងវិញក្នុងរយៈពេល ៣០ថ្ងៃគិតពីថ្ងៃដែលខូចខាត ឬបាត់បង់ ។

**ប្រការ១១ :** ក្នុងករណីធ្វើអាជីវកម្មដោយ :

ក- ប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ឬអនុវត្តមិនបានត្រឹមត្រូវ តាមការណែនាំរបស់ក្រសួងទេសចរណ៍ អាជីវករ នឹងត្រូវទទួល នូវការផាកពិន័យ មានចំនួនទឹកប្រាក់ ២០០% (ពីររយភាគរយ)

នៃថ្លៃបង់ ប្រសិនបើអាជីវករ មិនអនុវត្តលើការផាកពិន័យនេះក្នុងរយៈពេល ០៣ខែ ក្រសួងទេសចរណ៍ នឹងផ្អាកការធ្វើ អាជីវកម្ម ឬដកហូតអាជ្ញាប័ណ្ណទេសចរណ៍ បិទអាជីវកម្ម ។

ខ- គ្មានអាជ្ញាប័ណ្ណទេសចរណ៍ នឹងត្រូវទទួលការព្រមានជាលាយល័ក្ខអក្សរ និងបិទអាជីវកម្ម ។

គ- រកឃើញថាអាជីវករបានផ្តល់ព័ត៌មានមិនពិត ឬប្រឌិតឯកសារពាក់ព័ន្ធ និងពាក្យសុំធ្វើអាជីវកម្ម ក្រសួង ទេសចរណ៍មានសិទ្ធ ផ្អាក ឬដកអាជ្ញាប័ណ្ណ ទេសចរណ៍ បិទអាជីវកម្ម ។

ឃ- អាជីវករប្រព្រឹត្តល្មើសនឹងច្បាប់បញ្ញត្តិទាំងឡាយរបស់រដ្ឋ នឹងត្រូវដកហូតអាជ្ញាប័ណ្ណ បិទអាជីវកម្មព្រមទាំងត្រូវទទួលទោសតាមច្បាប់រដ្ឋជាធរមាន ។

**ប្រការ ១២:** នៅពេលមូលដ្ឋានអាជីវកម្មត្រូវបានទទួលការផ្អាក ឬដកហូតអាជ្ញាប័ណ្ណទេសចរណ៍ ក្រសួងទេសចរណ៍ នឹងចេញសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរផ្ញើដល់ម្ចាស់ ឬអ្នកគ្រប់គ្រងដើម្បីទទួលប្រតិបត្តិតាម ។ ក្នុងករណីសេចក្តីជូនដំណឹងមិនអាចផ្ញើបានទៅដល់ម្ចាស់ ឬអ្នកគ្រប់គ្រងប្រការណាមួយ ឬក៏សាម៉ីខ្លួនជាម្ចាស់ ឬអ្នកគ្រប់គ្រងបដិសេធមិនព្រមទទួលស្គាល់នោះ សេចក្តីជូនដំណឹង នឹងត្រូវបិទនៅមុខក្រុមហ៊ុន ឬមូលដ្ឋាន អាជីវកម្ម ហើយត្រូវផ្ញើដល់គ្រប់ក្រុមហ៊ុនទេសចរណ៍ និងសមាគមទេសចរណ៍ក្នុងស្រុក ដើម្បីទុកជាព័ត៌មាន ។

**ប្រការ១៣:** អាជ្ញាប័ណ្ណទេសចរណ៍ដែលត្រូវបានផ្អាក ឬដកហូតមានរយៈពេលកំណត់មិនលើសពី ៦ខែ ។ ក្នុងរយៈពេល ផ្អាក ឬដកហូតអាជ្ញាប័ណ្ណនេះ មូលដ្ឋានអាជីវកម្មមិនត្រូវបានអនុញ្ញាតអោយធ្វើសកម្មភាពឡើយ ។ ក្រោយពីផុតកំណត់ពេលនៃការផ្អាក ឬដកហូត ម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវធ្វើលិខិតស្នើសុំមកក្រសួងទេសចរណ៍ ដើម្បីសុំដំណើរការអាជីវកម្មឡើងវិញ ។

**ប្រការ១៤:** បុគ្គលណាមួយដែលរារាំងដល់ការងារត្រួតពិនិត្យ ឬផ្តល់អាជ្ញាប័ណ្ណក្លែងបន្លំមិនត្រឹមត្រូវផ្ទុយទៅនឹង បទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ នឹងត្រូវទទួលនូវវិធានការ រដ្ឋបាល ឬទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ១៥:** ០៣ ខែ ក្រោយពីការចុះហត្ថលេខាលើប្រការនេះ ក្រសួងទេសចរណ៍នឹងមិន

អនុញ្ញាតអោយធ្វើអាជីវកម្ម រមណីយដ្ឋានទេសចរណ៍ ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ទៀតឡើយ ។

**ប្រការ១៦:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១៧:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍

**ថោង ខុន**

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ខេត្ត-ក្រុង "ដើម្បីមុខការ"
- គ្រប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ "ដើម្បីអនុវត្តន៍"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

៤០

ក្រសួងទេសចរណ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder

រាជធានីភ្នំពេញ, ថ្ងៃទី .....ខែ....... ឆ្នាំ២០០..

ឧបសម្ព័ន្ធទី១
ស្តង់ដាររមណីយដ្ឋានទេសចរណ៍អប្បបរមា

១_លក្ខណៈពិសេសរបស់រមណីយដ្ឋាន

ក. ទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ
- សារៈសំខាន់នៃវប្បធម៌ដើម និងធនធានប្រវត្តិសាស្ត្រ
- រក្សាភាពដើម បូរណភាពរបស់រមណីយដ្ឋាន
- កំណត់បុរាណវត្ថុដែលនៅសល់ តំលៃមនុស្សជាតិ ការរស់នៅ ទំនៀមទំលាប់ ការប្រើប្រាស់ដីធ្លី ការរស់នៅបែបប្រពៃណី

ខ. ទេសចរណ៍កែច្នៃ
- ការកែច្នៃទៅតាមសក្តានុពលធម្មជាតិ
- រក្សាបុរាណវត្ថុដែលនៅសល់ តំលៃមនុស្សជាតិ ការរស់នៅ ទំនៀមទំលាប់ ការរស់នៅបែបប្រពៃណី
- កំណត់ប្លង់មេក្នុងការអភិវឌ្ឍន៍សេវាកម្មកំសាន្ត

គ. ទេសចរណ៍ធម្មជាតិ
- សារៈសំខាន់នៃប្រពន្ធ័អេកូឡូស៊ី និងលំនៅដ្ឋានធម្មជាតិ
- បរិស្ថានដែលមិនត្រូវបានបំផ្លាញ ដូចជា តំបន់ដីសើម ឬតំបន់ឆ្នេរ ។
- លក្ខណៈពិសេស និងភាពកម្រមានផ្សេងៗនៅក្នុងរមណីយដ្ឋាន

ឃ. ទេសចរណ៍វប្បធម៌ ធម្មជាតិ
- សារៈសំខាន់នៃវប្បធម៌ដើម និងធនធានប្រវត្តិសាស្ត្រ
- រក្សាភាពដើម បូរណភាពរបស់រមណីយដ្ឋាន
- កំណត់បុរាណវត្ថុដែលនៅសល់ តំលៃមនុស្សជាតិ ការរស់នៅ ទំនៀមទំលាប់ ការប្រើប្រាស់ដីធ្លី ការរស់នៅបែបប្រពៃណី

- ធម្មជាតិដែលអាចទាក់ទាញភ្ញៀវទេសចរ
- សារៈសំខាន់នៃប្រពន្ធ័ជីវចំរុះ និងលំនៅស្ថានធម្មជាតិ
- បរិស្ថានដែលមិនត្រូវបានបំផ្លាញ ដូចជា តំបន់ដីសើម ទីរហោដ្ឋាន ឬតំបន់ឆ្នេរ។

ង. កសិទេសចរណ៍
- ទេសភាពវាលស្រែ ប្រឡាយទឹកដែលអាចទាក់ទាញភ្ញៀវទេសចរ
- ធនធានជីវចំរុះ ក្នុងវាលស្រែនិងការរស់នៅបែបធម្មជាតិ និងប្រពៃណី
- ជាតំបន់ដែលមិនសូវមានលំនៅដ្ឋាន
- វប្បធម៌ សុច្ចរិតនៃការរស់នៅរបស់សហគមន៍ក្នុងតំបន់

ច. អេកូទេសចរណ៍
- ធម្មជាតិដែលអាចទាក់ទាញភ្ញៀវទេសចរ
- ធនធានជីវចំរុះ និងការរស់នៅបែបធម្មជាតិ និងប្រពៃណី
- បរិស្ថានដែលមិនត្រូវបានបំផ្លាញ ឬបរិស្ថានដែលបង្ហាញពីការវិវឌ្ឍរបស់ធម្មជាតិ (តំបន់ដីសើម ទីរហោដ្ឋាន តំបន់ឆ្នេរ សមុទ្រ កោះ ទន្លេ ទឹកធ្លាក់ ព្រៃភ្នំ ។ល។)
- ជាតំបន់ដែលមិនសូវមានលំនៅស្ថាន
- វប្បធម៌ សុច្ចរិតនៃការរស់នៅរបស់សហគមន៍ក្នុងតំបន់
- ភាពដើមនៃធនធានវប្បធម៌ និងធម្មជាតិមានក្នុងរមណីយដ្ឋាន (អេកូទេសចរណ៍នឹងមានស្តង់ដារដោយឡែកមួយ)

## ២-ការការពារនិងអភិរក្សតំបន់រមណីយដ្ឋាន

ក. ត្រូវមានការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតំលៃ ដើម្បីធ្វើឱ្យប្រាកដនូវសមត្ថភាពទ្រទ្រង់របស់ រមណីយដ្ឋាន

ខ. អនុវត្តយន្តការការពារ គ្រប់គ្រងដើម្បីកាត់បន្ថយការបំផ្លាញធនធានឱ្យនៅកំរិតទាបបំផុត

គ. រៀបចំការពារលក្ខណៈពិសេសរបស់រមណីយដ្ឋានឱ្យស្ថិតនៅក្នុងសភាពដើមរបស់វា

ឃ. អភិរក្សស្ថានភាពទីតាំង បូរាណភាពរមណីយដ្ឋាន និងលក្ខណៈដើមពិសេសដែលមានស្រាប់

ង. អភិរក្សធនធានវប្បធម៌ ប្រវត្តិសាស្ត្រ លំនៅដ្ឋានវប្បធម៌ប្រពៃណី និង ប្រព័ន្ធបរិស្ថានជីវចំរុះ ដែលមានស្រាប់

ច. កំណត់ការថែរក្សាវត្ថុបុរាណដែលនៅសេសសល់ តម្លៃមនុស្សជាតិ ការរស់នៅ ទំនៀមទំលាប់ ការប្រើប្រាស់ដីធ្លី ការរស់នៅលក្ខណៈប្រពៃណី និងពិធីបុណ្យប្រពៃណី ។

## ៣. ការគ្រប់គ្រងទេសចរណ៍ និងរមណីយដ្ឋាន

### ៣-១-តំបន់រមណីយដ្ឋាន

ក. ត្រូវមានស្លាកឈ្មោះ មុនដល់រមណីយដ្ឋានចំងាយ២០០ម៉ែត្រ និងស្លាកឈ្មោះ តំបន់រមណីយដ្ឋាន ត្រូវសរសេរអក្សរឱ្យបានធំៗច្បាស់ ជាអក្សរខ្មែរខាងលើ និងអក្សរបរទេសនៅខាងក្រោម

ខ. មានបញ្ជរលក់សំបុត្រ

គ. ចំណតយានយន្តគ្រប់ប្រភេទ

ឃ. បង្គន់អនាម័យបុរស-នារីត្រូវស្អាត និងមានការថែទាំអនាម័យដោយមិនបង់ប្រាក់

ង. រៀបចំឱ្យមានសណ្តាប់ធ្នាប់ល្អ ដោយលុបបំបាត់អ្នកសុំទាន ក្មេងបក់ផ្លិតដែលបង្កឱ្យមានការ រំខានដល់អ្នកទេសចរ

ច. រៀបចំឱ្យមានសួនច្បារពណ៌បៃតងស្រស់ក្នុងរមណីយដ្ឋាន

ឆ. គ្រប់សំណង់ទាំងអស់នៅក្នុងរមណីយដ្ឋានត្រូវសិក្សាទៅតាមរចនាបថក្នុងតំបន់ ឬរចនាបថខ្មែរ (តូបសំរាកលំហែ ត្រូវកំណត់តម្លៃនៅលើតូប)

ជ. ភោជនីយដ្ឋាន អាហារដ្ឋានមានអនាម័យស្អាត ឆ្ងាញ់ ផ្តល់សុវត្ថិភាពដល់ភ្ញៀវ ដោយមានមុខម្ហូប និងតម្លៃមុខម្ហូបត្រឹមត្រូវ

ឈ. អ្នកលក់ដូរ និងអ្នកបំរើសេវាកម្មត្រូវមានភាពរួសរាយរាក់ទាក់ និងសំលៀកបំពាក់សមរម្យ

ញ. ត្រូវមានការចូលរួមរបស់ប្រជាជនក្នុងសហគមន៍ ដើម្បីដំណើរការអភិវឌ្ឍន៍ និងការគ្រប់គ្រងទេសចរណ៍

ដ. បង្កើតឱ្យមានមុខរបរ និងលើកទឹកចិត្ត ដល់ការផលិត និងប្រើប្រាស់ផលិតផលក្នុងស្រុក

ឋ. លើកទឹកចិត្តឱ្យមានការប្រើកំលាំងពលកម្ម ចំណេះដឹង ជំនាញ និង

ប្រពៃណី ក្នុងតំបន់

ឌ. ប្រើប្រាស់នូវមធ្យោបាយផ្តល់ព័ត៌មានឱ្យបានសមស្របនៅក្នុងទីតាំងរមណីយដ្ឋាន ដើម្បីឱ្យភ្ញៀវ បានសិក្សារៀនសូត្រពីរមណីយដ្ឋាន ដូចជា:

- មណ្ឌលព័ត៌មាន ដែលមានដាក់តាំង រូបចំលាក់ រូបភាពទាក់ទងទៅនឹង ប្រពៃណី ប្រវត្តិរមណីយដ្ឋាន
- ស្លាកសញ្ញាប្រាប់ទិស ហាមឃាត់ គ្រោះថ្នាក់ ស្លាកអត្ថបទខ្លីៗពន្យល់ពី អត្ថន័យរបស់រូបភាព រូបចំលាក់ធម្មជាតិ ឬវត្ថុផ្សេងៗក្នុងរមណីយដ្ឋាន
- សៀវភៅមគ្គុទេសក៍ទេសចរណ៍ សៀវភៅផ្ទត់ ផែនទី និងអត្ថបទអត្ថាធិប្បាយ ស្តីអំពីប្រវត្តិ និងវត្ថុផ្សេងៗនៅក្នុងរមណីយដ្ឋាន
- បង្កើតព្រឹត្តិការណ៍សិល្បៈ របាំ ល្បែងប្រជាប្រិយ នៅក្នុងតំបន់រមណីយដ្ឋាន
- ត្រូវមានចងបដា ពាក្យស្លោកដែលទាក់ទងនិងសេវាកម្មទេសចរណ៍ និងការការពាររមណីយដ្ឋាន

ឍ. មានកន្លែងលក់វត្ថុអនុស្សាវរីយ៍ ជាផលិតផលក្នុងស្រុក ដូចជា សិប្បកម្ម ផ្កា ផ្លែឈើ ។ល។

ណ. មានសេវាកម្មស្នាក់នៅឱ្យបានសមរម្យ (ដូចជា សណ្ឋាគារ ម៉ូតែល ប៊ឹងកាឡូ ផ្ទះសំណាក់ បោះតង់ ជាដើម)

ត. ការិយាល័យបំរើការងាររបស់រមណីយដ្ឋាន

ថ. អាគារស្នាក់នៅរបស់បុគ្គលិកប្រចាំការ

ទ. មានសេវាកម្មមធ្យោបាយធ្វើដំណើរក្នុងរមណីយដ្ឋាន ដូចជា ជិះកង់ ម៉ូតូ រទេះសេះ គោក្របី ...ល។

ធ. ត្រូវមានមគ្គុទេសក៍ក្នុងតំបន់ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីបំរើភ្ញៀវ

ន. ពន្យល់ណែនាំភ្ញៀវពីក្រុមប្រតិបត្តិ អ្វីដែលភ្ញៀវគួរធ្វើ និងអ្វីដែលគួរចៀសវាងពេលទស្សនាក្នុង រមណីយដ្ឋាន

ប. ត្រូវមានកម្មវិធីត្រួតពិនិត្យក្នុងរមណីយដ្ឋាន ដើម្បីប៉ាន់ប្រមាណពី

ផលប៉ះពាល់ទេសចរណ៍មកលើ រមណីយដ្ឋាន។

ផ. សេវាទូរគមនាគមន៍ (ប្រព័ន្ធទូរស័ព្ទ អ៊ីមែល វែបសាយ)

**៣-២-តំបន់ឆ្នេរសមុទ្រ ទន្លេ បឹង និងជ្រោះ**

ក. ពោងកំណត់ជំរៅទឹក, សញ្ញាគ្រោះថ្នាក់ (ថ្មប៉ប្រះទឹក, ថ្មក្នុងទឹក, អន្លង់, ទឹកគួច, រអិល, ខ្សាច់ផុង, ឬស្រូប)

ខ. ទង់សញ្ញាខ្យល់-រលក (ទង់សុវត្ថិភាព, ទង់ប្រុងប្រយ័ត្ន, ទង់គ្រោះថ្នាក់)

គ. នៅតាមឆ្នេរ មានប៉មឆ្មាំឆ្នេរចេះសង្គ្រោះអ្នកលង់ទឹក,ទូក ឬអូប័រសង្គ្រោះ អ្នកលង់ទឹក,ឃោសនៈ ប្រកាសអាសន្ន និងវិទ្យុទាក់ទង

ឃ. លើឆ្នេរមានផ័ត្រពណ៌ ឬផត្រស្បូវ និងបន្ទប់ផ្លាស់សំលៀកបំពាក់ដោយមានអនាម័យល្អ

**៤-ការគ្រប់គ្រងបរិស្ថាន**

ក. ត្រូវមានប្រព្ធន័គ្រប់គ្រងកាកសំណល់រឹងឱ្យបានសមរម្យ និងធុងសំរាមមានគំរបត្រឹមត្រូវ

ខ. រៀបចំឱ្យមានការចំរោះទឹកកខ្វក់មុននឹងបញ្ចេញទៅលូសាធារណៈ

គ. កំណត់ទីតាំងបង្គន់អនាម័យឱ្យបានត្រឹមត្រូវ

ឃ. ត្រួតពិនិត្យឱ្យបានត្រឹមត្រូវ នូវសំភារៈប្រើប្រាស់ទាំងឡាយដែលនាំចូលក្នុងរមណីយដ្ឋាន ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន

**៥-ភាពដែលអាចទៅដល់**

ក. មានហេដ្ឋារចនាសម្ព័នគ្រប់គ្រាន់ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់រមណីយដ្ឋានដោយសុវត្ថិភាព

ខ. មានស្លាកសញ្ញាបង្ហាញផ្លូវទៅកាន់រមណីយដ្ឋានគ្រប់គ្រាន់ និងច្បាស់លាស់

**៦-សម្បទាគ្រប់គ្រាន់**

ក. ត្រូវមានសម្បទាគ្រប់គ្រាន់ ដូចជា ការថែទាំវិជ្ជសាស្ត្រ សង្គ្រោះបន្ទាន់ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី និងឧបករណ៍ទំនាក់ទំនង

ខ. មានបុគ្គលិកជំនាញ មន្ត្រីយាមកាម ឬឆ្មាំការពារមូលដ្ឋានអង្គភាពការពារមូលដ្ឋាន សម្រាប់យាមកាមការពារសន្តិសុខ សុវត្ថិភាពរបស់ភ្ញៀវ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder

ក្រសួងទេសចរណ៍

រាជធានីភ្នំពេញ. ថ្ងៃទី .....ខែ....... ឆ្នាំ២០០..

# ឧបសម្ព័ន្ធទី២
# គំរូទង់សញ្ញាចំណាត់ថ្នាក់រមណីយដ្ឋានទេសចរណ៍

១-វត្ថុធាតុដើមនៃទង់សញ្ញា

ធ្វើពីក្រណាត់ ឬក្រដាសពណ៌បៃតងចាស់ ( ដូចមានគំរូជាប់ជាមួយ)

២-ទំរង់ទង់សញ្ញា

- ទំរង់ទង់សញ្ញាមានបួនជ្រុងទ្រវែង
- ទំហំទង់សញ្ញាអាស្រ័យទៅតាមទីតាំងរមណីយដ្ឋាន

៣-របៀបរចនាទង់សញ្ញា

- ផ្ទៃពណ៌បៃតងចាស់
- នៅកណ្តាលមានរង្វង់មូលចំរុះពណ៌ ដែលរំលេចទៅដោយអក្សរ A ( ផ្កាចន្ទន៍ ៣) ឬអក្សរ B ( ផ្កាចន្ទន៍ ២) ឬអក្សរ C ( ផ្កាចន្ទន៍ ១) ដែលមានបាតដៃពីរ ទ្រពីក្រោម
- មានឆ្នូតផ្កាចន្ទន៍លាតបណ្តោយទង់: ឆ្នូតផ្កាចន្ទន៍ ១ជួរ ឬ ឆ្នូតផ្កាចន្ទន៍ ២ជួរ និងយកឆ្នូតផ្កាចន្ទន៍ ៣ជួរ ទៅតាមប្រភេទនៃចំណាត់ថ្នាក់
- នៅផ្នែកខាងលើរង្វង់មូល មានឈ្មោះរមណីយដ្ឋាន ជាភាសាខ្មែរនិងអង់គ្លេស ដោយមានកំណត់ សុពលភាពរយៈពេល ២ឆ្នាំនៅខាងក្រោម
- នៅផ្នែកខាងឆ្វេង ខាងក្រោមមានពាក្យថា : ក្រសួងទេសចរណ៍កម្ពុជា និងខាងស្តាំ ខាងក្រោម មានពាក្យថា MINISTRY OF TOURISM ,CAMBODIA
- នៅក្រោមរង្វង់មូលមានសរសេរអក្សរ គុណភាពខ្ពស់ High Quality ឬ គុណភាពល្អ Good Quality ឬ គុណភាពមធ្យម Medium Quality

៤-បំរាម

ហាមការប្រើប្រាស់ទង់សញ្ញាចំណាត់ថ្នាក់រមណីយដ្ឋានខុសពីគំរូលំអិតខាងលើនេះ។

ក្រសួងទេសចរណ៍

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

រាជធានីភ្នំពេញ, ថ្ងៃទី .....ខែ....... ឆ្នាំ២០០..

## ឧបសម្ព័ន្ធទី៣

## តារាងដាក់ពិន្ទុវាយតម្លៃចំណាត់ថ្នាក់រមណីយដ្ឋាន

ឈ្មោះរមណីយដ្ឋានទេសចរណ៍ :..........................................................................

ឈ្មោះអង្គភាព និងម្ចាស់អាជីវកម្ម :..........................................................................

អាស័យដ្ឋាន :..........................................................................

..........................................................................

ថ្ងៃខែឆ្នាំ ចុះត្រួតពិនិត្យ :.................................ត្រួតពិនិត្យលើកទី..............

| ល.រ | បរិយាយ | ពិន្ទុគំរូ | មេគុណ | ពិន្ទុផ្តល់ជូន | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | **លក្ខណៈពិសេសរបស់រមណីយដ្ឋាន**<br>*(លក្ខណៈនីមួយៗទទួល បាន៣០ពិន្ទុ)* | | | | |
| ១-១ | ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ | | | | |
| ១-២ | ទេសចរណ៍វប្បធម៌ធម្មជាតិ | | | | |
| ១-៣ | ទេសចរណ៍ធម្មជាតិ | ៥-១០ | ៣ | | |
| ១-៤ | ទេសចរណ៍កែច្នៃ | | | | |
| ១-៥ | កសិទេសចរណ៍ | | | | |
| ១-៦ | អេកូទេសចរណ៍ | | | | |
| ២ | **ការការពារ និងអភិរក្សតំបន់រមណីយដ្ឋាន** | | | | |
| ២-១ | ការគ្រប់គ្រងទ្រង់ទ្រាយរមណីយដ្ឋាន | ៥-១០ | ១ | | |
| ២-២ | ការការពារកាត់បន្ថយការបំផ្លាញ | ៥-១០ | ៣ | | |

១៤

| | | | | | |
|---|---|---|---|---|---|
| ២-៣ | ការអភិរក្សធនធានមានស្រាប់វប្បធម៌ ប្រាសាទ ធម្មជាតិ ជីវចំរុះ | ៥-១០ | ២ | | |
| ២-៤ | ការអភិរក្សលំនៅស្ថាន,តំលៃមនុស្សជាតិ | ៥-១០ | ២ | | |
| ២.៥ | ការថែរក្សាការប្រើប្រាស់ដីធ្លី រមណីយដ្ឋានទេសចរណ៍ | ៥-១០ | ២ | | |
| ៣ | ការគ្រប់គ្រងរមណីយដ្ឋានទេសចរណ៍ | | | | |
| ៣-១ | ស្លាកឈ្មោះមុនដល់ និងស្លាកឈ្មោះ រមណីយដ្ឋាន ជាភាសា ខ្មែរនិងអង់គ្លេស | ៥-១០ | ២ | | |
| ៣-២ | បញ្ជរលក់សំបុត្រ | ៥-១០ | ១ | | |
| ៣-៣ | ចំណតយានយន្តគ្រប់បភេទ | ៥-១០ | ២ | | |
| ៣-៤ | ការថែទាំបង្គន់អនាម័យ ( មានអ្នកថែទាំប្រចាំ) និងធុងសំរាម មានគំរប | ៥-១០ | ៣ | | |
| ៣-៥ | សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យល្អ ក្នុងរមណីយដ្ឋាន | ៥-១០ | ៣ | | |
| ៣-៦ | សួនច្បារ និងការដាំដើមឈើ | ៥-១០ | ១ | | |
| ៣-៧ | តូបលំហែរ ( តម្លៃជួលជាប់តូប) | ៥-១០ | ១ | | |
| ៣-៨ | ភោជនីយដ្ឋាន, អាហារដ្ឋាន ម្ហូបឆ្ងាញ់អនាម័យល្អ ថ្លៃសមរម្យ មានវាយឈ្មោះម្ហូប និងកំណត់ថ្លៃ | ៥-១០ | ៣ | | |
| ៣-៩ | សេវាអ្នកបំរើ ឯកសណ្ឋាន សមរម្យ ញញឹម-រាក់ទាក់ អាកប្បកិរិយាល្អ | ៥-១០ | ២ | | |
| ៣-១០ | ប្រើប្រាស់ផលិតផលក្នុងតំបន់ ឬក្នុងស្រុក | ៥-១០ | ៣ | | |
| ៣-១១ | ប្រើប្រាស់កំលាំងពលកម្មក្នុងតំបន់រមណីយដ្ឋាន | ៥-១០ | ៣ | | |

| | | | | |
|---|---|---|---|---|
| ៣-១២ | ការផ្តល់ប្រព័ន្ធព័ត៌មាន (សៀវភៅផ្តត់ ផែនទី សៀវភៅមគ្គុទ្ទេស ,ពាក្យស្លោក,ទូរស័ព្ទ,អ៊ិនធើរណែត, អ៊ីម៉ែល) | ៥-១០ | ២ | | |
| ៣-១៣ | សេវាទំនាក់ទំនង (សេវាទូរស័ព្ទ សេវាប្រៃសណីយ៍) | ៥-១០ | ២ | | |
| ៣-១៤ | ព្រឹត្តិការណ៍ របាំ,ល្បែងប្រជាប្រិយ | ៥-១០ | ២ | | |
| ៣-១៥ | កន្លែងលក់វត្ថុអនុស្សាវរីយ៍ក្នុងស្រុក (ផលិត-ផលក្នុងស្រុក, ផ្កា, ផ្លែឈើ) | ៥-១០ | ២ | | |
| ៣-១៦ | សេវាស្នាក់នៅ សមស្រប និងមានស្តង់ដារ | ៥-១០ | ២ | | |
| ៣-១៧ | សេវាដឹកជញ្ជូន (មានកង់, រទេះគោ, រទេះសេះ, រ៉ឺម៉ក់,ម៉ូតូ...) | ៥-១០ | ២ | | |
| ៣-១៨ | មគ្គុទ្ទេសក៏ទេសចរណ៍ក្នុងរមណីយដ្ឋាន (ជ្រើសរើសយកប្រជាជនក្នុងមូលដ្ឋាន) | ៥-១០ | ៣ | | |
| ៣-១៩ | ការិយាល័យបុគ្គលិកបំរើ និងបុស្តិ៍ប្រចាំការ | ៥-១០ | ១ | | |
| ៣-២០ | ផ្លាកសញ្ញាគ្រោះថ្នាក់, ព័ត៌មាន, ហាមឃាត់គ្រប់ប្រភេទ, ស្លាក សញ្ញាចេញចូល | ៥-១០ | ២ | | |
| ៣-២១ | សេវាសង្គ្រោះបន្ទាន់ | ៥-១០ | ២ | | |
| ៤ | **ការគ្រប់គ្រងបរិស្ថាន** | | | | |
| ៤-១ | ការគ្រប់គ្រងកាកសំណល់រឹង និងរាវ | ៥-១០ | ៣ | | |
| ៤-២ | ការកំណត់ទីតាំង បង្គន់អនាម័យត្រឹមត្រូវ | ៥-១០ | ៣ | | |
| ៤-៣ | ឧបករណ៍ប្រើប្រាស់គ្រប់ប្រភេទដែលធ្វើមិនអោយពុលបរិស្ថាន និងគ្មានអនាម័យល្អ | ៥-១០ | ៣ | | |
| ៥ | **ភាពដែលអាចទៅដល់** *(ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវក្នុងរមណីយដ្ឋាន)* | ៥-១០ | ២ | | |

| | | | | | |
|---|---|---|---|---|---|
| ៦ | **សម្ភារទ្រទ្រង់** | | | | |
| ៦-១ | ការសង្គ្រោះបន្ទាន់, ទឹកស្អាត, អគ្គីសនី | ៥-១០ | ២ | | |
| ៦-២ | ឆ្មាំយាមកាម, បុគ្គលិកប្រចាំការ | ៥-១០ | ២ | | |
| **ពិន្ទុសរុបទាំងអស់** | | **៧២០ ពិន្ទុ** | | | |

-ប្រភេទរមណីយដ្ឋានទេសចរណ៍គុណភាពខ្ពស់ (A) ផ្កាចន្ទន៍ ៣ : ៦០០-៧២០
-ប្រភេទរមណីយដ្ឋានទេសចរណ៍គុណភាពល្អ (B) ផ្កាចន្ទន៍ ២ : ៥០០-៦០០
-ប្រភេទរមណីយដ្ឋានទេសចរណ៍គុណភាពមធ្យម (C) ផ្កាចន្ទន៍ ១ : ៤០០-៥០០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**
លេខ...០០២...សរណន

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០៧

## សារាចរណែនាំ
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍

ដើម្បីគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍ អោយមានសណ្តាប់ធ្នាប់របៀបរៀបរយប្រកបដោយសន្តិសុខ សុវត្ថិភាព មានសុជីវធម៌ជូនទេសចរជាតិ-អន្តរជាតិ និងក្នុងគោលបំណងធានាការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ថែរក្សាការពារវប្បធម៌ ប្រពៃណីជាតិ តាមគោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីអនុវត្តប្រកាសលេខ ០៦២ ប្រ.ក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដូចខាងក្រោម :

១ : - រាល់ការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍ អាជីវករត្រូវមានច្បាប់អនុញ្ញាតពីក្រសួងទេសចរណ៍ ។ ទំរង់បែបបទនៃការសុំធ្វើអាជីវកម្ម ត្រូវបំពេញដោយម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍ និងត្រូវគោរពអនុវត្តតាមប្រកាសរបស់ក្រសួងទេសចរណ៍ ។

- ការដាក់ទីតាំងធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍កែច្នៃបង្កើតថ្មី ត្រូវស្ថិតនៅចម្ងាយយ៉ាងតិច ២០០ ម៉ែត្រ ពីសាលារៀន វត្តអារាម មន្ទីរពេទ្យ ស្ថានទូត និងទីកន្លែងស្ថាប័នរដ្ឋបាលសំខាន់ៗ ។
- មុននឹងចាប់ផ្តើមរាល់ការសាងសង់ ឬរៀបចំទីតាំងអាជីវកម្ម អាជីវករត្រូវមកទំនាក់ទំនងជាមួយក្រសួងទេសចរណ៍ដើម្បីពិគ្រោះសុំការណែនាំ ។
- ឯកសារផ្សេងៗទៀត ដែលក្រសួងទេសចរណ៍ត្រូវការរួមមាន :
  - កិច្ចសន្យារបស់ម្ចាស់អាជីវកម្មចំពោះក្រសួងទេសចរណ៍ ក្នុងការប្រកបរអាជីវកម្ម
  - កិច្ចសន្យាជំពាក់ឯកសារ ដែលត្រូវបំពេញឡើងវិញក្នុងរយៈពេល ០៣ ខែ
  - បើសិនការធ្វើអាជីវកម្មនេះមានការពាក់ព័ន្ធទៅនឹងក្រសួង ស្ថាប័នជំនាញណាមួយ ម្ចាស់អាជីវកម្មចាំបាច់ត្រូវសុំលិខិតបញ្ជាក់ យល់ព្រមជាមុនពីក្រសួង - ស្ថាប័ននោះ
  - ត្រូវបំពេញតារាងត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម ។ ៤ម



២០៣ ២០៣

២ : ក្នុងការធ្វើអាជីវកម្ម អាជីវករត្រូវគោរពអនុវត្តតាមសារាចរណែនាំ និងបទប្បញ្ញត្តិស្តីអំពីការគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍ ច្បាប់ការងារ អនាម័យម្ហូបអាហារព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មទេសចរណ៍ ដើម្បីជាកិច្ចធានាដល់សន្តិសុខ សុវត្ថិភាព សុខុមាលភាពជូនទេសចរ ។

៣ : រាល់ការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍ ត្រូវធានាថាមិនធ្វើអោយប៉ះពាល់ដល់ វប្បធម៌ ប្រពៃណីជាតិ សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន និង របៀបរៀបរយសង្គម ។

៤ : ដើម្បីពង្រឹងនូវលក្ខណៈសម្បត្តិ និងគុណភាពសេវាកម្ម អាជីវករត្រូវអនុវត្តតាមបទដ្ឋាន និងស្តង់ដាដូចខាងក្រោម :

- ត្រូវមានកន្លែងសំរាប់ចតរថយន្តគ្រប់ប្រភេទរបស់ទេសចរ
- សំបុត្រចូលទស្សនាត្រូវដាក់លក់ក្នុងបញ្ជរ
- ត្រូវរៀបចំដាក់បង្ហាញប្លង់ទីតាំង រូបសំណាកសំខាន់ៗ នៅទីកន្លែងដំបូងនៃច្រកចូល
- ត្រូវលើកផ្លាកសញ្ញាចង្អុលទីកន្លែងកំសាន្តផ្សេងៗនៅតាមគ្រប់ច្រកចេញ-ចូល និងត្រូវដាក់ផ្លាកសញ្ញាចរាចរអោយបានត្រឹមត្រូវ ដើម្បីងាយស្រួលទេសចរធ្វើដំណើរកំសាន្តក្នុងរមណីយដ្ឋាន
- ត្រូវដាក់តាំងអាជ្ញាប័ណ្ណទេសចរណ៍នៅកន្លែងទទួលភ្ញៀវ
- បុគ្គលិក-កម្មករបំរើការងារក្នុងរមណីយដ្ឋានទេសចរណ៍ ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ និងមានប័ណ្ណពិនិត្យសុខភាពចេញដោយនាយកដ្ឋានពេទ្យការងារ ឬ មន្ទីរសុខាភិបាលខេត្ត-ក្រុង ត្រូវមានឯកសណ្ឋានសមរម្យ និងមានផ្លាកឈ្មោះសំគាល់ ព្រមទាំងមានអាកប្បកិរិយាថ្លៃថ្នូរ សុជីវធម៌ គោរពសិទ្ធិ និងផលប្រយោជន៍ទេសចរ
- ត្រូវមានបទបញ្ជាផ្ទៃក្នុង និង ការណែនាំអំពីវិធីបង្ការគ្រោះថ្នាក់ផ្សេងៗ ប្រសិនបើមានល្បែងកំសាន្តក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន និងត្រូវមានតារាងកំណត់តំលៃនិមួយៗអោយបានច្បាស់លាស់
- ក្នុងរមណីយដ្ឋាន ត្រូវមានផ្លាកសញ្ញាសំគាល់ឈ្មោះរុក្ខជាតិធំៗ និងឈ្មោះសត្វគ្រប់ប្រភេទ ជាភាសាជាតិ និងអន្តរជាតិ ព្រមទាំងមានសញ្ញាប្រុងប្រយ័ត្ន ឬហាមឃាត់នៅតំបន់មានគ្រោះថ្នាក់ ឬតំបន់មានជ្រោះ
- ត្រូវមានកៅអីវែង ឬ បង់អង្គុយសំរាក លំអទៅដោយសួនច្បារ សួនស្មៅ ក្បូរក្បាច់រចនាម៉ូត ប្រកបដោយសោភ័ណភាព
- ត្រូវបំពាក់គ្រឿងឧបករណ៍ការពារសុវត្ថិភាព អោយបានគ្រប់គ្រាន់ និងត្រូវថែទាំពិនិត្យជាប្រចាំ ព្រមទាំងត្រូវផ្លាស់ប្តូរថ្មីជាបន្ទាន់ពេលមានការខូចខាត ឬចាស់ ទ្រុឌទ្រោម
- ត្រូវមានរថយន្តពន្លត់អគ្គីភ័យ និងឧបករណ៍ពន្លត់អគ្គីភ័យផ្សេងៗទៀត ព្រមទាំងវិទ្យុទាក់ទង សំរាប់ប្រើប្រាស់ពេលមានការចាំបាច់
- ត្រូវមានផ្នែកសង្គ្រោះបន្ទាន់ និងមានទូរថ្នាំពេទ្យសង្គ្រោះ ព្រមទាំងបុគ្គលិកប្រចាំការ ដើម្បីត្រៀមលក្ខណៈជួយដល់ភ្ញៀវទេសចរនៅពេលមានគ្រោះថ្នាក់ជាយថាហេតុ មុនពេលភ្នាក់ងារសុខាភិបាលមកដល់ ឬមុនពេលបញ្ជូនទៅមន្ទីរពេទ្យដែលនៅជិតបំផុត
- ហាមមានអាវុធ ជាតិផ្ទុះ នៅក្នុងរមណីយដ្ឋាន
- ត្រូវធ្វើអនាម័យជាប្រចាំ មានធុងសំរាមដាក់តាមតំបន់នានាក្នុងទីសាធារណៈ និងកន្លែងកំសាន្ត

- ត្រូវមានបង្គន់អនាម័យសំរាប់បុរស និងនារីដោយសំអាតជាប្រចាំ និងត្រូវរៀបចំអោយមានចំនួនបង្គន់សមស្រប ទៅនឹងចំនួនទេសចរ និងទំហំផ្ទៃដីរបស់រមណីយដ្ឋាន
- ត្រូវមានមគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានសមត្ថភាព និង បទពិសោធន៍សំរាប់ជូនដំណើរទេសចរកំសាន្តនៅក្នុង រមណីយដ្ឋានទាំងមូល ។

៥ : ការដាក់លក់ម្ហូបអាហារ ត្រូវបានអនុញ្ញាតលើទីតាំងសមស្រប ប៉ុន្តែត្រូវមានកិច្ចសន្យាច្បាស់លាស់ ។

៦ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ត្រូវសហការ និងរាយការណ៍ជាបន្ទាន់ ជូនអាជ្ញាធរមានសមត្ថកិច្ច និងមន្ទីរទេសចរណ៍ នូវរាល់បាតុភាពមិនប្រក្រតីដែលអាចកើតឡើង ឬបានកើតឡើងនៅទីកន្លែងអាជីវកម្ម ។

៧ : ក្នុងករណីមិនគោរពតាមបទប្បញ្ញត្តិ ស្តីពីការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍ អាជីវករត្រូវទទួលការផាកពិន័យតាមច្បាប់កំណត់ ។ ករណីធ្វើអោយមានការប៉ះពាល់ធ្ងន់ធ្ងរ ដល់សុវត្ថិភាព ឬបង្កអោយមានគ្រោះថ្នាក់ដល់ទេសចរត្រូវទទួលទោសតាមច្បាប់រដ្ឋ ។

៨ : ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីប្រកបអាជីវកម្មរមណីយដ្ឋានទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍ខេត្ត-ក្រុង ដែលត្រូវត្រួតពិនិត្យ និងអនុញ្ញាតដោយក្រសួងទេសចរណ៍ ។

៩ : ក្នុងករណីចាំបាច់ក្រសួងនឹងមានវិធានការចាត់តាំងអធិការ និងមន្ត្រីជំនាញ ចុះធ្វើអធិការកិច្ចលើការអនុវត្តន៍លិខិតបទដ្ឋានស្តីពីអាជីវកម្មរមណីយដ្ឋានរបស់ក្រសួង ។

១០ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវធ្វើការសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ត្រួតពិនិត្យទៅលើអាជីវកម្មដែលប្រព្រឹត្តផ្ទុយនឹងគោលការណ៍ របស់ក្រសួងទេសចរណ៍ និងច្បាប់របស់រដ្ឋ និងរាយការណ៍មកក្រសួងទេសចរណ៍ ។

១១ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវអនុវត្តអោយបានម៉ឺងម៉ាត់ តាមគោលការណ៍កំណត់របស់ក្រសួងទេសចរណ៍ ។

ទទួលបាននូវសារាចរណែនាំនេះ មន្ទីរទេសចរណ៍ខេត្ត-ក្រុងត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីដើម្បីធ្វើការផ្សព្វផ្សាយណែនាំដល់ម្ចាស់អាជីវកម្ម ទទួលអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ក្នុងការរួមចំណែកបំរើវិស័យទេសចរណ៍កម្ពុជាអោយអភិវឌ្ឍន៍បានកាន់តែល្អប្រពៃ ។

រដ្ឋមន្ត្រី

ថោង ខុន

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរទេសចរណ៍ខេត្ត-ក្រុង "ដើម្បីមុខការ"
- គ្រប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

២០៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE

លេខ(No) MOC-5658683 ពណ ចបព

# វិញ្ញាបនបត្រ

## បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

## CERTIFICATE OF INCORPORATION

| | | |
|---|---|---|
| នាមករណ៍<br>NAME | : | សឺម៉ាំង អង្គរ<br>CHEMINS D'ANGKOR |
| ចុះបញ្ជីក្រោមលេខ<br>REGISTRATION NUMBER | : | 50001339 |
| អត្តលេខចុះបញ្ជីចាស់<br>ORIGINAL REGISTRATION NUMBER | : | Co.2111/041 |
| កាលបរិច្ឆេទចុះក្នុងបញ្ជីពាណិជ្ជកម្ម<br>INCORPORATION DATE | : | 03 ធ្នូ 2004<br>03 December 2004 |
| ត្រូវបានទទួលស្គាល់ជា<br>IS ACKNOWLEDGE AS | : | សហគ្រាសឯកបុគ្គល<br>Sole Proprietorship |

ភ្នំពេញ, 03 ធ្នូ 2004
PHNOM PENH, 03 DECEMBER 2004
ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
F. MINISTER OF COMMERCE
រដ្ឋលេខាធិការ
SECRETARY OF STATE

គឹម_ស៊ីថន
Kem Sithan

ស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

UNDER THE REGULATIONS OF COMMERCIAL RULES AND REGISTER LAW, COMMERCIAL ENTERPRISES LAW, CIVIL CODE AND PENAL CODE OF THE KINGDOM OF CAMBODIA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

[illegible]



[illegible] : សីម៉ាំង អង្គរ
លេខអត្តសញ្ញាណកម្មសារពើពន្ធ : E116-1500015096
ចុះបញ្ជីនៅ៖ អគ្គនាយកដ្ឋានពន្ធដារ ស្ថិតនៅក្រោមការគ្រប់គ្រង៖ សាខាពន្ធដារខេត្តសៀមរាប
ទម្រង់សហគ្រាស : សហគ្រាសឯកបុគ្គល
សកម្មភាពអាជីវកម្មចម្បង : ទីភ្នាក់ងារទេសចរណ៍
អាសយដ្ឋានសហគ្រាស៖ # ផ្លូវ ភូមិ គោកក្រសាំង សង្កាត់ ស្វាយដង្គំ ក្រុង សៀមរាប ខេត្ត សៀមរាប
ឈ្មោះម្ចាស់សហគ្រាស៖ តែស្រី សុជាតា សញ្ជាតិ៖ ខ្មែរ

## PATENT TAX 2019

Company name : CHEMINS D'ANGKOR
Tax Identification Number (TIN) : E116-1500015096
Registered at : General Department of Taxation Under : SIEM REAP TAX BRANCH
Main business activity(ies) : Travel agency
Forms of business : Sole proprietorship
Owner's name TESREY SOCHEATA Nationality Cambodian

[illegible]
៤០០ ០០០ រៀល

លេខ SN : 003437955

អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation

២០៧

**FTB**

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

ភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៩

**លេខ** : 943-02/8266/2019 លើកទី 16

# លិ ខិ ត ធា នា

អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ជូនភ្ញៀវចូលមកកម្សាន្តក្នុងប្រទេស
**(Inbound Tour Operators)**

**យោង**: ប្រកាសលេខ ០៤១ ប្រក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ របស់ក្រសួងទេសចរណ៍ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ។

តាមលិខិតស្នើសុំលេខ : ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៩

របស់ការីទេសចរណ៍ : **CHEMINS D'ANGKOR**

**ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃ កម្ពុជា សូមចេញជូន :**

ការីទេសចរណ៍ : **CHEMINS D'ANGKOR**

នូវលិខិតធានាដែលមានទឹកប្រាក់ចំនួន : ៥,០០០.០០ ដុល្លារអាមេរិក (ប្រាំពាន់ដុល្លារអាមេរិកគត់) ដើម្បីបំពេញបែបបទស្នើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ជូនភ្ញៀវចូលមកកម្សាន្តក្នុងប្រទេស (Inbound Tour Operators) ស្របតាមប្រកាសលេខ ០៤១ ប្រក ចុះថ្ងៃទី១៨ ខែ មករា ឆ្នាំ ២០១៦ របស់ក្រសួងទេសចរណ៍ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍។

លិខិតធានានេះមានសុពលភាពរយៈពេល ០១ឆ្នាំ គិតចាប់ពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៩ រហូតដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២០។ ផុតកាលបរិច្ឆេទធនាគារពុំមានការទទួលខុសត្រូវចំពោះ លិខិតធានានេះឡើយ។ ប្រតិបត្តិករទេសចរណ៍ជាការីទេសចរណ៍ រឺភ្នាក់ងារទេសចរណ៍ត្រូវមកស្នើសុំអោយធនាគារចេញលិខិតធានាសារជាថ្មីឡើងវិញមុនពេលផុតសុពលភាព ។

**ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃ កម្ពុជា**
**អគ្គនាយក**

FOREIGN TRADE BANK OF CAMBODIA
ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

នួន បុរ៉ានី

២០៤

Building No. 33C-D, Street 169, Sangkat Veal Vong, Khan 7Makara, Phnom Penh, Cambodia.
Tel: (855-23) 862 111 / 724 466 / 723 854 / 722 466 / 725 266, Fax: (855-23) 426 108 / 426 410
Email: info@ftbbank.com Website: www. ftbbank.com SWIFT: FTCCKHPP
P.O. Box 114 PNH, Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ: ៥៦៥ ក.ឆ.ច

# អាជ្ញាបណ្ណទេសចរណ៍

# TOURISM LICENSE



អនុញ្ញាតឱ្យលោក លោកស្រី តែ ស្រីសុជាតា TE SREYSOCHEATA (ខ្មែរ)

ស្ថិតនៅផ្ទះលេខ ភូមិ គោកក្រសាំង សង្កាត់ ស្វាយដង្គំ

ក្រុង ស្រុក ខណ្ឌ សៀមរាប រាជធានី ខេត្ត សៀមរាប

ប្រកបអាជីវកម្ម ការីទេសចរណ៍នាំភ្ញៀវចូលមកកម្ពុជាក្នុងប្រទេស (Inbound Tour Operators) (បន្ត)

អាជីវកម្មឈ្មោះ សឺម៉ាំង ដង់គ័រ CHEMINS D' ANGKOR

ចាប់ពីថ្ងៃទី ១៦ - ១២ - ២០១៨ ដល់ ១៥ - ១២ - ២០១៩

ថ្ងៃ ... ខែ ... ឆ្នាំ ច ឯកស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៨

រដ្ឋមន្ត្រី

ថោង ខុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

# បណ្ណស្រង់ព័ត៌មាន

## ការប្រកបអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍

ការីទេសចរណ៍/ភ្នាក់ងារទេសចរណ៍ឈ្មោះ (ជាអក្សរខ្មែរ និងអក្សរឡាតាំង) ..........................................

..........................................................................................................................................

ម្ចាស់អាជ្ញាបណ្ណ-អ្នកគ្រប់គ្រងឈ្មោះ..........................................................ទីតាំងផ្ទះលេខ................

ផ្លូវលេខ..............សង្កាត់-ឃុំ..............................ក្រុង-ស្រុក-ខណ្ឌ..............................រាជធានីភ្នំពេញ។

**I-ទីតាំងអាជីវកម្ម**

១.ស្ថានភាពខាងមុខ និងខាងក្នុង៖

- ស្លាកឈ្មោះការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ : .................................... ☐មាន ☐គ្មាន
- បន្ទប់ទទួលភ្ញៀវ..........................................................................................................
- លេខទូរស័ព្ទ...................................................... លេខទូរស័ព្ទដៃ..........................................
- លេខទូរសារ...................................................... E-mail.......................................................
- គេហទំព័រ(Website)......................................................................................................

**II-ប្រភេទអាជ្ញាបណ្ណទេសចរណ៍ស្នើសុំ**

១.ការីទេសចរណ៍នាំភ្ញៀវទៅកម្សាន្តនៅក្រៅប្រទេស(Outbound Tour Operator)........... ☐

២.ការីទេសចរណ៍នាំភ្ញៀវចូលមកកម្សាន្តក្នុងប្រទេស(Inbound Tour Operator).............. ☐

៣. ការីទេសចរណ៍នាំភ្ញៀវទេសចរកម្សាន្តក្នុងប្រទេស(Domestic Tour Operator)............. ☐

៤. ភ្នាក់ងារទេសចរណ៍ (Travel Agent) .............................................................................. ☐

**III-សមាជិកសមាគមទេសចរណ៍**

១.សមាជិកសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)......................... ☐មាន ☐គ្មាន

២. សមាជិកសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា(PATA)......................... ☐មាន ☐គ្មាន

៣.សមាជិកសមាគមដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ(IATA)......................... ☐មាន ☐គ្មាន

៤.សមាជិកសមាគមផ្សេងៗ........................................................................ ☐មាន ☐គ្មាន

**IV-បុគ្គលិក មគ្គុទ្ទេសក៍ទេសចរណ៍ និងមធ្យោបាយដឹកជញ្ជូនទេសចរណ៍**

១. ចំនួនបុគ្គលិក (Staff)៖

- ស្ត្រីជនជាតិខ្មែរ......................................នាក់ ស្ត្រីជនជាតិបរទេស.............................នាក់
- បុរសជនជាតិខ្មែរ....................................នាក់ បុរសជនជាតិបរទេស...........................នាក់
- បុគ្គលិកបានឆ្លងវគ្គបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈទេសចរណ៍(Training Course) ៖

ស្ត្រីជនជាតិខ្មែរ.......................................នាក់ បុរសជនជាតិខ្មែរ...................................នាក់

- បុគ្គលិកធ្វើកម្មសិក្សា(Training Staff) ៖

ស្ត្រីជនជាតិខ្មែរ.......................................នាក់ បុរសជនជាតិខ្មែរ...................................នាក់

២. មគ្គុទ្ទេសក៍ទេសចរណ៍ (Tour Guide)

-មគ្គុទ្ទេសក៍ទេសចរណ៍ជាប់កិច្ចសន្យា ៖ ស្ត្រី.....................នាក់ បុរស.......................នាក់

- មគ្គុទ្ទេសក៍ទេសចរណ៍មិនជាប់កិច្ចសន្យា ៖ ស្ត្រី.....................នាក់ បុរស.......................នាក់

៣. មធ្យោបាយដឹកជញ្ជូនទេសចរណ៍ (Tourism Transport) ៖

- រថយន្តទេសចរណ៍ អាជ្ញាបណ្ណទេសចរណ៍ ☐មាន អាជ្ញាបណ្ណលេខ.......................... ☐គ្មាន

- កាណូតទេសចរណ៍ អាជ្ញាបណ្ណទេសចរណ៍ ☐មាន អាជ្ញាបណ្ណលេខ.......................... ☐គ្មាន

**V-សកម្មភាពអាជីវកម្មទេសចរណ៍**

**១.ការរៀបចំទទួលភ្ញៀវទេសចរអន្តរជាតិចូលមកទស្សនាក្នុងប្រទេសកម្ពុជា**(Inbound Package Tours)៖

១.១-ភ្ញៀវចូលតាមផ្លូវគោក ផ្លូវអាកាស ☐មាន ☐គ្មាន មានប្រភពទីផ្សារទេសចរណ៍សំខាន់ៗចំនួន៣៖

A.**ទីផ្សារទេសចរណ៍សំខាន់ទី១** ៖...........................................................................................

- រយៈពេលភ្ញៀវស្នាក់នៅជាមធ្យម (Average Lengthof Stay)៖................................................
- ចំណាយជាមធ្យមក្នុងមួយថ្ងៃសម្រាប់ភ្ញៀវម្នាក់ (Average Expenditure per day) ៖...................
- ថ្លៃកញ្ចប់ទស្សនកិច្ចជាមធ្យមសម្រាប់ភ្ញៀវម្នាក់ (Average Package Tour) ៖...................

B.**ទីផ្សារទេសចរណ៍សំខាន់ទី២** ៖...........................................................................................

- រយៈពេលភ្ញៀវស្នាក់នៅជាមធ្យម (Average Length of Stay) ៖................................................
- ចំណាយជាមធ្យមក្នុងមួយថ្ងៃសម្រាប់ភ្ញៀវម្នាក់ (Average Expenditure per day) ៖...................
- ថ្លៃកញ្ចប់ទស្សនកិច្ចជាមធ្យមសម្រាប់ភ្ញៀវម្នាក់ (Average Package Tour) ៖...................

C.**ទីផ្សារទេសចរណ៍សំខាន់ទី៣** ៖...........................................................................................

- រយៈពេលភ្ញៀវស្នាក់នៅជាមធ្យម (Average Length of Stay) ៖................................................
- ចំណាយជាមធ្យមក្នុងមួយថ្ងៃសម្រាប់ភ្ញៀវម្នាក់ (Average Expenditure per day) ៖...................
- ថ្លៃកញ្ចប់ទស្សនកិច្ចជាមធ្យមសម្រាប់ភ្ញៀវម្នាក់ (Average Package Tour) ៖...................

-ចំនួនភ្ញៀវទទួលបានក្នុងឆ្នាំ២០..... ៖..................... ត្រីមាសទី១/ឆមាសទី១ឆ្នាំ២០..... ៖.....................

-តំបន់ទេសចរណ៍-រមណីយដ្ឋាន ៖...........................................................................................

..........................................................................................................................................

១.២-ភ្ញៀវចូលតាមនាវាទេសចរណ៍សមុទ្រ និងទន្លេមេគង្គ ៖

- ភ្ញៀវមកតាមសមុទ្រ ☐មាន ☐គ្មានមានចំនួន.................នាក់ ស្មើនឹងចំនួន.............ជើង
- មកតាមទន្លេមេគង្គ ☐មាន ☐គ្មាន មានចំនួន.................នាក់ ស្មើនឹងចំនួន.............ជើង

**២- ការរៀបចំដំណើរកម្សាន្តជូនភ្ញៀវទៅទស្សនានៅក្រៅប្រទេស ៖**

- Outbound Package Tours .......☐មាន ☐គ្មាន រៀបរាប់ប្រទេសសំខាន់ៗចំនួន៣ ៖

A.**ប្រទេសក្នុងទ្វីបអាស៊ី** ៖...........................................................................................

- រយៈពេលភ្ញៀវស្នាក់នៅជាមធ្យម (Average Length of Stay) ៖................................................

- ចំណាយជាមធ្យមក្នុងមួយថ្ងៃសម្រាប់ភ្ញៀវម្នាក់ (Average Expenditure per day) ៖....................
- ថ្លៃកញ្ចប់ទស្សនកិច្ចជាមធ្យមសម្រាប់ភ្ញៀវម្នាក់ (Average Package Tour) ៖....................

B. **ប្រទេសក្នុងទ្វីបអឺរ៉ុប** ៖......................................................................................

- រយៈពេលភ្ញៀវស្នាក់នៅជាមធ្យម (Average Length of Stay) ៖..............................................
- ចំណាយជាមធ្យមក្នុងមួយថ្ងៃសម្រាប់ភ្ញៀវម្នាក់ (Average Expenditure per day) ៖....................
- ថ្លៃកញ្ចប់ទស្សនកិច្ចជាមធ្យមសម្រាប់ភ្ញៀវម្នាក់ (Average Package Tour) ៖....................

C. **ប្រទេសក្នុងទ្វីបអាមេរិក** ៖......................................................................................

- រយៈពេលភ្ញៀវស្នាក់នៅជាមធ្យម (Average Length of Stay) ៖..............................................
- ចំណាយជាមធ្យមក្នុងមួយថ្ងៃសម្រាប់ភ្ញៀវម្នាក់ (Average Expenditure per day) ៖....................
- ថ្លៃកញ្ចប់ទស្សនកិច្ចជាមធ្យមសម្រាប់ភ្ញៀវម្នាក់ (Average Package Tour) ៖....................

- ចំនួនភ្ញៀវទទួលបានក្នុងឆ្នាំ២០...... ៖.................... ត្រីមាសទី១/ឆមាសទី១ឆ្នាំ២០..... ៖....................

**៣- ការរៀបចំដំណើរកម្សាន្តសម្រាប់ភ្ញៀវទេសចរក្នុងស្រុក**(Domestic Tourist)☐ មាន ☐ គ្មាន

- រយៈពេលភ្ញៀវស្នាក់នៅជាមធ្យម (Average Length of Stay) ៖..............................................
- ចំណាយជាមធ្យមក្នុងមួយថ្ងៃសម្រាប់ភ្ញៀវម្នាក់ (Average Expenditure per day) ៖....................
- ថ្លៃកញ្ចប់ទស្សនកិច្ចជាមធ្យមសម្រាប់ភ្ញៀវម្នាក់ (Average Package Tour) ៖....................
- ចំនួនភ្ញៀវទទួលបានក្នុងឆ្នាំ២០..... ៖.................... ត្រីមាសទី១/ឆមាសទី១ឆ្នាំ២០..... ៖....................
- តំបន់ទេសចរណ៍-រមណីយដ្ឋាន ៖..............................................................................

..........................................................................................................................

**៤-ភ្នាក់ងារទេសចរណ៍ (Travel Agent)ជួយលក់សេវាកម្មទេសចរណ៍៖**

-លក់កញ្ចប់ទស្សនកិច្ចដែលរៀបចំដោយការីទេសចរណ៍ ............................ ☐មាន ☐គ្មាន

- លក់សំបុត្រមធ្យោបាយធ្វើដំណើរ ៖ សំបុត្រយន្តហោះ.............................. ☐មាន ☐គ្មាន

សំបុត្ររថយន្ត.................................. ☐មាន ☐គ្មាន

សំបុត្រកាណូត.................................. ☐មាន ☐គ្មាន

- សេវាកម្មទេសចរណ៍ផ្សេងៗទៀត : ..........................................................................

..........................................................................................................................

**៥- ទីស្នាក់ការកណ្តាល**(Head Office) និងសាខា (Branch Office) :

- Head Office :.............................................ឈ្មោះអ្នកគ្រប់គ្រង..............................
- Branch Office : ...........................................ឈ្មោះអ្នកគ្រប់គ្រង..............................
- Branch Office : ...........................................ឈ្មោះអ្នកគ្រប់គ្រង..............................
- Branch Office : ...........................................ឈ្មោះអ្នកគ្រប់គ្រង..............................

**៦-ថ្ងៃចាប់ផ្តើមអាជីវកម្ម** : ..........................................................................................

៧-ការចូលរួមថែរក្សាបរិស្ថានគ្មានផ្សែងបារីនៅក្នុងអាជីវកម្មទីភ្នាក់ងារទេសចរណ៍

- ពិទសញ្ញាហាមជក់បារី ☐មាន ☐គ្មាន
- ផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ ☐មាន ☐គ្មាន

- ដាក់តាំងបង្ហាញចានគោះក្រញូមបារី ☐មាន ☐គ្មាន
- តាំងកញ្ចប់បារីធម្មតាមិនលើសពី ០១កញ្ចប់ក្នុង ១ម៉ាកក្នុងទូ ឬសម្ភារៈតាំងមិនលើសពី ១ដែលសម្ភារៈនោះមានផ្ទៃក្រឡាសម្រាប់តាំងសរុបមិនលើសពី ២.០០០ស.ម២ ☐មាន ☐គ្មាន
- តាំងនិងលក់តែបារីដែលមានសារព្រមានសុខភាពជាភាសាខ្មែរ និងរូបភាពទំហំ ៥៥% បោះពុម្ពលើកញ្ចប់ទាំងសងខាង ☐មាន ☐គ្មាន
- ប្រតិបត្តិករទេសចរណ៍ ត្រូវបង្គាប់អ្នកជក់បារីឱ្យជក់បារីខាងក្រៅអគារ ☐មាន ☐គ្មាន

## VI-សេចក្ដីសន្និដ្ឋាន

.............................................................................................................................

.............................................................................................................................

.............................................................................................................................

**កិច្ចសន្យា**

ខ្ញុំបាទ-នាងខ្ញុំសូមធានាអះអាងថា រាល់ការឆ្លើយបំភ្លឺខាងលើពិតជាត្រឹមត្រូវពុំមានការកុហកឡើយក្នុងករណីមិនពិត ខ្ញុំបាទ-នាងខ្ញុំសុខចិត្តទទួលខុសត្រូវតាមច្បាប់ជាធរមាន។

ខ្ញុំបាទ-នាងខ្ញុំសុខចិត្តធ្វើការកែប្រែតាម សេចក្ដីណែនាំរបស់ក្រសួងទេសចរណ៍។

**ម្ចាស់អាជ្ញាបណ្ណ ឬ អ្នកគ្រប់គ្រង**

**ស្នាមមេដៃ ឬ ហត្ថលេខា**

ធ្វើនៅ.................. ថ្ងៃ.................... ខែ............... ឆ្នាំ២០.............

ព.ស.២៥៦១ ត្រូវនឹង ថ្ងៃទី.......... ខែ.......... ឆ្នាំ២០.......

**អ្នកត្រួតពិនិត្យ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍**

៤X៦

# ពាក្យសុំអាជ្ញាបណ្ណទេសចរណ៍

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ (ជាអក្សរខ្មែរ និងអក្សរឡាតាំង)..........................................................................

ភេទ...................... សញ្ជាតិ ......................... ថ្ងៃ ខែ ឆ្នាំ កំណើត ...................................................

អាស័យដ្ឋានបច្ចុប្បន្ន ..........................................................................................................

## សូមគោរពជូន

## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍

**កម្មវត្ថុ** ៖សំណើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់ ការីទេសចរណ៍ នាំភ្ញៀវចូលមកកម្សាន្តក្នុងប្រទេស (Inbound Tour Operators)( សុំថ្មី )។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងអនុញ្ញាតផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់រូបខ្ញុំបាទ/នាងខ្ញុំ ជាការីទេសចរណ៍នាំភ្ញៀវទេសចរចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជាឈ្មោះ (ជាអក្សរខ្មែរ និងអក្សរឡាតាំង) ៖..........................................................................

..........................................................................................................................

អាស័យដ្ឋាន ..................................................................................................................

ទូរស័ព្ទ ..................................... ទូរសារ.............................................ទូរស័ព្ទដៃ..........................................

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងអនុញ្ញាតដោយសេចក្ដីអនុគ្រោះ។

**សូមគោរពជូនភ្ជាប់មកជាមួយ ៖**

១- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ( *ថតចម្លង* ) ...........................................................................០១ច្បាប់

២- លិខិតតម្កល់ប្រាក់ធានាអាជីវកម្មពីធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ( *ច្បាប់ដើម*).....០១ច្បាប់

៣- លិខិតបញ្ជាក់ទីស្នាក់ការ ឬកិច្ចសន្យាជួលផ្ទះ ( *ថតចម្លង*) និងរូបថតទីតាំង......................................០១ច្បាប់

៤- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ( *ថតចម្លងមានហត្ថលេខា*)...................................០១ច្បាប់

៥- កិច្ចសន្យាគោរពច្បាប់រដ្ឋ និងបង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណទេសចរណ៍.....................................០១ច្បាប់

៦- រូបថតម្ចាស់អាជ្ញាបណ្ណ (៤x៦) .......................................................................................០៣សន្លឹក

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/ នាងខ្ញុំ។

ធ្វើនៅ.............................ថ្ងៃទី ខែ ឆ្នាំ២០....

**ស្នាមមេដៃ និងឈ្មោះ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

៤X៦

# ពាក្យសុំអាជ្ញាបណ្ណទេសចរណ៍

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ (ជាអក្សរខ្មែរ និងអក្សរឡាតាំង)....................................................................................

ភេទ...................... សញ្ជាតិ .......................... ថ្ងៃ ខែ ឆ្នាំ កំណើត .....................................................

អាសយដ្ឋានបច្ចុប្បន្ន .........................................................................................................................

## សូមគោរពជូន

## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍

**កម្មវត្ថុ** ៖សំណើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់ ការីទេសចរណ៍ នាំភ្ញៀវចូលមកកម្សាន្តក្នុងប្រទេស (Inbound Tour Operators) (បន្ត)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងអនុញ្ញាតផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់រូបខ្ញុំបាទ/នាងខ្ញុំ ជាការីទេសចរណ៍នាំភ្ញៀវទេសចរចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជាឈ្មោះ

..............................................................................................................................................

អាសយដ្ឋាន ..............................................................................................................................

ទូរស័ព្ទ......................................ទូរសារ.........................................ទូរស័ព្ទដៃ........................................

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងអនុញ្ញាតដោយសេចក្តីអនុគ្រោះ។

**សូមគោរពជូនភ្ជាប់មកជាមួយ ៖**

១- លិខិតតម្កល់ប្រាក់ធានាអាជីវកម្មបន្តពីធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)(*ច្បាប់ដើម*)..០១ច្បាប់

២- អាជ្ញាបណ្ណទេសចរណ៍ (*ច្បាប់ដើម*)..............................................................................០១ច្បាប់

៣- របាយការណ៍អំពីសកម្មភាពអាជីវកម្មឆ្នាំមុន.....................................................................០១ច្បាប់

៤- កិច្ចសន្យាគោរពច្បាប់រដ្ឋ និងបង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណទេសចរណ៍ ..................................០១ច្បាប់

៥- រូបថតម្ចាស់អាជ្ញាបណ្ណ (៤x៦) .........................................................................................០៣សន្លឹក

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ............................ថ្ងៃទី ខែ ឆ្នាំ ២០...

ស្នាមមេដៃ និងឈ្មោះ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ (ជាអក្សរខ្មែរ និងឡាតាំង) ..............................................................................

..................................................... ភេទ ................................ សញ្ជាតិ .................................................

ថ្ងៃ ខែ ឆ្នាំ កំណើត ...........................................................................................................................

អាសយដ្ឋានបច្ចុប្បន្ន ........................................................................................................................

ទូរស័ព្ទដៃ ............................................អ៊ីម៉ែល (E-mail) :...........................................................................

គេហទំព័រ (Website) :........................................................................................................................

**សូមសន្យា**

១- ការបន្តអាជ្ញាបណ្ណទេសចរណ៍ ខ្ញុំបាទ/នាងខ្ញុំ ត្រូវដាក់ពាក្យស្នើសុំមកក្រសួងឱ្យបាន ៣០ (សាមសិប)ថ្ងៃ យ៉ាងតិចមុនថ្ងៃផុតកំណត់សុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់មកជាមួយនូវប្រាក់កម្រៃអាជ្ញាបណ្ណទេសចរណ៍ព្រមទាំងឯកសារ និងព័ត៌មានផ្សេងៗ។

២- ត្រូវដាក់តាំងអាជ្ញាបណ្ណទេសចរណ៍នៅទីកន្លែងដែលងាយមើលឃើញច្បាស់ក្នុងទីបរិវេណធ្វើអាជីវកម្ម។

៣- មុន និងចាប់ផ្ដើមប្រកប ឬបិទអាជីវកម្ម ក្នុងករណីមានការផ្ទេរ លក់អាជ្ញាបណ្ណទេសចរណ៍ ប្ដូរអ្នកគ្រប់គ្រង ប្ដូរនាមករណ៍ ឬប្ដូរទីស្នាក់ការ ខ្ញុំបាទ/នាងខ្ញុំត្រូវជូនដំណឹងមកក្រសួងទេសចរណ៍ឱ្យបានមុន៣០(សាមសិប)ថ្ងៃ។

៤- ត្រូវធានាមិនប៉ះពាល់ដល់សន្តិសុខ សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ បរិស្ថាន សុវត្ថិភាព សុខមាលភាពសង្គម និងចូលរួមការពារ និងអភិរក្សមរតកវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទំលាប់របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពអាជីវកម្មរបស់ខ្លួន។

៥- ក្នុងដំណើរការអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍នេះ ខ្ញុំបាទ/នាងខ្ញុំ សន្យាគោរព និងអនុវត្តន៍ឱ្យបានល្អប្រសើរតាមច្បាប់ស្ដីពីទេសចរណ៍ និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រសួងទេសចរណ៍។

៦- ក្នុងដំណើរការអាជីវកម្ម ខ្ញុំបាទ/នាងខ្ញុំសន្យានឹងមិនជួល ឬចុះកិច្ចសន្យាជាមួយមគ្គុទ្ទេសក៍ទេសចរណ៍ និងអាជីវកម្មសេវាកម្មទេសចរណ៍ដែលគ្មានអាជ្ញាបណ្ណទេសចរណ៍ត្រឹមត្រូវ។

៧- ផ្ដល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់ និងទទួលខុសត្រូវផ្ដល់សេវាកម្មដូចដែលបានសន្យា ព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរ និងរាល់ការខូចខាតប៉ះពាល់សម្ភារៈ ឬរូបកាយទេសចរដែលកើតមានឡើងជាយថាហេតុក្នុងពេលធ្វើដំណើរកម្សាន្ត នាងខ្ញុំ/ខ្ញុំបាទនឹងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

៨- ខ្ញុំបាទ/នាងខ្ញុំនឹងផ្ដល់ជូនក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្តឱ្យបានទាន់ពេលវេលានូវស្ថិតិ និងធ្វើរបាយការណ៍ស្ដីពីហេតុការណ៍ផ្សេងៗ ដែលទាក់ទងនឹងអាជីវកម្មទេសចរណ៍តាមការស្នើសុំ និងការតម្រូវដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្ត។

៩- ត្រូវផ្ដល់របាយការណ៍អំពីសកម្មភាពអាជីវកម្មរបស់ខ្លួន និងស្ថិតិភ្ញៀវជូនក្រសួងទេសចរណ៍នៅពេលស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍។

១០- ត្រូវមានផែនការ និងមានសកម្មភាពបណ្ដុះបណ្ដាល និងហ្វឹកហ្វឺនដល់បុគ្គលិកបម្រើការងារអំពីជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ស្របតាមការណែនាំរបស់ក្រសួងទេសចរណ៍។

១១- ម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវមានសញ្ញាបត្រកំរិតឧត្ដមសិក្សាបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ ឬសញ្ញាបត្រសមមូល (ឬខ្ពស់ជាងនេះ)។

១២- បុគ្គលិកបំរើការត្រូវមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាអំពីមុខជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍ (យ៉ាងតិច៣០%នៃចំនួនបុគ្គលិកសរុប)។

១៣- ខ្ញុំបាទ/នាងខ្ញុំសន្យានឹងអនុវត្តតាមប្រភេទអាជ្ញាបណ្ណទេសចរណ៍ និងវិសាលភាពអាជីវកម្មដែលខ្លួនបានស្នើសុំ។

១៤- ត្រូវមានបំពាក់បំពង់ពន្លត់អគ្គីភ័យក្នុងទីស្នាក់ការ និងត្រូវមានច្រកចេញនៅពេលមានអាសន្ន។

១៥- ខ្ញុំបាទ/នាងខ្ញុំនឹងចូលរួមក្នុងយុទ្ធនាការទេសចរម្នាក់ដើមឈើមួយដើម ដើម្បីគាំទ្រ និងចូលរួមចំណែកកាត់បន្ថយផលប៉ះពាល់នៃការកើនឡើងកំដៅផែនដី ។

១៦- ខ្ញុំបាទ/នាងខ្ញុំសន្យាគោរព និងអនុវត្តឱ្យបានម៉ឺងម៉ាត់តាមច្បាប់ស្ដីពីទេសចរណ៍ដូចមានចែងក្នុងមាត្រា ៤៤ និងមាត្រា ៤៨។

១៧- ខ្ញុំបាទ-នាងខ្ញុំសន្យាគោរពតាមសេចក្ដីណែនាំរបស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីបរិស្ថានគ្មានផ្សែងបារីដល់អ្នកគ្រប់គ្រង ឬម្ចាស់អាជីវកម្ម សេវាកម្មទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា។

១៨- ខ្ញុំបាទ/នាងខ្ញុំសន្យាគោរព និងអនុវត្តតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈទេសចរណ៍ឱ្យបានល្អ។

១៩- ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងចំពោះការមិនបានអនុវត្តន៍តាមប្រការណាមួយនៃកិច្ចសន្យានេះ។

ធ្វើនៅ.............................ថ្ងៃទី ខែ ឆ្នាំ ២០..

**ស្នាមមេដៃ និងឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder

## របាយការណ៍អំពីសកម្មភាពអាជីវកម្មឆ្នាំមុន

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ..............................................................ជាម្ចាស់អាជ្ញាបណ្ណទេសចរណ៍
..................................................................................................................................
មានទីស្នាក់ការស្ថិតនៅផ្ទះលេខ.......................ក្រុមទី...............ភូមិ.......................ផ្លូវលេខ.............................
សង្កាត់-ឃុំ...............................ក្រុង-ស្រុក-ខណ្ឌ...............................រាជធានី-ខេត្ត...................................។

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**កម្មវត្ថុ** ÷ សេចក្តីរាយការណ៍អំពីសកម្មភាពអាជីវកម្មទេសចរណ៍បានប្រតិបត្តិការក្នុងរយៈពេលមួយឆ្នាំកន្លងមក។

**យោង** ÷- ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍

- ប្រកាសលេខ ០៤១ប្រក. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍របស់ក្រសួងទេសចរណ៍។

សេចក្តីដូចមានចែងតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា អនុវត្តន៍តាមច្បាប់ស្តីពីទេសចរណ៍ និងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ខ្ញុំបាទ/នាងខ្ញុំ សូមអនុញ្ញាតគោរពរាយការណ៍អំពីសកម្មភាពអាជីវកម្មទេសចរណ៍ដែលបានប្រតិបត្តិក្នុងរយៈពេលមួយឆ្នាំកន្លងមកនូវសកម្មភាពដូចខាងក្រោម ៖

**I-ស្ថានភាពទូទៅ និងគុណភាពសេវាកម្ម**

១- ទិដ្ឋភាពទូទៅ ៖..................................................................................................................
..................................................................................................................................

២- ប្រភេទអាជ្ញាបណ្ណប្រកបរអាជីវកម្ម ៖......................................................................................
..................................................................................................................................

៣- ជាសមាជិកសមាគម ៖.........................................................................................................
..................................................................................................................................

៤- ការងារបដិសណ្ឋារកិច្ច ៖

- ឯកសណ្ឋានសម្រាប់បុគ្គលិក ៖.........................................................................................

- កម្មវិធីអប់រំណែនាំដល់បុគ្គលិករួសរាយរាក់ទាក់ចំពោះភ្ញៀវ ៖..........................................................
- មគ្គុទ្ទេសក៍ទេសចរណ៍ (Tour Guide) ៖..........................................................

**៥- អ្នកគ្រប់គ្រង និងបុគ្គលិកទទួលការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈទេសចរណ៍ (Training Course)**

- ..........................................................
- ..........................................................
- ..........................................................

**៦- កិច្ចសន្យាដំណើរការអាជីវកម្ម**

- ..........................................................
- ..........................................................
- ..........................................................

**៧- មធ្យោបាយដឹកជញ្ជូនទេសចរណ៍** (Tourism Transport)

- ..........................................................
- ..........................................................

**៨-ការងារសន្តិសុខ និងសុវត្ថិភាព**

- ..........................................................
- ..........................................................

**៩- ការងារប្រឡងប្រណាំង**

- ..........................................................

..........................................................

**II-សកម្មភាពអាជីវកម្ម និងស្ថិតិភ្ញៀវ**

១- សកម្មភាពអាជីវកម្មរយៈពេល ១ឆ្នាំកន្លងមក

ក- ស្ថិតិភ្ញៀវទេសចរអន្តរជាតិចូលមកទស្សនាក្នុងប្រទេសកម្ពុជា (Inbound) ៖

- ..........................................................
- ..........................................................

➢ **ការរៀបចំទទួលភ្ញៀវទេសចរអន្តរជាតិចូលមកទស្សនាក្នុងប្រទេសកម្ពុជា តាមនាវាទេសចរណ៍សមុទ្រ**

- ..........................................................
- ..........................................................
- ..........................................................

➢ ការរៀបចំទទួលភ្ញៀវទេសចរអន្តរជាតិចូលមកទស្សនាក្នុងប្រទេសកម្ពុជា ដោយនាវាទេសចរណ៍ តាមដងទន្លេមេគង្គ និងទៅតំបន់ទេសចរណ៍ភូមិភាគឦសាន និង សហគមន៍ទេសចរណ៍

- ..........................................................
- ..........................................................

ខ- ស្ថិតិភ្ញៀវទេសចរទៅទស្សនានៅក្រៅប្រទេស (Outbound)

- ..........................................................
- ..........................................................

គ- ស្ថិតិភ្ញៀវទេសចរក្នុងស្រុក (Domestic)

- ........................................................................................................................

- ........................................................................................................................

ឃ- សកម្មភាពការងាររបស់ភ្នាក់ងារទេសចរណ៍ (Travel Agent) ៖

- ........................................................................................................................

- ........................................................................................................................

២- គោលដៅទេសចរណ៍សំខាន់ៗ ៖

- តំបន់ទេសចរណ៍-រមណីយដ្ឋាន ៖...................................................................................

- ទេសចរណ៍សហគមន៍ ៖...................................................................................

៣- សកម្មភាពផ្សព្វផ្សាយទេសចរណ៍ ៖

- ........................................................................................................................

៤- ការសន្យារៀបចំផែនការបណ្តុះបណ្តាល ៖

- ប្រតិបត្តិករទេសចរណ៍ត្រូវមានផែនការ និងមានសកម្មភាពបណ្តុះបណ្តាលនិងហ្វឹកហ្វឺនដល់បុគ្គលិក

........................................................................................................................

III-ភាតព្វកិច្ច និងការងារសង្គម

១- កាតព្វកិច្ចក្នុងដំណើរការអាជីវកម្ម

ក-........................................................................................................................

ខ-........................................................................................................................

គ.ការងារសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរ

- ........................................................................................................................

២- ចូលរួមក្នុងសកម្មភាពសង្គម និងសប្បុរសធម៌នានា

- ........................................................................................................................

- ........................................................................................................................

VI-បញ្ហាប្រឈម និងសំណូមពរ

១- បញ្ហាប្រឈម

........................................................................................................................

២- សំណូមពរ

........................................................................................................................

V-លទ្ធផលអាជីវកម្ម

........................................................................................................................

........................................................................................................................

VI- ទិសដៅផែនការសកម្មភាពអនុវត្តបន្ត

១- ផែនការពង្រឹងសកម្មភាពអាជីវកម្ម

- ........................................................................................................................

២ ផែនការឃោសនាផ្សព្វផ្សាយទេសចរណ៍

- ........................................................................................................................

**៣- ផែនការបណ្តុះបណ្តុះបណ្តាល**

- .........................................................................................................................................................

៤- បន្តចូលរួមក្នុងចលនាប្រឡងប្រណាំង“**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**”

.........................................................................................................................................................

៥- បន្តចូលរួមកិច្ចសហការជាមួយក្រសួងទេសចរណ៍ និងសមាគមទីភ្នាក់ងារទេសចរណ៍...................

.........................................................................................................................................................។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីរាយការណ៍ដ៏ខ្ពង់ខ្ពស់ និងអនុញ្ញាតបន្តអាជ្ញាបណ្ណទេសចរណ៍ដល់រូបខ្ញុំបាទ-នាងខ្ញុំដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ធ្វើនៅ.......................... ថ្ងៃ..................... ខែ.............. ឆ្នាំ....................... ព.ស.២៥៦១

ត្រូវនឹង ថ្ងៃទី.................. ខែ.................... ឆ្នាំ២០.......

**ហត្ថលេខា និងត្រា**

ឈ្មោះ.........................

**ម្ចាស់អាជ្ញាបណ្ណទេសចរណ៍**